ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
# សំរាប់អនុវត្ត
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

រៀបចំដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សំរាប់កិច្ចប្រជុំពិគ្រោះយោបល់លើកទី ៨

ថ្ងៃទី ២- ៣ ខែមិនា ឆ្នាំ ២០០៦

រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
# សំរាប់អនុវត្ត
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

រៀបចំដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សំរាប់កិច្ចប្រជុំពិគ្រោះយោបល់លើកទី ៨

ថ្ងៃទី ២-៣ ខែមិនា ឆ្នាំ ២០០៦

រាជធានីភ្នំពេញ

# អារម្ភកថា

ឯកសារនេះ មានលក្ខណៈខុសពីឯកសារជំហរ ដែលរាជរដ្ឋាភិបាលបានបង្ហាញនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់កន្លងមក ។ គោលដៅនៃឯកសារនេះ គឺការបង្ហាញជូនដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ នូវរបាយការណ៍សង្ខេបរបស់រាជរដ្ឋាភិបាល ស្តីពីបញ្ហាទាំងឡាយដែលត្រូវប្រឈមដោះស្រាយ ដើម្បីអនុវត្តឱ្យបានជោគជ័យ នូវ *«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ២០០៦-២០១០»* និងដើម្បីបង្កើនប្រសិទ្ធភាពជំនួយ ។ ឯកសារនេះបានធ្វើបច្ចុប្បន្នភាព អំពីសមិទ្ធផលម៉ាក្រូសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ឯកសារនេះក៏បានលើកឡើងអំពីបណ្តាការងារអាទិភាពសំរាប់កិច្ចអភិវឌ្ឍន៍ ដែលមានចែងក្នុង *«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ២០០៦-២០១០»* ។ ឯកសារក៏បានធ្វើបច្ចុប្បន្នភាពអំពីវឌ្ឍនភាពរយៈពេលមួយឆ្នាំកន្លងមក ក្នុងការពង្រឹងភាពជាដៃគូ ជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ (ដៃគូសហប្រតិបត្តិការទ្វេ-ពហុភាគី និងអន្តរជាតិ ផ្នែកឯកជន និងសង្គមស៊ីវិល) ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ ។ លើសពីនេះ ក៏បានលើកឡើងអំពីបណ្តាបញ្ហាប្រឈមនានា និងសកម្មភាពអាទិភាពមួយចំនួន ដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវដោះស្រាយរួមគ្នា ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ ព្រមទាំងបានលើកឡើងអំពីបណ្តាផ្នែកអាទិភាព ដែលដៃគូអភិវឌ្ឍន៍ត្រូវផ្តល់ការយកចិត្តទុកដាក់ ។ ចុងបញ្ចប់ ក៏បានផ្តល់ព័ត៌មានអំពីតំរូវការក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ បន្ថែមលើធនធានរបស់ប្រទេសដែលមាន សំរាប់គាំទ្រដល់ការអនុវត្តន៍បណ្តាកម្មវិធីនិងគំរោងដែលមានចែងក្នុង*«កម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ ២០០៦-២០០៨»* សំរាប់អនុវត្ត *«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ២០០៦-២០១០»* ។ រាជរដ្ឋាភិបាលបានអនុមតិឯកសារទាំង២នេះ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។

ដើម្បីសំរេចទិសដៅនៃកិច្ចអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានប្តេជ្ញាប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ និងអនុវត្តឱ្យបានពេញលេញ នូវ «***យុទ្ធសាស្ត្រចតុកោណ***» ពិសេស ការបន្តអនុវត្តគោលនយោបាយម៉ាក្រូ-សេដ្ឋកិច្ច និងវិន័យក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ រាជរដ្ឋាភិបាលនឹងខិតខំយ៉ាងពេញទំហឹង ក្នុងការបង្កើនសញ្ចយក្នុងស្រុកនិងធនធានជាមូលធន ដើម្បីហិរញ្ញប្បទានឱ្យបានច្រើនដល់កម្មវិធីអភិវឌ្ឍន៍របស់កម្ពុជា ។ ខ្ញុំមានជំនឿថា ឯកសារនេះនឹងជួយឱ្យបណ្តាដៃគូអភិវឌ្ឍន៍ធ្វើសុខដុមនីយកម្មជាមួយគ្នា និងតម្រឹមការផ្តល់ជំនួយរបស់ខ្លួនជាមួយនឹងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាល ដែលមានចែងក្នុង *«កម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ ២០០៦-២០០៨»* និង *«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ២០០៦-២០១០»* ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៦



**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សេចក្តីថ្លែងអំណរគុណ

អំណរគុណជូនចំពោះដៃគូអភិវឌ្ឍន៍ ពិសេស ចំពោះអង្គការអភិវឌ្ឍន៍សហប្រជាជាតិ ធនាគារពិភពលោក និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដែលបានផ្តល់ការគាំទ្រដល់ការរៀបចំ និងការប្រព្រឹត្តទៅនៃកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៨ ។

# ខ្លឹមសារសង្ខេបប្រតិបត្តិ

១- ដំណាក់កាលពីឆ្នាំ១៩៩៩មក គឺជាលើកទីមួយនៃប្រវត្តិសាស្ត្រដែលកម្ពុជាសំរេចបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធមនុស្ស និងស្ថិរភាពសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តកម្មវិធីកំណែទំរង់លើគ្រប់វិស័យ ទោះបីប្រឈមនឹងការលំបាកជាច្រើនយ៉ាងណាក៏ដោយ ។ កម្ពុជាបានសំរេចវឌ្ឍនភាពជាច្រើន និងជាបន្តបន្ទាប់ ក្នុងការឆ្លងកាត់អន្តរកាលពីសេដ្ឋកិច្ចមានផែនការ ដែលបានចាប់ផ្តើមពីពាក់កណ្តាលទសវត្សរ៍ឆ្នាំទី៨០ មកសេដ្ឋកិច្ចទីផ្សារ ។ សមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោកចាប់តាំងពីខែតុលា ឆ្នាំ២០០៤ ជាសក្ខីភាពមិនអាចប្រកែកបាននូវវឌ្ឍនភាពទាំងនេះ ។ កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យបានជំរុញអោយកម្ពុជាស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវមួយ ឈានទៅសំរេចគោលដៅ នៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

២- ជោគជ័យនៃការអនុវត្តន៍ *«យុទ្ធសាស្ត្រត្រីកោណ»* បានធ្វើអោយប្រទេសកម្ពុជាឆ្លងកាត់ដំណាក់កាលប្រែប្រួលយ៉ាងធំធេង ពីប្រទេសមួយដែលគ្មានស្ថានភាពច្បាស់លាស់ មានកលយុគ សង្គ្រាម ជម្លោះផ្ទៃក្នុង អស្ថិរភាព និងភាពអន់ថយទៅជាប្រទេសមួយដែលមានសុខ សន្តិភាពពេញលេញ មានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម មានការគោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍន៍ ។ *«យុទ្ធសាស្ត្រចតុកោណ»* គឺជារបៀបវារៈសេដ្ឋកិច្ចរបស់រាជ រដ្ឋាភិបាល ដែលបន្តសកម្មភាពនិងពង្រឹងសមិទ្ធផលនានា ដែលសំរេចបានពីការអនុវត្តន៍ *«យុទ្ធសាស្ត្រត្រីកោណ»* ។ ឆ្លងកាត់រយៈពេលដ៏ខ្លីបំផុត ប្រសិនបើប្រៀបធៀបនឹងប្រវត្តិសាស្ត្រនៃប្រទេសជឿនលឿន រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញដោយគ្មានការសង្ស័យថា កម្ពុជាពិតជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលប្រឡូកដោយស្មើភាពនិងស្មើសិទ្ធិក្នុងកិច្ចការតំបន់និងពិភពលោក ។

៣- ទោះបីមានការខិតខំប្រឹងប្រែង ហើយទទួលបានជោគជ័យយ៉ាងណាក្តី រាជរដ្ឋាភិបាលមិនអាចជៀសផុតពីការខ្វះខាតបានឡើយ ។ ជាក់ស្តែង រចនាសម្ព័ន្ធផលិតកម្មជាតិនៅមានទំហំតូច និងមានលក្ខណៈប្រមូលផ្តុំនៅតាមតំបន់មួយចំនួនតូច ដែលទាមទារអោយពង្រីកនិងធ្វើពិពិធកម្មផលិតកម្ម ដើម្បីធានាអោយមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ម៉្យាងវិញទៀត ទោះបីជាបានអនុវត្តយន្តការនិងនីតិវិធីមួយចំនួនសំរាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីបង្កើនចំណូលរដ្ឋក៏ដោយ ក៏យន្តការនិងនីតិវិធីទាំងនេះនៅពុំទាន់បានដំណើរការប្រកបដោយភាពឥតខ្ចោះ និងរលូននៅឡើយ ដោយសារមានឥទ្ធិពលជាអន្តរវិស័យ និងការលំបាកមួយចំនួន ដែលបានប៉ះពាល់យ៉ាងខ្លាំងដល់ទិសដៅនៃការបង្កើនចំណូល និងការវិភាជន៍ចំណាយ ។ លើសពីនេះ ក៏កត់សំគាល់អំពីកង្វះខាតនិងភាពទន់ខ្សោយ ក្នុងការសំរបសំរួលរវាងក្រសួង និងស្ថាប័នជំនាញមួយចំនួនផងដែរ ។

៤- ដើម្បីពង្រឹងនីតិរដ្ឋ ច្បាប់និងបទបញ្ញត្តិជាច្រើនត្រូវបានរៀបចំ និងអនុម័ត ។ រាជរដ្ឋាភិបាលជឿជាក់ថា ការកសាងច្បាប់និងបទបញ្ញត្តិជាជំហានសំខាន់បំផុតក្នុងការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។ ប៉ុន្តែ ក៏នៅមិនទាន់គ្រប់គ្រាន់ឡើយ ព្រោះថា ការពង្រឹងសមត្ថភាពក្រសួងនិងស្ថាប័នជំនាញសំរាប់អនុវត្តច្បាប់និងបទបញ្ញត្តិទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាពនិងគណនេយ្យភាព គឺជាការចាំបាច់ក្នុងការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។ ការរៀបចំ និងការកែទំរង់ឡើងវិញ នូវបរិធានតុលាការនៅតែជាបញ្ហាប្រឈមសំរាប់រាជ រដ្ឋាភិបាលដោយសារកង្វះខាតនូវធនធានមនុស្សនិងបច្ចេកទេស ។ កង្វះខាតអ្នកឯកទេសកម្ពុជាខាងផ្នែកច្បាប់ បាននាំអោយកម្ពុជាជួបនឹងស្ថានភាព ដែលការរៀបចំសេចក្តីព្រាងច្បាប់ត្រូវទទួលរងឥទ្ធិពល ពីអ្នកជំនាញការបរទេស ។ ប្រការនេះបានបង្កើតភាពមិនស៊ីសង្វាក់គ្នាមួយចំនួន ក្នុងការតាក់តែងច្បាប់កន្លងមក ដែលអាចនាំអោយមានការលំបាកក្នុងពេលអនុវត្តន៍ច្បាប់ ។ ភាពទន់ខ្សោយក្នុងការអនុវត្តន៍ច្បាប់ក៏បណ្តាលមកពីមូលហេតុផ្សេងៗជាច្រើន ក្នុងនោះ ក៏មានកត្តាប្រាក់បៀវត្សរ៍ទាបផងដែរ ។ យើងមានការលំបាកក្នុងការអនុវត្តន៍ច្បាប់ប្រកបដោយតម្លាភាព និងដោយគ្មានការភ័យខ្លាច ប្រសិនបើបៀវត្សរបស់មន្ត្រីអនុវត្តច្បាប់មានកំរិតទាប ក្រោមតំរូវការអប្បរមា ។

៥- រាជរដ្ឋាភិបាលកម្ពុជាបានបន្តអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ហើយទទួលបានវឌ្ឍនភាពគួរអោយកត់ សំគាល់ក្នុងការសំរេចឱ្យបាន នូវកំណើនសេដ្ឋកិច្ចរយៈពេលយូរអង្វែងប្រកបដោយសមធម៌ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះបានផ្តោតការយកចិត្តទុកដាក់លើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងស្ថាប័នហិរញ្ញវត្ថុនិងធនាគារ ការអនុវត្តន៍វិធានការកំណែទំរង់សារពើពន្ធ ការគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិសាធារណៈ និងការបង្កើនវិនិយោគសាធារណៈសំរាប់ស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមកិច្ច និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ចំពោះរាជរដ្ឋាភិបាល កំណើនសេដ្ឋកិច្ចគឺជាអាវុធដ៏ខ្លាំងក្លាសំរាប់ប្រឆាំងនឹងភាពក្រីក្រ ហើយរាជរដ្ឋាភិបាលនៅតែបន្តអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីរក្សាអោយបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្វែរប្រភពធនធាន ទៅក្នុងវិស័យណាដែលមានប្រសិទ្ធិភាពជាង និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក ។ ការរក្សាស្ថិរភាពនយោបាយ សន្តិភាព និងសន្តិសុខក្នុងប្រទេស បានជួយរាជរដ្ឋាភិបាលក្នុងការពង្រឹង ដំណើរការកែទំរង់អោយកាន់តែទូលំទូលាយនិងស៊ីជំរៅថែមទៀត ព្រមទាំងរក្សាបាននូវចលនាការសំរាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយចីរភាព ។

៦- ក្នុងរយៈកាល៥ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលសំរេចបានវឌ្ឍនភាពគួរអោយកត់សំគាល់ ក្នុងការអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចដោយផ្តោតទៅលើអ្នកក្រីក្រ ការសំរេចបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ការបន្តអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ការពង្រឹងនីតិរដ្ឋនិងអភិបាលកិច្ចល្អ និងការកៀរគរធនធានសំរាប់កិច្ចអភិវឌ្ឍន៍ ព្រមទាំងការកែលំអការផ្តល់សេវា សាធារណៈដើម្បីឆ្លើយតបនឹងតំរូវការ និងសំណូមពររបស់ប្រជាជន ។ កិច្ចប្រឹងប្រែងទាំងអស់នេះត្រូវ បានអនុវត្តក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍ កម្ពុជា ។ ទន្ទឹមនេះរាជរដ្ឋាភិបាលក៏បានទទួលស្គាល់ផងដែរថា កម្ពុជាត្រូវធ្វើដំណើរលើផ្លូវដ៏វែងអន្លាយទៅមុខទៀត ដោយត្រូវ

ពុះពារឆ្លងកាត់ឧបសគ្គច្រើនរាប់មិនអស់ថែមទៀត ដើម្បីសំរេចបាននូវវឌ្ឍនភាពប្រកបដោយចិរភាព និង វិបុលភាពដ៏រុងរឿងថ្កើងថ្កានជូនប្រទេសជាតិនិងប្រជាជន ។ ការជំរុញអោយមានការចូលរួមទូលំទូលាយពីប្រជាជនក្នុងការកាត់បន្ថយភាពក្រីក្រ នៅតែជាគោលដៅចំបងរបស់រាជរដ្ឋាភិបាល ។

៧- ចាប់ពីឆ្នាំ១៩៩៣មក សភាពការណ៍សេដ្ឋកិច្ចទូទៅមានដំណើរការល្អគួរអោយកត់សំគាល់ ។ នៅចន្លោះឆ្នាំ ១៩៩៣-២០០៤ ផ.ស.ស (គិតតាមតំលៃឆ្នាំ២០០០) បានកើនឡើងជាមធ្យមចំនួន៧,១% ហើយតាមការប៉ាន់ស្មានបឋម ផ.ស.ស ក្នុងឆ្នាំ២០០៥ អាចកើនឡើងរហូតដល់៧,០% ។ ទន្ទឹមនឹងនេះ កំរិតនៃភាពក្រីក្រក៏បានថយចុះគួរអោយកត់សំគាល់ផងដែរ ។ ផ្អែកតាមលទ្ធផលនៃការធ្វើអង្កេតសេដ្ឋកិច្ច និងសង្គម កិច្ច ឆ្នាំ២០០៤ បានបង្ហាញថា ក្នុង៥៦%នៃភូមិនៅជនបទ ដែលតំណាងអោយ៦៥%នៃប្រជាជនជនបទនិង ទីក្រុង ហើយដែលបានធ្វើអង្កេតក្នុងឆ្នាំ១៩៩៣ និង២០០៤ ចំនួនប្រជាជនកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ បានថយចុះពី ៣៩%មក ២៨% ឬថយចុះច្រើនជាង២៨% ។ អង្កេតក្នុងឆ្នាំ១៩៩៣ ពុំបានគ្របដណ្តប់តំបន់មួយចំនួន ដែលមិនទាន់មានសុវត្ថិភាពពេញលេញឡើយ ។

៨- កន្លងមកថ្មីៗនេះ ធនាគារពិភពលោកបានធ្វើការសិក្សាមួយស្តីពី «ការវាយតំលៃភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០០៥» ដើម្បីប៉ាន់ស្មានកំរិតនៃភាពក្រីក្រនៅឆ្នាំ១៩៩៣សំរាប់ទូទាំងប្រទេសឡើងវិញ ។ ការសិក្សានេះបានធ្វើការប៉ាន់ស្មានឡើងវិញ ដោយផ្អែកលើទិន្នន័យឆ្នាំ១៩៩៣ និងអង្កេតបន្តបន្ទាប់មកទៀត ។ ផ្អែកតាមការគណនាឡើងវិញនេះ ការសិក្សាបានប៉ាន់ស្មានឃើញថា សមាមាត្រនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ នាឆ្នាំ១៩៩៣ មាន៤៧% ។ ផ្អែកតាមការប៉ាន់ស្មានកំរិតនៃភាពក្រីក្រក្នុងឆ្នាំ១៩៩៣នេះ ការសិក្សាបានសន្និដ្ឋានថា ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ បានថយចុះពី ៤៧%នៅឆ្នាំ ១៩៩៣ មកត្រឹមតែ ៣៥% នៅឆ្នាំ២០០៤ ។ ការសិក្សាបានរកឃើញទៀតថា «តំរូវការប្រើប្រាស់ក្នុងគ្រួសារជាមធ្យម» មានការកើនឡើង ហើយបច្ចុប្បន្ន ប្រជាជនមានទ្រព្យផលិតកម្ម សំភារៈប្រើប្រាស់យូរអង្វែងកាន់តែប្រសើរជាងមុន រីឯស្ថានភាពរស់នៅក៏បានល្អប្រសើរជាងមុនផងដែរ ។ កំរិតជីវភាពរស់នៅរបស់ប្រជាជន ក៏បានកែលំអឱ្យប្រសើរឡើង ចំពោះក្រុមប្រជាជនក្រីក្របំផុត ដែលមានប្រមាណ២០% នៃប្រជាជន ក៏ដូចជាក្រុមប្រជាជនមានបំផុត ២០% ផងដែរ ទោះបីជានៅមានគម្លាតខុសពីគ្នារវាងក្រុម ទាំង ២ នេះ ក៏ដោយ ។ ដូចគ្នានេះដែរ ភាពក្រីក្របានថយចុះទាំងនៅតំបន់ជនបទ ក៏ដូចជានៅតំបន់ ទីក្រុង ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ភាពក្រីក្រនៅតំបន់ទីក្រុង បានថយចុះច្រើនជាង ធៀបនឹងនៅតំបន់ជនបទ ក៏ដោយ ។

៩- ចក្ខុវិស័យអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល គឺការកសាងសង្គមមួយដែលមានសាមគ្គីភាពរឹងមាំ មានប្រព័ន្ធ អប់រំ និងវប្បធម៌ជឿនលឿន ដើម្បីរំដោះប្រជាជនអោយរួចផុតពីច្រវាក់ខ្នោះឃ្នាងនៃភាពក្រីក្រ គ្មានអនក្ខរភាព និងជម្ងឺដម្កាត់ផ្សេងៗ ។ ការអនុវត្តន៍អោយបានសម្រេចចក្ខុវិស័យនេះ ទាមទារអោយប្រកាន់ខ្ជាប់នូវតម្លៃ យុត្តិធម៌ក្នុងសង្គម សុខុមាលភាព ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ និងការរៀបចំនិងការអនុវត្តន៍គោល

នយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការពង្រឹងអភិបាលកិច្ចល្អ ។

**សមិទ្ធិផលរបស់រាជរដ្ឋាភិបាលបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ខែធ្នូ ឆ្នាំ២០០៤**

១០- ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តន៍កំណែទំរង់សារពើពន្ធបានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ច ឆ្នាំ២០០៤-២០០៥ មានភាពរឹងមាំ ទោះបីជាមានកត្តាអវិជ្ជមានក្រៅប្រទេសខ្លះក៏ដោយ (ដូចជា ការកើនឡើងនៃតំលៃប្រេង ជំងឺសារស៍ ការរាតត្បាតនៃជំងឺគ្រុនផ្តាសាយបក្សី និងលក្ខខ័ណ្ឌអាកាសធាតុមិនអនុគ្រោះនៅក្នុងឆ្នាំ២០០៤) ។ នៅក្នុងឆ្នាំ២០០៤ កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស) គិតតាមតំលៃស្ថេរ បានកើនដល់ ៧,៧% ធៀបនឹងកំណើន ផ.ស.ស ៧,០% ក្នុងឆ្នាំ២០០៣ និង ៥,២% ក្នុងឆ្នាំ២០០២ ។ តាមការប៉ាន់ស្មានបឋម សេដ្ឋកិច្ចក្នុងឆ្នាំ ២០០៥ បានកើន ៧% ដោយសារកំណើនយ៉ាងខ្លាំងក្លានៅក្នុងវិស័យកសិកម្ម ការបន្តពង្រីកសកម្មភាពនាំចេញ ទេសចរណ៍ និងសំណង់ ។ ផ.ស.ស សរុបក្នុងឆ្នាំ២០០៤ មាន ១៩.៦៣០ពាន់លានរៀល ស្មើនឹងប្រមាណ ៤,៩ពាន់លានដុល្លារអាមេរិក) ។

១១- គោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលត្រូវបានរៀបចំឡើង ដើម្បីធានាឱ្យក៏រិតចំណាយមានសង្គតិភាពជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ កម្មវិធីចំណាយកំពុងត្រូវបានរៀបចំ ដើម្បីឱ្យក្លាយទៅជាផ្នែកមួយនៃប្រព័ន្ធកំណែទំរង់ ដែលជំរុញកំណើនសន្សំក្នុងស្រុក ការវិនិយោគប្រកបដោយផលិតភាពខ្ពស់ និងការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព ។ ស្ថានភាពសារពើពន្ធក្នុងឆ្នាំ២០០៤-២០០៥ មានភាពល្អប្រសើរ ដោយមានកំណើនចំណូលក្នុងស្រុក និងមានការត្បិតត្បៀតចំណាយសាធារណៈ ។

១២- ចំណូលក្នុងស្រុកសរុបបានកើនឡើងពី១០,២% នៃ ផ.ស.ស ក្នុងឆ្នាំ២០០៣ទៅ១១,៣% នៅឆ្នាំ២០០៤ និង ១១,៧% នៅឆ្នាំ២០០៥ ។ ចំណូលពន្ធបានកើនពី៨,៤% ក្នុងឆ្នាំ២០០៤ ដល់ ៨,៧% នៃ ផ.ស.ស ក្នុងឆ្នាំ ២០០៥ ។ កំណើនចំណូលបានឆ្លុះបញ្ចាំងនូវប្រសិទ្ធភាពនៃវិធានការនានាសំរាប់ប្រមូលចំណូល ដែលបានដាក់អោយអនុវត្តក្នុងត្រីមាសទី៤ឆ្នាំ២០០៣និងដើមឆ្នាំ២០០៤ ។ វិធានការទាំងនេះគឺជាវិធានការ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់អោយអនុវត្ត សំរាប់បន្តប្រឹងប្រែងប្រមូលចំណូលពីប្រៃសណីយ៍ ពីទូរស័ព្ទ និងពីទូរគមនាគមន៍ ការប្រមូលចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងវិធានការបន្ថែមផ្សេងៗទៀត ដូចជាការពង្រីកមូលដ្ឋានយកពន្ធ ការបង្កើនការប្រមូលថ្លៃទិដ្ឋាការ និងចំណូលពី ទេសចរណ៍ជាដើម ។

១៣- ក្នុងឆ្នាំ២០០៤-២០០៥ រាជរដ្ឋាភិបាលបានប្រឹងប្រែងក៏រិតចំណាយអោយនៅក្រោមគោលដៅ ដែលអាចជួយកាត់បន្ថយការធ្វើហិរញ្ញប្បទានពីប្រភពក្នុងស្រុក ។ ក្នុងកំឡុងពេល២ឆ្នាំនេះ ចំណាយចរន្តសរុបមានក៏រិតទាបជាងចំណូលដែលប្រមូលបាន គិតទាំងន័យនាមករណ៍ និងជាភាគរយ នៃ ផ.ស.ស ។ ចំណាយចរន្ត

សរុបបានធ្លាក់ចុះពី១០,៦% នៃ ផ.ស.ស នៅក្នុងឆ្នាំ២០០៣ ដល់៩,៥% ក្នុងឆ្នាំ២០០៤ និង៩,៣% ក្នុងឆ្នាំ២០០៥ (តាមការប៉ាន់ស្មានបឋម) ។

១៤- ជារួម យើងបានសំរេចវឌ្ឍនភាពក្នុងការសំរេចនូវគោលដៅនៃសូចនាករពិនិត្យរួមគ្នា ដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់កន្លងមក ។ បញ្ហាមួយដែលបានកត់សំគាល់ គឺកង្វះនូវទំនាក់ទំនងរវាងសកម្មភាពដែលត្រូវអនុវត្តដើម្បីសំរេចនូវសូចនាករត្រួតពិនិត្យរួមគ្នា ជាមួយនឹងធនធានដែលកៀរគរ បាន ។ របាយការណ៍ស្តីពីការត្រួតពិនិត្យប្រចាំឆ្នាំ២០០៥ បានគូសបញ្ជាក់ថា នៅក្នុងវិស័យណាដែលមានទំនាក់ទំនងយ៉ាងច្បាស់លាស់ រវាងសកម្មភាពដែលបានគ្រោងទុកជាមួយនឹងធនធានដែលត្រូវការ សម្រាប់អនុវត្តសកម្មភាពទាំងនេះ វិស័យនោះមានវឌ្ឍនភាពជាដុំកំភួនជាងនៅតាមវិស័យណាដែលមានទំនាក់ទំនងខ្សោយ ឬគ្មានទំនាក់ទំនង ឬខ្វះភាពជាម្ចាស់របស់ស្ថាប័នពាក់ព័ន្ធ ។

១៥- សម្រាប់រាជរដ្ឋាភិបាល បញ្ហាប្រឈមដែលត្រូវជំនះ ដោះស្រាយក្នុងកិច្ចអភិវឌ្ឍន៍ គឺការកាត់បន្ថយភាពក្រីក្រ និងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន និងជីវិតរស់នៅកាន់តែល្អប្រសើររបស់ប្រជាជនដែលកំពុងតែកើនឡើង ។ ទោះបីជារាជរដ្ឋាភិបាលបានសម្រេចនូវវឌ្ឍនភាពជាដុំកំភួនទាទស្សវត្សរ៍ចុងក្រោយនេះ ក៏ការបន្តកាត់បន្ថយកំរិតភាពក្រីក្រ ពិសេសនៅតំបន់ជនបទ និងការលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជនអោយបានល្អប្រសើរ នៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ ការពន្លឿនកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម ដែលកំលាំងពលកម្មប្រមាណ៧៥% កំពុងពឹងផ្អែកលើវិស័យនេះ គឺជាអាទិភាពសខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា មិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការកែលំអជាដុំកំភួនខាងផ្នែកផលិតភាព និងការបង្វែរពីផលិតផលស្រូវ ទៅជាដំណាំផ្សេងៗទៀតក្នុងវិស័យកសិកម្ម ។ ការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម និងទឹកឱ្យបានឆាប់ គឺជាអាទិភាពខ្ពស់មួយទៀតរបស់រាជរដ្ឋាភិបាល ។ ក្រសួងពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ ចាំបាច់ត្រូវផ្តល់អាទិភាពខ្ពស់ដើម្បីធ្វើកិច្ចការនេះ ។ រាជរដ្ឋាភិបាលយល់ថា ភាពក្រីក្រគឺជាការខ្ជះខ្ជាយធនធានសេដ្ឋកិច្ចដ៏មានតម្លៃ ដែលមិនត្រឹមតែមិនអាចទទួលយកបានប៉ុណ្ណោះទេ ប៉ុន្តែ អាចធ្វើឱ្យមានការបែកខ្ញែក ប្រេះឆា និងអស្ថិរភាពសង្គមទៀតផង ។

១៦- យើងក៏ទទួលស្គាល់អំពីសមត្ថភាពមានកំរិតនៃប្រព័ន្ធច្បាប់ និងតុលាការដែរ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ក្នុងឆ្នាំ២០០៥ យើងមានវឌ្ឍនភាពជាច្រើនក្នុងការរៀបចំសេចក្តីព្រាងច្បាប់ទាំងនេះ ។ ក្នុង ឆ្នាំ២០០៥ ច្បាប់ចំនួន៤៥បានអនុមត់ដោយរដ្ឋសភារួចហើយ ធៀបនឹងច្បាប់ចំនួន៩០ប៉ុណ្ណោះ ដែលបានអនុម័តក្នុងរយៈពេល៥ ឆ្នាំ១៩៩៣-១៩៩៨កន្លងមក ។ ទន្ទឹមនេះ ក៏មានច្បាប់មួយចំនួនទៀតដែរ ដែលត្រូវបានស្នើជូនរដ្ឋសភាក្នុងឆ្នាំ២០០៥នេះ ហើយនៅកំពុងរង់ចាំការអនុមត់នៅឡើយ ។

១៧- រាជរដ្ឋាភិបាលក៏សូមរីករាយជំរាបដែរថា ក្នុងការបន្តពង្រឹងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម នៅកម្ពុជា ដំណើរការនៃការបោះឆ្នោតព្រឹទ្ធសភាដោយសេរី និងយុត្តិធម៌បានប្រព្រឹត្តទៅ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០០៥ ។ ដំណើរការនៃការបោះឆ្នោតនេះត្រូវប្រើប្រាស់ថវិការដ្ឋ និងមន្ត្រីកម្ពុជា ហើយក៏គ្មានការពិភាក្សាណាមួយអំពីការរៀបចំថវិកាបរទេស ឬការប្រើប្រាស់អ្នកជំនាញបរទេសសំរាប់ដំណើរការបោះឆ្នោតនេះដែរ ។

## ការអនុវត្តន៍បណ្តាអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦ - ២០១០

១៨- «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» គឺជាផែនទីចង្អុលផ្លូវ សំរាប់ដឹកនាំប្រទេសពីកំរិតបច្ចុប្បន្ន ក្នុងឆ្នាំ២០០៥ ទៅដល់កំរិតមួយដែលត្រូវសំរេចឱ្យបាន នាឆ្នាំ២០១០ ខាងមុខនេះ ដោយត្រូវប្រើប្រាស់ធនធានដែលមានប្រកបដោយប្រសិទ្ធភាព និងដោយផ្តោតទៅលើលទ្ធផល ។ ដើម្បីឈានទៅអនុវត្តឱ្យបានសំរេចនូវទស្សនទាន រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើអាទិភាព និងគោលដៅជា យុទ្ធសាស្ត្រព្រមទាំងសូចនាករ ដែលមានចែងក្នុង«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ គឺជាឯកសារតែមួយគត់ ដែលមានដាក់បញ្ចូលនូវបណ្តាគោលដៅ និងយុទ្ធសាស្ត្រអាទិភាពនានារបស់រាជ រដ្ឋាភិបាល សំរាប់កាត់បន្ថយភាពក្រីក្រអោយបានឆាប់រហ័ស ដើម្បីឈានទៅសំរេចបានគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍កម្ពុជា និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច សំរាប់ជាប្រយោជន៍ដល់ប្រជាជនទាំងមូល ។ រីឯ «កម្មវិធីវិនិយោគសាធារណៈ ឆ្នាំ២០០៦-២០០៨» ត្រូវបានរៀបចំសំរាប់គាំទ្រដល់ការអនុវត្តន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ឯកសារទាំង២នេះត្រូវបានអនុមតិដោយរាជរដ្ឋាភិបាលក្នុងអង្គប្រជុំរបស់ គណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ ឯកសារទាំងនេះក៏មានគោលដៅឱ្យដៃគូអភិវឌ្ឍន៍ ទាំងអស់ធ្វើការតំរឹម និងធ្វើសុខដុមនីយកម្មកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ និងផ្ទេរធនធានពិតប្រាកដមកកម្ពុជាឱ្យបានច្រើនជាងមុន ។ រាជរដ្ឋាភិបាលសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ ទ្វេ-ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាលសូមតម្រឹមយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ខ្លួន ឱ្យស្របនឹង បណ្តាអាទិភាព ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងតម្រឹមគំរោងនិងកម្មវិធី ជាមួយនឹងកម្មវិធីវិនិយោគសាធារណៈ ។

## ការកសាងភាពជាដៃគូ សំរាប់បង្កើនប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ

១៩- ចាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ដែលបានប្រព្រឹត្តទៅនាខែធ្នូ ឆ្នាំ២០០៤ កន្លងមក យើងបានកត់សំគាល់អំពីវឌ្ឍនភាពជាច្រើន ទាំងនៅលើឆាកអន្តរជាតិ ទាំងក្នុងប្រទេសកម្ពុជា ក្នុងការខិតខំដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពជំនួយ ។ នៅលើឆាកអន្តរជាតិ វេទិកាកំរិតខ្ពស់លើកទី២បានប្រារព្ធឡើង ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី០២ ខែមិនា ឆ្នាំ ២០០៥ នៅទីក្រុងប៉ារីស ដើម្បីពិនិត្យឡើងវិញអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍ការប្តេជ្ញានៃ «សេចក្តីប្រកាស ទីក្រុងរ៉ូម» ។ នៅក្នុងវេទិកានោះ រាជរដ្ឋាភិបាលបានធ្វើលើកបង្ហាញពី «របាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការពង្រឹងប្រសិទ្ធភាពជំនួយនៅកម្ពុជា» ។ នៅពេលបិទសម័យប្រជុំនេះ សេចក្តីប្រកាសរួមដែលបានឯកភាពដោយរដ្ឋមន្ត្រីនៃបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍

ទទួលបន្ទុកខាងកិច្ចអភិវឌ្ឍន៍ និងប្រធានស្ថាប័នទទួលបន្ទុកកិច្ចអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី បានកំណត់គោលការណ៍ថ្មីៗមួយចំនួន សំរាប់បណ្តាប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍ សំរាប់ដោះស្រាយបញ្ហាប្រសិទ្ធភាពនៃជំនួយ ។ បណ្តាការប្តេជ្ញាចិត្តនៃ «សេចក្តីប្រកាសទីក្រុងប៉ារីស» បានកំណត់បណ្តាវិធានការសកម្មភាពទូលំទូលាយមួយចំនួន ហើយដែលអាចត្រួតពិនិត្យបាន ដើម្បីកែទំរង់បែបបទនៃការផ្តល់ និងគ្រប់គ្រងជំនួយ ។

២០- បន្ទាប់ពី «សេចក្តីប្រកាសទីក្រុងប៉ារីស»មក ក្រុមការងារស្តីពីប្រសិទ្ធភាពជំនួយនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ បានបង្កើតក្រុមការងារចំណុះមួយ សំរាប់ត្រួតពិនិត្យការអនុវត្តន៍ «សេចក្តីប្រកាសទីក្រុងប៉ារីស» ។ ក្រុមការងារចំណុះនេះត្រូវបានដឹកនាំដោយសហប្រធាន ដែលវៀតណាមជាតំណាងឱ្យប្រទេសជាដៃគូ និងចក្រភពអង់គ្លេសជាតំណាងឱ្យដៃគូអភិវឌ្ឍន៍ ។ រីឯសមាជិកនៃក្រុមការងារចំណុះនេះរួមមាន តំណាងប្រទេសអូទ្រីស កម្ពុជា កាណាដា សហគមន៍ អឺរ៉ុប បារាំង អាល្លឺម៉ង់ ហ្គាណា ម៉ាលី នីការ៉ាហ្គា ណ័រវ៉េ សេនេហ្គាល់ អាហ្វ្រិកខាងត្បូង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សហរដ្ឋអាមេរិក និងធនាគារពិភពលោក ។ ការចូលរួមនៃបណ្តាប្រទេសជាដៃគូក្នុងកិច្ចការនេះ ក៏ត្រូវពង្រីកឱ្យកាន់តែទូលំទូលាយផងដែរ ហើយបច្ចុប្បន្ន នេះ ក្រុមការងារនេះរួមមានប្រទេសដៃគូចំនួន២៣ និងដៃគូអភិវឌ្ឍន៍ទ្វេភាគី ២៣ និងស្ថាប័នពហុភាគីជាច្រើនទៀត ។ ក្រុមការងារចំណុះនេះមានភារកិច្ចរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពចំនួនពីរ ស្តីពីការអនុវត្តន៍ការប្តេជ្ញាចិត្តនៃ «សេចក្តីប្រកាសទីក្រុងប៉ារីស» មុនពេលប្រារព្ធវេទិកាកំរិតខ្ពស់លើកទី៣ ដែលគ្រោងរៀបចំនៅប្រទេសហ្គាណា នាឆ្នាំ២០០៨ ។ ការរៀបចំរបាយការណ៍លើកទី១ ស្តីពីវឌ្ឍនភាពនឹងត្រូវអនុវត្តក្នុងឆ្នាំ២០០៦នេះ ។ ប្រទេសកម្ពុជាត្រូវបានជ្រើសរើសជាប្រទេសមួយក្នុងចំណោមប្រទេសដៃគូចំនួន៦ សំរាប់អនុវត្តសាកល្បងសំណួរអង្កេតស្តីពីការអនុវត្តន៍ការប្តេជ្ញាចិត្តដែលមានចែងក្នុង «សេចក្តីប្រកាសទីក្រុងប៉ារីស» នាដើមឆ្នាំ២០០៦ ។

២១- រីឯនៅក្នុងប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ២០០៥នេះ រាជរដ្ឋាភិបាល ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយដៃគូអភិវឌ្ឍន៍ បានសម្រេចនូវវឌ្ឍនភាពជាដុំកំភួនក្នុងកិច្ចការមួយចំនួន ដូចជា ÷

- បង្កើតយន្តការថ្មីមួយសម្រាប់សម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលយន្តការនេះអាចឱ្យរាជរដ្ឋាភិបាលត្រួតពិនិត្យ ជារៀងរាល់ត្រីមាស អំពីវឌ្ឍនភាពនៃការអនុវត្តន៍សកម្មភាពនានានៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករត្រួតពិនិត្យតាមដានរួមគ្នាដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧កន្លងមក ។
- ការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខុដុមនីយកម្ម និងការតំរឹម ។
- ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។
- ការរៀបចំគោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់គ្រប់គ្រងជំនួយឥតសំណង និងនីតិវិធីបទដ្ឋានប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី ។

- ការគាំទ្រមន្ត្រីជាន់ខ្ពស់នៅតាមក្រសួងនិងស្ថាប័ននានា ដើម្បីពង្រឹងភាពជាម្ចាស់ក្នុងការគ្រប់គ្រង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

២២- ការបង្កើតយន្តការក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺជាការផ្លាស់ប្តូរជាសារវ័ន្ត ខាងផ្នែកស្ថាប័ន ខាងការរៀបចំផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យវឌ្ឍនភាពស្តីពីការអនុវត្តន៍ជំនួយអភិវឌ្ឍន៍ ដើម្បីពង្រឹងប្រសិទ្ធភាពជំនួយ ។ ការពង្រឹងយន្តការនេះសំរាប់កែលំអដំណើរការនៃការកៀរគរ ការបែងចែក និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការសំរាប់បង្កើនប្រសិទ្ធភាពជំនួយ គឺជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ ការប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានផ្តល់ឱ្យភាគីទាំងសងខាង ពិនិត្យរួមគ្នា អំពីវឌ្ឍនភាពដែលសំរេចបាន និងបញ្ហាលំបាក ព្រមទាំងលើកវិធានការសំរាប់ដោះស្រាយ ។

២៣- ជារួម ក្រុមការងារបច្ចេកទេសចម្រុះសម្រេចបាននូវវឌ្ឍនភាពជាដុំកំភួនក្នុងឆ្នាំ២០០៥នេះ ។ ក្រុមការងារខ្លះបំពេញកិច្ចការរបស់ខ្លួនបានប្រសើរជាងក្រុមការងារដទៃទៀត ។ ឆ្នាំ២០០៥ គឺជា «ឆ្នាំរៀន ផង- ធ្វើផង» សម្រាប់ក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ដែលជាសមាជិកនៃក្រុមការងារចម្រុះ ។ ក្នុងពេលរៀបចំប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នាខែធ្នូ ឆ្នាំ ២០០៥ លេខាធិការដ្ឋានបានព្យាយាមប្រមូលពត៌មានពីក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីការប៉ាន់ស្មានធនធានហិរញ្ញវត្ថុ ដែលក្រុមការងារត្រូវការសម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងធនធានដែលក្រុមការងារអាចកៀរគរបានក្នុងឆ្នាំ២០០៥ នេះ ។ កំហើញដ៏សំខាន់មួយនៃការអង្កេតនេះ បានបង្ហាញថា មានក្រុមការងារបច្ចេកទេសតិចតួចប៉ុណ្ណោះ ដែលបានរៀបចំការប៉ាន់ស្មានពីតំរូវការធនធាន សម្រាប់អនុវត្តផែនការសកម្មភាពឆ្នាំ២០០៥ ។ ក្នុងរបាយការណ៍ដែលស្នើជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ លេខាធិការដ្ឋានបានបញ្ជាក់ថា ក្រុមការងារបច្ចេកទេសណា ដែលបាន ផ្សារភ្ជាប់សកម្មភាពរបស់ខ្លួនជាមួយនឹងតំរូវការធនធានសម្រាប់អនុវត្ត ក្រុមការងារបច្ចេកទេសនោះ សម្រេចបានលទ្ធផលប្រសើរជាងក្រុមការងារណាដែលមិនបានអនុវត្តតាមរបៀបនេះ ។ លើសពីនេះ លេខាធិការដ្ឋានក៏បានកត់សំគាល់ផងដែរថា ក្នុងវិស័យដែលមានទំនាក់ទំនងយ៉ាងច្បាស់លាស់ រវាងសកម្មភាពដែលបានគ្រោងទុក ជាមួយនឹងធនធានដែលត្រូវការសម្រាប់អនុវត្តសកម្មភាពទាំងនេះ វិស័យនោះមានវឌ្ឍនភាពល្អប្រសើរជាងវិស័យដែលមានទំនាក់ទំនងខ្សោយ ឬគ្មានទំនាក់ទំនង ឬខ្វះភាពជាម្ចាស់របស់ស្ថាប័នពាក់ព័ន្ធ ។ ដូចនេះ ក្រុមការងារបច្ចេកទេសចម្រុះចាំបាច់ត្រូវយកចិត្តទុកដាក់ពិសេស ទៅលើបញ្ហានេះ ។ ដោយសារតែធនធានហិរញ្ញវត្ថុមានកំរិត ជំនួយអភិវឌ្ឍន៍ផ្លូវការគឺជាប្រភពដ៏សំខាន់ សម្រាប់ផ្តល់ហិរញ្ញប្បទានដល់កម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ ការបែងចែក និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ក្នុងក្របខ័ណ្ឌគណនេយ្យភាពទ្វេទិស ដើម្បីឆ្លើយតបនឹងអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល គឺជាប្រការមានសារៈសំខាន់សម្រាប់រាជរដ្ឋាភិបាល ។

២៤- ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ដែលបានរៀបចំតាមរយៈការពិគ្រោះយោបល់ទូលំទូលាយរវាងបណ្តាក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រី នាថ្ងៃ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤កន្លងមក ។ ដៃគូអភិវឌ្ឍន៍ចំនួន១២ ដែលបានបង្ហាញអំពីឆន្ទៈរបស់ខ្លួន ក្នុងការគាំទ្រការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម បានចុះហត្ថលេខាជាមួយរាជរដ្ឋាភិបាល នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍ទាំងនោះរួមមាន ÷ អូស្ត្រាលី កាណាដា ដាណឺម៉ាក បារាំង អាល្លឺម៉ង់ ជប៉ុន ស៊ុយអ៊ែត ចក្រភពអង់គ្លេស ធនាគារអភិវឌ្ឍន៍អាស៊ី សហគមន៍អឺរ៉ុប អង្គការអភិវឌ្ឍន៍ សហប្រជាជាតិ និងធនាគារពិភពលោក ។

២៥- របាយការណ៍របស់លេខាធិការដ្ឋានស្តីពីវឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្មនេះ ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នាខែធ្នូ ឆ្នាំ ២០០៥ បានបង្ហាញថា វឌ្ឍនភាពជាវិជ្ជមានលើផ្នែកទាំងឡាយណាដែលទាមទារអោយមានសកម្មភាពពីរាជរដ្ឋាភិបាល ។ ប៉ុន្តែ ផ្នែកទាំងឡាយណាដែលតំរូវអោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍វិញ គឺមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ។ ក្នុងឆ្នាំ២០០៥ កន្លងមក ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព នូវផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតំរឹម និងលទ្ធផលនេះ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ ។ ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល បានអនុមតិដោយសម្តេច នាយករដ្ឋមន្ត្រី នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០០៦ ។

២៦- ក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តាមរយៈការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍ ។ សេចក្តីព្រាងយុទ្ធសាស្ត្រនេះត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ហើយកំពុងត្រូវបានអនុវត្តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ទន្ទឹមនេះ គោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់ជំនួយឥតសំណង និងទំរង់ការស្តង់ដារនៃកិច្ចប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី ក៏ត្រូវបានរៀបចំបញ្ចប់ហើយដែរ ។ លើសពីនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការ នូវយន្តការសំរាប់ពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន និងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលផងដែរ ។

២៧- សេចក្តីប្រកាសទីក្រុងរ៉ូមស្តីពីសុខដុមនីយកម្មនាឆ្នាំ ២០០៣ និងសេចក្តីប្រកាសទីក្រុងប៉ារីស ស្តីពីប្រសិទ្ធភាពជំនួយ នាដើមឆ្នាំ២០០៥ បានបញ្ជាក់ពីភាពជាម្ចាស់នៃកិច្ចដំណើរការអភិវឌ្ឍន៍របស់ប្រទេសទទួលជំនួយអភិវឌ្ឍន៍ផ្លូវការ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាធ្វើជាម្ចាស់យ៉ាងពេញលេញ មិនត្រឹមតែក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ ប៉ុន្តែ នឹងធានាថា ធនធានជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវបានប្រើប្រាស់ចំទិសដៅ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍អាទិភាព សម្រាប់ជាអត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

២៨- ទោះជាមានការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិយ៉ាងណាក៏ដោយ ក៏ការអនុវត្តន៍ជាក់ស្តែងរបស់ដៃគូអភិវឌ្ឍន៍មួយចំនួន បាននិងកំពុងបន្តអនុវត្តតាមគន្លងនៃទសវត្សរ៍ឆ្នាំ១៩៩០ ដែលការសិក្សាជាច្រើនបានប្រសិទ្ធនាមថា ជាដំណាក់នៃ «ការផ្តល់ជំនួយតាមទស្សនៈរបស់ពួកអ្នកផ្តល់ជំនួយ» ។ បញ្ហាប្រឈមរបស់ដៃគូអភិវឌ្ឍន៍ទ្វេ-ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល គឺការប្រែក្លាយឱ្យបានឆាប់នូវការប្តេជ្ញាចិត្ត ដែលបានធ្វើឡើងក្នុងវេទិកាអន្តរជាតិ ឱ្យទៅជាសកម្មភាពប្រតិបត្តិការជាក់លាក់ ដើម្បីផ្លាស់ប្តូរទំលាប់នៃការអនុវត្តន៍ របស់ដៃគូអភិវឌ្ឍន៍ សំដៅផ្តល់ឱកាសអោយរាជរដ្ឋាភិបាលពង្រឹងភាពជាម្ចាស់ក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ក្នុងបរិបថនៃកិច្ចសហប្រតិបត្តិការ ដោយមានការជឿទុកចិត្តគ្នាទៅវិញទៅមក មានគណនេយ្យទ្វេទិស សំដៅបង្កើនប្រសិទ្ធភាពជំនួយ ដើម្បីផ្តល់អត្ថប្រយោជន៍ឱ្យបានច្រើនបំផុតដល់ប្រជាពលរដ្ឋកម្ពុជា ។ ចំពោះបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលវិញ គឺការបន្តពង្រឹងប្រព័ន្ធគ្រប់គ្រង និងការរៀបចំស្ថាប័នឱ្យមាន តម្លាភាព និងគណនេយ្យភាព សំដៅពង្រឹងប្រសិទ្ធភាពជំនួយ ។

២៩- បញ្ហាបន្ទាន់នាពេលនេះ គឺការបោះបង់ចោលនូវទំលាប់ដែលធ្លាប់អនុវត្តកន្លងមកក្នុងកំឡុងទស្សវត្សរ៍ ឆ្នាំ៩០ ដែលសកម្មភាពនៃជំនួយអភិវឌ្ឍន៍បានត្រូវរៀបចំ គ្រប់គ្រង និងផ្តល់ដោយដៃគូអភិវឌ្ឍន៍ ហើយភាពជាម្ចាស់ក្នុងការជ្រើសរើសសំរាប់កិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងអភិវឌ្ឍន៍របស់ស្ថាប័នកម្ពុជានៅមានកំរិត ។ ដូចបានរៀបរាប់ពីខាងដើម ក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នាខែធ្នូ ឆ្នាំ២០០៥ ស្តីពីវឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្មនិងការតម្រឹម លេខាធិការដ្ឋានបានបញ្ជាក់ថា មានវឌ្ឍនភាពជាវិជ្ជមាននៅតាមបណ្តាផ្នែកដែលទាមទារអោយមានសកម្មភាពពីរាជរដ្ឋាភិបាល ។ ប៉ុន្តែ ចំពោះផ្នែកទាំងឡាយណាដែលគាំទ្រពីដៃគូអភិវឌ្ឍន៍វិញ គឺមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ។ ទន្ទឹមនេះ របកគំហើញនៃការសិក្សារបស់ចក្រភពអង់គ្លេស ស្តីពីសុខដុមនីយកម្មនិងការសម្របសម្រួលជំនួយនៅកម្ពុជាដែលបានបញ្ចប់នៅចុងឆ្នាំ២០០៥នេះ ក៏បានបង្ហាញថា ទាំងខាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ មិនទាន់យល់បានច្បាស់លាស់អំពីការប្តេជ្ញាដែលបានឯកភាពជាអន្តរជាតិ ហើយដែលមានចែងក្នុងសេចក្តីប្រកាសទីក្រុងរ៉ូម និងសេចក្តីប្រកាសទីក្រុងប៉ារីសនៅឡើយ ។ រាជរដ្ឋាភិបាលទទួលស្គាល់អំពីភាពចាំបាច់ ក្នុងការពង្រឹងការយល់ដឹងអំពីសេចក្តីប្រកាសទីក្រុងរ៉ូមនិងទីក្រុងប៉ារីស ដល់មន្ត្រីរបស់ក្រសួងនិងស្ថាប័ន តាមរយៈការចាត់វិធានការជាក់លាក់ក្នុងឆ្នាំ២០០៥កន្លងមក ។ រាជរដ្ឋាភិបាលក៏ចង់អោយដៃគូអភិវឌ្ឍន៍ បញ្ជាក់អំពីការប្តេជ្ញា និងឆន្ទៈខាងនយោបាយរៀងៗខ្លួន ដើម្បីអនុវត្តរួមគ្នានូវការប្តេជ្ញាចិត្តនៃសេចក្តីប្រកាស ទីក្រុងរ៉ូម និងទីក្រុងប៉ារីស ។ តាមរយៈស្មារតីនៃ សេចក្តីប្រកាសទទាំង២នេះ ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវផ្តល់អាទិភាពខ្ពស់ទៅលើកិច្ចការមួយចំនួនដូចខាង ក្រោម ÷

- ធ្វើសុខដុមនីយកម្មការអនុវត្តន៍របស់ខ្លួន ដើម្បីកាត់បន្ថយបន្ទុកខាងស្ថាប័នប្រតិបត្តិឱ្យបានច្រើន និងកាត់បន្ថយភាពខ្ជះខ្ជាយ តាមរយៈការកាត់បន្ថយសកម្មភាពជាន់គ្នា សំដៅបង្កើនប្រសិទ្ធភាពជំនួយអភិវឌ្ឍន៍ផ្លូវការ ។

- តម្រឹមការគាំទ្ររបស់ខ្លួន ជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ ២០០៦-២០១០ ។
- ទម្រង់ការនៃការគ្រប់គ្រងកម្មវិធី និងគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវអនុវត្តតាមគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ ស្តីពីការអនុវត្តន៍ល្អៗសម្រាប់ការគ្រប់គ្រង ដោយផ្តោតលើលទ្ធផល និងគោលការណ៍នៃភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ។
- ផ្ទេរធនធានជំនួយអភិវឌ្ឍន៍ផ្លូវការច្រើនជាងមុន ដោយឆ្ពោះទៅលើជនក្រីក្រ និងជនងាយរងគ្រោះ សំដៅកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

៣០- រាជរដ្ឋាភិបាលបានប្តេជ្ញាពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ (អ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល) ដោយផ្អែកលើគោលការណ៍នៃកិច្ចសហប្រតិបត្តិការការជឿទុកចិត្តគ្នាទៅវិញទៅមក និងគណនេយ្យភាពទ្វេទិស ។ ដូចបានរៀបរាប់ពីខាងដើម យន្តការថ្មីក្នុងការពង្រឹងការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ ។ យន្តការថ្មីនេះ ដែលមានក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យទាំង ១៨ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺជាវេទិកាសម្រាប់អោយស្ថាប័នផ្តល់ជំនួយទ្វេភាគី និងពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមពិភាក្សាជាមួយរាជរដ្ឋាភិបាល ទាំងក្នុងកំរិតបច្ចេកទេស និងកំរិតនយោបាយ ។ រីឯយន្តការនៃវេទិការវាងវិស័យឯកជននិងរាជរដ្ឋាភិបាលវិញ ក៏បានដំណើរការរលូនសម្រាប់កសាងភាពជាដៃគូឱ្យមានប្រសិទ្ធភាពជាមួយនឹងវិស័យឯកជនផងដែរ ។

៣១- ចំពោះអាទិភាពសំរាប់ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាស្នើដៃគូអភិវឌ្ឍន៍ទ្វេនិងពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល ឱ្យយកចិត្តទុកដាក់លើបណ្តាចំណុចដូចខាងក្រោម ÷

ក- បង្កើនភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើកម្មវិធីនិងគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ ក្នុងក្របខ័ណ្ឌនៃគណនេយ្យភាពទ្វេទិស ។ លើសពីនេះ បណ្តាអង្គការមិនមែនរដ្ឋាភិបាល ត្រូវសម្របសម្រួលសកម្មភាពរបស់ខ្លួន ជាមួយនឹងក្រសួងពាក់ព័ន្ធ ដើម្បីកំណត់ទិសដៅ និងកាត់បន្ថយសកម្មភាពជាន់គ្នាឱ្យបាន ច្រើនសំដៅទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនបំផុតពីធនធានអភិវឌ្ឍន៍ដែលមានកំរិតកំណត់ ។ ក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យត្រូវអាចដើរតួនាទីដ៏សំខាន់ ក្នុងការសម្របសម្រួលកិច្ចការងារទាំងនេះ ។

ខ- ពង្រឹងការសម្របសម្រួលកម្មវិធី និងគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល ជាមួយនឹងក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមថ្នាក់ជាតិ ។

គ- អនុវត្តបណ្តាគោលការណ៍ ដែលចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងមាត្រា១៣ ១៤ ១៥ និង១៦ នៃអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥ ក៏ដូចជាគោលការណ៍ណែនាំ និងនីតិវិធី ដែលមានចែងក្នុងគោលការណ៍ប្រតិបត្តិជាតិរបស់រាជរដ្ឋាភិបាលសម្រាប់ជំនួយឥតសំណង និងទំរង់ការស្តង់ដារនៃកិច្ចប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី ។

ឃ- បង្វែរពីរូបភាពទៅខ្លឹមសារ សំរាប់កិច្ចពិភាក្សារបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ការងារនេះទាមទារ ឱ្យមានការចូលរួមពីមន្ត្រីរបស់ដៃគូអភិវឌ្ឍន៍ដែលមានជំនាញកំរិតខ្ពស់ នៅតាមវិស័យនីមួយៗនៃក្រុម ការងារបច្ចេកទេសចម្រុះ ។ រាជរដ្ឋាភិបាលស្នើអោយដៃគូអភិវឌ្ឍន៍បញ្ឈប់ការចំណាយសំរាប់រក្សាអ្នក ដែលគ្មានឯកទេសច្បាស់លាស់នៅតាមក្រុមការងារ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏ស្នើឱ្យដៃគូអភិវឌ្ឍន៍ នីមួយៗធ្វើការជ្រើសរើសវិស័យសំខាន់ចម្បងៗរបស់ខ្លួន ហើយផ្តល់អ្នកឯកទេសកំរិតអន្តរជាតិតាម វិស័យទាំងនោះ ទៅតាមលទ្ធភាពថវិការបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។ រាជរដ្ឋាភិបាលមិនលើកទឹកចិត្ត ការប្រើប្រាស់មន្ត្រីរបស់ដៃគូអភិវឌ្ឍន៍ ដែលគ្មានជំនាញបច្ចេកទេសឯកទេសគ្រប់គ្រាន់ និងច្បាស់លាស់ ឬគ្មានបទពិសោធន៍ មកជួយរៀបចំផែនការ និងយុទ្ធសាស្ត្រនៅតាមក្រុមការងារបច្ចេកទេសតាមវិស័យ នីមួយៗទៀតឡើយ ។

ង- បង្កើនប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ។ ប្រធាននិងអ្នកសម្រប សម្រួលនាំមុខ ត្រូវធានាថា កិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសចម្រុះនីមួយៗត្រូវមានគោលបំណង ច្បាស់លាស់ និងត្រូវកំណត់អោយបានអំពីលទ្ធផលរំពឹងទុក ។ ដើម្បីកាត់បន្ថយចំនួននៃការចូលរួម ប្រជុំរបស់មន្ត្រីតំណាងក្រសួងនិងស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាលយល់ថា ដៃគូអភិវឌ្ឍន៍ ទាំងអស់ត្រូវកំណត់អោយបានច្បាស់លាស់ អំពីការចូលរួមរបស់ខ្លួននៅតាមក្រុមការងារបច្ចេកទេស ចម្រុះចំពោះតែវិស័យណាដែលដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទាន ឬសម្រួចការគាំទ្ររបស់ខ្លួននៅ ក្នុងវិស័យអាទិភាពមួយចំនួន ដែលមានចែងក្នុងយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។

ច- ពិនិត្យអំពីរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីឆ្លើយតបនឹងតំរូវការបច្ចុប្បន្ន និងបន្ទាន់របស់ក្រុមការងារ ក៏ដូចជារៀបចំគោលការណ៍ណែនាំរួមសម្រាប់កិច្ចដំណើរការរបស់ក្រុម ការងារបច្ចេកទេស ដើម្បីកាត់បន្ថយបន្ទុករបស់ក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ក្នុងការចូលរួម ការងារក្នុងក្រុមការងារបច្ចេកទេសចម្រុះ ។

ឆ- ជំរុញការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីកាត់បន្ថយ ចំនួនគម្រោងទោល ។ ការសម្រេចអនុវត្តអភិក្រមនេះ មិនត្រឹមតែកែលំអការតម្រឹមសកម្មភាពរបស់ ដៃគូអភិវឌ្ឍន៍ជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ អភិក្រមនេះនឹងជំរុញឱ្យមាន សុខដុមនីយកម្មនៃការអនុវត្តន៍របស់បណ្តាដៃគូអភិវឌ្ឍន៍ និងកាត់បន្ថយបន្ទុកខាងផ្នែកសមត្ថភាពរបស់ ក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាលដែលជាអ្នកអនុវត្តផងដែរ ។

ជ- កាត់បន្ថយចំនួននៃការសិក្សារបស់ដៃគូអភិវឌ្ឍន៍លើប្រធានបទប្រហាក់ប្រហែល ដោយបង្កើតនីតិវិធី មួយ សម្រាប់ត្រួតពិនិត្យសំណើស្តីពីការសិក្សាដែលបានគ្រោងឡើងដោយដៃគូអភិវឌ្ឍន៍ និងក្រសួងនិងស្ថាប័ន ពាក់ព័ន្ធ ។

ឈ- កាត់បន្ថយចំនួនជំនួយបច្ចេកទេសរយៈពេលវែង ដោយផ្តោតជាសំខាន់ទៅលើគុណភាព និងដោយ យកចិត្តទុកដាក់លើចំណុចទី៣ខាងលើ ដោយធានាថា ជំនួយបច្ចេកទេសរយៈពេលខ្លីពិតជាតម្រូវការ

ពិតប្រាកដ ដូចមានចែងក្នុងចំណុចទី៤ខាងលើដែរ ។ រាជរដ្ឋាភិបាលជឿជាក់ថា វត្តមានរបស់អ្នកជំនាញឯកទេសកំរិតខ្ពស់ ក្នុងការិយាល័យរបស់ដៃគូអភិវឌ្ឍន៍ ដែលមានភារកិច្ចចូលរួមយ៉ាងសកម្ម ក្នុងកិច្ចការនៃក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ នឹងជួយកាត់បន្ថយបានច្រើននូវតម្រូវការជំនួយបច្ចេកទេសរយៈពេលខ្លី ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ក្នុងរយៈពេលពេលខ្លីនិងមធ្យម យើងនៅត្រូវការជំនួយបច្ចេកទេសកំរិតខ្ពស់ ដើម្បីជួយសម្របសម្រួលការអនុវត្តន៍គម្រោងធំៗ ការអនុវត្តន៍កម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល និងការងារនានាដែលពាក់ព័ន្ធនឹងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច និងសម្រាប់ពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំរាប់រៀបចំ អនុវត្ត និងត្រួតពិនិត្យសកម្មភាពអភិវឌ្ឍន៍ ។ ទន្ទឹមនេះ តម្រូវការជំនួយបច្ចេកទេស ក្នុងរយៈពេលខ្លី និងមធ្យម ត្រូវគិតគូរដល់ការងារខ្លះៗដែលត្រូវធ្វើជំនួសជាបណ្តោះអាសន្ន នៅតាមវិស័យយុទ្ធសាស្ត្រមួយចំនួន ទន្ទឹមនឹងការជួយពង្រឹងសមត្ថភាពផងដែរ ។ ទន្ទឹមនឹងនេះដែរ នៅពេលដែលសមត្ថភាពក្នុងស្រុកត្រូវបានពង្រឹង រាជរដ្ឋាភិបាលក៏ចង់អោយមានការកាត់បន្ថយដោយពិតប្រាកដ នូវការធ្វើជំនួសជាបណ្តោះអាសន្នដោយអ្នកជំនាញការបរទេសផងដែរ ។

ញ- បញ្ជាក់ពីឆន្ទៈ និងការប្តេជ្ញាចិត្ត ព្រមទាំងអនុវត្តនូវទស្សនៈនៃការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ដើម្បីឱ្យស្របតាមគោលការណ៍ដែលមានចែងក្នុងសេចក្តីប្រកាសទីក្រុងរ៉ូម និងសេចក្តីប្រកាសទីក្រុងប៉ារីស ។ ទន្ទឹមនេះ ក៏ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាអោយក្រុមការងារបច្ចេកទេសចម្រុះអាចពង្រឹងសមត្ថភាពរបស់ខ្លួន សំរាប់អនុវត្តផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ដែលបានឯកភាពរួមគ្នារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ក្នុងស្មារតីនេះ ដៃគូអភិវឌ្ឍន៍ចាំបាច់ត្រូវប្រញាប់អនុវត្តនូវសកម្មភាពដូចខាងក្រោម ÷

- ធ្វើប្រតិភូកម្មអំណាចក្នុងការអនុវត្តន៍កិច្ចសហប្រតិបត្តិការ ពីការិយាល័យកណ្តាលនៃប្រទេសផ្តល់ជំនួយ ឱ្យការិយាល័យនៃដៃគូអភិវឌ្ឍន៍នៅកម្ពុជាអោយបានច្រើន ដើម្បីអោយពួកគេអាចអនុវត្តការងារដែលពាក់ព័ន្ធនឹងសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ជាមួយនឹងដៃគូអភិវឌ្ឍន៍ដទៃទៀត និងជាមួយរាជរដ្ឋាភិបាល នៅក្នុងបរិបថនៃកម្ពុជា ។
- បង្កើនការរៀបចំកម្មវិធីរួមគ្នា តាមរយៈការធ្វើប្រតិភូកម្មក្នុងកិច្ចសហប្រតិបត្តិការ ។
- កាត់បន្ថយចំនួនបេសកកម្មទោលរបស់ដៃគូអភិវឌ្ឍន៍ និងបង្កើនចំនួនបេសកកម្មរួមគ្នា ដោយត្រូវសម្របបេសកកម្មដែលបានគ្រោង តាមរយៈយន្តការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីកាត់បន្ថយចំណាយ និងបន្ទុកលើក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល។

៣២- រាជរដ្ឋាភិបាលទទួលស្គាល់ផងដែរថា ដៃគូអភិវឌ្ឍន៍ត្រូវចំណាយផ្នែករដ្ឋបាលជាច្រើន ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍មកកម្ពុជា ហើយដែលចំណាយទាំងនេះត្រូវបានកត់ត្រា និងរាប់បញ្ចូលទៅក្នុងបរិមាណសរុបនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលបានប្រើប្រាស់នៅកម្ពុជា ។ ប៉ុន្តែ រហូតមកដល់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលមិនមានព័ត៌មានគ្រប់គ្រាន់ ស្តីពីបរិមាណជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានចំណាយផ្នែករដ្ឋបាល ទាំងក្នុង

ប្រទេស និងក្រៅប្រទេសឡើយ ហើយក៏មិនទាន់ដឹងអំពីបរិមាណជំនួយពិតប្រាកដដែលត្រូវបានប្រើប្រាស់សំរាប់ជាផលប្រយោជន៍របស់ជនក្រីក្រ និងជនងាយរងគ្រោះនៅឡើយដែរ ។

**ហិរញ្ញប្បទាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈកម្មវិធីវិនិយោគសាធារណៈ**

៣៣- ការអនុវត្តន៍យុទ្ធសាស្ត្រ និងគោលនយោបាយដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងត្រូវអនុវត្តឱ្យបានសំរេច តាមរយៈការធ្វើអាទិភាពូបនីយកម្មនៃកម្មវិធីវិនិយោគសាធារណៈ ដែលជាឧបករណ៍យ៉ាងសំខាន់ សំរាប់អនុវត្តបណ្តាយុទ្ធសាស្ត្រនិងគោលនយោបាយទាំងនេះ ។ កម្មវិធីវិនិយោគសាធារណៈនេះក៏ត្រូវបានអនុមតិពីរាជរដ្ឋាភិបាលក្នុងកិច្ចប្រជុំកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ កម្មវិធីវិនិយោគសាធារណៈនេះត្រូវបានរៀបចំក្នុងក្របខ័ណ្ឌរំកិលបីឆ្នាំ ដើម្បីឆ្លុះបញ្ចាំងអំពីតំរូវការអាទិភាព ដែលកំពុងអនុវត្ត ។ កម្មវិធី និងគំរោងដែលចែងក្នុងកម្មវិធីវិនិយោគសាធារណៈនឹងត្រូវធ្វើហិរញ្ញប្បទានដោយថវិការដ្ឋ និងពីដៃគូអភិវឌ្ឍន៍ ។ ចាប់ពីពេលនេះទៅ ថវិការដ្ឋនឹងត្រូវតម្រឹម ដើម្បីគាំទ្រដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈការធ្វើហិរញ្ញប្បទានកម្មវិធីវិនិយោគសាធារណៈ ។ កម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល រួមមានបណ្តាគំរោងអាទិភាពដែលកំពុងអនុវត្ត និងគំរោងដែលគ្រោងអនុវត្តនៅតាមវិស័យនានា ហើយក៏ជាប្រភពព័ត៌មានដ៏សំខាន់ សំរាបវិភាជន៍ថវិការដ្ឋ និងសំរាប់កៀរគរធនធានពីដៃគូអភិវឌ្ឍន៍ដែរ ។

៣៤- ផ្អែកតាមការប៉ាន់ស្មានកំណើនម៉ាក្រូសេដ្ឋកិច្ច និងតំរូវការវិនិយោគក្នុងវិស័យសាធារណៈ តំរូវការនៃវិស័យសាធារណៈសំរាប់៥ឆ្នាំ ២០០៦-២០១០ មានប្រមាណ ៣.៥០០លានដុល្លារអាមេរិក សំរាប់រយៈពេល៥ឆ្នាំ ដើម្បីសំរេចឱ្យបាន នូវបណ្តាគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ធនធានសំរាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ អាចមានប្រភពមកពី ÷ ១-អតិរេកនៃគណនីចរន្តរបស់ថវិការដ្ឋ ។ ២-ជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ជាប្រពៃណី ។ ៣-កម្ចីសម្បទាននៃស្ថាប័នហិរញ្ញវត្ថុពហុភាគី ។ ៤-ធនធានពីដៃគូអភិវឌ្ឍន៍មិនប្រពៃណី រួមទាំងធនធានមូលធនធម្មតា (Ordinary capital resources-OCR) ពីស្ថាប័នហិរញ្ញវត្ថុពហុភាគី សំរាប់អនុវត្តគំរោងនិងកម្មវិធីយុទ្ធសាស្ត្រ ដែលមានផលចំណូលខ្ពស់ ។ ៥-ធនធានដែលបានមកពីការលុបបំណុល ។ អាទិភាពរបស់រាជរដ្ឋាភិបាល គឺការផ្ទេរធនធានដែលមានសំរាប់ការវិនិយោគពិតប្រាកដ និងការកាត់បន្ថយចំណាយលើជំនួយបច្ចេកទេស ព្រមទាំងស្នើដៃគូអភិវឌ្ឍន៍តម្រឹមជំនួយរបស់ខ្លួនឱ្យស្របនឹងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងកាត់បន្ថយបន្ទុកដល់មនុស្សជំនាន់ក្រោយ រាជរដ្ឋាភិបាលសូមស្នើឱ្យដៃគូអភិវឌ្ឍន៍ ពិចារណាអំពីលទ្ធភាពផ្តល់ជំនួយឥតសំណង សំរាប់អនុវត្តបណ្តាគោលនយោបាយ និងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ រាជរដ្ឋាភិបាលនឹងដាក់កំហិត ក្នុងការប្រើប្រាស់ជំនួយជាកំចីសំរាប់តែគំរោង ឬកម្មវិធីណាដែលមិនអាចស្វែងរកហិរញ្ញប្បទានជាជំនួយឥតសំណង ហើយដែលជាគំរោង ឬកម្មវិធីផ្តល់លទ្ធផលសេដ្ឋកិច្ច

មកវិញភ្លាមៗ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងពិនិត្យដោយប្រយ័ត្នប្រយែង អំពីការជះឥទ្ធិពលនៃកម្ចីទៅលើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច មុននឹងយល់ព្រមទទួលកម្ចីទាំងនេះ ។

៣៥- សរុបតម្រូវការហិរញ្ញប្បទានសំរាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ២០០៦-២០០៨ គឺ ១.៩៧៥លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ៥៦,៥% នៃតម្រូវការហិរញ្ញប្បទានសរុបនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ ២០០៦-២០១០ ដែលមានចំនួន ៣.៥០០លានដុល្លារអាមេរិក ។ ផែនការវិភាជន៍ថវិកាសំរាប់អនុវត្តគំរោង និងកម្មវិធីនៃកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ ២០០៦-២០០៨ មានលក្ខណៈស្របជាមួយនឹងការវិភាជន៍ ធនធានតាមវិស័យអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ថវិការដ្ឋប្រមាណជាង ៨០% ត្រូវបាន វិភាជន៍សំរាបវិស័យសង្គមកិច្ច ។ ទន្ទឹមនេះ បន្ថែមលើធនធានដែលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានសន្យារួចហើយ ធនធានដែលត្រូវកៀរគរបន្ថែមទៀត សំរាប់រយៈពេល៣ឆ្នាំ ២០០៦-២០០៨ មានចំនួន ៥៦៣,៤លានដុល្លារអាមេរិក សំរាបវិស័យដូចខាងក្រោមនេះ ÷

- ចំនួន១៨៩,៨លានដុល្លារអាមេរិក ស្មើនឹង៣៣,៧% សំរាបវិស័យហេដ្ឋារចនាសម្ព័ន្ធ ។
- ចំនួន១៧១,៧លានដុល្លារអាមេរិក ស្មើនឹង៣០,៥% សំរាបវិស័យសេដ្ឋកិច្ច ។
- ចំនួន១២៩,៧លានដុល្លារអាមេរិក ស្មើនឹង២៣% សំរាប់ផ្នែកសេវា និងកម្មវិធីអន្តរវិស័យ ។
- ចំនួន៧២,២លានដុល្លារអាមេរិក ស្មើនឹង១២,៨% សំរាបវិស័យសង្គមកិច្ច ។

៣៦- នៅក្នុងកម្មវិធីវិនិយោគសាធារណៈ ធនធានប្រមាណ៨២% នឹងត្រូវប្រើប្រាស់សំរាប់អនុវត្តកម្មវិធី និងគំរោងដែលកំពុងអនុវត្ត និងដែលមានការសន្យាហិរញ្ញប្បទានរួចហើយ ។ រីឯធនធានប្រមាណ ១៨% សំរាប់គាំទ្រគំរោង និងកម្មវិធីដែលមានអាទិភាពខ្ពស់ ។ លើសពីនេះ ធនធានដែលដៃគូអភិវឌ្ឍន៍បានសន្យាសំរាប់រយៈពេល៣ឆ្នាំខាងមុខ ប្រមាណ ២៥% នឹងត្រូវប្រើប្រាស់សំរាប់ជំនួយបច្ចេកទេស ។ ដូចនេះ ធនធានដែលត្រូវកៀរគរសំរាប់រយៈពេល៣ឆ្នាំខាងមុខ នឹងត្រូវផ្តោតទៅលើការកាត់បន្ថយផ្នែកជំនួយបច្ចេកទេសឱ្យនៅក្រោម ១៥% នៃធនធានថ្មីដែលត្រូវកៀរគរ ។

៣៧- បណ្តាគំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ ត្រូវបានបែងចែកតាមវិស័យ ដូចខាងក្រោម ÷

- ក្នុងវិស័យសង្គមកិច្ច គំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ មានប្រមាណ ៩៨% នៃធនធានដែលបានវិភាជន៍សំរាបវិស័យនេះ ។
- ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ គំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ មានប្រមាណ៨១% នៃធនធានដែលបានវិភាជន៍សំរាបវិស័យនេះ ។
- ក្នុងវិស័យសេដ្ឋកិច្ច និងសេវានិងកម្មវិធីអន្តរវិស័យ គំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ មានប្រមាណជាង ២/៣ នៃធនធានដែលបានវិភាជន៍សំរាប់វិស័យទាំងនេះ ។

៣៨- តំរូវការហិរញ្ញប្បទានសរុបសំរាប់អនុវត្តកម្មវិធីកំពុងដំណើរការនិងកម្មវិធីថ្មី ក្នុងរយៈពេល៣ឆ្នាំខាងមុខ ២០០៦-២០០៨ មានប្រមាណ១.៩៧៥លានដុល្លារអាមេរិក ។ រាជរដ្ឋាភិបាលបានប្តេជ្ញាផ្តល់ធនធានផ្ទាល់ចំនួន៣៥០លានដុល្លារអាមេរិកសំរាប់កម្មវិធីអភិវឌ្ឍន៍ទាំងនេះ ។ ដូចនេះ តម្រូវការធនធានបន្ថែមសំរាប់រយៈពេល៣ឆ្នាំខាងមុខ គឺ ១.៦២៥លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ៥៤១,៧លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។ ដៃគូអភិវឌ្ឍន៍ដៃគូសហប្រតិបត្តិការទ្វេ-ពហុភាគី និងអន្តរជាតិមួយចំនួនបានសន្យាផ្តល់ហិរញ្ញប្បទាន ចំនួន ១.១១៧,៣លាន ដុល្លារអាមេរិករួចហើយ ។ ដូចនេះ រាជរដ្ឋាភិបាលត្រូវស្វះស្វែងរកការគាំទ្របន្ថែមទៀតចំនួន ៥៦៣,៤លានដុល្លារអាមេរិក ពីដៃគូអភិវឌ្ឍន៍ជាប្រពៃណីនិងមិនជាប្រពៃណីរបស់ខ្លួន ។

# មាតិការឿង


| | ទំព័រ |
|---|---|
| អារម្ភកថា | |
| ខ្លឹមសារសង្ខេបប្រតិបត្តិ | I-XVI |
| ជំពូកទី១ : សេចក្តីផ្តើម | ១ |
| ជំពូកទី២ : សមិទ្ធិផលសំខាន់ៗរបស់រាជរដ្ឋាភិបាលបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ លើកទី៧ ខែធ្នូ ឆ្នាំ២០០៤ | ៤ |
| ១- ស្ថានភាពទូទៅ | ៤ |
| ២- សមិទ្ធិផលម៉ាក្រូសេដ្ឋកិច្ច | ៧ |
| ៣- សមិទ្ធិផលរូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈ | ១១ |
| ៣.១- គោលនយោបាយរូបិយវត្ថុ និងសមិទ្ធិផល | ១១ |
| ៣.២- គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងសមិទ្ធិផល | ១២ |
| ៣.៣- ចំណូលក្នុងស្រុក | ១៣ |
| ៣.៤- ចំណាយសាធារណៈ | ១៣ |
| ៤- សមិទ្ធិផលនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល | ១៦ |
| ៤.១- ការប្រឆាំងអំពើពុករលួយ និងការបង្កើនគណនេយ្យភាព | ១៧ |
| ៤.២- កំណែទំរង់ប្រព័ន្ធតុលាការ និងយុត្តិធម៌ និងការពារសិទ្ធមនុស្ស | ១៩ |
| ៤.៣- កំណែទំរង់រដ្ឋបាលសាធារណៈ | ២០ |
| ៤.៤-វិមជ្ឈការ និងសហវិមជ្ឈការ | ២២ |
| ៤.៥- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ២៣ |
| ៤.៦- អន្តរវិស័យសំរាប់កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ | ២៤ |
| ៤.៧- ការអភិវឌ្ឍន៍វិស័យឯកជន | ២៧ |
| ៤.៨- យេនឌ័រ ភាពក្រីក្រ និងការប្រយុទ្ធប្រឆាំងជំងឺអេដស៍ | ៣០ |
| ៤.៩- សុខាភិបាល និងអប់រំ | ៣១ |
| ៤.១០- សុខដុមនីយកម្ម | ៣២ |
| ជំពូកទី៣ : ការអនុវត្តន៍បណ្តាអាទិភាពនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ | ៣៣ |
| ជំពូកទី៤ : ការកសាងភាពជាដៃគូ សំរាប់បង្កើនប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ | ៤២ |
| ១- សមិទ្ធិផលសំរេចបានបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ចុងក្រោយ | ៤២ |
| ១.១- យន្តការថ្មីសំរាប់សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ | ៤៣ |

១.២- ការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល
ស្តីពីសុខដុមនីយកម្ម និងការតម្រឹម ៤៦
១.៣- ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី
ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ៤៩
១.៤- ការរៀបចំគោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់ជំនួយឥតសំណង
និងនិតិវិធីបទដ្ឋានសហប្រតិបត្តិការសំរាប់ជំនួយជាកម្ចី ៥១
១.៥- ការគាំទ្រមន្ត្រីនៃក្រសួងនិងស្ថាប័ននានា ក្នុងការធ្វើជាម្ចាស់ពិតប្រាកដ
លើសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ ៥១
១.៦- ការរៀបចំ និងអនុវត្តន៍ការប្រមូលព័ត៌មានអំពីការប្រើប្រាស់ជំនួយ ៥២
អភិវឌ្ឍន៍ផ្លូវការ តាមគេហទំព័ររបស់ ក.អ.ក/ គ.ជ.នា
១.៧- ភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជន ៥២
១.៨- ភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ៥៣
២- បញ្ហាប្រឈម និងទិសដៅអនាគត ៥៤

<u>ជំពូកទី៥</u> : ហិរញ្ញប្បទាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈកម្មវិធី
វិនិយោគសាធារណៈ ៥៩

<u>ជំពូកទី៦</u> : សេចក្តីសន្និដ្ឋាន ៦៦

## តារាង

<u>តារាងទី១</u> : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ៩
<u>តារាងទី២</u> : ផ.ផ.ស តាមវិស័យសេដ្ឋកិច្ចសំខាន់ៗ ១០
<u>តារាងទី៣</u> : សូចនាករនៃថវិការដ្ឋ ១៥
<u>តារាងទី៤</u> : គោលដៅជាតិ និងសូចនាករសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៣៨
<u>តារាងទី៥</u>: កម្មវិធីនិងគម្រោងអភិវឌ្ឍន៍តាមវិស័យនៃកម្មវិធីវិនិយោគសាធារណៈ ៦៤
<u>តារាងទី៦</u>: កម្មវិធីនិងគម្រោងអភិវឌ្ឍន៍តាមប្រភេទនៃកម្មវិធីវិនិយោគសាធារណៈ ៦៤
<u>តារាងទី៧</u>: កម្មវិធី និងគម្រោងអភិវឌ្ឍន៍កំពុងដំណើរការ និងមានការសន្យាផ្តល់ជំនួយ
ព្រមទាំងអាទិភាពខ្ពស់តាមវិស័យនៃកម្មវិធីវិនិយោគសាធារណៈ ៦៥

<u>ឧបសម្ព័ន្ធទី១</u> : ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល

# ជំពូកទី១
# សេចក្តីផ្តើម

១- ដំណាក់កាលពីឆ្នាំ១៩៩៩មក គឺជាលើកទីមួយនៃប្រវត្តិសាស្ត្រដែលកម្ពុជាសំរេចបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធមនុស្ស និងស្ថិរភាពសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តកម្មវិធីកំណែទំរង់លើគ្រប់វិស័យ ទោះបីប្រឈមនឹងការលំបាកជាច្រើនយ៉ាងណាក៏ដោយ ។ កម្ពុជាបានសំរេចវឌ្ឍនភាពជាច្រើន និងជាបន្តបន្ទាប់ ក្នុងការឆ្លងកាត់អន្តរកាលពីសេដ្ឋកិច្ចមានផែនការ ដែលបានចាប់ផ្តើមពីពាក់កណ្តាលទសវត្សរ៍ឆ្នាំទី៨០ មកសេដ្ឋកិច្ចទីផ្សារ ។ សមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោកចាប់តាំងពីខែតុលា ឆ្នាំ២០០៤ ជាសក្ខីភាពមិនអាចប្រកែកបាននូវវឌ្ឍនភាពទាំងនេះ ។ កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ បានជំរុញឱ្យកម្ពុជាស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវមួយ ឈានទៅសំរេចគោលដៅនៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

២- ជោគជ័យនៃការអនុវត្តន៍ «**យុទ្ធសាស្ត្រត្រីកោណ**» បានធ្វើឱ្យប្រទេសកម្ពុជាឆ្លងកាត់ដំណាក់កាលប្រែប្រួលយ៉ាងធំធេង ពីប្រទេសមួយដែលគ្មានស្ថានភាពច្បាស់លាស់ មានកលយុគ សង្គ្រាម ជម្លោះផ្ទៃក្នុង អស្ថិរភាព និងភាពអន់ថយទៅជាប្រទេសមួយដែលមានសុខ សន្តិភាពពេញលេញ មានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម មានការគោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍន៍ ។ «**យុទ្ធសាស្ត្រចតុកោណ**» គឺជារបៀបវារៈសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ដែលបន្តសកម្មភាពនិងពង្រឹងសមិទ្ធផលនានា ដែលសំរេចបានពីការអនុវត្តន៍ «**យុទ្ធសាស្ត្រត្រីកោណ**» ។ ឆ្លងកាត់រយៈពេលដ៏ខ្លីបំផុត ប្រសិនបើប្រៀបធៀបនឹងប្រវត្តិសាស្ត្រនៃប្រទេសជឿនលឿន រាជរដ្ឋាភិបាល កម្ពុជាបានបង្ហាញដោយគ្មានការសង្ស័យថា កម្ពុជាពិតជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលប្រឡូក ដោយស្មើភាពនិងស្មើសិទ្ធិក្នុងកិច្ចការតំបន់និងពិភពលោក ។

៣- ទោះបីមានការខិតខំប្រឹងប្រែង ហើយទទួលបានជោគជ័យយ៉ាងណាក្តី រាជរដ្ឋាភិបាលមិនអាចជៀសផុតពីការខ្វះខាតបានឡើយ ។ ជាក់ស្តែង រចនាសម្ព័ន្ធផលិតកម្មជាតិនៅមានទំហំតូច និងមានលក្ខណៈប្រមូលផ្តុំនៅតាមតំបន់មួយចំនួនតូច ដែលទាមទារឱ្យពង្រីកនិងធ្វើពិពិធកម្មផលិតកម្ម ដើម្បីធានាឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ម៉្យាងវិញទៀត ទោះបីជាបានអនុវត្តយន្តការនិងនីតិវិធីមួយចំនួនសំរាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីបង្កើនចំណូលរដ្ឋក៏ដោយ ក៏យន្តការនិងនីតិវិធីទាំងនេះនៅពុំទាន់បានដំណើរការប្រកបដោយភាពឥតខ្ចោះ និងរលូននៅឡើយ ដោយសារមានឥទ្ធិពលជាអន្តរវិស័យ និងការលំបាកមួយចំនួន ដែលបានប៉ះពាល់យ៉ាងខ្លាំងដល់ទិសដៅនៃការបង្កើនចំណូល និងការវិភាជន៍ចំណាយ ។ លើសពីនេះ ក៏កត់សំគាល់អំពីកង្វះខាតនិងភាពទន់ខ្សោយ ក្នុងការសំរបសំរួលរវាងក្រសួងនិងស្ថាប័នជំនាញមួយចំនួនផងដែរ ។

៤- ដើម្បីពង្រឹងនីតិរដ្ឋ ច្បាប់និងបទបញ្ញត្តិជាច្រើនត្រូវបានរៀបចំ និងអនុម័ត ។ រាជរដ្ឋាភិបាលជឿជាក់ថា ការកសាងច្បាប់និងបទបញ្ញត្តិជាជំហានសំខាន់បំផុតក្នុងការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។ ប៉ុន្តែ ក៏នៅមិនទាន់គ្រប់គ្រាន់ឡើយ ព្រោះថា ការពង្រឹងសមត្ថភាពក្រសួងនិងស្ថាប័នជំនាញសំរាប់អនុវត្តច្បាប់និងបទបញ្ញត្តិទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាពនិងគណនេយ្យភាព គឺជាការចាំបាច់ក្នុងការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។ ការរៀបចំ និងការកែទំរង់ឡើងវិញ នូវបរិធានតុលាការនៅតែជាបញ្ហាប្រឈមសំរាប់រាជរដ្ឋាភិបាល ដោយសារកង្វះខាតនូវធនធានមនុស្សនិងបច្ចេកទេស ។ កង្វះខាតអ្នកឯកទេសកម្ពុជាខាងផ្នែកច្បាប់ បាននាំឱ្យកម្ពុជាជួបនឹងស្ថានភាព ដែលការរៀបចំសេចក្តីព្រាងច្បាប់ត្រូវទទួលរងឥទ្ធិពលពីអ្នកជំនាញការបរទេស ។ ប្រការនេះបានបង្កើតភាពមិនស៊ីសង្វាក់គ្នាមួយចំនួន ក្នុងការតាក់តែងច្បាប់កន្លងមក ដែលអាចនាំឱ្យមានការលំបាកក្នុងពេលអនុវត្តន៍ច្បាប់ ។ ភាពទន់ខ្សោយក្នុងការអនុវត្តន៍ច្បាប់ក៏បណ្តាលមកពីមូលហេតុផ្សេងៗជាច្រើន ក្នុងនោះ ក៏មានកត្តាប្រាក់បៀវត្សរ៍ទាបផងដែរ ។ យើងមានការលំបាកក្នុងការអនុវត្តន៍ច្បាប់ប្រកបដោយតម្លាភាព និងដោយគ្មានការភ័យខ្លាច ប្រសិនបើបៀវត្សរបស់មន្ត្រីអនុវត្តច្បាប់មានកំរិតទាប ក្រោមតំរូវការអប្បរមា ។

៥- ក្នុងរយៈកាល៥ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលសំរេចបានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ក្នុងការអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចដោយផ្តោតទៅលើអ្នកក្រីក្រ ការសំរេចបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ការបន្តអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ការពង្រឹងនីតិរដ្ឋនិងអភិបាលកិច្ចល្អ និងការកៀរគរធនធានសំរាប់កិច្ចអភិវឌ្ឍន៍ ព្រមទាំងការកែលំអការផ្តល់សេវា សាធារណៈដើម្បីឆ្លើយតបនឹងតំរូវការ និងសំណូមពររបស់ប្រជាជន ។ កិច្ចប្រឹងប្រែងទាំងអស់នេះត្រូវ បានអនុវត្តក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍ កម្ពុជា ។ ទន្ទឹមនេះរាជរដ្ឋាភិបាលក៏បានទទួលស្គាល់ផងដែរថា កម្ពុជាត្រូវធ្វើដំណើរលើផ្លូវដ៏វែងអន្លាយ ទៅមុខទៀតដោយត្រូវពុះពារឆ្លងកាត់ឧបសគ្គច្រើនរាប់មិនអស់ថែមទៀត ដើម្បីសំរេចបាននូវវឌ្ឍនភាពប្រកបដោយចីរភាព និងវិបុលភាពដ៏រុងរឿងថ្កើងថ្កានជូនប្រទេសជាតិនិងប្រជាជន ។ ការជំរុញអោយមានការចូលរួមទូលំទូលាយពីប្រជាជនក្នុងការកាត់បន្ថយភាពក្រីក្រ នៅតែជាគោលដៅចំបងរបស់រាជរដ្ឋាភិបាល ។

៦- ឯកសារនេះនឹងបង្ហាញពីសមិទ្ធផលដែលរាជរដ្ឋាភិបាលសំរេចបានបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ នាខែ ធ្នូ ឆ្នាំ២០០៤ នៅរាជធានីភ្នំពេញកន្លងមក ។ ឯកសារនេះបានធ្វើបច្ចុប្បន្នភាពអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ការអនុវត្តន៍គោលនយោបាយរូបិយវត្ថុនិងសារពើពន្ធ ព្រមទាំងបានបូកសរុបអំពីលទ្ធផលនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ជំពូកបន្ទាប់បានសង្ខេបអំពីអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ ។ ជំពូក៤ នឹងធ្វើបច្ចុប្បន្នភាពអំពីការកសាងភាពជាដៃគូ សំដៅលើកកំពស់ប្រសិទ្ធភាពជំនួយ ព្រមទាំងបញ្ហាប្រឈម និងវិធានការសំរាប់ពេលអនាគតផងដែរ ។ ជំពូក៥ នឹងបញ្ជាក់អំពីតំរូវការហិរញ្ញប្បទាន សំរាប់អនុវត្តអាទិភាពអភិវឌ្ឍន៍ដែលមាន

ចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈកម្មវិធីវិនិយោគសាធារណៈឆ្នាំ២០០៦-២០០៨ ។ រីឯជំពូកចុងក្រោយ គឺសេចក្តីសន្និដ្ឋាន ។

## ជំពូកទី២

## សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ខែធ្នូ ឆ្នាំ២០០៤

### ១- ស្ថានភាពទូទៅ

| សមិទ្ធផលសំខាន់ៗ |
|---|
| ១- ស្ថានភាពទូទៅ |
| ២- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច |
| ៣- ស្ថានភាពរូបិយវត្ថុនិងសារពើពន្ធ |
| ៤- ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល |

៧- ចាប់តាំងពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ដែលបានប្រារព្ធនៅរាជធានីភ្នំពេញ នាថ្ងៃទី៦-៧ខែធ្នូឆ្នាំ២០០៤កន្លងមក រាជរដ្ឋាភិបាលក្នុងអាណត្តិបច្ចុប្បន្នរបស់ខ្លួន បានខិតខំប្រឹងប្រែងយ៉ាងច្រើន ក្នុងការអនុវត្តន៍ «យុទ្ធសាស្រ្តចតុកោណ» សំដៅកាត់បន្ថយភាព ក្រីក្រ និងសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ រាជរដ្ឋាភិបាលបានប្តេជ្ញាយកអស់កំលាំងកាយចិត្ត អនុវត្តតាមបណ្តាអនុសាសន៍ដ៏មានសារៈប្រយោជន៍ ដែលបានលើកឡើងក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិសំរាប់ឆ្នាំ ២០០៦-២០១០បានត្រូវរៀបចំ ដោយបានពិភាក្សាយ៉ាងទូលំទូលាយជាមួយដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីអនុវត្តគោលនយោបាយដែលមានចែងក្នុង «យុទ្ធសាស្រ្តចតុកោណ» ។ កម្មវិធីវិនិយោគសាធារណៈឆ្នាំ២០០៦-២០០៨ ក៏ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិនេះ ។ ឯកសារទាំង២នេះត្រូវបានអនុមតិក្នុងអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ រាជរដ្ឋាភិបាលសូមស្នើឱ្យដៃគូអភិវឌ្ឍន៍ទ្វេ-ពហុភាគី តម្រឹមយុទ្ធសាស្រ្តផ្តល់ជំនួយរបស់ខ្លួន ឱ្យស្របនឹងបណ្តាអាទិភាពនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងសូមផ្តល់គំរោងនិងកម្មវិធីអភិវឌ្ឍន៍ សំរាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ ។

៨- ចាប់ពីឆ្នាំ១៩៩៣មក សភាពការណ៍សេដ្ឋកិច្ចទូទៅមានដំណើរការល្អគួរឱ្យកត់សំគាល់ ។ នៅចន្លោះឆ្នាំ ១៩៩៣-២០០៤ ផ.ស.ស (គិតតាមតំលៃឆ្នាំ២000) បានកើនឡើងជាមធ្យមចំនួន៧,១% ហើយតាមការប៉ាន់ស្មានបឋម ផ.ស.ស ក្នុងឆ្នាំ២០០៥ អាចកើនឡើងរហូតដល់៧,០% ។ ទន្ទឹមនឹងនេះ កំរិតនៃភាពក្រីក្រក៏បានថយចុះគួរឱ្យកត់សំគាល់ផងដែរ ។ ផ្អែកតាមលទ្ធផលនៃការធ្វើអង្កេតសេដ្ឋកិច្ច និងសង្គម កិច្ចឆ្នាំ២០០៤ បានបង្ហាញថា ក្នុង៥៦%នៃភូមិនៅជនបទ ដែលតំណាងឱ្យ៦៥%នៃប្រជាជនជនបទ និងទីក្រុងហើយដែលបានធ្វើអង្កេតក្នុងឆ្នាំ១៩៩៣ និង២០០៤ ចំនួនប្រជាជនកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្របានថយចុះពី ៣៩%មក ២៨% ឬថយចុះច្រើនជាង២៨% ។ អង្កេតក្នុងឆ្នាំ១៩៩៣ ពុំបានគ្របដណ្តប់តំបន់មួយចំនួន ដែលមិនទាន់មានសុវត្ថិភាពពេញលេញឡើយ ។

៩- កន្លងមកថ្មីៗនេះ ធនាគារពិភពលោកបានធ្វើការសិក្សាមួយស្តីពី «ការវាយតំលៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២០០៥» ដើម្បីប៉ាន់ស្មានកំរិតនៃភាពក្រីក្រនៅឆ្នាំ១៩៩៣សំរាប់ទូទាំងប្រទេសឡើងវិញ ។ ការសិក្សានេះបានធ្វើការប៉ាន់ស្មានឡើងវិញ ដោយផ្អែកលើទិន្នន័យឆ្នាំ១៩៩៣ និងអង្កេតបន្តបន្ទាប់មកទៀត ។ ផ្អែកតាមការគណនាឡើងវិញនេះ ការសិក្សាបានប៉ាន់ស្មានឃើញថា សមាមាត្រនៃប្រជាជនរស់នៅក្រោមបន្ទាត់

ភាពក្រីក្រ នាឆ្នាំ១៩៩៣ មាន៤៧% ។ ផ្អែកតាមការប៉ាន់ស្មានកំរិតនៃភាពក្រីក្រក្នុងឆ្នាំ១៩៩៣នេះ ការសិក្សាបានសន្និដ្ឋានថា ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ បានថយចុះពី ៤៧%នៅឆ្នាំ ១៩៩៣ មកត្រឹមតែ ៣៥% នៅឆ្នាំ២០០៤ ។ ការសិក្សាបានរកឃើញទៀតថា «តំរូវការប្រើប្រាស់ក្នុងគ្រួសារជា មធ្យម» មានការកើនឡើង ហើយបច្ចុប្បន្ន ប្រជាជនមានទ្រព្យផលិតកម្ម សំភារៈប្រើប្រាស់យូរអង្វែងកាន់តែប្រសើរជាងមុន រីឯស្ថានភាពរស់នៅក៏បានល្អប្រសើរជាងមុនផងដែរ ។ កំរិតជីវភាពរស់នៅរបស់ប្រជាជន ក៏បានកែលំអឱ្យប្រសើរឡើង ចំពោះក្រុមប្រជាជនក្រីក្របំផុត ដែលមានប្រមាណ២០% នៃប្រជាជន ក៏ដូចជាក្រុមប្រជាជនមានបំផុត ២០% ផងដែរ ទោះបីជានៅមានគម្លាតខុសពីគ្នារវាងក្រុម ទាំង ២ នេះក៏ដោយ ។ ដូចគ្នានេះដែរ ភាពក្រីក្របានថយចុះទាំងនៅតំបន់ជនបទ ក៏ដូចជានៅតំបន់ ទីក្រុង ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ភាពក្រីក្រនៅតំបន់ទីក្រុង បានថយចុះច្រើនជាង ធៀបនឹងនៅ តំបន់ជនបទ ។

១០- ការពង្រឹងបន្ថែមទៀតនូវស្ថិរភាពនយោបាយនិងសន្តិសុខ សុទ្ធតែជាប្រការគន្លឹះបំផុត សម្រាប់កម្ពុជាបោះជំហានឆ្ពោះទៅមុខ ដើម្បីលើកកំពស់កំរិតជីវភាព ការគោរពសិទ្ធិមនុស្សរបស់ប្រជាជន និងការសំរេចឱ្យបាននូវកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ សម្រាប់រាជរដ្ឋាភិបាល បញ្ហាប្រឈមដែលត្រូវជំនះ ដោះស្រាយក្នុងកិច្ចអភិវឌ្ឍន៍ គឺការកាត់បន្ថយភាពក្រីក្រ និងការលើកកំពស់ជីវភាពរស់នៅរបស់ ប្រជាជន និងជីវិតរស់នៅកាន់តែល្អប្រសើររបស់ប្រជាជនដែលកំពុងតែកើនឡើង ។ រាជរដ្ឋាភិបាលបានសម្រេចនូវវឌ្ឍនភាពជាដុំកំភួននាទស្សវត្សរ៍ចុងក្រោយនេះ ។ ការបន្តកាត់បន្ថយកំរិតក្រីក្រ ពិសេស នៅតំបន់ជនបទនិងការលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជនអោយបានល្អប្រសើរ នៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ ការពន្លឿនកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម ដែលកំលាំងពលកម្មប្រមាណ៧៥% កំពុងពឹងផ្អែកលើវិស័យនេះ ជាអាទិភាពសខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។ កំណើនសេដ្ឋកិច្ចប្រកបដោយ ចីរភាព ការកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា មិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការកែលំអជាដុំកំភួនខាងផ្នែកផលិតភាព និងការបង្វែរពីផលិតផលស្រូវ ទៅជាដំណាំផ្សេងៗទៀតក្នុងវិស័យកម្ម ។ ការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម និងទឹកឱ្យបានឆាប់ គឺជាអាទិភាពខ្ពស់មួយទៀតរបស់រាជរដ្ឋាភិបាល ។ ក្រសួងពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ ចាំបាច់ត្រូវផ្តល់អាទិភាពខ្ពស់ដើម្បីធ្វើកិច្ចការនេះ ។ រាជរដ្ឋាភិបាលយល់ថាភាពក្រីក្រ គឺជាការខ្ជះខ្ជាយធនធានសេដ្ឋកិច្ចដ៏មានតម្លៃ ដែលមិនត្រឹមតែមិនអាចទទួលយកបានប៉ុណ្ណោះទេ ប៉ុន្តែ អាចធ្វើឱ្យមានការបែកខ្ញែក ប្រេះឆា និងអស្ថិរភាពសង្គមទៀតផង ។

១១- ចក្ខុវិស័យអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល គឺការកសាងសង្គមមួយដែលមានសាមគ្គីភាពរឹងមាំ មានប្រព័ន្ធ អប់រំ និងវប្បធម៌ជឿនលឿន ដើម្បីរំដោះប្រជាជនឱ្យរួចផុតពីច្រវាក់ខ្នោះឃ្នាងនៃភាពក្រីក្រ គ្មាន អនក្ខរភាព និងជម្ងឺដម្កាត់ផ្សេងៗ ។ ការអនុវត្តន៍ឱ្យបានសម្រេចចក្ខុវិស័យនេះ ទាមទារឱ្យប្រកាន់ខ្ជាប់នូវតម្លៃយុត្តិធម៌ក្នុងសង្គម សុខុមាលភាព ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ និងការរៀបចំនិងការ

អនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការពង្រឹងអភិបាលកិច្ចល្អ ។

១២- កត្តាអំណោយផលចំបងក្នុងឆ្នាំ២០០៥ ដែលអាចផ្តល់ការគាំទ្របន្ថែមទៀតសំរាប់រក្សាឱ្យបាននូវចលនាការនៃកំណើនសេដ្ឋកិច្ចដែលសម្រេចបានកន្លងមក គឺការរកឃើញអណ្តូងប្រេងនៅក្នុងដែនសមុទ្រកម្ពុជា នៃឈូងសមុទ្រថៃឡង់ត៍ នាខែមករា ឆ្នាំ២០០៥ ។ រាជរដ្ឋាភិបាលបានធ្វើកិច្ចសន្យាគ្របដណ្តប់ផ្ទៃទឹកប្រមាណ ៦.២៧៨ម២(ក្នុងប្លុក A) ជាមួយក្រុមហ៊ុនប្រេងឥន្ធនៈ Chevron Oversea Petroleum ដែលកាន់កាប់ភាគហ៊ុន៥៥៥ ដោយធ្វើប្រតិបត្តិការជាមួយក្រុមហ៊ុន Moeco Cambodia Co. Limited ដែលគ្រប់គ្រងដោយក្រុមហ៊ុនរុករក ប្រេង Mitsui Oil Exploration Co.Limited កាន់កាប់ភាគហ៊ុនចំនួន ៣០៥ និងក្រុមហ៊ុន LG Caltex មានភាគហ៊ុន ១៥៥ ។ ក្នុងខែមករា ឆ្នាំ២០០៥ ក្រុមហ៊ុនប្រេងឥន្ធនៈ Chevron បានប្រកាសថា ក្រុមការងាររបស់ខ្លួនបានរុករកឃើញអណ្តូងប្រេងចំនួន៤កន្លែង ។ ការរុករកអណ្តូងប្រេងបានបង្ហាញនូវលទ្ធផលបឋមជាវិជ្ជមាន ។ ក្រុមហ៊ុនប្រេងឥន្ធនៈ Chevron គ្រោងខួងអណ្តូងប្រេងចំនួន១០បន្ថែមទៀត ក្នុងឆ្នាំ២០០៦ ។ ការបូមប្រេងពីអណ្តូងប្រេងទាំងអស់ អាចចាប់ផ្តើមនាចុងទសវត្សរ៍នេះ ។

១៣- រាជរដ្ឋាភិបាលក៏មានសេចក្តីសោមនស្សផងដែរ ចំពោះគំនិតផ្តួចផ្តើមស្តីពីការលុបចោលបំណុលរបស់ដៃគូអភិវឌ្ឍន៍ពហុភាគី ។ គណៈកម្មាធិការប្រតិបត្តិនៃអង្គការរូបិយវត្ថុអន្តរជាតិ បានសម្រេចលុបចោលបំណុលរបស់កម្ពុជា កាលពីកិច្ចប្រជុំរបស់ខ្លួននាខែធ្នូ ឆ្នាំ២០០៥ ។ ផ្អែកតាមគំនិតផ្តួចផ្តើមនេះ អង្គការរូបិយវត្ថុអន្តរជាតិនឹងលុបចោលបំណុល១០០% ដែលកម្ពុជាបានខ្ចីរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ពីអង្គការនេះ ចំនួន ៨២លានដុល្លាអាមេរិក ។ ការគ្រប់គ្រងសេដ្ឋកិច្ចយ៉ាងប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាល គឺជាកត្តាសំខាន់នៃកិច្ចដំណោះស្រាយរបស់អង្គការរូបិយវត្ថុអន្តរជាតិ ។

១៤- រាជរដ្ឋាភិបាលក៏សូមរីករាយជំរាបដែរថា ក្នុងការបន្តពង្រឹងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម នៅកម្ពុជា ដំណើរការនៃការបោះឆ្នោតព្រឹទ្ធសភាដោយសេរី និងយុត្តិធម៌បានប្រព្រឹត្តទៅ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០០៥ ។ ដំណើរការនៃការបោះឆ្នោតនេះត្រូវប្រើប្រាស់ថវិការដ្ឋ និងមន្ត្រីកម្ពុជា ហើយក៏គ្មានការពិភាក្សាណាមួយអំពីការរៀបចំថវិកាបរទេស ឬការប្រើប្រាស់អ្នកជំនាញបរទេសសំរាប់ដំណើរការបោះឆ្នោតនេះដែរ ។

១៥- ទោះបីជាសមត្ថភាពរបស់ប្រព័ន្ធច្បាប់និងតុលាការនៅកម្ពុជានៅមានកំរិតយ៉ាងណាក៏ដោយ ក៏នៅក្នុងឆ្នាំ ២០០៥ យើងមានវឌ្ឍនភាពជាច្រើនក្នុងការរៀបចំសេចក្តីព្រាងច្បាប់ ។ ក្នុងឆ្នាំ២០០៥ ច្បាប់ចំនួន ៤៥ បានអនុម័តដោយរដ្ឋសភារួចហើយ ធៀបនឹងច្បាប់ចំនួន ៩០ ប៉ុណ្ណោះ ដែលបានអនុម័តក្នុងរយៈពេល៥ឆ្នាំ ១៩៩៣-១៩៩៨កន្លងមក ។ បន្ថែមលើនេះ ក៏មានច្បាប់មួយចំនួនទៀតដែរ ដែលត្រូវបានស្នើជូនសភាក្នុងអំឡុងឆ្នាំ២០០៥ ដែលកំពុងរង់ចាំការអនុម័តពីស្ថាប័ននេះ ។ ទន្ទឹមនេះ ការចូលជាសមាជិករបស់

កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក នាខែតុលា ឆ្នាំ២០០៤ ក៏តម្រូវឱ្យកម្ពុជាខិតខំបន្ថែមទៀត ក្នុងការធ្វើវិសោធនកម្មច្បាប់បច្ចុប្បន្ន ឬរៀបចំច្បាប់បន្ថែមទៀតប្រមាណជាង៤០ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលស្នើដល់ភាគីពាក់ព័ន្ធទាំងអស់ សូមយកចិត្តទុកដាក់អំពីភាពជាក់ស្តែងក្នុងការកំណត់ កាលបរិច្ឆេទនៃការរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់នានា ដោយត្រូវយកចិត្តទុកដាក់អំពីសមត្ថភាពរបស់ ក្រសួងពាក់ព័ន្ធ និងធនធានដែលមាន ក៏ដូចជាភាពស្មុគស្មាញនៃកិច្ចដំណើរការពិនិត្យ និងអនុមត័ សេចក្តីព្រាងច្បាប់ពីស្ថាប័នប្រតិបត្តិ និងនីតិបញ្ញត្តិផងដែរ ។

១៦- ក្រោយការពិគ្រោះយោបល់ជាច្រើនជាមួយដៃគូអភិវឌ្ឍន៍ នាចុងឆ្នាំ២០០៣ និងឆ្នាំ២០០៤មក យើងបានដាក់ឱ្យដំណើរការ នូវយន្តការថ្មីសម្រាប់សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ក្នុងឆ្នាំ ២០០៥ ។ យន្តការនេះរួមមាន ÷ ១) ក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យចំនួន១៨ និង២) គណៈ-កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ សំរាប់សម្របសម្រួលកិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះទាំង១៨ និងផ្តល់ការណែនាំក៏រិតគោលនយោបាយ កំណត់អាទិភាពនានា និងស្នើឡើងនូវវិធានការ ដើម្បីដោះស្រាយបញ្ហានានា ដែលលើកឡើងដោយក្រុមការងារបច្ចេកទេសចម្រុះ ។ នៅក្នុងកិច្ចប្រជុំត្រៀមពិគ្រោះយោបល់នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានចាត់តាំងឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យធ្វើជាប្រធាននៃគណៈកម្មាធិការនេះ ។ ការប្រជុំប្រចាំត្រីមាសនៃគណៈកម្មាធិការសម្របសម្រួលនេះ បានផ្តល់កាលានុវត្តភាពឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រួតពិនិត្យវឌ្ឍនភាព រួមគ្នាការប្រឈម និងចំណាត់ការនានាសំរាប់ដោះស្រាយបញ្ហាប្រឈមទាំងនេះ ។ ព័ត៌មានលំអិតស្តីពីយន្តការនឹងបកស្រាយលំអិតក្នុងជំពូក ៤ នៃឯកសារនេះ ។ ការបង្កើតយន្តការនៃក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺជាការផ្លាស់ប្តូរជា សារវ័ន្តខាងផ្នែកស្ថាប័ន ខាងការរៀបចំផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យវឌ្ឍនភាព ស្តីពីការអនុវត្តន៍ជំនួយអភិវឌ្ឍន៍ ដើម្បីពង្រឹងប្រសិទ្ធភាពជំនួយ ។ ការពង្រឹងយន្តការនេះសំរាប់កែលំអកិច្ចដំណើរការកៀរគរ ការបែងចែក និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ សំរាប់បង្កើនប្រសិទ្ធភាពជំនួយ នៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។

## ២- សមិទ្ធិផលម៉ាក្រូសេដ្ឋកិច្ច

១៧- រាជរដ្ឋាភិបាលកម្ពុជាបានបន្តអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ហើយទទួលបានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ក្នុងការសំរេចឱ្យបាន នូវកំណើនសេដ្ឋកិច្ចរយៈពេលយូរអង្វែងប្រកបដោយសមធម៌ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះបានផ្តោតការយកចិត្តទុកដាក់លើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងស្ថាប័នហិរញ្ញវត្ថុនិងធនាគារ ការអនុវត្តន៍វិធានការកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិសាធារណៈ និងការបង្កើនវិនិយោគសាធារណៈសំរាប់ស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គមកិច្ច និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ចំពោះរាជ

រដ្ឋាភិបាល កំណើនសេដ្ឋកិច្ចគឺជាអាវុធដ៏ខ្លាំងក្លាសំរាប់ប្រឆាំងនឹងភាពក្រីក្រ ហើយរាជរដ្ឋាភិបាលនៅតែបន្តអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្វែរប្រភពធនធានទៅក្នុងវិស័យណាដែលមានប្រសិទ្ធិភាពជាង និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក ។ ការរក្សាស្ថិរភាពនយោបាយ សន្តិភាព និងសន្តិសុខក្នុងប្រទេស បានជួយរាជរដ្ឋាភិបាលក្នុងការពង្រឹងដំណើរការកែទំរង់ឱ្យកាន់តែទូលំទូលាយនិងស៊ីជំរៅថែមទៀត ព្រមទាំងរក្សាបាននូវចលនាការសំរាប់អភិវឌ្ឍ សេដ្ឋកិច្ចនិងសង្គមកិច្ចប្រកបដោយចីរភាព ។

១៨- ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តន៍កំណែទំរង់សារពើពន្ធបានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ច ឆ្នាំ២០០៤-២០០៥ មានភាពរឹងមាំ ទោះបីជាមានកត្តាអវិជ្ជមានក្រៅប្រទេសខ្លះក៏ដោយ (ដូចជា ការកើនឡើងនៃតំលៃប្រេង ជំងឺសារស៍ ការរាតត្បាតនៃជំងឺគ្រុនផ្តាសាយបក្សី និងលក្ខខ័ណ្ឌអាកាសធាតុមិនអនុគ្រោះនៅក្នុងឆ្នាំ២០០៤) ។ នៅក្នុងឆ្នាំ២០០៤ កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស) គិតតាមតំលៃស្ថេរ បានកើនដល់ ៧,៧% ធៀបនឹងកំណើន ផ.ស.ស ៧,០% ក្នុងឆ្នាំ២០០៣ និង ៥,២%ក្នុងឆ្នាំ២០០២ ។ តាមការប៉ាន់ស្មានបឋម សេដ្ឋកិច្ចក្នុងឆ្នាំ ២០០៥ បានកើន ៧% ដោយសារកំណើនយ៉ាងខ្លាំងក្លានៅក្នុងវិស័យកសិកម្ម ការបន្តពង្រីកសកម្មភាព នាំចេញ ទេសចរណ៍ និងសំណង់ ។ ផ.ស.ស សរុបក្នុងឆ្នាំ២០០៤ មាន ១៩.៦៣០ពាន់លានរៀល (ប្រហាក់ប្រហែលនឹង ៤,៩ពាន់លានដុល្លារអាមេរិក) និងឆ្នាំ២០០៥ មាន ២២.០៨៦ពាន់លានរៀល (ប្រហាក់ប្រហែល នឹង ៥,៤ពាន់លានដុល្លារអាមេរិក) ។

១៩- វិស័យសេដ្ឋកិច្ចសំខាន់ៗនៃ ផ.ស.ស គិតតាមតំលៃចរន្ត រួមមាន ÷ វិស័យកសិកម្ម នេសាទ និងរុក្ខាប្រមាញ់ ក្នុងឆ្នាំ២០០៤ ស្មើនឹង៣១,១% នៃ ផ.ស.ស ធៀបនឹង ៤៥,១% ក្នុងឆ្នាំ១៩៩៣ ។ វិស័យឧស្សាហកម្មបន្តកើនឡើងច្រើនជាង២ដង ពោលគឺ បានកើនពី១២,៧%ក្នុងឆ្នាំ១៩៩៣ដល់២៧,៥% ក្នុងឆ្នាំ ២០០៤ ដោយសារការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៃផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់និងស្បែកជើង ជាមួយនឹងការកើនឡើងនៃការសាងសង់ ។ ទោះបីជាមានកំណើនគួរឱ្យកត់សំគាល់នៅក្នុងវិស័យសេវាកម្មដែលបំរើវិស័យទេសចរណ៍ក៏ដោយ ប៉ុន្តែ ដោយសារការរីកចំរើនយ៉ាងឆាប់រហ័សក្នុងវិស័យឧស្សាហកម្ម វិស័យសេវាកម្មបានថយចុះពី៣៩,៥% នៃ ផ.ស.ស ក្នុងឆ្នាំ១៩៩៣ មកត្រឹម ៣៥,៨% ក្នុងឆ្នាំ២០០៤ វិញ ។

២០- គ្រោះរាំងស្ងួត ទឹកជំនន់ និងការធ្លាក់ចុះនៃផលិតផលព្រៃឈើ បានធ្វើឱ្យវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្លាក់ចុះ២,០%នៅក្នុងឆ្នាំ២០០៤ ធៀបនឹងកំណើន១២,២%ក្នុងឆ្នាំ២០០៣ ។ តំលៃបន្ថែមនៃវិស័យកសិផលបានធ្លាក់ចុះ ៣,៤% ហើយផលនេសាទបានធ្លាក់ចុះ ៣,៣% ។ ចំណែកតំលៃបន្ថែមនៃផលនេសាទទឹកសាបនិងសមុទ្របន្តធ្លាក់ចុះ៤,៦% និង៧,៨% ក្នុងឆ្នាំ ២០០៤ដែរ ។ ការចិញ្ចឹមសត្វនិង បសុបក្សីបានកើនឡើង៤,៣% ។ តំលៃបន្ថែមកើនឡើង០,២%នៅក្នុងវិស័យព្រៃឈើ ដោយសារការកើនឡើងនៃតំរូវការប្រើប្រាស់និងការសាងសង់ក្នុងស្រុក និងផលិតកម្មគ្រឿងសង្ហារឹម ព្រមទាំងការថយចុះនៃ ការនាំចេញ ។ ផលិតផលកសិកម្មបានកើន៤,៥% ក្នុងឆ្នាំ២០០៥ ក្នុងនោះ ផលិតផលស្រូវកើនឡើង ២០%។

## តារាងទី ១ : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

| សូចនាករ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|---|---|
| **<u>ផលិតផលក្នុងស្រុកសរុប</u>** (ពាន់លានរៀល គិតតាមថ្លៃបច្ចុប្បន្ន) | **១៤.៨៦០** | **១៥.៩៩៤** | **១៧.៣១១** | **១៩.៦៣០** | **២២.០៨៦** |
| ផលិតផលក្នុងស្រុកសរុប (លានដុល្លារ គិតតាមថ្លៃបច្ចុប្បន្ន) | ៣.៧៨៧ | ៤.០៧៩ | ៤.៣៥៥ | **៤.៨៨៨** | **៥.៣៦៣** |
| **<u>កំណើនផលិតផលក្នុងស្រុកសរុប</u>** ( % ) | **៥,៥%** | **៥,២%** | **៧,០%** | **៧.៧ %** | **៧.០ %** |
| **<u>អត្រានៃផលិតផលក្នុងស្រុកសរុប</u>** (គិតតាមថ្លៃបច្ចុប្បន្ន) | | | | | |
| -កសិកម្ម (% ) | ៣៤,០% | ៣២,២% | ៣៣,២% | ៣១.១% | ៣៣.៨% |
| -ឧស្សាហកម្ម (% ) | ២៣,៦% | ២៥,០% | ២៦,៤% | ២៧.៥ % | ២៥.៧% |
| -សេវាកម្ម (% ) | ៣៧,២% | ៣៧,១% | ៣៥,២% | ៣៥.៨ % | ៣៥.០% |
| ផលិតផលក្នុងស្រុកសរុបសំរាប់ប្រជាជនម្នាក់ (គិតជាដុល្លារ) | ២៩៣ | ៣១០ | ៣២៥ | ៣៥៧ | ៣៨៥ |
| ចំនួនប្រជាជនសរុប  (លាននាក់ ) | ១២,៩ | ១៣,១ | ១៣,៤ | ១៣.៧ | ១៣.៩ |
| អតិផរណាប្រាក់រៀល (មធ្យមភាគប្រចាំឆ្នាំ %) | | | | | |
| អតិផរណាប្រាក់រៀល (ប្រៀបធៀបតាមត្រីមាស %) | -០,២% | ៣,៣% | ១,២% | ៥,៦% | ៦,៧% |
| ទុនបំរុងអន្តរជាតិ (គិតជាលានដុល្លារ) | ៤៦៧ | ៥៦៧ | ៦៣៣ | ៧១២ | ៨១៧ |
| ទុនបំរុងអន្តរជាតិ<u>ទាំងអស់</u> (គិតជាលានដុល្លារ) | ៥៤៨ | ៦៦៣ | ៧៣៧ | ៨០៩ | ៨៦៧ |
| ទុនបំរុងអន្តរជាតិ<u>ទាំងអស់</u> (ចំនួនខែនាំចូល) | ២,៨ | ៣,១ | ៣,១ | ២,៧ | ២,៥ |
| សរុបថវិការបំរុង (គិតជា %នៃផ. ស. ស ) | ១៧,៦% | ២០,៩% | ១៦,៥% | ១៥,៧% | ១៧,៥% |
| អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ | ៣.៩២៤ | ៣.៩១៨ | ៣.៩៨៤ | ៤.០១៩ | ៤.១១៨ |
| អត្រាប្តូរប្រាក់មធ្យមចុងឆ្នាំ | ៣.៩៣០ | ៣.៩៤០ | ៤.០០០ | ៤.០៣៨ | ៤.១៦០ |
| **វិនិយោគសរុប (លានដុល្លារ)** | **៦៦៥,៨** | **៨៥២,១** | **៧១៥,២** | **៧៦៧,៥** | **៩៣៦,៥** |
| វិនិយោគសាធារណៈ | ២៨០,៧ | ៣៥៤,៤ | ២៩៨,៣ | ៣០៤,៧ | ២៨៣,៩ |
| -ហិរញ្ញប្បទានក្នុងប្រទេស | ៥៨,៣ | ៤០,៩ | ៤៨,៨ | ៦២,៨ | ៦៦,៨ |
| -ហិរញ្ញប្បទានក្រៅប្រទេស | ២២២,៤ | ៣១៣,៥ | ២៤៩,៥ | ២៤១,៨ | **២១៧,១** |
| វិនិយោគឯកជន | ៤២២,៦ | ៤៥២,៣ | ៤៣២,៤ | ៤៦២,៨ | ៦៥២,៦ |
| -ហិរញ្ញប្បទានក្នុងប្រទេស | ២៨០,៦ | ៣១៣,៣ | ៣៥៥,១ | ៣៤១,៨ | ៤៣៦,៦ |
| -ហិរញ្ញប្បទានក្រៅប្រទេស | ១៤២ | ១៣៩ | ៧៧,៣ | ១២១ | ២១៦ |
| **<u>សរុបការវិនិយោគគិតជាភាគរយនៃផ. ស. ស</u>** | **១៧,៦%** | **២០,៩%** | **១៦,៥%** | **១៥,៧%** | **១៧,៥%** |
| - វិនិយោគសាធារណៈ | ៧,៤% | ៨,៧% | ៦,៩% | ៦,២% | ៥,៣% |
| - វិនិយោគឯកជន | ១០,២០% | ១២,២% | ៩,៦% | ៩,៥% | ១២,២% |

<u>ប្រភពពតិមាន</u> : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ -ធនាគារជាតិនៃកម្ពុជា -វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

២១- វិស័យឧស្សាហកម្មបានកើនឡើង១៦,១% ក្នុងឆ្នាំ២០០៤ ធៀបនឹងកំណើន១១,៩% ក្នុងឆ្នាំ២០០៣ ។ វិស័យនេះបានកើនឡើងខ្ពស់ ដោយសារការកើនឡើងនៃឧស្សាហកម្មកម្មន្តសាល (៧៥,៤%) និងសំណង់ (២២,០%) ។ ផលិតកម្មវាយនភ័ណ្ឌសំលៀកបំពាក់និងស្បែកជើង បានបង្កើនតំលៃបន្ថែម ២៤,៩% នៅក្នុងឆ្នាំ២០០៤ បន្ទាប់ពីបានកើនចំនួន១៦,៩% នាឆ្នាំ២០០២ និង២១,២% ក្នុងឆ្នាំ២០០៣មក ។ ការនាំចេញផលិតផលភាគច្រើនក្នុងប្រព័ន្ធអនុគ្រោះទូទៅ ដែលជាផលិតផលសំលៀកបំពាក់ បានកើនឡើងពី ៨២,៦% នៃទំនិញនាំចេញសរុបក្នុងឆ្នាំ២០០៣ ដល់៨៨,៨% នៅឆ្នាំ២០០៤ ។ តំលៃបន្ថែមនៃវិស័យសំណង់ក៏បានចូលរួមក្នុងកំណើនក្នុងឆ្នាំ២០០៤ យ៉ាងខ្លាំងក្លាដែរ គឺកើនចំនួន១៣,២% ធៀបនឹង១១,១% នៅឆ្នាំ២០០២ និង២៧,១% នៅឆ្នាំ២០០៣ ។ ក្នុងឆ្នាំ២០០៥ វិស័យឧស្សាហកម្មកើនឡើង១០,៧% ដោយសារការបន្តពង្រឹងផ្នែកកម្មន្តសាលដែលបានកើនឡើង១០,២% និងផ្នែកសំណង់កើនឡើង១៣% ។ តំលៃបន្ថែមនៃការនាំចេញសំលៀកបំពាក់បានកើនឡើង ពី១,៩៨ពាន់លានដុល្លារអាមេរិក នាឆ្នាំ២០០៤ ដល់ ២,១៧ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥ ។

### តារាងទី ២ : ផ.ស.ស តាមវិស័យសេដ្ឋកិច្ចសំខាន់ៗ




២២- វិស័យសេវាកម្មបានកើនឡើង៩,២% នៅឆ្នាំ២០០៤ ធៀបនឹង ០,២% នៅក្នុងឆ្នាំ២០០៣ ។ ទេសចរណ៍នៅតែជាវិស័យដែលបានចូលរួមចំបងសំរាប់កំណើនក្នុងវិស័យសេវាកម្ម ។ ភ្ញៀវទេសចរណ៍បរទេសបានកើនឡើងចំនួន ៥០,៤% ក្នុងឆ្នាំ២០០៤ ។ ភ្ញៀវទេសចរណ៍បរទេសបានរួមចំណែកដល់កំណើនក្នុងផ្នែកសណ្ឋាគារ និងភោជនីយដ្ឋាន (២៣,៦%) ឧស្សាហកម្មដឹកជញ្ជូន និងទូរគមនាគមន៍ (៦,២%) និងសេវាកម្មផ្សេងៗទៀត (១៨,៥%) ។ នៅក្នុងឆ្នាំ២០០៥ វិស័យសេវាកម្មកើនឡើង៦,២% គិតតាម តំលៃស្ថេរ ក្នុងនោះ តំលៃបន្ថែមផ្នែកសណ្ឋាគារនិងភោជនីយដ្ឋាន បានកើនឡើងចំនួន ១៥% ។

២៣- ផ.ស.ស សំរាប់មនុស្សម្នាក់ក្នុងឆ្នាំ២០០៤មាន១,៤៣៥លានរៀល ពោលគឺកើនឡើង១១,២% ធៀបនឹងឆ្នាំ២០០៣ ។ ផ.ស.ស នេះបានកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំ ៦,៧% ក្នុងរយៈ៤ឆ្នាំកន្លងមក ។ កំណើន

ប្រជាជនមធ្យមក្នុងរយៈពេលដូចគ្នានេះ មាន ១,៩% ក្នុងមួយឆ្នាំ ។ ដោយគិតតាមតំលៃស្ថេរ ផ.ស.ស សរុបប្រចាំឆ្នាំសំរាប់ប្រជាជនម្នាក់មាន ១,៣១៩លានរៀលនៅឆ្នាំ២០០៤ កើនឡើង ៥,៦% ធៀបនឹងឆ្នាំ ២០០៣ ។ កំណើនជាមធ្យមនៃ ផ.ស.ស សរុប តាមតំលៃស្ថេរ សំរាប់ប្រជាជនម្នាក់ៗមានប្រហែល ៤,៤% ក្នុងរយៈពេល៤ឆ្នាំ កន្លងមកនេះ ។ ផ.ស.ស សំរាប់ប្រជាជនម្នាក់ គិតជាប្រាក់ដុល្លារអាមេរិក បានកើនប្រចាំឆ្នាំ ៤,៦% នៅឆ្នាំ២០០៤ ពោលគឺ បានកើនដល់៣២៨ដុល្លារអាមេរិក ធៀបទៅនឹង កំណើន ៣,៦%នៅឆ្នាំ២០០៣ និង៣,៤% នៅឆ្នាំ២០០២ ។ ផ.ស.ស សំរាប់ប្រជាជនម្នាក់ៗបានកើន ឡើងពី ៣២៥ដុល្លារអាមេរិក នៅឆ្នាំ២០០៣ ដល់៣៥៧ដុល្លារអាមេរិក នៅឆ្នាំ២០០៤ ។

## ៣- សមិទ្ធិផលរូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈ

### ៣.១- គោលនយោបាយរូបិយវត្ថុ និងសមិទ្ធិផល

២៤- ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិត និងប្រកាន់យករបបអត្រាប្តូរប្រាក់អណ្តែតដែលមានការគ្រប់គ្រង ។ អតិផរណា និងអត្រាប្តូរប្រាក់បានស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ។ មកទល់បច្ចុប្បន្ន គោលនយោបាយនេះបានចូលរួមចំណែកក្នុងការបង្កើនជំនឿទុកចិត្តរបស់សាធារណជនក្នុងបរិស្ថានម៉ាក្រូសេដ្ឋកិច្ចកម្ពុជា និងបានជួយជំរុញវិស័យពាណិជ្ជកម្ម និងការវិនិយោគឯកជនទៀតផង ។

២៥- ជាក់ស្តែង សេដ្ឋកិច្ចកម្ពុជាសម្រេចបានកម្រិតថ្លៃស្ថិរភាពមួយ នាអំឡុងពេលប្រមាណ ៥ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩៩មក ជាមួយនឹងការប្រែប្រួលអតិផរណាមធ្យមប្រចាំឆ្នាំប្រមាណ១%ប៉ុណ្ណោះ ។ ក៏ប៉ុន្តែ នៅឆ្នាំ ២០០៤ និងឆ្នាំ២០០៥ សេដ្ឋកិច្ចបានរងផលប៉ះពាល់ដោយផ្ទាល់ពីបញ្ហាសេដ្ឋកិច្ចមួយ ក្នុងបណ្តាបញ្ហាសេដ្ឋកិច្ចដទៃទៀត ពោលគឺ កម្រិតដ៏ខ្ពស់នៃថ្លៃប្រេងដែលមិនធ្លាប់មានពីមុនមក ដែលបានជះឥទ្ធិពលដល់គ្រប់វិស័យ រួមទាំងអ្នកប្រើប្រាស់ អ្នកផលិត និងរាជរដ្ឋាភិបាល ។ ការឡើងថ្លៃប្រេង និងកំណើនថ្លៃម្ហូបអាហារក្នុងស្រុក បានជំរុញឱ្យអតិផរណាកើនដល់ប្រហែល៦%ក្នុងឆ្នាំ២០០៥ ។ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការ ដើម្បីកាត់បន្ថយសម្ពាធអតិផរណា តាមរយៈការគ្រប់គ្រងកំណើនរូបិយវត្ថុ ។

២៦- ស្របពេលជាមួយគ្នានេះដែរ ការប្រែប្រួលយ៉ាងខ្លាំងនៃទីផ្សាររូបិយប័ណ្ណសកលលោកក៏មានផលប៉ះពាល់ទៅលើទីផ្សាររូបិយប័ណ្ណក្នុងស្រុកដែរ ក្នុងខណៈដែលអត្រាប្តូរប្រាក់រៀលធៀបជាមួយប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះបន្តិចក្នុងឆ្នាំ២០០៥ ធៀបនឹងឆ្នាំមុន ។ ប្រាក់រៀលបានធ្លាក់ចុះប្រមាណ២% ក្នុងខែធ្នូ ឆ្នាំ២០០៥ ធៀបនឹងការធ្លាក់ចុះប្រមាណ១%ក្នុងរយៈពេលដូចគ្នានៃឆ្នាំមុន ។ ប៉ុន្តែ បម្រែបម្រួលនេះស្ថិតក្នុងចន្លោះមួយ ដែលអាចគ្រប់គ្រងបាននៅឡើយ ។

២៧- ទិន្នន័យរូបិយវត្ថុសម្រាប់ឆ្នាំ២០០៥ បង្ហាញថា សាច់ប្រាក់ក្នុងប្រព័ន្ធធនាគារ បានបន្តនិន្នាការកើនឡើងទោះបីក្នុងល្បឿនយឺតជាងមុនក៏ដោយ ។ កំណើនរូបិយវត្ថុទូទៅ (M2) មានល្បឿនថយចុះដល់១៦%

ដែលនាំឱ្យការផ្គត់ផ្គង់រូបិយវត្ថុកើនឡើងពី៤,៣២៩ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៤ ដល់៥,០២៥ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៥ ។ កំណើននេះមានកម្រិត ១៤% នាខែធ្នូ ឆ្នាំ២០០៥ ធៀបនឹង ៣០% ក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០០៤ ។ ការកើនឡើងបន្តិចបន្តួចនៃសាច់ប្រាក់ និងអត្រាកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ ៧% ក្នុងឆ្នាំ២០០៥ បង្ហាញឱ្យឃើញថា ការកើនឡើងនៃរូបិយវត្ថុត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ ។ ប្រការនេះអាចបញ្ជាក់បានថា ការកើនឡើងនៃអតិផរណាក្នុងឆ្នាំនេះបណ្តាលមកពីកត្តាផ្សេងៗក្រៅពីមូលហេតុរូបិយវត្ថុ ។ កំណើនរូបិយវត្ថុមួយចំនួនធំក្នុងរយៈពេលនេះ បណ្តាលមកពីកំណើនទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារ ដែលបានកើនឡើងប្រមាណ១៤,២% ដែលជាលទ្ធផលនៃការកើនឡើងទ្រព្យសកម្មបរទេសប្រមាណ ១២% និងការកាត់បន្ថយបំណុលបរទេសប្រមាណ ២,៦% ។ រីឯរូបិយវត្ថុក្រៅប្រព័ន្ធធនាគារបានកើនឡើងប្រមាណ១៥% ប៉ុន្តែ ចាប់ផ្តើមពីមូលដ្ឋានទាបមួយ ធៀបនឹងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ។ កំណើនឥណទានក្នុងស្រុកបានថយចុះមកត្រឹម ២១,៣% ធៀបនឹង ៣៥,៨%ក្នុង ខែធ្នូ ឆ្នាំ២០០៤ ។

២៨- ទិន្នន័យបឋមស្តីអំពីការអភិវឌ្ឍន៍វិស័យក្រៅប្រទេសបង្ហាញឱ្យឃើញថា កំណើនឱនភាពពាណិជ្ជកម្មបានកើនឡើងដល់ ៤៣,៧% ក្នុងឆ្នាំ២០០៥ ធៀបនឹង ៣៤,៧% ក្នុងឆ្នាំ២០០៤ ដែលមូលហេតុចំបងគឺ ការកើនឡើងនៃតម្លៃប្រេងនាំចូល ។ ការកើនឡើងយ៉ាងខ្លាំងនៃចំណូលទេសចរណ៍បានជួយកែលំអមួយផ្នែកនូវស្ថានភាពទន់ខ្សោយនៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិ ដែលបណ្តាលឱ្យមានឱនភាពគណនីចរន្ត (មិនគិតបញ្ចូលការផ្ទេរផ្លូវការ) បានកើនបន្តិចបន្តួច ១០,៥% នៃ ផ.ស.ស ធៀបនឹង៩,៨%នៃ ផ.ស.ស ឆ្នាំ២០០៤ ។ ភាពប្រសើរឡើងនៃលំហូរវិនិយោគផ្ទាល់ពីបរទេស គួបផ្សំនឹងការកើនឡើងមួយចំនួននៃកាផ្ទេរផ្លូវការ បានធ្វើឱ្យគណនីមូលធននិងហិរញ្ញវត្ថុមានអតិរេកដែលមានកម្រិតខ្ពស់ជាងឱនភាពគណនីចរន្ត ។ ជាលទ្ធផល សមតុល្យរួមនៃជញ្ជីងទូទាត់មានអតិរេក៤៣,៦លានដុល្លាអាមេរិក ហើយទុនបម្រុងអន្តរជាតិសុទ្ធ បានកើនឡើងប្រមាណ១៧,៦% និងមានកម្រិតស្មើនឹង២,៥ខែនៃការនាំចូល។

## ៣.២- គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងសមិទ្ធិផល

២៩- គោលដៅនៃគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាល គឺការរក្សានូវតុល្យភាពសារពើពន្ធប្រកបដោយចីរភាព ជាមួយនឹងកំណើនជាលំដាប់នូវថវិកាសំរាប់វិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច ដោយត្រូវធ្វើសនិទានីយកម្មចំណាយសាធារណៈ ពង្រីកមូលដ្ឋានយកពន្ធ និងទប់ស្កាត់ការគេចពន្ធ ព្រមទាំងពង្រឹងរដ្ឋបាលគយនិងពន្ធដារ ក្នុងការប្រមូលចំណូលបន្ថែម ។ ការអនុវត្តន៍គោលនយោបាយសារពើពន្ធដោយប្រុងប្រយ័ត្នបាននាំឱ្យរាជរដ្ឋាភិបាលរក្សាបាននូវស្ថេរភាពតំលៃ នៅក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មកម្ពុជា ។

៣០- គោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលត្រូវបានរៀបចំឡើង ដើម្បីធានាឱ្យក៏រិតចំណាយមានសង្គតិភាពជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ កម្មវិធីចំណាយកំពុងត្រូវបានរៀបចំ ដើម្បីឱ្យក្លាយទៅជាផ្នែកមួយនៃប្រព័ន្ធកំណែទំរង់ ដែលជំរុញកំណើនសន្សំក្នុងស្រុក ការវិនិយោគប្រកបដោយផលិតភាពខ្ពស់

និងការវិភាជន៍ធនធានប្រកបដោយប្រសិទ្ធភាព ។ ស្ថានភាពសារពើពន្ធក្នុងឆ្នាំ២០០៤-២០០៥ មានភាពល្អប្រសើរ ដោយមានកំណើនចំណូលក្នុងស្រុក និងមានការត្បិតត្បៀតចំណាយសាធារណៈ ។

### ៣.៣- ចំណូលក្នុងស្រុក

៣១- ចំណូលក្នុងស្រុកសរុបបានកើនឡើងពី១០,២%នៃ ផ.ស.ស ក្នុងឆ្នាំ២០០៣ទៅ១១,៣%នៅឆ្នាំ២០០៤ និង ១១,៧%នៅឆ្នាំ២០០៥ ។ ចំណូលពន្ធបានកើនពី៨,៤%ក្នុងឆ្នាំ២០០៤ ដល់ ៨,៧% នៃ ផ.ស.ស ក្នុងឆ្នាំ ២០០៥ ។ កំណើនចំណូលបានឆ្លុះបញ្ចាំងនូវប្រសិទ្ធភាពនៃវិធានការនានាសំរាប់ប្រមូលចំណូល ដែលបានដាក់ឱ្យអនុវត្តក្នុងត្រីមាសទី៤ឆ្នាំ២០០៣និងដើមឆ្នាំ២០០៤ ។ វិធានការទាំងនេះគឺជាវិធានការដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្ត សំរាប់បន្តប្រឹងប្រែងប្រមូលចំណូលពីប្រេសណីយ៍ ពីទូរស័ព្ទ និងពីទូរគមនាគមន៍ ការប្រមូលចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងវិធានការបន្ថែមផ្សេងៗទៀត ដូចជាការបន្តពង្រីកមូលដ្ឋានយកពន្ធ ការបង្កើនការប្រមូលថ្លៃទិដ្ឋាការ និងចំណូលពីទេសចរណ៍ជាដើម ។

៣២- ចំណូលក្នុងស្រុកសរុបអាចកើនពី ១.៧៧៦ពាន់លានរៀល ស្មើនឹង ៤៤៦,៧លានដុល្លាអាមេរិក នាឆ្នាំ ២០០៣ ដល់២.២១២ពាន់លានរៀល ក្នុងឆ្នាំ២០០៤ ស្មើនឹង៥៥០,៧លានដុល្លារអាមេរិក ហើយបានបន្តកើន រហូតដល់ ២.៥៩១ពាន់លានរៀល ស្មើនឹងប្រមាណ ៦២៩,២លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥ នេះ ។ ក្នុង ឆ្នាំ២០០៥ នេះ ចំណូលក្នុងស្រុកដែលប្រមូលបាន រួមមាន ÷ ចំណូលពន្ធដារចំនួន ១.៩២៩ពាន់លានរៀល ចំណូលមិនមែនពន្ធ ចំនួន៥៥៥ពាន់លានរៀល និងចំណូលជាមូលធន ដែលបានមកពីការធ្វើឯកជនភាវូបនីយកម្ម និងប្រភពផ្សេងៗ ចំនួន ១០៦ពាន់លានរៀល ។

៣៣- ចំណូលក្នុងស្រុកសរុបនាឆ្នាំ២០០៤រួមមាន ÷ ចំណូលពន្ធដារ ១.៦៤៨ពាន់លានរៀល ចំណូលមិនមែនពន្ធ ៥៤៤ពាន់លានរៀល និងចំណូលមូលធន ១៩ពាន់លានរៀល ដែលបានមកពីការធ្វើឯកជនភាវូបនីយកម្ម និងពីប្រភពផ្សេងៗទៀត ។

### ៣.៤- ចំណាយសាធារណៈ

៣៤- ពិនិត្យជារួម នៅក្នុងឆ្នាំ២០០៤ និងឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានប្រឹងប្រែងកំរិតចំណាយឱ្យនៅក្រោមគោលដៅ ដែលអាចជួយកាត់បន្ថយការធ្វើហិរញ្ញប្បទានពីប្រភពក្នុងស្រុក ។ ក្នុងកំឡុងពេល២ឆ្នាំនេះ ចំណាយចរន្តសរុបមានកំរិតទាបជាងចំណូលដែលប្រមូលបាន គិតទាំងន័យនាមករណ៍ និងជាភាគរយ នៃ ផ.ស.ស ។ ចំណាយចរន្តសរុបបានធ្លាក់ចុះពី១០,៦% នៃ ផ.ស.ស នៅក្នុងឆ្នាំ២០០៣ ដល់៩,៥% ក្នុងឆ្នាំ២០០៤ និង៩,៣% ក្នុងឆ្នាំ២០០៥ (តាមការប៉ាន់ស្មានបឋម) ។

៣៥- នៅឆ្នាំ២០០៤ ចំណាយទូទាត់តាមរតនាគារមានចំនួនសរុប ២.០៧៨,៨ពាន់លានរៀល ស្មើនឹង ៥១៥,៧ លានដុល្លារអាមេរិក ។ ចំណាយទាំងនេះរួមមាន ចំណាយចរន្តចំនួន១.៧៤៥,៧ពាន់លានរៀល ស្មើនឹង

៤៣៣,១លានដុល្លារអាមេរិក ចំណាយមូលធននិងការអភិវឌ្ឍន៍ចំនួន៣៣៣,១ពាន់លានរៀល ស្មើនឹង ៨២,៦លានដុល្លារអាមេរិក ។ រីឯចំណាយមូលធនសរុបនៅក្នុងឆ្នាំ២០០៤ ដែលមានប្រភពមកពីក្នុងស្រុក និងក្រៅប្រទេស មានប្រមាណ ១.២៦០,៦ពាន់លានរៀល ឬ ៣១២,៧លានដុល្លារអាមេរិក ។

៣៦- នៅឆ្នាំ២០០៤ ចំណាយចរន្តសរុបមានចំនួន ១.៧៤៥,៦ពាន់លានរៀល ដែលក្នុងនោះរួមមាន ÷

- ចំណាយរដ្ឋបាលស៊ីវិលមាន១.២៧៤,២ពាន់លានរៀល ស្មើនឹង៣១៦,១លានដុល្លារអាមេរិក ត្រូវជា ៧៣% នៃចំណាយចរន្តសរុប ក្នុងនោះ ចំណាយលើប្រាក់បៀវត្សមាន ៣៤៣,៦ពាន់លានរៀល ស្មើនឹង ៨៥,២លានដុល្លារអាមេរិក ត្រូវជា ២៧% នៃចំណាយរដ្ឋបាលស៊ីវិលសរុប ។
- ចំណាយយោធានិងសន្តិសុខ មានចំនួន៤២២,៨ពាន់លានរៀល ស្មើនឹង១០៤,៩លានដុល្លារអាមេរិក គឺស្មើនឹង២៤,២% នៃចំណាយចរន្តសរុប ក្នុងនោះ ចំណាយប្រាក់បៀវត្សមានចំនួន ២៩៦,១ពាន់លានរៀល ស្មើនឹង៧៣,៥លានដុល្លារអាមេរិក ត្រូវជា៧០%នៃចំណាយយោធានិងសន្តិសុខ ។
- ចំណាយការប្រាក់លើប្រាក់កម្ចីមាន៤៨,៦ពាន់លានរៀល ស្មើនឹង១២,១លានដុល្លារអាមេរិក ស្មើនឹង ២,៨% នៃចំណាយចរន្តសរុប ។

៣៧- តួរលេខបឋមស្តីពីចំណាយក្នុងរយៈពេល១១ខែដើមឆ្នាំ២០០៥ បានបង្ហាញថា ចំណាយដែលឆ្លងកាត់ប្រព័ន្ធរតនាគារជាតិ មានចំនួន ១.៧៨៩,៨ពាន់លានរៀល ។ ក្នុងនោះ ចំណាយចរន្តស្រូបយក១.៤៧៥,៨ពាន់លានរៀល និងចំណាយមូលធនមាន៣១៤ពាន់លានរៀល ដែលត្រូវធ្វើហិរញ្ញប្បទានដោយធនធានក្នុងស្រុកតាមរយៈប្រព័ន្ធរតនាគារជាតិ ។ ចំណាយមូលធនសរុប រួមទាំងធនធានក្នុងស្រុកនិងធនធានពីបរទេស មានចំនួន៩៥០ពាន់លាន់រៀល ។

៣៨- ចំណាយសរុបដែលឆ្លងកាត់ប្រព័ន្ធរតនាគារជាតិក្នុងរយៈពេល១១ខែដើមឆ្នាំ២០០៥ ចំនួន១.៤៧៥,៨ពាន់លានរៀល ត្រូវបានប្រើប្រាស់សំរាប់រដ្ឋបាលស៊ីវិល ការពារប្រទេស និងសន្តិសុខ ព្រមទាំងចំណាយសំរាប់សងការប្រាក់លើបំណុលផងដែរ ។ ជាក់ស្តែងគឺ ÷

- ចំណាយសំរាប់រដ្ឋបាលស៊ីវិលមាន១.០៩២,៧ពាន់លានរៀល ស្មើនឹង៧៤,១% នៃចំណាយចរន្ត សុរប ក្នុងនោះ ចំណាយសំរាប់ប្រាក់បៀវត្សមាន៣២៤,១ពាន់លានរៀល ស្មើនឹង២៩,៧%នៃចំណាយសំរាប់រដ្ឋបាលស៊ីវិល ។
- ចំណាយការពារប្រទេសនិងសន្តិសុខ មានចំនួន៣៣៦,៨ពាន់លានរៀល ស្មើនឹង២៨% នៃចំណាយចរន្តសុរប ក្នុងនោះ ចំណាយសំរាប់ប្រាក់បៀវត្សមានចំនួន២៥៥,៨ពាន់លានរៀល ស្មើនឹង៧៦%នៃចំណាយការពារប្រទេសនិងសន្តិសុខ ។
- ចំណាយសំរាប់សងការប្រាក់លើបំណុលមានចំនួន៤៦, ៣ពាន់លានរៀល ស្មើនឹង៣,១%នៃចំណាយចរន្ត ។

## តារាងទី ៣ : សូចនាករនៃថវិការដ្ឋ

| | ២០០១ ផែនការថវិការ | | | ២០០២ ផែនការថវិការ | | | ២០០៣ ផែនការថវិការ | | | ២០០៤ ផែនការថវិការ | | | ២០០៥ ផែនការថវិការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | លានដុល្លារ | %ផសស | ពាន់លានរៀល | លានដុល្លារ | %ផសស | ពាន់លានរៀល | លានដុល្លារ | %ផសស | ពាន់លានរៀល | លានដុល្លារ | %ផសស | ពាន់លានរៀល | លានដុល្លារ | %ផសស |
| **ចំណូលក្នុងប្រទេស** | **១.៥៦១** | **៣៩៧,៨** | **១០,៣%** | **១.៧៦២** | **៤៤៩,៣** | **១១%** | **១.៧៧៦** | **៤៥៦,៧** | **១០,២%** | **២.២១២** | **៥៥០,៧** | **១១,៣%** | **២.៥៩១** | **៦២៩,២** | **១១,៧%** |
| **១. ចំណូលពន្ធដារ** | ១.១២៨ | ២៨៧,៤ | ៧,៥% | ១.២៤៥ | ៣១៧,៥ | ៧,៧% | ១.២១៩ | ៣០៦,៦ | ៧,១% | ១.៦៤៨ | ៤១០,៣ | ៨,៤% | ១៩២៩ | ៤៦៨,៤ | ៨,៧% |
| ពន្ធចំពោះ | ១៤០ | ៣៥,៦ | ០,៩% | ១៣២ | ៣៣,៦ | ០,៨% | ១៥០ | ៣៧,៧ | ០,៩% | ១៥៨ | ៣៩,៣ | ០,៨% | ២១២ | ៥១,៥ | ១% |
| ពន្ធមិនចំពោះ | ៥៧២ | ១៤៥,៧ | ៤,០% | ៦៥៤ | ១៦៦,៧ | ៤% | ៦៣៥ | ១៥៩,៧ | ៣,៧% | ៨៩៥ | ២២២,៨ | ៤,៦% | ១.០៨៦ | ២៦៣,៧ | ៤,៩% |
| ចំណូលពន្ធគយ | ៣៧៦ | ៩៥,៨ | ២,៥% | ៤២៤ | ១០៨,១ | ២,៦% | ៣៩៥ | ៩៩,៣ | ២,៣% | ៥១៦ | ១២៨,៤ | ២,៦% | ៥៦០ | ១៣៦ | ២,៥% |
| ផ្សេងៗ | ៤១ | ១០,៤ | ០,០២ % | ៣៥ | ៨,៩ | ០,២ % | ៣៩ | ៩,៨ | ០,២% | ៧៩ | ១៩,៦ | ០,៤ % | ៧១ | | ០,៣% |
| **២. ចំណូលមិនមែនពន្ធដារ** | ៤២៤ | ១០៨ | ២,៨% | ៥០១ | ១២៧,៧ | ៣,១% | ៥២៥ | ១៣២ | ៣% | ៥៤៤ | ១៣៥,៤ | ២,៨% | ៥៥៥ | ១៣៤,៨ | ២,៥% |
| **៣. ចំណូលមូលធន** (ក្នុងប្រទេស) | ៩ | ២,២ | ០,០១% | ១៦ | ៤ | ០,១% | ៣១ | ៧,៧ | ០,១% | ១៩ | ៤,៧ | ០,១% | ១០៦ | | ០,៥% |
| **ចំណាយ** | **២.៥១៦** | **៦៤១,១** | **១៦,៩%** | **២.៩៦៣** | **៧៥៥,៦** | **១៨,៥%** | **២.៩៤៦** | **៧៤១,១** | **១៧%** | **២.៩៧០** | **៧៣៩,៥** | **១៥,១%** | **៣.២៩៤** | **៧៩៩,៩** | **១៤,៩%** |
| **១. ចំណាយចរន្ត** | ១.៤១៥ | ៣៦០,៦ | ៩,៥% | ១.៥៧៤ | ៤០១,៤ | ៩,៩% | ១,៧៥៨ | ៤៤២,២ | ១០,១% | ១.៧៤៥ | ៤៣៤,៥ | ៨,៩% | ២.១២៥ | ៥១៦ | ៩,៦% |
| - ការពារប្រទេសនិងសន្តិសុខ | ៤១៧ | ១០៦,២ | ២,៨% | ៤០៦ | ១០៣,៨ | ២,៥% | ៤១១ | ១០៣,៣ | ២,៣% | ៤២២ | ១០៥ | ២,២% | ៤៥២ | ១០៩,៨ | ២,០% |
| - រដ្ឋបាលស៊ីវិល | ៩៩៨ | ២៥៤,៣ | ៦,៧% | ១.១៦៨ | ២៩៧,៨ | ៧,៤% | ១.៣៤៧ | ៣៣៨,៨ | ៧,៨% | ១.២៧៤ | ៣១៧,២ | ៦,៥% | ១.៦៧៣ | ៤០៦,២ | ៧,៦% |
| **២. ចំណាយមូលធន** | **១.១០១** | **២៨០,៥** | **៧,៤%** | **១.៣៨៨** | **៣៥៣,៩** | **៨,៦%** | **១.១៨៨** | **២៩៨,៨** | **៦,៩%** | **១.២២៤** | **៣០៤,៧** | **៦,២%** | **១.១៦៩** | **២៨៣,៩** | **៥,៣%** |
| - ហិរញ្ញប្បទានវិនិយោគក្នុងស្រុក | ២៨៣ | ៧២,១ | ១,៩% | ៣៣៨ | ៨៦,២ | ២,១% | ៣៣៣ | ៨៣,៧ | ១,៩% | ២៩៧ | ៧៣,៩ | ១,៥% | ៣៤២ | ៨៣,១ | ១,៥% |
| - ហិរញ្ញប្បទានវិនិយោគក្រៅប្រទេស | ៨១៨ | ២០៨,៤ | ៥,៥% | ១.០៤៩ | ២៦៧,៥ | ៦,៥% | ៨៥៤ | ២១៤,៨ | ៥% | ៩២៧ | ២៣០,៨ | ៤,៧% | ៨២៧ | ២០០,៨ | ៣,៧% |
| **ឱនភាព/អតិរេក** | | | | | | | | | | | | | | | |
| **- សរុប** | **៩៨៧** | **២៥១,៧** | **៦,៦៤%** | **១.២១៩** | **៣១០,៨** | **៧,៦%** | **១.១៨១** | **២៩៧,១** | **៦,៨%** | **៨៦៤** | **២១៥,១** | **៤,៤%** | **៦៩៤** | **១៦៨,៥** | **៣,១%** |
| **- ក្នុងនោះចរន្ត** | ១១៣ | ២៨,៧ | ០,៧% | ១៦៩ | ៤៣,១ | ១,០% | ៦ | ១,៥ | ០,០៣% | ៣៤០ | ៨៤,៦ | ១,៧% | ៣៦០ | ៨៧,៤ | ១,៦% |
| **ផ. ស. ស/ពាន់លានរៀល** | **១៤.៨៦០** | | | **១៥.៩៩៤** | | | **១៧.៣១១** | | | **១៩.៦៣០** | | | ២២.០៨៦ | | |
| **ផ. ស. សលានដុល្លាអាមេរិក** | **៣.៧៨៦,៩** | | | **៤.០៧៩,១** | | | **៤.៣៥៤,៩** | | | **៤.៨៨៧,៩** | | | ៥.៣៦៣ | | |

ប្រភព :ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ៤- សមិទ្ធិផលនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល

៣៩- ក្នុងប្រវត្តិកិច្ចប្រជុំពិគ្រោះយោបល់កន្លងមកនៅកម្ពុជា កិច្ចប្រជុំពិគ្រោះយោបល់នាចុងឆ្នាំ ២០០៤ គឺជា កិច្ចប្រជុំពិគ្រោះយោបល់លើកដំបូង ដែលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានចូលរួមពិនិត្យ និង ឯកភាពរួមគ្នា ក្នុងការកំណត់សូចនាករសំរាប់ត្រួតពិនិត្យអំពី វឌ្ឍនភាព ។ ការពិភាក្សាទាំងនេះបានប្រព្រឹត្តទៅ ក្នុងកិច្ចប្រជុំលើកទី១នៃគណៈកម្មាធិការសំរបសំរួល រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ មុនកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ។ តាំងពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧មក គណៈកម្មាធិការសំរបសំរួលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានជួបប្រជុំរៀងរាល់ត្រីមាស ដើម្បីពិនិត្យឡើងវិញ អំពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករត្រួតពិនិត្យរួមគ្នា ដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់នេះ ។ ការប្រជុំពិនិត្យប្រចាំត្រីមាស ដែលរួមមានតំណាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដូចជា : ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬប្រធានស្ថាប័ននៃរាជរដ្ឋាភិបាល ឯកអគ្គរដ្ឋទូត ឬប្រធានស្ថានបេសកកម្មការទូត និងប្រធានស្ថាបន័ពហុភាគី បានផ្តល់ឱកាសអោយ ភាគីទាំងសងខាងពិនិត្យឡើងវិញពីវឌ្ឍនភាព និងផ្តល់ព័ត៌មានអោយគ្នាទៅវិញទៅមក អំពីឧបសគ្គដែលបានជួបប្រទះ ព្រមទាំងស្វែងរកវិធានការសំរាប់ជំនះឧបសគ្គទាំងនេះ ។

> **លទ្ធផលនៃការអនុវត្តន៍គោលនយោបាយ**
> ៤.១- ការប្រឆាំងអំពើពុករលួយ និងការបង្កើនគណនេយ្យភាព
> ៤.២- កំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ និងការការពារសិទ្ធិមនុស្ស
> ៤.៣- កំណែទំរង់រដ្ឋបាលសាធារណៈ
> ៤.៤-វិមជ្ឈការ និងវិសហមជ្ឈការ
> ៤.៥- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
> ៤.៦- អន្តរវិស័យ កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ
> ៤.៧- ការអភិវឌ្ឍន៏វិស័យឯកជន
> ៤.៨- យេនឌ័រ ភាពក្រីក្រ និងអេដស៍
> ៤. ៩- សុខាភិបាល និងអប់រំ
> ៤.១០- សុខដុមនីយកម្ម និងការតម្រឹម

៤០- ក្រុមការងារបច្ចេកទេសចម្រុះតាមវិសយ័ទាំង ១៨ និងយន្តការនៃគណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលបានដំណើរការពេញលេញបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់កន្លងមក បានក្លាយជាកម្លាំងចលករសំរាប់ជំរុញការអនុវត្តន៍កំណែទំរង់នានារបស់រាជរដ្ឋាភិបាល ។ ការប្រជុំត្រួតពិនិត្យប្រចាំត្រីមាសនៃគណៈកម្មាធិការសំរបសំរួលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានជួយជំរុញឱ្យបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍រួមគ្នាអនុវត្តក្នុងរយៈពេលពេញមួយឆ្នាំកន្លងមក ដើម្បីឈានទៅសំរេចឱ្យបាន នូវបណ្តាគោលដៅនៃសូចនាករត្រួតពិនិត្យរួមគ្នា ។ នេះក៏ជាយន្តការមួយដែលបានផ្តល់លទ្ធភាពឱ្យភាគីទាំងសងខាង ពិនិត្យឡើងវិញនូវការលំបាកទាំងឡាយ ដែលបានជួបប្រទះ ព្រមទាំងរិះរកវិធានការដោះស្រាយសមស្រប ។ ឆ្នាំ២០០៥ ជាឆ្នាំ «រៀនផង- ធ្វើផង» សំរាប់បណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ភាគីទាំងសងខាងនៃក្រុមការងារមួយចំនួនដំណើរការបានល្អប្រសើរតាមយន្តការនេះ ។ រីឯក្រុមការងារមួយចំនួនទៀតបាននិងកំពុងខិតខំប្រឹងប្រែងបន្ថែម ។

៤១- ជារួម យើងបានសំរេចវឌ្ឍនភាពក្នុងការសំរេចនូវគោលដៅនៃសូចនាករពិនិត្យរួមគ្នា ដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់កន្លងមក ។ បញ្ហាមួយដែលបានកត់សំគាល់ គឺកង្វះនូវទំនាក់ទំនងរវាងសកម្មភាពដែលត្រូវអនុវត្តដើម្បីសំរេចនូវសូចនាករត្រួតពិនិត្យរួមគ្នា ជាមួយនឹងធនធានដែលកៀរគរ

បាន ។ របាយការណ៍ស្តីពីការត្រួតពិនិត្យប្រចាំឆ្នាំ២០០៥ បានគូសបញ្ជាក់ថា នៅក្នុងវិស័យណាដែលមានទំនាក់ទំនងយ៉ាងច្បាស់លាស់ រវាងសកម្មភាពដែលបានគ្រោងទុកជាមួយនឹងធនធានដែលត្រូវការសម្រាប់អនុវត្តសកម្មភាពទាំងនេះ វិស័យនោះមានវឌ្ឍនភាពជាដុំកំភួនជាងនៅតាមវិស័យណាដែលមានទំនាក់ទំនងខ្សោយ ឬគ្មានទំនាក់ទំនង ឬខ្វះភាពជាម្ចាស់របស់ស្ថាប័នពាក់ព័ន្ធ ។

៤២- ក្នុងកិច្ចប្រជុំលើកទី៥នៃគណៈកម្មាធិការសំរបសំរួលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលបានប្រារព្ធនៅថ្ងៃទី១២ខែធ្នូឆ្នាំ២០០៥ តាងនាមរាជរដ្ឋាភិបាល ប្រធានគណៈកម្មាធិការសំរបសំរួលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានស្នើឱ្យដៃគូអភិវឌ្ឍន៍ប្រើប្រាស់ឱ្យមានប្រសិទ្ធភាព នូវយន្តការនៃក្រុមការងារបច្ចេកទេសសំរាប់កំណត់សូចនាករពិនិត្យរួមគ្នា សំរាប់កិច្ចប្រជុំពិគ្រោះយោបល់លើកក្រោយនេះ ។ ផ្អែកតាមគោលការណ៍គណនេយ្យភាពទ្វេទិស រាជរដ្ឋាភិបាលស្នើឱ្យក្រុមការងារបច្ចេកទេស មិនត្រឹមតែកំណត់សូចនាករពិនិត្យរួមគ្នា នៅក្នុងបរិស្ថានដែលរាជរដ្ឋាភិបាលត្រូវធ្វើជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវកំណត់ឱ្យច្បាស់ អំពីអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ឱ្យបានសំរេចនូវគោលដៅនៃសូចនាករពិនិត្យរួមគ្នានេះ និងតំរូវការធនធាន ព្រមទាំងកំណត់អំពីអ្នកផ្តល់ធនធានផងដែរ ។ លើសពីនេះ រាជរដ្ឋាភិបាលក៏ស្នើឱ្យក្រុមការងារបច្ចេកទេសទាំងអស់ កំណត់ឱ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទ ដែលត្រូវសំរេចគោលដៅរបស់ខ្លួន ដោយត្រូវយកចិត្តទុកដាក់ដល់សមត្ថភាពជាក់ស្តែងរបស់ក្រសួងពាក់ព័ន្ធ ព្រមទាំងភាពស្មុគស្មាញនៃកិច្ចដំណើរការផងដែរ ។

៤៣- វឌ្ឍនភាពនៃការអនុវត្តន៍សូចនាករពិនិត្យរួមគ្នា ដែលបានឯកភាពគ្នាក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ នាថ្ងៃទី៦-៧ ខែធ្នូ ឆ្នាំ២០០៤ ត្រូវបានរៀបរាប់ដោយសង្ខេបដូចខាងក្រោមនេះ ។

### ៤.១- ការប្រឆាំងអំពើពុករលួយ និងការបង្កើនគណនេយ្យភាព

៤៤- សូចនាករពិនិត្យរួមគ្នាដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ មាន :

ក- អនុលោមតាមច្បាប់ព្រហ្មទណ្ឌដែលនៅមានជាធរមាន ករណីពុករលួយដែលត្រូវបានរកឃើញ និងត្រូវបញ្ជូនទៅតុលាការ ។ ការចាត់វិធានការប្រឆាំងករណីអំពើពុករលួយនឹងត្រូវអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច ដោយប្រើប្រាស់យុទ្ធសាស្ត្រដែលមានលក្ខណៈច្បាស់លាស់ និងមានសង្គតិភាព ។ ត្រូវប្រមែប្រមូលព័ត៌មានសំរាប់តាមដានវឌ្ឍនភាពក្នុងវិស័យនេះ ។

ខ- សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយមានលក្ខណៈស្របតាមនិយាមអន្តរជាតិ ដូចមាននៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ ។

គ- រាជរដ្ឋាភិបាលនឹងចាប់ផ្តើមរៀបចំក្របខ័ណ្ឌច្បាប់ ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋមានសិទ្ធិទទួលព័ត៌មានដែលទាក់ទងនឹងអំណាចសាធារណៈ (ដូចជាច្បាប់ស្តីពីសេរីភាពទទួលព័ត៌មាន) ។ ស្របពេលជាមួយនេះ អាជ្ញាធរសាធារណៈត្រូវកែប្រែទំលាប់អនុវត្តន៍ការងាររបស់ខ្លួន ដើម្បីចែករំលែកព័ត៌មានជាមួយសាធារណជននិងស្ថាប័ននៃរាជរដ្ឋាភិបាល ។ ក្រុមការងារបច្ចេកទេសចំរុះនឹងតាមដាន

វឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករនៅតាមវិស័យការងាររបស់ខ្លួន ។

៤៥- ក្នុងឆ្នាំ២០០៥ យើងមានវឌ្ឍនភាពជាច្រើន ក្នុងការសំរេចសូចនាករពិនិត្យរួមគ្នាទាំង៣នេះ ។ ចំពោះសូចនាករពិនិត្យរួមគ្នាទី១ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានចាត់តាំងក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍ករណីអំពើពុករលួយ ។ ក្រសួងនេះបានផ្តល់របាយការណ៍លំអិត នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសំរបសំរួលរវាងរដ្ឋាភិបាលនិងដៃគូ អភិវឌ្ឍន៍ អំពីករណីបាត់ស្បៀងពលកម្ម ករណីអំពើពុករលួយក្នុងប្រព័ន្ធតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជីជាដើម ។

៤៦- បន្ទាប់ពីមានការពិភាក្សាដ៏ទូលំទូលាយមក និងកែសំរួលតាមធាតុចូលពីភាគីពាក់ព័ន្ធមក ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាស្ថាប័នទទួលខុសត្រូវរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ក៏បានស្នើសេចក្តីព្រាងច្បាប់នេះ ជូនគណៈរដ្ឋមន្ត្រី ។ ដំណើរការនៃការពិគ្រោះយោបល់ក្នុងឆ្នាំ ២០០៥ សំរាប់រៀបចំសេចក្តីព្រាងច្បាប់នេះ រួមមាន ÷

- បង្កើតអនុក្រុមការងារនៃក្រុមការងារបច្ចេកទេស «កំណែទំរង់ច្បាប់និងតុលាការ» ដែលដឹកនាំដោយប្រធានគណៈកម្មាធិការប្រឆាំងអំពើពុករលួយ ។ សមាជិកក្រុមការងារនេះ រួមមានតំណាងរាជរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ គឺ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងគំរោងការពារក្តីកម្ពុជា ។ អ្នកជំនាញការអន្តរជាតិមួយចំនួនក៏បានចូលរួមក្នុងការរៀបចំសេចក្តីព្រាងច្បាប់នេះផងដែរ ។
- ផ្អែកលើធាតុចូល សេចក្តីព្រាងច្បាប់ក៏បានត្រូវពិនិត្យ និងកែសំរួលឡើងវិញ ហើយត្រូវបានលើកបង្ហាញនៅក្នុងសិក្ខាសាលា ២ ថ្ងៃ នាថ្ងៃទី១៧-១៨ ខែសីហា ឆ្នាំ២០០៥ នៅរាជធានីភ្នំពេញ ដោយមានការចូលរួមពីគ្រប់ភាគីទាំងអស់ ។
- បន្ទាប់ពីសិក្ខាសាលានេះ ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក៏បានកែសំរួលសេចក្តីព្រាងច្បាប់នេះឡើងវិញ ហើយបានស្នើជូនក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៥ ។ ឯកសារពង្រាងនេះក៏បានការឯកភាពពីក្រុមប្រឹក្សាអ្នកច្បាប់ នាថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ ។ បន្ទាប់ពីការយល់ព្រមពីក្រុមប្រឹក្សាអ្នកច្បាប់ សេចក្តីព្រាងនេះនឹងត្រូវស្នើជូនគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសំរេច ។
- សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ បានបញ្ចូលនូវបណ្តាគោលការណ៍សំខាន់ៗនៃអនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ និងឯកសារពាក់ព័ន្ធដទៃទៀត ។

៤៧- ចំពោះសូចនាករពិនិត្យរួមគ្នាទី៣ យើងបានអនុវត្តសកម្មភាពជាក់លាក់មួយចំនួនក្នុងឆ្នាំ២០០៥ ដើម្បីឱ្យអាជ្ញាធរសាធារណៈបានផ្តល់ព័ត៌មានជាសាធារណៈ ដូចជា ÷

- នាយកដ្ឋានជលផលបានបើកការដេញថ្លៃឡូត៍នេសាទជាសាធារណៈ ។

- ក្រសួងកសិកម្មបានចាប់ផ្តើមផ្តល់ព័ត៌មានស្តីពីដីសម្បទានសេដ្ឋកិច្ច ។ ផ្នែកទី ១ នៃព័ត៌មានរួមមាន ឈ្មោះក្រុមហ៊ុនសម្បទានដែលបានចុះកិច្ចព្រមព្រៀង ឬដែលកំពុងដំណើរការរៀបចំកិច្ចព្រមព្រៀង សំរាប់ចុះហត្ថលេខាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ព័ត៌មានលំអិតបន្ថែមដែល ពាក់ព័ន្ធនឹងដីសម្បទាន នឹងផ្តល់ជូនតាមរយៈ Website នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅក្នុងត្រីមាសទី២ ឆ្នាំ២០០៦ ។
- ព័ត៌មានស្តីពីការពិនិត្យព្រៃសម្បទានឡើងវិញ ត្រូវបានតំកល់នៅអង្គភាពកិច្ចការសាធារណៈនៃ រដ្ឋបាលព្រៃឈើ ។

## ៤.២- កំណែទំរង់ប្រព័ន្ធតុលាការនិងយុត្តិធម៌ និងការពារសិទ្ធិមនុស្ស

៤៨- នៅកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ស្ទួចនាករពិនិត្យរួមគ្នាបានឯកភាពគ្នា មានដូចតទៅ÷

- ក្របខ័ណ្ឌគតិយុត្តិជាមូលដ្ឋាន : សេចក្តីព្រាងច្បាប់ចំនួន៨ ត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី និង បញ្ជូនទៅរដ្ឋសភា ដោយចាត់ទុកថាជាការប្រញាប់÷
  - ក- ក្រមព្រហ្មទ័ណ្ឌ
  - ខ- ក្រមស្តីពីនីតិវិធីព្រហ្មទ័ណ្ឌ
  - គ- ក្រមរដ្ឋប្បវេណី
  - ឃ- ក្រមស្តីពីនីតិវិធីរដ្ឋប្បវេណី
  - ង- ច្បាប់អង្គការស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គតុលាការ
  - ច- វិសោធនកម្មលើច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សាអង្គចៅក្រម (រួមបញ្ចូលការតែងតាំង ការតំលើង ឋានៈ ការផ្លាស់ប្តូរ លាភការណ៍ និងវិន័យរបស់ចៅក្រម ព្រមទាំងការធានាឯករាជ្យភាពរបស់ ចៅក្រម និងព្រះរាជអាជ្ញា) - អនុវត្តបន្តពីលើកមុន
  - ឆ- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា – អនុវត្តបន្តពីលើកមុន
  - ជ- ច្បាប់ប្រឆាំងអំពើពុករលួយ – អនុវត្តបន្តពីលើកមុន ។

៤៩- ក្នុងឆ្នាំ២០០៥ យើងមានវឌ្ឍនភាពជាច្រើនក្នុងការរៀបចំសេចក្តីព្រាងច្បាប់ទាំងនេះ ។ សរុបរួម ក្នុង ឆ្នាំ២០០៥ ច្បាប់ចំនួន៤៥បានអនុមត័ដោយរដ្ឋសភារួចហើយ ធៀបនឹងច្បាប់ចំនួន៩០ប៉ុណ្ណោះ ដែលបាន អនុម័តក្នុងរយៈពេល៥ ឆ្នាំ១៩៩៣-១៩៩៨កន្លងមក ។ ទន្ទឹមនេះ ក៏មានច្បាប់មួយចំនួនទៀតដែរ ដែល ត្រូវបានស្នើជូនរដ្ឋសភាក្នុងឆ្នាំ២០០៥នេះ ហើយនៅកំពុងរង់ចាំការអនុមត័នៅឡើយ ។ រាជរដ្ឋាភិបាល ស្នើដល់ភាគីពាក់ព័ន្ធទាំងអស់ សូមយកចិត្តទុកដាក់អំពីកត្តភាពក្នុងការកំណត់កាលបរិច្ឆេទនៃការរៀបចំ បញ្ចប់សេចក្តីព្រាងច្បាប់នានា ដោយត្រូវយកចិត្តអំពីសមត្ថភាពរបស់ក្រសួងពាក់ព័ន្ធ និងធនធានដែល មាន ក៏ដូចជាភាពស្មុគស្មាញនៃកិច្ចដំណើរការពិនិត្យ និងអនុមតិសេចក្តីព្រាងច្បាប់ពីស្ថាប័នប្រតិបត្តិ និងនីតិបញ្ញត្តិផងដែរ ។ សេចក្តីព្រាងច្បាប់ទាំងនេះកំពុងស្ថិតនៅក្នុងដំណាក់កាលដូចខាងក្រោមនេះ÷

- នីតិវិធីនៃក្រមព្រហ្មទ័ណ្ឌត្រូវបានពិនិត្យឡើងវិញក្នុងកិច្ចប្រជុំអន្តរក្រសួង ហើយសង្ឃឹមថានឹង បញ្ចប់នាចុងខែកុម្ភៈ ឆ្នាំ២០០៦ ។
- ក្រមព្រហ្មទ័ណ្ឌ ត្រូវបានពិនិត្យឡើងដោយក្រុមប្រឹក្សាអ្នកច្បាប់ មុននឹងដាក់ស្នើក្នុងកិច្ចប្រជុំអន្តរក្រសួង ។
- ច្បាប់រដ្ឋប្បវេណីកំពុងពិនិត្យឡើងវិញដោយអង្គប្រជុំអន្តរក្រសួង ។
- នីតិវិធីនៃក្រមរដ្ឋប្បវេណីកំពុងពិនិត្យឡើងវិញដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ហើយក៏មានកម្មវិធីសំរាប់កិច្ចពិភាក្សាពេញអង្គរបស់រដ្ឋសភា ។
- ច្បាប់អង្គការស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គតុលាការក៏កំពុងពិនិត្យឡើងវិញ ដោយក្រុមការងាររបស់ក្រសួងយុត្តិធម៌ ។
- ច្បាប់វិសោធនកម្មស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏បានព្រាងរួចហើយ ហើយត្រូវបានពិនិត្យឡើងវិញដោយក្រុមប្រឹក្សាអ្នកច្បាប់ ។ ក្រុមការងាររបស់ក្រសួងយុត្តិធម៌ កំពុងពិនិត្យ បញ្ចប់សេចក្តីព្រាងច្បាប់នេះ ។
- ច្បាប់និងលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ក៏ត្រូវបានព្រាង និងបានពិនិត្យឡើងវិញដោយក្រុមប្រឹក្សាអ្នកច្បាប់ ។ បច្ចុប្បន្ននេះ ក្រុមការងាររបស់ក្រសួងយុត្តិធម៌ កំពុងពិនិត្យបញ្ចប់សេចក្តីព្រាងច្បាប់នេះ ។

## ៤.៣- កំណែទំរង់រដ្ឋបាលសាធារណៈ

៥០- នៅកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ សូចនាករពិនិត្យរួមគ្នាបានឯកភាពគ្នា មានដូចតទៅ ÷

ក- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ស្តីពីយុទ្ធសាស្រ្តលុបចោល នូវទំលាប់របស់អ្នកផ្តល់ជំនួយសំរាប់ផ្តល់ប្រាក់បៀវត្សបន្ថែម និងបង្វែរហិរញ្ញប្បទាននេះ សំរាប់គាំទ្រកំណែទំរង់ប្រាក់បៀវត្សក្នុងផ្នែកអាទិភាព នៅខែមិថុនា ឆ្នាំ២០០៥ (យោងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម និង NPAR ផ្នែក ២.១.៣) ។

ខ- គណៈរដ្ឋមន្ត្រីអនុម័តនៅខែវិច្ឆិកាឆ្នាំ២០០៥ សំរាប់អនុវត្តក្នុងខែមករាឆ្នាំ២០០៧ និងរៀបចំផែនការលាភការរយៈពេលមធ្យមរបស់មន្ត្រីរាជការស៊ីវិល ដើម្បីកែលំអប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិលក្នុងកំរិតសមស្រប ដែលអាចទាក់ទាញ និងរក្សាមន្ត្រីមានទេពកោសល្យ ។ ផែនការត្រូវមានភាពរលូនក្នុងចំណោមស្ថាប័នរដ្ឋ និងត្រូវធានាចីរភាព និងត្រូវមានសង្គតិភាពជាមួយនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ។(យោង NPAR ផ្នែក ២.១.១ និង ២.១.៣ និង ៥.១ និងផែនការសកម្មភាព PFM វិធានការ ២.៣ និង ២.៤) ។

គ- ការអនុវត្តន៍សាកល្បងនូវកំណែទំរង់ការងារនិងប្រាក់បៀវត្ស ដែលមានសង្គតិភាពពេញលេញជាមួយគ្នាទៅវិញទៅមក និងការអនុវត្តន៍ការលើកទឹកចិត្ត និងសមត្ថភាពប្រកបដោយវិជ្ជាជីវៈ នៅក្នុងវិស័យ៣យ៉ាងតិច នៅក្នុងឆ្នាំ២០០៦ ។

ឃ- កាត់បន្ថយជាបណ្តើរៗការបើកប្រាក់បៀវត្សសាច់ប្រាក់ តាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារ និងការផ្ទេរអេឡិចត្រូនិច ។ ការរៀបចំប៉ារ៉ាម៉ែត្រ និងការរៀបចំគំរោងសាកល្បងសំរាប់បើកប្រាក់បៀវត្សតាមរយៈការផ្ទេរអេឡិចត្រូនិចនៅធនាគារ ត្រូវបញ្ចប់នៅខែវិច្ឆិកា ឆ្នាំ២០០៥ ។ (យោងផ្នែក ២.១.២ និង ផែនការសកម្មភាព PFM ៧.១២)។

ង- គោលនយោបាយស្តីពីធនធានមនុស្សដោយផ្អែកតាមទេពកោសល្យ និងផែនការអនុវត្តលំអិតនឹងត្រូវអនុមតិដោយគណៈរដ្ឋមន្ត្រី ។

៥១- ក្នុងឆ្នាំ២០០៥ យើងមានវឌ្ឍនភាពជាច្រើន ក្នុងការអនុវត្តន៍សូចនាករទាំង៥នៃផ្នែកនេះ ។ ចំពោះសូចនាករទី១ បន្ទាប់ពីមានការពិគ្រោះជាច្រើន យុទ្ធសាស្ត្រត្រូវបានរៀបចំឡើងបញ្ចប់ ហើយត្រូវបានអនុមតិដោយក្រុមការងារក្នុងអង្គប្រជុំរបស់ខ្លួន កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ ការអនុវត្តន៍យុទ្ធសាស្ត្របានចាប់ផ្តើមអនុវត្ត ពីថ្ងៃទី២៧ ខែមករា ដោយបានផ្ញើរសំណួរស្តីពីព័ត៌មានមួយចំនួន ទៅឱ្យដៃគូអភិវឌ្ឍន៍ ដោយតំរូវឱ្យពួកគេឆ្លើយតបមកវិញ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ ។ ស្នូលនៃយុទ្ធសាស្ត្រនេះបានផ្តោតទៅលើការអនុវត្តន៍ PMGs និង PMG/MBPIs នៅតាមវិស័យ ព្រមទាំងបានបំពេញបន្ថែមទំរង់បែបបទមួយចំនួន ដើម្បីបង្កើនតម្លាភាព និងសុខដុមនីយកម្ម ។

៥២- ចំពោះសូចនាករទី២ របបលាភការដែលផ្តោតលើប្រសិទ្ធភាពត្រូវបានដាក់ឱ្យអនុវត្ត ចាប់តាំងពីឆ្នាំ ២០០២ មកម្ល៉េះ ។ កំណែទំរង់នេះត្រូវតែមានចីរភាព ហើយត្រូវពឹងផ្អែកទៅលើប្រភពចំណូលរបស់រាជ រដ្ឋាភិបាល ។ អភិក្រមរបស់រាជរដ្ឋាភិបាលក្នុងកិច្ចការនេះ ត្រូវបានផ្តោតលើភារកិច្ចអាទិភាពមួយចំនួន (ការគ្រប់គ្រង អប់រំ សុខាភិបាល) និង PMGs ទន្ទឹមនឹងការខិតខំប្រឹងប្រែងបង្កើនប្រាក់បៀវត្សជា មូលដ្ឋាន តាមការដែលអាចធ្វើទៅបាន ។ លាភការត្រូវបានកើនឡើងចំនួន ១១៦% ចាប់តាំងពីខែមករា ឆ្នាំ២០០២មក ។ ប្រាក់បំណាច់ផ្សេងៗទៀតនឹងត្រូវអនុវត្តក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីកាត់បន្ថយ ហានភ័យ ។ ទន្ទឹមនេះក៏កំពុងស្វែងយល់អំពីវិធីសាស្ត្រ និងមធ្យោបាយក្នុងការបង្កើនល្បឿន តាមរយៈ ការសិក្សាលើប្រព័ន្ធលាភការ ការប្រើប្រាស់ និងទីផ្សារពលកម្ម ដែលគ្រោងបញ្ចប់នាខែមិថុនា ឆ្នាំ២០០៦ ខាងមុខនេះ សំរាប់ជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យម ។

៥៣- ចំពោះសូចនាករទី៣វិញ យើងមានវឌ្ឍនភាពលើសពីការអនុវត្តន៍សាកល្បងនូវអនុក្រឹត្យលេខ៩៨ ទៅទៀត ដោយអនុញ្ញាតិឱ្យអនុវត្តនៅក្នុងរដ្ឋបាលទាំងមូលតែម្តង ។ PMGs និង PMG/MBPIs កំពុងត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ។ PMGs និង PMG/MBPIs លើកទី១ ត្រូវបានអនុវត្តសំរាប់គាំទ្រដល់កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយកំពុងត្រូវបានពង្រីកបន្ថែមទៀត សំរាប់គាំទ្រដល់ការកំណែទំរង់នៅក្នុងវិស័យដីធ្លី ពាណិជ្ជកម្ម និងសុខាភិបាល ។ ក្រសួង និងស្ថាប័នជាង ១០ បានចូលរួមក្នុងកិច្ចការនេះកន្លងមក ។

៥៤- ចំពោះសូចនាករទី៤វិញ សកម្មភាពទាំងឡាយត្រូវនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ ដែលកំពុងមានវឌ្ឍនភាពល្អប្រសើរ ។

៥៥- ចំពោះសូចនាករចុងក្រោយ ការគ្រប់គ្រងធនធានមនុស្សកំពុងត្រូវបានដំណើរការ សំរាប់គាំទ្រដល់ការអនុវត្តន៍ប្រព័ន្ធលាភការតាមសមត្ថភាពនិងប្រសិទ្ធភាព ។ សេចក្តីណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្សកំពុងត្រូវបានរៀបចំក្នុងដំណាក់កាលដំបូងនៅឡើយ ។ ផ្អែកតាមលទ្ធផលនៃសិក្ខាសាលា យើងនឹងរៀបចំផែនការមេស្តីពីការគ្រប់គ្រងធនធានមនុស្ស ។ ទន្ទឹមនេះ ក្រុមការងារកំណែទំរង់រដ្ឋបាលក៏បានគ្រោងឱ្យមានកិច្ចពិភាក្សាលើគោលនយោបាយ និងការងារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធាន មនុស្សនាខែមិនា ឆ្នាំ២០០៦ នេះផងដែរ ហើយយន្តការមួយនឹងដាក់ឱ្យអនុវត្ត សំរាប់ត្រួតពិនិត្យកិច្ចដំណើរការនេះ ។

## ៤.៤- វិមជ្ឈការ និងសហវិមជ្ឈការ

៥៦- នៅកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ សូចនាករពិនិត្យរួមគ្នាបានឯកភាពគ្នា មានដូចតទៅ ÷

ក- រៀបចំបញ្ចប់នូវគោលនយោបាយជាតិ ក្របខ័ណ្ឌការងារយុទ្ធសាស្ត្រ និងផែនការសកម្មភាព នៅខែមិនា ឆ្នាំ២០០៥ និងដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីអនុមតិ ។

ខ- រៀបចំសេចក្តីព្រាងច្បាប់អង្គការសំរាប់គ្រប់គ្រងខេត្ត-ក្រុង និងស្រុក នៅក្នុងក្របខ័ណ្ឌការងារយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ សំរាប់ពិគ្រោះយោបល់ ។

៥៧- នៅក្នុងឆ្នាំ២០០៥ យើងមានវឌ្ឍនភាពជាច្រើននៅលើកំណែទំរង់វិមជ្ឈការនិងសហវិមជ្ឈការ ពិសេសលើសូចនាករពិនិត្យរួមគ្នាទាំងពីរនៃវិស័យនេះ ។

៥៨- ចំពោះសូចនាករទី១ សេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់វិមជ្ឈការនិងសហវិមជ្ឈការត្រូវបានរៀបចំ ហើយត្រូវបានពិនិត្យឡើងវិញដោយថ្នាក់ដឹកនាំកំពូលនៃរាជរដ្ឋាភិបាល ។ បន្ទាប់មកទៀត ក៏ត្រូវបានដាក់ឱ្យពិភាក្សានៅក្នុងសិក្ខាសាលាជាតិ ដែលសម្តេច នាយករដ្ឋមន្ត្រី បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ចូលរួមបើកសិក្ខាសាលា ហើយដែលឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំរហូតដល់ពេលចប់សិក្ខាសាលា ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះត្រូវគណៈរដ្ឋមន្ត្រីអនុមតិនាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ កន្លងមក ។

៥៩- ក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់វិមជ្ឈការនិងសហវិមជ្ឈការ បានកំណត់អំពីគោលនយោបាយ និងបណ្តាគោលការណ៍នានា សំរាប់កែសំរួលរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមបណ្តាថ្នាក់រដ្ឋបាលក្រោមថ្នាក់ជាតិ (ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងឃុំ-សង្កាត់) ដែលអាចនាំឱ្យមានការពិនិត្យ និងការកែតំរូវប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ជាតិផងដែរ ។ គោលដៅចំបងនៃយុទ្ធសាស្ត្រនេះ គឺការជំរុញកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រជាធិបតេយ្យ នៅតាមបណ្តាថ្នាក់ក្រោមថ្នាក់ជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការកែលំអការផ្តល់សេវាសាធារណៈនិងកម្មវិធី និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ ឱ្យកាន់តែប្រសើរឡើង ។

៦០- ចំពោះសូចនាករទី២ ការរៀបចំសេចក្តីព្រាងច្បាប់អង្គការបានចាប់ផ្តើមក្នុងឆ្នាំ២០០៥កន្លងមក ។ សេចក្តីព្រាងលើកទី១ នឹងត្រូវបញ្ចប់នាចុងត្រីមាសទី១ឆ្នាំ២០០៦នេះ ហើយនឹងត្រូវដាក់ពិភាក្សាជាមួយគ្រប់ភាគីពាក់ព័ន្ធ រួមទាំងក្រុមការងារចំរុះស្តីពីវិមជ្ឈការនិងវិសហមជ្ឈការ ដែលទើបបានបង្កើតកាលពីខែ វិច្ឆិកា ឆ្នាំ២០០៥ កន្លងមកផងដែរ ។

៦១- វឌ្ឍនភាពមួយទៀតដែលគួរឱ្យមោទនភាពក្នុងការងារវិមជ្ឈការនិងវិសហមជ្ឈការ ហើយដែលត្រូវបានផ្តួចផ្តើមដោយក្រសួងមហាផ្ទៃ តាមរយៈគណៈកម្មាធិការអន្តរក្រសួង គឺការសិក្សាឯករាជ្យ ។ ការសិក្សានេះនឹងផ្តោតទៅលើការប្រៀបធៀបអំពីទំរង់ការនៃផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នានា និងការផ្តល់សេវាសំរាប់គាំទ្រកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ រួមទាំងកម្មវិធីផ្តល់មូលនីធិ ការរៀបចំផ្នែកស្ថាប័នសំរាប់គ្រប់គ្រងមូលនីធិ និងយន្តការហិរញ្ញប្បទាន ព្រមទាំងកម្មវិធីសិលាផងដែរ ។

៦២- ការសិក្សាឯករាជ្យ ដែលគ្រោងបញ្ចប់នាចុងត្រីមាសទី១ ឆ្នាំ២០០៦ នេះ តាមរយៈការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ នឹងអាចផ្តល់ធាតុចូលជាច្រើន សំរាប់កែលំអកិច្ចសហប្រតិបត្តិការ និងបង្កើនការយល់ដឹងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ទៅលើវិធីសាស្រ្ត ទំរង់ការ និងយន្តការ សំរាប់ធានាឱ្យមានការគាំទ្ររយៈពេលវែងពីដៃគូអភិវឌ្ឍន៍ សំរាប់ពង្រឹងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រជាធិបតេយ្យ នៅតាមបណ្តាថ្នាក់ក្រោមថ្នាក់ជាតិ ។

### ៤.៥- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៦៣- នៅកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ សូចនាករពិនិត្យរួមគ្នាបានឯកភាពគ្នា គឺការអនុវត្តរបៀបវារៈ សំរាប់ ១២ ខែដំបូងនៃកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

៦៤- កម្មវិធីកំណែទំរង់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងត្រូវបានអនុវត្តប្រកបដោយជោគជ័យ ដើម្បីឈានទៅសំរេចផែនការសកម្មភាពសំរាប់រយៈពេល១២ខែដំបូងរបស់ខ្លួន ។ ទោះបីជាកម្មវិធីកំណែទំរង់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងថិតក្នុងដំណាក់កាលដំបូងនៃការអនុវត្តន៍ក៏ដោយ ក៏វឌ្ឍនភាពនៃឆ្នាំដំបូងបានផ្តល់លទ្ធផលល្អប្រសើរ ដែលបានជះឥទ្ធិពលជាវិជ្ជមានដល់ការបង្កើនចំណូលក្នុងស្រុកនៅឆ្នាំ២០០៥ ។ វឌ្ឍនភាពជាដុំកំភួនក៏បានរំលេចនៅក្នុងផ្នែកជាច្រើន ដូចជានៅក្នុងការប្រែប្រួលខាងការគ្រប់គ្រង (ពិសេស ការប្រែប្រួលខាងផ្នែកស្ថាប័ន និងការពង្រឹងភាពជាម្ចាស់ និងការទទួលខុសត្រូវ) កាបង្កើនសមត្ថភាព ការគ្រប់គ្រងសារពើពន្ធ និងការប៉ាន់ស្មានក្នុងក៏រិតម៉ាក្រូ ការរៀបចំថវិកា និងការអនុវត្តន៍ទំរង់ការស្តីពីលទ្ធកម្ម សវនករផ្ទៃក្នុង ការគ្រប់គ្រងសាច់ប្រាក់ និងការកែលំអការប្រមូលចំណូល ពន្ធ និងមិនមែនពន្ធ ។

៦៥- នៅក្នុងឆ្នាំ២០០៥ កម្មវិធីកំណែទំរង់នេះគ្រោងអនុវត្តសកម្មភាព២៧ ដែលបែងចែកជា ២៥៤អនុសកម្មភាព សំរាប់អនុវត្តក្នុងដំណាក់កាលទី១ ។ ក្នុងចំណោមអនុសកម្មភាពទាំង២៥៤នេះ សកម្មភាពចំនួន

២២៤ ត្រូវបានគ្រោងអនុវត្ត ក្នុងឆ្នាំ២០០៥ ។ សកម្មភាពចំនួន២០៨ត្រូវបានអនុវត្តតាមកាលបរិច្ឆេទកំណត់ រីឯសកម្មភាពចំនួន១៦ទៀត ស្មើនឹង៧% ត្រូវបានពន្យារការអនុវត្តន៍ ។ ក្នុងចំណោមបណ្តាសកម្មភាព ដែលគ្រោងអនុវត្ត សកម្មភាពចំនួន៣៥ ស្មើនឹង១៦% ត្រូវបានអនុវត្តចប់ជាស្ថាពរ ហើយកំពុងអនុវត្ត បន្តសកម្មភាពចំនួន១៧៣ទៀត (៧៧%) រហូតដល់ដំណាច់ឆ្នាំ២០០៥ ។ ក្នុងបណ្តាសកម្មភាពដែល កំពុងអនុវត្ត សកម្មភាពចំនួន២៥ ត្រូវបានវាយតំលៃថាវឌ្ឍនភាពស្ថិតនៅក្រោមការរំពឹងទុក ។ មូលហេតុ មួយក្នុងការពន្យាពេលអនុវត្ត គឺ លំដាប់លំដោយនៃបណ្តាសកម្មភាព លក្ខណៈអន្តរវិស័យនៃសកម្មភាព ខ្លះ ហើយដែលទាមទារឱ្យកិច្ចសហការរវាងនាយកដ្ឋានជាច្រើន ព្រមទាំងកិច្ចសហការពីតួអង្គសំខាន់ៗ ក្នុងកិច្ច ការទាំងនេះ ។

៦៦- ដោយសារភាពស្មុគស្មាញនៃកំណែទំរង់ កម្មវិធីត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយផ្អែកតាមក្របខ័ណ្ឌ គ្រប់គ្រងមួយ ដែលរួមបញ្ចូលនូវសូចនាករសំរាប់វាស់ស្ទង់ ហើយត្រូវវាយតំលៃប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ ក្នុងក្រុមការងារចំរុះស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការកំណែទំរង់ មួយត្រូវបានបង្កើតឡើង សំរាប់ដឹកនាំ និងសំរបសំរួលកិច្ចការក្នុងរាជរដ្ឋាភិបាល និងជាមួយបណ្តាដៃគូ អភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានជួបជុំគ្នាជាទៀងរាល់ខែ ហើយក្រុមការងារចំរុះស្តីពីការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានជួបជុំគ្នាទៀងរាល់ត្រីមាស ។ បច្ចុប្បន្ននេះ កម្មវិធីស្តីពីការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈនេះនឹងត្រូវពិនិត្យនិងកែសំរួល ពីរដងក្នុងមួយឆ្នាំ ដោយក្រុមការងារចំរុះ និងតាម រយៈការវាយតំលៃឯករាជ្យពីខាងក្រៅ ។ ការត្រួតពិនិត្យប្រចាំឆ្នាំលើកទី១ កំពុងត្រូវបានអនុវត្ត ដើម្បីវាយ តំលៃអំពីវឌ្ឍនភាព និងបញ្ហាប្រឈម ពិនិត្យឡើងវិញអំពីផែនការសកម្មភាព និងសូចនាករសំរាប់ វាស់ស្ទង់ ព្រមទាំងត្រួតពិនិត្យអំពីលទ្ធផលនៃការអនុវត្តន៍ស្តីពីការផ្តួចផ្តើមគំនិតនៃការផ្តល់ប្រាក់បៀវត្ស តាមសមត្ថភាព (MBPI) ហើយនឹងឯកភាពលើផែនការសកម្មភាព សូចនាករសំរាប់វាស់ស្ទង់ ការរៀបចំ អនុវត្តន៍ការផ្តល់ប្រាក់បៀវត្សតាមសមត្ថភាព (MBPI) សំរាប់ដំណាក់កាលទី២ ដែលគ្រោងបញ្ចប់នាចុង ខែមិនា ឆ្នាំ២០០៦ នេះ ។

## ៤.៦- អន្តរវិស័យសំរាប់កសិកម្មនិងការគ្រប់គ្រងធនធានធម្មជាតិ

៦៧- នៅកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ សូចនាករពិនិត្យរួមគ្នាបានឯកភាពគ្នា មានដូចតទៅ÷

ក- ដាក់អោយប្រើច្បាប់និងអនុក្រឹត្យ សំរាប់គ្រប់គ្រងធនធានធម្មជាតិ រួមមាន ÷ ច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីសហគមន៍នេសាទ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យស្តីពីដីសម្បទាន សេដ្ឋកិច្ច និងការជំរុញអនុវត្តន៍មាត្រាទី១៨នៃច្បាប់ភូមិបាល ។ ការលក់ដូរដីរដ្ឋជាលក្ខណៈឯកជន គឺជាទង្វើខុសច្បាប់ ហើយមិនត្រូវទទួលស្គាល់ជាផ្លូវការពីមន្ត្រីមានសមត្ថកិច្ចឡើយ ។ រៀបចំរួមគ្នា យុទ្ធសាស្ត្ររយៈពេលមធ្យមសំរាប់វិស័យកសិកម្ម រួមទាំងការស្រោចស្រព នាខែមិនាឆ្នាំ២០០៥ ហើយត្រូវចប់សព្វគ្រប់ក្នុងខែធ្នូ ឆ្នាំ ២០០៥ ។

ខ- បន្តផ្អាកកាប់ឈើ ដឹកជញ្ជូនឈើ (លើកលែងតែបានធ្វើបញ្ជីសារពើភ័ណ្ឌ និងបានបង់ពន្ធគ្រប់

ចំនួន) និងផ្អាកការផ្តល់ដីសម្បទានសេដ្ឋកិច្ច រហូតដល់ពេលបញ្ចប់ដំណើរការពិនិត្យវាយតំលៃឡើងវិញ និង/ឬ ក្របខ័ណ្ឌច្បាប់ ។

គ- បង្កើនតំលាភាពក្នុងការគ្រប់គ្រងរដ្ឋលើធនធានធម្មជាតិ តាមរយៈការផ្តល់ព័ត៌មានជាសាធារណៈនូវកិច្ចសន្យា និងភាពត្រឹមត្រូវនៃកិច្ចសន្យាដែលកំពុងអនុវត្ត (ទឹកប្រាក់ដែលត្រូវផ្តល់ឱ្យ និងការផ្គត់ផ្គង់សំខាន់ផ្សេងៗទៀត) ដូចជា កិច្ចសន្យាគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការធ្វើសម្បទានក្នុងការធ្វើអាជីវកម្មរ៉ែ ឡូត៍នេសាទ និងស្ថានភាពនៃការត្រួតពិនិត្យវាយតំលៃសម្បទានព្រៃឈើ ។

ឃ- អនុវត្តផែនការគ្រប់គ្រងប្រកបដោយចិរភាព រួមមាន ESIAs ការវាយតំលៃរបស់អ្នកវិនិយោគ ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ការផ្តល់ព័ត៌មានជាសាធារណៈ និងរយៈពេលនៃការផ្តល់អនុសាសន៍ មុនពេលកិច្ចសន្យាថ្មីស្តីពីការប្រើប្រាស់/ការគ្រប់គ្រងធនធានធម្មជាតិរដ្ឋដោយឯកជនត្រូវចូលជាធរមាន (ដី នេសាទ ព្រៃ ឈើ និងរ៉ែ) ។

ង- រាជរដ្ឋាភិបាលផ្តល់ព័ត៌មានស្តីពីដំណើរការ និងគតិយុត្តិ ក្នុងការបញ្ចប់កិច្ចសន្យាអាជីវកម្មរ៉ែ តំបន់អភិវឌ្ឍន៍យោធា ដីសម្បទានសេដ្ឋកិច្ច និងការរៀបចំផ្សេងៗទៀតសំរាប់ការអភិវឌ្ឍន៍ក្នុងតំបន់ព្រៃឈើ ឬតំបន់ការពារ ហើយដែលមិនសមស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងតំបន់ទាំងនោះ ។

៦៨- បន្ទាប់កិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកចុងក្រោយ យើងមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ក្នុងការអនុវត្តន៍សូចនាករពិនិត្យរួមគ្នានៅក្នុងវិស័យ ។ ក្រុមការងារបច្ចេកទេសចំរុះនៅក្នុងវិស័យទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តន៍កំណែទំរង់នេះ ហើយក៏បានប្រឹងប្រែងអនុវត្តតាមគោលការណ៍គណនេយ្យភាពទ្វេរទិស ក្នុងការងាររបស់ពួកគេដែរ ។

៦៩- វឌ្ឍនភាពនៃការអនុវត្តន៍ធៀបនឹងសូចនាករពិនិត្យរួមគ្នាទី១ រួមមាន ÷

- រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍លើគោលនយោបាយជាតិស្តីពីវិស័យជលផល កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ ។
- ការរៀបចំសេចក្តីព្រាងច្បាប់ជលផល ហើយបានបញ្ជូនទៅរដ្ឋសភា ។
- ព្រះរាជក្រឹត្យស្តីពីសហគមន៍ជលផល ត្រូវបានឡាយព្រះហត្ថលេខាដោយព្រះមហាក្សត្រ កាលពីថ្ងៃទី២៩ខែឧសភាឆ្នាំ២០០៥ ។ អនុក្រឹត្យត្រូវបានចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី១០ខែមិថុនាឆ្នាំ២០០៥ ។ នាយកដ្ឋានជលផលបានរៀបចំកិច្ចប្រជុំ នាខែកក្កដា ឆ្នាំ២០០៥ ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនិងការិយាល័យជលផលខេត្ត-ក្រុង ដើម្បីផ្សព្វផ្សាយព្រះ រាជក្រឹត្យ និងអនុក្រឹត្យទាំងនេះ ។
- ការិយាល័យជលផលខេត្ត-ក្រុងកំពុងធ្វើការផ្សព្វផ្សាយព័ត៌មាន ស្តីពីព្រះរាជក្រឹត្យនិងអនុក្រឹត្យ នេះនៅថ្នាក់សហគមន៍ ។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងដីសម្បទានសង្គម ត្រូវបានអនុមតិរួចហើយ ហើយកំពុងដំណើរការអនុវត្ត ។ គណៈរដ្ឋមន្ត្រីកំពុងពិនិត្យអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច ហើយរំពឹងថា នឹងអនុមតិ

នាពេលឆាប់ៗខាងមុខនេះ ។ ការពិភាក្សាស្ដីពីការអនុវត្តន៍មាត្រាទី១៨នៃច្បាប់ភូមិបាល កំពុងអនុវត្តបន្ត ។

៧០- ចំពោះសូចនាករពិនិត្យរួមគ្នាស្ដីពីការបន្តផ្អាកកាប់ឈើ និងដឹកជញ្ជូនឈើ ក្រុមការងារបច្ចេកទេសចំរុះខាងព្រៃឈើនិងបរិស្ថាន បានរាយការណ៍ជូនគណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ថា ក្រុមការងារបានសំរេចបណ្ដាគោលដៅនៃសូចនាករពិនិត្យរួមគ្នានេះរួចហើយ ។ ទន្ទឹមនេះក្រុមការងារក៏បានលើកអំពីការព្រួយបារម្ភផងដែរ អំពីតំរូវការផ្គត់ផ្គង់ឈើសំរាប់ការប្រើប្រាស់ក្នុងស្រុក ដែលបណ្ដាលមកពីការផ្អាកការកាប់ឈើនេះ ។

៧១- ចំពោះសូចនាករពិនិត្យរួមគ្នាស្ដីពីការបង្កើនតំលាភាពក្នុងការគ្រប់គ្រងរដ្ឋលើធនធានធម្មជាតិ ក្រុមការងារបច្ចេកទេសចំរុះខាងព្រៃឈើនិងបរិស្ថានបានរាយការណ៍ ជូនគណៈកម្មាធិការសំរបសំរួលរវាងរាជ-រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ថា ក្រុមការងារបានសំរេចបណ្ដាគោលដៅនៃសូចនាករពិនិត្យរួមគ្នានេះរួចហើយ ។ ក្រុមការងារចំរុះនេះបានរាយការណ៍លំអិតថា ÷

- ព័ត៌មានស្ដីពីការពិនិត្យឡើងវិញសម្បទានព្រៃឈើ ត្រូវបានតំកល់នៅអង្គភាពកិច្ចការសាធារណៈនៃរដ្ឋបាលព្រៃឈើ ។
- នាយកដ្ឋានជលផលបានបើកដំណើរការដេញថ្លៃសំរាប់ឡូតិ៍នេសាទជាសាធារណៈ ។
- ក្រសួងកសិកម្មបានចាប់ផ្ដើមផ្ដល់ព័ត៌មានស្ដីពីដីសម្បទានសេដ្ឋកិច្ច ។ ផ្នែកទី ១ នៃព័ត៌មាន រួមមានឈ្មោះក្រុមហ៊ុនសម្បទាន ដែលបានចុះកិច្ចព្រមព្រៀង ឬដែលកំពុងដំណើរការរៀបចំកិច្ចព្រមព្រៀងសំរាប់ចុះហត្ថលេខាជាមួយក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ។ ព័ត៌មានលំអិតបន្ថែមដែលពាក់ព័ន្ធនឹងដីសម្បទាន នឹងផ្ដល់ជូនតាមរយៈ Website របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងត្រីមាសទី២ ឆ្នាំ២០០៦ ។

៧២- ចំពោះសូចនាករពិនិត្យរួមគ្នាស្ដីពីការអនុវត្តន៍ផែនការគ្រប់គ្រងប្រកបដោយចីរភាព ក្រុមការងារបច្ចេក-ទេសចំរុះស្ដីពីព្រៃឈើនិងបរិស្ថានបានរាយការណ៍ ជូនគណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ថា ក្រុមការងារបានសំរេចបណ្ដាគោលដៅនៃសូចនាករពិនិត្យរួមគ្នានេះរួចហើយ ។ ក្រុមការងារចំរុះនេះបានរាយការណ៍លំអិតថា ÷

ក- ក្រុមការងារកំពុងពិនិត្យផែនការគ្រប់គ្រងប្រកបដោយចីរភាពឡើងវិញ ដើម្បីឱ្យស្របនឹងទំរង់ការដែលមានចែងក្នុងអនុក្រឹត្យ ។

ខ- នាយកដ្ឋានជល ដោយសហការជាមួយនឹងការិយាល័យជលផលខេត្ត-ក្រុង កំពុងអនុវត្តវិធានការមួយចំនួន ដើម្បីលុបបំបាត់បាតុភាពនេសាទខុសច្បាប់ ព្រមទាំងបង្កើនការយល់ដឹងរបស់ប្រជាជនស្ដីពីការការពារធនធានជលផល ។

គ- ចំពោះសហគមន៍នេសាទវិញ បទបញ្ញត្តិនានាកំពុងត្រូវបានអនុវត្ត ។ ចំពោះការអភិរក្សធនធានសមុទ្រ ផែនការសកម្មភាព១០ឆ្នាំសំរាប់គ្រប់គ្រងផ្កាសមុទ្រ និងស្មៅសមុទ្រត្រូវបានរៀបចំបញ្ចប់

រួចហើយ ។

៧៣- ចំពោះសូចនាករពិនិត្យរួមគ្នាទី៥ វឌ្ឍនភាពមានដូចខាងក្រោម ÷

- ដោយបានសហការជាមួយនឹងមន្ទីរកសិកម្មខេត្ត-ក្រុង នាយកដ្ឋានជលផលបាន និងកំពុងចាត់វិធានការបង្ក្រាបសកម្មភាពកាប់ព្រៃលិចទឹក ។ នាយកដ្ឋានក៏បានសហការជាមួយនឹងម្ចាស់ឡូតិ៍នេសាទ ដើម្បីទប់ស្កាត់ការនេសាទខុសច្បាប់នៅក្នុងអំឡុងពេលបិទរដូវនេសាទ ។
- ប៉ុន្តែ ទោះជាមានកិច្ចប្រឹងប្រែងកន្លងមកក៏ដោយ ក៏នៅតែជួបការលំបាកក្នុងការប្រមូលព័ត៌មានពីស្ថាប័ននានា ស្តីពីការអភិវឌ្ឍន៍នៅក្នុងតំបន់ព្រៃឈើ ។

## ៤.៧- ការអភិវឌ្ឍន៍វិស័យឯកជន

៧៤- សូចនាករតាមដានរួមដែលបានព្រមព្រៀងហើយក្នុងវិស័យនេះនាកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ រួមមាន:

ក- រាជរដ្ឋាភិបាលនឹងបង្កើតច្រកចូលតែមួយ ឬ «ច្រកទ្វារតែមួយ» ដែលបង្កលក្ខណៈអោយអាជីវករអាចបំពេញតំរូវការខាងផ្នែកបែបបទ និងឯកសារសំរាប់នាំចូល-នាំចេញ នៅក្នុងអន្តរកម្មធុរៈកិច្ចតែមួយ ។ ពហុអន្តរកម្មធុរៈកិច្ចជាមួយស្ថាប័ននានា នឹងត្រូវជំនួសដោយការចែកចាយព័ត៌មានក្នុងរង្វង់រាជរដ្ឋាភិបាល ។ ការងារទាំងនេះដែលត្រូវអនុវត្តឱ្យសំរេច គឺជាជំហានគន្លឹះមួយ ដែលឈានទៅរកដំណើរការ«ច្រកទ្វារតែមួយជាលក្ខណៈស្វ័យប្រវត្តិ» រួមមាន CED និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ។

ខ- ការកែសំរួលកិច្ចដំណើរការ PPI ក្នុងសេចក្តីព្រាងច្បាប់ស្តីពីសម្បទាន ដែលនឹងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី និងត្រូវដាក់ជូនរដ្ឋសភាពិនិត្យនិងសំរេច នៅក្នុងឆ្នាំ២០០៥ ។ លិខិតបទដ្ឋានស្តីពីការណែនាំអនុវត្តន៍ នឹងត្រូវប្រកាសឱ្យប្រើប្រាស់នៅ ក្នុងខែមិថុនា ឆ្នាំ២០០៥ ។ ចាប់ពីដើមខែ មិថុនា ឆ្នាំ២០០៥ PPI នឹងត្រូវអនុវត្តស្របតាមច្បាប់ ដែលបានដាក់ជូនរដ្ឋសភា និងបទបញ្ញត្តិ នានា ។

គ- គណៈរដ្ឋមន្ត្រីនឹងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសតូចនិងមធ្យម រួមមាន និយមន័យនៃសហគ្រាសតូចនិងមធ្យម ដែលត្រូវកំណត់ដោយគណកម្មាធិការសហគ្រាសតូចនិងមធ្យម នឹងត្រូវដាក់ឱ្យប្រើប្រាស់ក្នុងបណ្តាស្ថាប័ននៃរាជរដ្ឋាភិបាល និងដោយមានកិច្ចសហការនិងការពិគ្រោះយោបល់ ជាមួយក្រសួងជំនាញ និងតំណាងផ្នែកឯកជន ។

ឃ- សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាកណ្តាលពាណិជ្ជកម្ម ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី និងត្រូវដាក់ជូនរដ្ឋសភាពិនិត្យ និងសំរេច ។ ក្នុងពេលអនុវត្តច្បាប់ មជ្ឈមណ្ឌលអាជ្ញាកណ្តាលមួយយ៉ាង តិចដោយមានបុគ្គលិកមានការបណ្តុះបណ្តាល និងបញ្ជីឈ្មោះអាជ្ញាកណ្តាលនឹងត្រូវវាយតំលៃ និងប្រកាសផ្សាយ តាមរយៈការវិនិច្ឆ័យរបស់អាជ្ញាកណ្តាលយ៉ាងតិចពីរ ។

៧៥- ក្រុមការងារបច្ចេកទេសសំរេចបានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ក្នុងការអនុវត្តន៍សូចនាករពិនិត្យរួមគ្នាក្នុងវិស័យនេះ ។ រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជនជាក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ចជាតិ ។ ក្នុងន័យនេះ គោលនយោបាយសំរាប់ជំរុញឱ្យមានការលូតលាស់នៃផ្នែកឯកជន តំរូវឱ្យរាជរដ្ឋាភិបាលដើរតួនាទីជាយុទ្ធសាស្ត្រសំខាន់ ក្នុងការបង្កើតឡើងនូវបរិយាកាសអំណោយផល សំរាប់ការរីកលូតលាស់នៃសហគ្រាសឯកជន និងក្នុងការគ្រប់គ្រងនូវដំណើរការអភិវឌ្ឍន៍នៃវិស័យនេះ ។ ដើម្បីបន្តផ្តល់ការគាំទ្របន្ថែមទៀតដល់យន្តការវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការដឹកនាំការងារសំរាប់កិច្ចអភិវឌ្ឍន៍ផ្នែកឯកជន កាលពីខែកក្កដាឆ្នាំ២០០៤ ។ គណៈកម្មាធិការដឹកនាំការងារសំរាប់អភិវឌ្ឍផ្នែកឯកជនមានអនុគណៈកម្មាធិការបី សំរាប់ជួយការងារតាមវិស័យសំខាន់ៗបី គឺ ÷ ១) អនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ២)អនុគណៈកម្មាធិការសំរួលពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ និង ៣)អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ក្នុង កិច្ចសំរួលពាណិជ្ជកម្ម យុទ្ធសាស្ត្រស្តីពីឯកសាររដ្ឋបាល «ច្រកទ្វារតែមួយ» និងការគ្រប់គ្រងហានិភ័យកំពុងត្រូវបានរៀបចំនាពេលបច្ចុប្បន្ននេះ ដើម្បីបញ្ចប់នាឆ្នាំ២០០៦ ។

៧៦- ផ្អែកតាមអនុសាសន៍នៃវេទិកាលើកទី៨ រវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីប្រកាសលេខ២៩៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការអនុវត្តន៍ពន្ធលើតំលៃបន្ថែមសំរាប់ផ្នែកឧស្សាហកម្មគាំទ្រ និងរោងចក្រចុះកិច្ចសន្យាផ្តល់ផលិតផល និងសេវាសំរាប់រោងចក្រកាត់ដេរសំលៀកបំពាក់ និងស្បែកជើងសំរាប់បំរើឱ្យការនាំចេញ ។ សេចក្តីប្រកាសនេះបានបញ្ជាក់ថា រដ្ឋជាអ្នកទទួលបន្ទុកលើពន្ធនាំចូលវត្ថុធាតុដើមសំរាប់ឧស្សាហកម្មគាំទ្រ និងរោងចក្រស្បែកជើងទាំងនេះ ។ រីឯពន្ធលើតំលៃបន្ថែមសំរាប់សេវាបំរើឱ្យការនាំចេញក៏មានអត្រាសូន្យដែរ ។

៧៧- ចំពោះរោងចក្រ សហគ្រាសដែលឋិតក្រោមរបបពន្ធពិត ហើយដែលបានផ្គត់ផ្គង់លើស ៨០% នៃផលិតផលរបស់ខ្លួនឱ្យរោងចក្រ សហគ្រាសនាំចេញសំលៀកបំពាក់ និងស្បែកជើង ពន្ធលើតំលៃបន្ថែមលើផលិតផលទាំងនេះក៏មានអត្រាសូន្យដែរ ។

៧៨- រាជរដ្ឋាភិបាលបានអនុមតិបទបញ្ញត្តិជាច្រើនដែលពាក់ព័ន្ធនឹងការវិនិយោគឯកជន ដូចជា អនុក្រឹត្យលេខសំរាប់អនុវត្តច្បាប់វិសោធនកម្មច្បាប់វិនិយោគ និងអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត- ក្រុង និងអនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ជាដើម ។

៧៩- ទន្ទឹមនេះ រាជរដ្ឋាភិបាលបានរៀបចំហេដ្ឋារចនាសម្ព័ន្ធច្បាប់ជាគន្លឹះផ្សេងៗទៀត ដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដូចជា ច្បាប់ស្តីពីក្រុមហ៊ុនពាណិជ្ជកម្ម ។ ច្បាប់នេះអាចយកទៅអនុវត្តបាន ដោយមិនចាំបាច់មានអនុក្រឹត្យឡើយ ។ សេចក្តីព្រាងច្បាប់ស្តីពីមូលប័ត្ររដ្ឋ សេចក្តីព្រាងច្បាប់ស្តីពីការបោះផ្សាយ

និងការជួញដូរមូលប័ត្រមហាជន និងសេចក្ដីព្រាងច្បាប់ស្ដីពីធនក្ស័យ នឹងត្រូវដាក់ស្នើជូនគណៈរដ្ឋមន្ត្រីនាពេលដ៏ខ្លីខាងមុខនេះ ។ រីឯសេចក្ដីព្រាងច្បាប់ស្ដីពីប្រតិបត្តិការមានការធានា ត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រីរួចហើយ ។ ក្នុងពេលបច្ចុប្បន្ននេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា កំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីភិតិសន្យា ។

៨០- ចំពោះការអនុវត្តន៍សូចនាករពិនិត្យរួមគ្នាទី១ ស្ដីពីការបង្កើត «ច្រកចេញ-ចូលតែមួយ» ដោយសារភាពស្មុគ្រស្មាញ និងមានលក្ខណៈអន្តរវិស័យ យើងត្រូវការពេលវេលាពិនិត្យពិចារណាបន្ថែមទៀត មុននឹងចាប់ផ្ដើមអនុវត្ត «ឯកសាររដ្ឋបាលតែមួយ-Single Administrative Document» និង «ច្រកចេញ-ចូលតែមួយ» ព្រមទាំងយុទ្ធសាស្ត្រគ្រប់គ្រងហានីភ័យ ។ យើងសង្ឃឹមថា សកម្មភាពទាំងនេះ អាចចាប់ផ្ដើមអនុវត្តក្នុងឆ្នាំ២០០៦ នេះ ។

៨១- រីឯគំរោងស្ដីពីការសំរួលពាណិជ្ជកម្ម និងការប្រណាំងប្រជែង ដែលត្រូវបានផ្ដួចផ្ដើមកន្លងមកដោយរាជរដ្ឋាភិបាល ត្រូវបានបញ្ចូលសមាសភាគជាច្រើន ដែលបានកំណត់អំពីកំណែទំរង់មួយចំនួនដែលត្រូវ អនុវត្ត ។ កំណែទំរង់ទាំងនេះ ដែលត្រូវការគាំទ្រពីបណ្ដាក្រសួងនិងស្ថាប័នជាច្រើន នឹងជះឥទ្ធិពលទៅលើភាគីជាច្រើន ដែលពាក់ព័ន្ធនឹងកិច្ចការរបស់ផ្នែកឯកជន និងរបស់រាជរដ្ឋាភិបាល ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏យើងមានការប្រែប្រួលមួយចំនួនរួចហើយ ពិសេសក្រោយពេលដែលការសិក្សានិងការវាយតំលៃអំពីបរិស្ថានវិនិយោគត្រូវបានបញ្ចប់កាលពីឆ្នាំ២០០៣ រួចមក ។

៨២- លទ្ធផលនៃការធ្វើអង្កេតមួយរបស់ Emergimg Markets Consulting បានបញ្ជាក់ថា ផ្នែកឯកជនបានវាយតំលៃថា រាជរដ្ឋាភិបាលបានកែលំអជាច្រើន ក្នុងការកាត់បន្ថយចំណាយ និងពេលវេលារបស់វិនិយោគិន ព្រមទាំងការចែករំលែកព័ត៌មានផងដែរ ។

៨៣- លើសពីនេះ ក៏មានការថយចុះជាច្រើនអំពីករណីតូញត្អែររបស់ក្រុមហ៊ុនឯកជន លើទំរង់បំពេញឯកសារដែលពាក់ព័ន្ធនឹងការនាំចេញ-នាំចូលរបស់ពួកគេ ។ ក្រុមហ៊ុនប្រមាណ៤៩% បានរាយការណ៍ថាបានជួបការលំបាកក្នុងកិច្ចការនេះ នាឆ្នាំ២០០៣ ហើយតួលេខនេះបានថយចុះមកត្រឹម១៣% ក្នុងឆ្នាំ២០០៥ ។ រីឯចំណាយមធ្យមក្នុងការបំពេញបែបបទនាំចូល បានថយពី ២.៤៧៧ដុល្លារ មកត្រឹមតែ៦៧៣ដុល្លារ ក្នុងឆ្នាំ២០០៥ ហើយចំណាយមធ្យមក្នុងការបំពេញបែបបទនាំចេញក៏បានថយចុះពី៩៤២ដុល្លារ មកត្រឹមតែ៥៩៨ដុល្លារ ក្នុងរយៈពេលដូចគ្នាដែរ ។ រីឯរយៈពេលដែលត្រូវចំណាយសំរាប់កិច្ចការទាំងនេះក្នុងឆ្នាំ២០០៥ ក៏ត្រូវបានកាត់បន្ថយជាច្រើន ប្រមាណ២០% ធៀបនឹងឆ្នាំ២០០៣ ។ ចំពោះការផ្សព្វផ្សាយព័ត៌មានវិញ ក៏មានការវិវត្តន៍ប្រសើរដែរ ព្រោះការធ្វើអង្កេតបានវាយតំលៃថា ៨៤%នៃចំលើយ បានបញ្ជាក់អំពីការយល់ដឹងរបស់ពួកគេ លើសោហ៊ុយចំណាយ ហើយ ៩១% បានដឹងអំពីតំរូវការពេលវេលា ។

៨៤- រីឯសូចនាករទីពីរក្នុងវិស័យនេះវិញ ច្បាប់ស្ដីពីសម្បទានត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តយល់ព្រម កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ ។

៨៥- ទន្ទឹមនេះ ចំពោះសូចនាករទីបីក្នុងវិស័យនេះ ក្របខ័ណ្ឌសំរាប់ការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ ។ សកម្មភាពដែលមាននៅក្នុងផែនការសកម្មភាពដើម្បីអនុវត្តក្របខ័ណ្ឌនេះ មានគោលដៅធ្វើឱ្យសាមញ្ញនូវរាល់បណ្តាបែបបទរដ្ឋបាលនានាដែលទាក់ទងនឹងការបង្កើត និងចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ។

៨៦- ចំពោះសូចនាករទីបួននៃវិស័យនេះ សេចក្តីព្រាងច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្ម កំពុងត្រូវបានពិនិត្យដោយគណៈកម្មាធិការទី៩ នៃរដ្ឋសភា ។

## ៤.៨- យេនឌ័រ ភាពក្រីក្រ និងការប្រយុទ្ធប្រឆាំងជំងឺអេដស៍

៨៧- សូចនាករតាមដានរួមគ្នាដែលបានព្រមព្រៀងនាកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ មាន ÷

ក- បញ្ហាទាំងនេះត្រូវបានចាត់ទុកថាជាបញ្ហារួម ដែលត្រូវបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ៥ ឆ្នាំ២០០៦-២០១០ ។

ខ- សមភាពយេនឌ័រៈ រៀបចំក្របខ័ណ្ឌច្បាប់សំរាប់សមភាពយេនឌ័រ

- ពង្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីហើយនិងដាក់ជូនទៅរដ្ឋសភា និងផែនការការពារមួយត្រូវបានអនុម័ត ។
- ពង្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីហើយបានដាក់ជូនរដ្ឋសភា និងផែនការការពារមួយត្រូវបានអនុម័ត ។

៨៨- ចំពោះសូចនាករតាមដានរួមទីមួយ ដែលបញ្ចូលបញ្ហាអន្តរវិស័យក្នុងការរៀបចំផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ ២០០៦-២០១០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់ទូលំទូលាយជាមួយបណ្តាដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការសង្គមស៊ីវិល ។ បញ្ហាអន្តរវិស័យត្រូវបានលើកបញ្ចូលក្នុងផែនការ ៥ ឆ្នាំលើកនេះ បានលើកច្រើនជាងនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច ៥ ឆ្នាំ ដែលបានរៀបចំកន្លងមក ។

៨៩- ទន្ទឹមនេះ រាជរដ្ឋាភិបាលបានសំរេចនូវគោលដៅនៃសូចនាករតាមដានរួមទីពីរផងដែរ ។ ច្បាប់ស្តីពីការប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ត្រូវបានប្រកាសអោយប្រើ នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ។ យើងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ និងផែនការសកម្មភាព សំរាប់អនុវត្តច្បាប់នេះ។ រីឯសេចក្តីព្រាងច្បាប់ស្តីពីការជួញដូរមនុស្ស និងផ្លូវភេទ ក៏កំពុងត្រូវបានពិនិត្យឡើងវិញដោយក្រសួងយុត្តិធម៌ដែរ ។ ទន្ទឹមនេះ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការពារ និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ត្រូវបានរដ្ឋសភាផ្តល់សច្ចាប័នកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ រួចហើយដែរ ។

## ៤.៩- សុខាភិបាល និង អប់រំ

៩០- សូចនាករតាមដានរួមដែលបានព្រមព្រៀងនាកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧គឺការផ្តល់ថវិកាទាន់ពេលវេលាសំរាប់វិស័យសុខាភិបាលនិងអប់រំដូច ដែលបានព្រមព្រៀងនៅក្នុងផែនការសកម្មភាពនៃកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៩១- ក្នុងឆ្នាំ ២០០៥ វិភាជន៍ថវិកាសំរាប់ក្រសួងសុខាភិបាលជាក់ស្តែងរួមមាន ÷

- នៅថ្នាក់ជាតិ វិភាជន៍ថវិកាសរុបអនុវត្តបាន១៤៧.៧ពាន់លានរៀល ស្មើ៩២%នៃថវិកាគ្រោង ១៦០.៣ពាន់លានរៀល និងត្រូវជា៩៥,៥%នៃថវិកាដែលស្នើដោយក្រសួងសុខាភិបាល (១៥៣,៦ ពាន់លានរៀល) ។ ថវិកាសំរាប់កម្មវិធីជាអាទិភាព អនុវត្តបាន៣០.១ពាន់លានរៀលត្រូវជា ៨១,៣%នៃថវិកាគ្រោង (៣៧ពាន់លានរៀល) ស្មើ៨៣,៥%នៃថវិកាដែលបានស្នើឡើងដោយក្រសួងសុខាភិបាល ។
- សំរាប់ថ្នាក់ខេត្ត-ក្រុង វិភាជន៍ថវិកាសរុប៥១ពាន់លានរៀល ត្រូវជា៦៥%នៃថវិកាគ្រោង ដែលមាន ៧៨.៥ពាន់លានរៀល ។ ថវិកាសំរាប់កម្មវិធីជាអាទិភាព ១១.៧ពាន់លានរៀល ស្មើ៦០,៣% នៃថវិកាគ្រោង ដែលមានចំនួន១៩.៤ ពាន់លានរៀល ។

៩២- ក្នុងរបាយការណ៍សំរាប់គណៈកម្មាធិការសំរបសំរួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក្រសួងសុខាភិបាលកត់សំគាល់ថា ការយឺតយ៉ាវក្នុងការវិភាជន៍ថវិកាសំរាប់ថ្នាក់ខេត្ត-ក្រុង គឺបណ្តាលមកពីសមត្ថភាពនៅមានកំរិតក្នុងការគ្រប់គ្រងថវិការបស់ក្រសួងសុខាភិបាល ពិសេសនៅថ្នាក់ខេត្ត-ក្រុង និងបែបបទស្មុគ្រស្មាញរវាងថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ។ រាជរដ្ឋាភិបាលស្នើឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ដែលគាំទ្រវិស័យសុខាភិបាល សូមផ្តល់អាទិភាពបន្ថែមទៀតដល់ការពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងថវិការបស់ក្រសួងសុខាភិបាល ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ។

៩៣- ចំពោះក្រសួងអប់រំវិញ ថវិកាក្នុងផែនការសកម្មភាពអាទិភាពឆ្នាំ២០០៥មាន៨៦,៧ពាន់លានរៀល ។ រហូតមកថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៦ យើងបានចំណាយជាក់ស្តែង ចំនួន៦១ពាន់លានរៀល ស្មើនឹង៧០,៣% នៃផែនការ ។ ចំណាយទាំងនេះ រួមមាន ÷

- នៅថ្នាក់ជាតិ ចំណាយជាក់ស្តែងមានចំនួន ១៣,៣ពាន់លានរៀល ស្មើនឹង៣៧,៣% នៃថវិកាដែលវិភាជន៍ក្នុងផែនការសកម្មភាពអាទិភាពសំរាប់ថ្នាក់ជាតិ ចំនួន៣៥,៧ពាន់លានរៀល ។
- នៅថ្នាក់ខេត្ត- ក្រុងវិញ ចំណាយជាក់ស្តែងមានចំនួន ៤៧,៧ពាន់លានរៀល ស្មើនឹង៩៣,៥% នៃថវិកាដែលវិភាជន៍ក្នុងផែនការសកម្មភាពអាទិភាពសំរាប់ថ្នាក់ខេត្ត- ក្រុង ចំនួន៥១ពាន់លាន រៀល ។

៩៤- ក្រសួងអប់រំ យុវជន និងកីឡាបានរាយការណ៍ជូនគណៈកម្មាធិការសំរបសំរួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ថា ក្រសួងអប់រំបានកត់សំគាល់អំពីមូលហេតុមួយចំនួននៃការយឺតយ៉ាវ ក្នុងការដកថវិកាសំរាប់

កម្មវិធីអាទិភាព ។ មូលហេតុទាំងនោះមានដូចជា ÷ ការយឺតយ៉ាវក្នុងការស្នើសុំ ការកែលំអបែបបទស្នើសុំ ការអនុវត្តន៍តាមនីតិវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការពន្យារការចាប់ផ្តើមប្រើប្រាស់ថវិកាកម្មវិធីអាទិភាពរហូតដល់បវេសនកាលរៀងរាល់ឆ្នាំ ដែលជាទូទៅនៅខែតុលា ។ ក្រសួងក៏បានបញ្ជាក់ថាក្រសួងត្រូវពិភាក្សាបន្តជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីកែលំអប្រព័ន្ធលំហូរសាច់ប្រាក់ ដោយត្រូវកាត់បន្ថយដំណាក់កាលនៃការបើកថវិកា ។ អាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺការពង្រឹងការរៀបចំផែនការ និងគ្រប់គ្រងថវិកា ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ។ រាជរដ្ឋាភិបាលស្នើឱ្យដៃគូអភិវឌ្ឍន៍ដែលគាំទ្រវិស័យអប់រំ ធ្វើការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់អាទិភាពទៅលើការពង្រឹងសមត្ថភាពសំរាប់រៀបចំផែនការថវិកា និងគ្រប់គ្រងថវិកា ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ។

### ៤.១០ - សុខដុមនីយកម្ម

៩៥- សូចនាករតាមដានរួមដែលបានព្រមព្រៀងនាកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៧ មាន ÷

- ការអនុវត្តន៍ និងការតាមដានវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពសុខដុមនីយកម្ម និងគោលការណ៍នៃភាពជាដៃគូ រៀងរាល់៦ខែ ។

៩៦- រាជរដ្ឋាភិបាលអនុវត្តបានសំរេចនូវគោលដៅនៃសូចនាករតាមដានរួមនេះ ។ របាយការណ៍ស្តីពី«វឌ្ឍនភាពនៃការធ្វើឱ្យប្រសើរឡើងប្រសិទ្ធិភាពជំនួយ» ត្រូវបានបង្ហាញដោយឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅក្នុងវេទិកាកំរិតខ្ពស់ទីក្រុងប៉ារីស ដែលប្រារព្ធធ្វើចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី២ ខែមិនា ឆ្នាំ២០០៥ ។ វេទិកាកំរិតខ្ពស់ក៏បានចេញសេចក្តីប្រកាសរួមមួយ ឈ្មោះថា«សេចក្តីប្រកាសក្រុងប៉ារីស» ។ របាយការណ៍ស្តីពីវឌ្ឍនភាពសំរាប់រយៈពេលប្រាំមួយខែ ក្នុងការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្មត្រូវបានបង្ហាញ និងពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ នាកិច្ចប្រជុំក្រុមការងារបច្ចេកទេសសំរាប់ភាពជាដៃគូនិងសុខដុមនីយកម្មកាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៥ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ វឌ្ឍនភាពនិងការវិវត្តន៍ថ្មីៗក្នុងកិច្ចការកសាងភាពជាដៃគូនិងការបង្កើនប្រសិទ្ធភាពជំនួយសំរាប់ឆ្នាំ២០០៥ នឹងមានបង្ហាញលំអិតក្នុងជំពូកទី៤ ។

# ជំពូកទី៣
## ការអនុវត្តន៍បណ្តាអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០

៩៧- ចក្ខុវិស័យនៃកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល គឺការកសាងសង្គមមួយ ដែលមានសាមគ្គីភាពរឹងមាំ មានប្រព័ន្ធអប់រំនិងវប្បធម៌ជឿនលឿន គ្មានភាពក្រីក្រ អនក្ខរភាព និងជម្ងឺដម្កាត់ផ្សេងៗ ។ ការសំរេចចក្ខុវិស័យនេះ ទាមទារឱ្យប្រកាន់ខ្ជាប់នូវតំលៃនៃយុត្តិធម៌សង្គម សុខមាលភាព ការផ្តល់សិទ្ធិអំណាចឱ្យប្រជាជន និងការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ ដោយជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាក្របខ័ណ្ឌទូលំទូលាយមួយ សំរាប់ជាផែនទីចង្អុលទិស និងផ្តល់គោលការណ៍ណែនាំ ដើម្បីនាំប្រទេសជាតិចេញពីស្ថានភាពមួយនាចុងឆ្នាំ២០០៥ ដើម្បីឈានទៅស្ថានភាពថ្មីមួយទៀតនាឆ្នាំ២០១០ ដោយប្រើប្រាស់ធនធានទាំងឡាយដែលមានស្រាប់ ឱ្យមានប្រសិទ្ធភាពខ្ពស់និងផ្តោតទៅលើលទ្ធផល ។ ដើម្បីឈានទៅសំរេចឱ្យបានឆាប់នូវចក្ខុវិស័យរួមនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់សំរេច ដើម្បីអនុវត្តឱ្យបានសំរេចនូវគោលដៅស្នូលជាយុទ្ធសាស្ត្រ និងជាអាទិភាពខ្ពស់ ដែលមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចមានចែងនៅក្នុងតារាងខាងក្រោម ។

៩៨- រាជរដ្ឋាភិបាលបានសំរេចថា បច្ចុប្បន្ននេះ ត្រូវផ្តោតការយកចិត្តទុកដាក់លើអាទិភាព និងគោលដៅជាយុទ្ធសាស្ត្រដែលត្រូវសំរេចឱ្យបានក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ហើយត្រូវបន្តអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះនានា ដើម្បីសំរេចឱ្យបាននូវបណ្តាគោលដៅទាំងនេះ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដ៏កម្រ ប្រកបដោយវិចារណញាណនិងសមស្រប ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ គឺជាឯកសារតែមួយគត់ ដែលមានដាក់បញ្ចូលនូវបណ្តាគោលដៅ និងយុទ្ធសាស្ត្រអាទិភាពនានារបស់រាជរដ្ឋាភិបាល សំរាប់កាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស ដើម្បីឈានទៅសំរេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច សំរាប់ជាប្រយោជន៍ដល់ប្រជាជនទាំងមូល ។ «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» គឺជាផែនការសំរាប់«យុទ្ធសាស្ត្រចតុកោណ» សំដៅឈានទៅសំរេចនូវបណ្តាគោលដៅនានាដែលបានកំណត់ ។ រីឯ «កម្មវិធីវិនិយោគសាធារណៈឆ្នាំ២០០៦-២០០៨» ត្រូវបានរៀបចំសំរាប់គាំទ្រដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ឯកសារទាំង២នេះត្រូវបានអនុមតិដោយរាជរដ្ឋាភិបាលក្នុងអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ ឯកសារទាំងនេះក៏មានគោលដៅឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ធ្វើការ តឹរឹម និងធ្វើសុខដុមនីយកម្មកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ និងផ្ទេរធនធានពិតប្រាកដមកកម្ពុជាឱ្យបានច្រើនជាងមុន ។ រាជរដ្ឋាភិបាលសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទ្វេ-ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល សូមតម្រឹមយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ខ្លួន ឱ្យស្របនឹងបណ្តាអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងតម្រឹមគំរោងនិងកម្មវិធី ជាមួយនឹងកម្មវិធីវិនិយោគសាធារណៈ ។

៩៩- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានរៀបចំឡើង តាមរយៈការពិគ្រោះយោបល់ដ៏ទូលំទូលាយ ដោយផ្ដោតជាសំខាន់ទៅលើលទ្ធផល ។ គោលដៅ និងសកម្មភាពជាយុទ្ធសាស្ត្រនានាដែលបានកំណត់ នឹងត្រូវលំអិតបន្ថែមទៀត តាមរយៈផែនការតាមវិស័យដែលកំពុងដំណើរការ ឬត្រូវរៀបចំក្នុងពេលឆាប់ៗខាង មុខ និងតាមរយៈការរៀបចំផែនការ និងគោលដៅនានានៅថ្នាក់ក្រោមជាតិ ។ កិច្ចប្រឹងប្រែងនេះនឹងជួយផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឱ្យកាន់តែប្រសើរ និងទូលំទូលាយឡើង ពិសេស នៅថ្នាក់ក្រោមជាតិ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាឯកសាររស់រវើក ដែលអាចពិនិត្យ និងធ្វើការកែតំរូវរៀងរាល់ឆ្នាំ ដោយផ្អែកតាមទិន្នន័យដែលទទួលបានថ្មីៗ និងការតាមដានត្រួតពិនិត្យ និងការវាយតំលៃប្រចាំឆ្នាំ ។

១០០- ដោយប្រកាន់ខ្ជាប់នូវសន្តិភាព និងស្ថិរភាពផ្ទៃក្នុង ការធ្វើឱ្យប្រសើរឡើងនូវសណ្ដាប់ធ្នាប់សង្គម និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងរយៈពេលកន្លងមក កម្ពុជាកំពុងស្ថិតនៅក្នុងចំណុចចាប់ផ្ដើមដ៏សំខាន់មួយ សំរាប់បង្កើនល្បឿននៃការអភិវឌ្ឍន៍នាពេលអនាគត ។ រយៈពេល១០ឆ្នាំខាងមុខ គឺជាទសវត្សរ៍នៃកាលានុវត្តភាព ដើម្បីសំរេចបណ្ដាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ សំរាប់កាត់បន្ថយភាពក្រីក្រ ពិសេសភាពងាយរងគ្រោះ ។ ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ ការរៀបចំផែនការ និងការអនុវត្តន៍គំរោង និងកម្មវិធីក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ នឹងត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើទិដ្ឋភាពចំបងខាងក្រោម ÷

- ជំរុញការកាត់បន្ថយភាពក្រីក្រ និងការបញ្ជ្រាបបញ្ហាយេនឌ់រនៅក្នុងគ្រប់សកម្មភាពទាំងអស់ ។
- អនុវត្តកំណែទំរង់លើគ្រប់វិស័យ ទោះមានការលំបាកនិងផលប៉ះពាល់ក្នុងរយៈពេលខ្លីក៏ដោយ ។
- ជំរុញកំណើនម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយសមធម៌ក្នុងការបែងចែកតាមតំបន់ និងតាមវិស័យ ។
- បង្កើនឱ្យបានច្រើននូវវិនិយោគពិតប្រាកដ សំរាប់ជំរុញកំណើនក្នុងវិស័យផលិតកម្ម និងការអភិវឌ្ឍន៍ធនធានមនុស្ស ។
- តំរង់សកម្មភាពឆ្ពោះទៅរកប្រជាជន និងតំបន់ដែលខ្វះខាតបំផុត ។
- ផ្ដោតការយកចិត្តទុកដាក់ទៅលើសកម្មភាពទាំងឡាយដែលត្រូវការចំណាយទាប ហើយអាចផ្ដល់ផលបានឆាប់រហ័ស និងផលខ្ពស់នៅតាមមូលដ្ឋាន ព្រមទាំងផ្ដល់ផលប្រយោជន៍ជាវិជ្ជមានជាច្រើនដល់ប្រជាជនក្រីក្រ ។
- ធ្វើឱ្យប្រសើរនូវកត្តានានា សំរាប់បង្កើនផលិតភាព ។
- ប្រើប្រាស់កំលាំងពលកម្មឱ្យបានច្រើនតាមដែលអាចធ្វើបាន សំរាប់គ្រប់ការងារសាងសង់ ដើម្បីបង្កើនចំណូលរបស់គ្រួសារ ពិសេសនៅតំបន់ជនបទ ។
- យកចិត្តទុកដាក់លើការកសាងសមត្ថភាពមនុស្សក្នុងគ្រប់វិស័យទាំងអស់ ។

១០១- រាជរដ្ឋាភិបាលនឹងប្រកាន់យកនូវយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗនានា ដើម្បីបន្តអនុវត្តបណ្ដាសមាសធាតុនៃយុទ្ធសាស្ត្រចតុកោណ ។ អាទិភាពក្នុងការលើកកំពស់អភិបាលកិច្ចល្អ រួមមាន ÷

- បន្តពង្រឹង និងពន្លឿនការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមគ្រប់រូបភាព ។
- អនុវត្តកំណែទំរង់ច្បាប់និងតុលាការ ។
- បង្កើនល្បឿន និងបន្តអនុវត្តកំណែទំរង់រដ្ឋបាលសាធារណៈ ។
- បន្តចាត់វិធានការសំរាប់អនុវត្តវិមជ្ឈការនិងវិសហមជ្ឈការ សំរាប់បង្កើនប្រសិទ្ធភាពថែមទៀត ។

១០២- ដើម្បីបង្កើតបរិស្ថានអំណោយផលសំរាប់អភិបាលកិច្ចល្អ រាជរដ្ឋាភិបាលនឹង ÷
- បន្តពង្រឹងជាបន្តបន្ទាប់ នូវសុខសន្តិភាព មានស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ដែលជាមូលដ្ឋានគ្រឹះសំរាប់វឌ្ឍនភាពផ្សេងទៀត ។
- ធ្វើសមាហរណកម្មកម្ពុជាឱ្យបានទូលំទូលាយ និងស៊ីជំរៅថែមទៀត ទៅក្នុងកិច្ចការតំបន់ និងពិភពលោក និងទាក់ទាញវិនិយោគសំរាប់ការរីកចំរើនសេដ្ឋកិច្ចដែលផ្តោតលើអ្នកក្រីក្រ ។
- បន្តពង្រឹងភាពជាដៃគូជាមួយសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍បរទេស ។

១០៣- កំណើនម៉ាក្រូសេដ្ឋកិច្ចឆាប់រហ័ស និងរឹងមាំ ការត្រួតពិនិត្យសារពើពន្ធ និងវិស័យហិរញ្ញវត្ថុដែលមានភាពរឹងមាំ គឺមានសារៈសំខាន់ណាស់សំរាប់វឌ្ឍនភាព ។ រាជរដ្ឋាភិបាលនឹងប្រកាន់គោលនយោបាយ ដែល ÷
- ធានាឱ្យមានស្ថេរភាពកំណើន ផ.ស.ស ៦% ក្នុងមួយឆ្នាំ ។
- រក្សាស្ថេរភាពវិស័យក្រៅប្រទេស និងអត្រាប្តូរប្រាក់ ។
- រក្សាអតិផរណាឱ្យស្ថិតនៅក្រោមកំរិត ៥% ។
- លើកទឹកចិត្តការវិនិយោគឯកជន នៅក្នុងសកម្មភាពអាទិភាពនានាតាមតំបន់ជនបទ ។
- កែលំអការអនុវត្តន៍ថវិកា ដែលរួមមានទាំងការបង្កើនចំណូលចរន្ត និងចំណាយសំរាប់គាំទ្រដល់អ្នកក្រីក្រ ។

ច- ធានាឱ្យមានតម្លាភាពនិងគណនេយ្យភាពពេញលេញនៅគ្រប់ប្រតិបត្តិការ រួមមានការដោះដូរឬជួលទ្រព្យសម្បត្តិរដ្ឋ ។

១០៤- នៅក្នុងវិស័យកសិកម្ម ការយកចិត្តទុកដាក់នឹងត្រូវផ្តោតទៅលើប្រពលវប្បកម្មផលិតកម្មដំណាំ ដើម្បីបង្កើនទិន្នផលនិងចំណូលនៅតាមជនបទ ការធ្វើពិពិធកម្ម ការកែលំអការគ្រប់គ្រងជលផល ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព តាមរយៈកំណែទំរង់ ការអភិរក្សបរិស្ថាន ការអនុវត្តន៍កំណែទំរង់ដីធ្លី ដើម្បីធានាសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាកសិករ ។ យុទ្ធសាស្ត្រសំខាន់ៗរបស់រាជរដ្ឋាភិបាលរួមមាន ÷
- រៀបចំយុទ្ធសាស្ត្រទូលំទូលាយមួយសំរាបវិស័យកសិកម្ម ។
- បង្កើនការវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម ។
- លើកកំពស់សកម្មភាពមីក្រូហិរញ្ញវត្ថុ ។
- លើកទឹកចិត្ត និងសំរបសំរួលការវិនិយោគឯកជនក្នុងវិស័យកសិកម្មនិងការកែច្នៃកសិផល ។
- លើកកំពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ។
- បង្កើនទិន្នផលតាមរយៈការបង្កើនសេវាផ្សព្វផ្សាយ ។

- ធ្វើអន្តរាគមន៍ដោយផ្ទាល់ ដោយតំរង់ទិសទៅរកមូលដ្ឋាន ដើម្បីកាត់បន្ថយភាពក្រីក្រ ។
- បង្កលទ្ធភាពឱ្យអ្នកក្រីក្រអាចទទួលផលពីវិស័យជលផលប្រកបដោយចីរភាព ។
- ពង្រឹង និងពង្រីកផលិតកម្មបសុសត្វ ។
- គ្រប់គ្រងតំបន់ការពារឱ្យបានប្រសើរ ។
- អភិរក្សព្រៃឈើ តាមរយៈការអនុវត្តន៍ការគ្រប់គ្រងប្រកបដោយចីរភាព ។
- រៀបចំ និងអនុវត្តគោលនយោបាយដីធ្លី ។
- អនុវត្តកម្មវិធីបែងចែកដីធ្លីជូនប្រជាកសិករក្រីក្រ ។
- បន្តដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។

១០៥- ដើម្បីជំរុញការអភិវឌ្ឍន៍ជនបទបន្ថែមទៀតឱ្យស្របនឹងវិមជ្ឈការនិងវិសហមជ្ឈការ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវ ទីផ្សារ ការផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធអនាម័យ ប្រព័ន្ធធារាសាស្រ្តខ្នាតតូច អាគារសាលារៀននិងមណ្ឌលសុខភាព ។ល។) ។ កិច្ចការទាំងនេះត្រូវបានអនុវត្ត តាមរយៈមូលនិធិរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ ។ ទន្ទឹមនេះ ក៏ត្រូវខិតខំប្រឹងប្រែងអនុវត្តបន្តសំរាប់បង្កើនការផ្តល់ឥណទានជនបទ និងដើម្បីបញ្ចុះអត្រាការប្រាក់ ។

១០៦- អាទិភាពក្នុងការស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន ផ្លូវជាតិ និងផ្លូវខេត្ត- ក្រុង និងអាកាសយានដ្ឋានផ្លូវរថភ្លើង កំពង់ផែ ប្រព័ន្ធធារាសាស្រ្ត ទូរគមនាគមន៍ ប្រព័ន្ធអគ្គិសនីនិងបណ្តាញចែកចាយ ។ ព្រមជាមួយនេះ ក៏យកចិត្តទុកដាក់ក្នុងការទាក់ទាញផ្នែកឯកជន ឱ្យចូលរួមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ តាមគោលការណ៍ «សាងសង់- ដំណើរការ- ផ្ទេរ» ។

១០៧- កម្ពុជាក៏មានក្តីសង្ឃឹមនៃការធ្វើអាជីវកម្មធនធានប្រេងនិងឧស្ម័នក្នុងសមុទ្រដែរ ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តការសិក្សាបន្ថែមទៀត ព្រមទាំងដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ដើម្បីធានាឱ្យមានការប្រើប្រាស់ធនធានមានតំលៃទាំងនេះបានល្អប្រសើរ ព្រមទាំងប្រមូលចំណូលពីធនធានទាំងនេះ ។

១០៨- ការទាក់ទាញវិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស គឺជាការសំខាន់បំផុតដើម្បីបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលនឹងលុបបំបាត់ចោលឱ្យអស់ និងឱ្យបានឆាប់រហ័ស នូវឧបសគ្គធំៗ នាពេល បច្ចុប្បន្ន រួមមាន ការពន្យាពេលក្នុងការផ្តល់សេចក្តីយល់ព្រម និងការចំណាយខ្ពស់សំរាប់កិច្ចការ ធុរៈកិច្ច ព្រមទាំងកែលំអបរិស្ថានទូទៅសំរាប់វិនិយោគ តាមរយៈកំណែទំរង់អភិបាលកិច្ច ។ សហគ្រាស ធុនតូចនិងមធ្យមនឹងទទួលបានការយកចិត្តទុកដាក់ខ្លាំង ក្នុងនោះ រួមមានទាំងលទ្ធភាពងាយស្រួលជាងមុនក្នុងការទទួលហិរញ្ញប្បទានរយៈពេលមធ្យម និងវែងផងដែរ ។

១០៩- កាលានុវត្តភាពសំរាប់ពាណិជ្ជកម្មជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀត បានដំណើរការប្រសើរ ឡើង ។ ប៉ុន្តែ នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្កើតតំរូវការ និងដើម្បីនាំចេញទំនិញ និង សេវាកម្មដោយប្រើប្រាស់ឧត្តមភាពប្រកួតប្រជែងរបស់ប្រទេសនៅឡើយ ។ ការកែទំរង់សំរាប់លើកកំពស់

ការចូលរួមរបស់ផ្នែកឯកជន នឹងអាចដោះស្រាយបណ្តាបញ្ហាដែលទាក់ទងនឹងការធ្វើពាណិជ្ជកម្ម ។

១១០- ការអប់រំជាវិស័យអាទិភាពមួយក្នុងការអភិវឌ្ឍន៍មនុស្ស និងការកសាងសមត្ថភាព ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៥ឆ្នាំ ២០០៦-២០១០ ត្រូវបានរៀបចំរួចហើយ ។ ក្រៅពីការផ្តល់ការអប់រំមូលដ្ឋានសកលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ត្រូវឱ្យយកចិត្តទុកដាក់ដល់ការអប់រំនៅតាមកម្រិតផ្សេងៗទៀត ដែរដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧត្តមសិក្សា ដើម្បីកសាងស្រទាប់ប្រជាជនដែលមានការអប់រំ មានជំនាញ មានទេពកោសល្យ មានសមត្ថភាព សំរាប់បំពេញតំរូវការអភិវឌ្ឍន៍ប្រទេស នៅតាមវិស័យ នានា ។ អាទិភាពសំរាប់រយៈពេលប្រាំឆ្នាំខាងមុខ រួមមាន ÷

ក- ផ្តល់ការអប់រំមូលដ្ឋានប្រកបដោយសមធម៌ ពិសេស សំរាប់សិស្សក្រីក្រ និងសិស្សដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាល តាមរយៈការបង្កើនចំនួនសាលាបឋមសិក្សា និងសាលាមធ្យម-សិក្សាបឋមភូមិ ។

ខ- សំរួលការចូលរៀនរបស់សិស្សស្រី ក្នុងមធ្យមសិក្សាបឋមភូមិ និងកំរិតផ្សេងៗទៀត តាមរយៈការបង្កើនចំនួនអន្តេវាសិកដ្ឋានសំរាប់សិស្សស្រី ។

គ- កាត់បន្ថយចំណាយសំរាប់សិស្សក្រីក្រ តាមរយៈការផ្តល់អាហារូបករណ៍ ។

ឃ- បង្កើនគុណភាព និងប្រសិទ្ធភាពសេវាអប់រំ ។

ង- ធានាទំនាក់ទំនងល្អនៃការអប់រំនិងការបណ្តុះបណ្តាល ជាមួយនឹងតំរូវការទីផ្សារពលកម្មនិងសង្គមក្នុងរយៈពេលខ្លី និងវែង ។

១១១- វិស័យសុខាភិបាលមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ប៉ុន្តែ សន្ទស្សន៍ខាងសុខភាពខ្លះនៅមានកំរិតទាបនៅឡើយ ។ រាជរដ្ឋាភិបាលសង្ឃឹមថា អាចនឹងសំរេចបាននូវគោលដៅមួយចំនួននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ គោលដៅផ្សេងៗទៀតក៏ទាមទារឱ្យមានកិច្ចប្រឹងប្រែងបន្តទៀតដែរ ។ អាទិភាពរួមមាន ÷

- បង្កើនល្បឿនកំណែទំរង់លើគ្រប់ផ្នែក ។
- ពង្រីកលទ្ធភាពក្នុងការផ្តល់សេវាថែទាំសុខភាព តាមរយៈការសាង និងការស្តារឡើងវិញនៃប្រព័ន្ធសុខាភិបាល ដូចជាមន្ទីរពេទ្យ មណ្ឌលសុខភាពនៅតាមតំបន់ជនបទ ជាដើម ។
- ពង្រីកនិងពង្រឹងវិធីសាស្ត្រប្រកបដោយចីរភាព សំរាប់ជនក្រីក្រឱ្យទទួលបានសេវាថែទាំសុខភាពសាធារណៈ ។
- លើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ក្នុងការផ្តល់សេវាថែទាំសុខភាព ទាំងនៅតំបន់ ទីប្រជុំជន និងជនបទ ។
- យកចិត្តទុកដាក់ជាពិសេសក្នុងការកាត់បន្ថយការរាលដាលនៃជំងឺអេដស៍ ពិសេស ទៅលើគ្រួសារតាមរយៈការអប់រំ និងការផ្តល់ព័ត៌មាន ។

# តារាង ៤ : គោលដៅជាតិ និងសូចនាករសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | ២០០៥ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|
| | ***លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ (*)*** | | | |
| ១* | ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ឆ្នាំ២០០៤ | ៣៤,៧ | ២៥ | ១៩,៥ |
| | ៥៦%នៃផ្ទៃដីទូទាំងប្រទេសនៃការធ្វើអង្កេតឆ្នាំ១៩៩៣-១៩៩៤ | (២៨,០) | | |
| ២* | ភាគរយនៃប្រជាជននៅតំបន់ជនបទ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ឆ្នាំ២០០៤ | ៣៩,២ | | |
| | ក្នុងតំបន់នៃការធ្វើអង្កេតឆ្នាំ១៩៩៣-១៩៩៤ | (៣៣,៧) | | |
| ៣* | ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ ឆ្នាំ២០០៤ | ១៩,៧ | ១៣ | ១០ |
| | ក្នុងតំបន់នៃការធ្វើអង្កេតឆ្នាំ១៩៩៣-១៩៩៤ | (១៤,២) | | |
| | ***ការពង្រឹងផលិតភាពនិងផលិតកម្មកសិកម្ម*** | | | |
| ៤ | ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ១,៩៧ | ២,៤ | |
| ៥ | ផ្ទៃដីស្រោចស្រព (រួមទាំងការស្រោចស្រព ដោយប្រព័ន្ធធារាសាស្ត្រ) (%នៃផ្ទៃដាំស្រូវ) | ២០ | ២៥ | |
| ៦ | កំណែទម្រង់ដីធ្លីៈ ចំនួនប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី ដែលបានផ្តល់ជូនកសិករ (%នៃផ្ទៃដីសរុប) | ១២ | ២៤ | |
| | ***ការលើកកំពស់ក្នុងវិស័យសុខាភិបាល (*)*** | | | |
| ៧* | អត្រាមរណភាពទារក ក្នុង១.០០០ កំណើតកូន | ៦៦ | ៦០ | ៥០ |
| ៨* | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ក្នុង១.០០០ កំណើតកូន | ៨២ | ៧៥ | ៦៥ |
| ៩* | អត្រាមរណភាពមាតា ក្នុង១០០.០០០ កំណើតកូន | | ២៤៣ | ១៩០ |
| ១០* | អត្រាសម្រាលកូនដោយមន្ត្រីជំនាញផ្នែកសុខាភិបាល (%) | | ៧០ | *៨០* |
| ១១* | អត្រាប្រេវ៉ាឡង់មេរោគហ៊ីវ/ជម្ងឺអេដស៍ ក្នុងចំណោមមនុស្សពេញវ័យអាយុពី១៥-៤៩ឆ្នាំ | ១,៩ | ១,៩ | ១,៨ |
| ១២* | អត្រាស្លាប់ដោយជម្ងឺគ្រុនចាញ់ | ០,៣៦ | ០,២ | ០,១ |
| ១៣* | ករណីអ្នកផ្ទុកជម្ងឺរបេងក្នុងប្រជាជន ១០០.០០០នាក់ | | ២១៤ | ១៣៥ |
| ១៤* | អត្រាស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប (%) | ២០,១ | ៤៤ | ៦០ |
| ១៥ | មណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពបន្តពូជ | ៣៣ | ៤៥ | ៧០ |
| | ***ការលើកកំពស់វិស័យអប់រំ (*)*** | | | |
| ១៦* | អត្រាពិតនៃការសិក្សានៅបឋមសិក្សា (សរុបអត្រាចូលរៀនរបស់សិស្សប្រុស និងសិស្សស្រី) | ៩១,៩ -៩៣,០ -៩០,៧ | ១០០ | ១០០ |
| ១៧* | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (សរុបអត្រាចូលរៀនរបស់សិស្សប្រុស និងសិស្សស្រី) | ២៦,១ -២៧,១ -២៤,៨ | ៧៥ | ១០០ |

| | | | | |
|---|---|---|---|---|
| ១៨* | អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ទី៦ | ៥៣,១ | ១០០ | ១០០ |
| ១៩* | អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ទី៩ | ៣០,១៨ | ៧៦ | ១០០ |
| ២០* | អត្រាកុមារមិនបានចូលរៀន ដែលមានអាយុ ៦-១៤ឆ្នាំ | ១៨,៧ | ១១ | ០ |
| | ***ការអភិវឌ្ឍន៍ជនបទ*** | | | |
| ២១* | ផ្លូវជនបទដែលបានស្តារនិងជួសជុល លើប្រវែងផ្លូវសរុប ២៨.០០០ គម | ២២.៧០០ | ២៥.០០០ | ២៨.០០០ |
| ២២* | សមាមាត្រប្រជាជនជនបទដែលមានលទ្ធភាពប្រើប្រាស់ទឹកស្អាត | ៤១,៦ | ៤៥ | ៥០ |
| ២៣* | សមាមាត្រប្រជាជនជនបទដែលមានលទ្ធភាពទទួលបានសេវាអនាម័យ | ១៦,៤ | ២៥ | ៣០ |
| | ***ចីរភាពផ្នែកបរិស្ថាន*** (*) | | | |
| ២៤* | សមាមាត្រនៃផ្ទៃដីសរុបដែលគ្របដណ្តប់ដោយព្រៃឈើ | ៦០ | ៥៨ | ៦០ |
| ២៥* | សមាមាត្រនៃគ្រួសារដែលពឹងផ្អែកលើអុស-ធ្យូង | ៨៣,៩ | ៦១ | ៥២ |
| ២៦* | សមាមាត្រនៃប្រជាជនទីក្រុង/ប្រជុំជន ដែលមានលទ្ធភាពប្រើប្រាស់ទឹកស្អាត | ៧៥,៨ | ៨៥ | ៨០ |
| ២៧* | សមាមាត្រប្រជាជនទីក្រុង/ប្រជុំជន ដែលមានលទ្ធភាពទទួលបានសេវាអនាម័យ | ៥៥ | ៦៧ | ៧៤ |
| | ***សមធម៌យេនឌ័រ*** (*) [1] | | | |
| ២៨* | បញ្ហាបយេនឌ័រនៅគ្រប់មជ្ឈដ្ឋាន (*) | នឹងត្រូវបង្កើតឡើង | | |
| ២៩* | សមាមាត្រនៃការចូលរួមរបស់ស្ត្រីក្នុងការធ្វើការងារ (កសិកម្ម ឧស្សាហកម្ម សេវាកម្ម) | ៥២,៥-៥៣,៥-២៧,០ | ៥០-៥០-៣៧ | ៥០-៥០-៥០ |
| ៣០* | សមាមាត្រកម្រិតយល់ដឹងស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី ដែលជាឧក្រិដ្ឋកម្ម | ៤,៥ | ២៥ | ១០០ |
| | ***កំណែទម្រង់*** | | | |
| ៣១ | បង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច | នឹងត្រូវរៀបចំ | | |
| | ***ស្ថេរភាពកំណើនម៉ាក្រូសេដ្ឋកិច្ចខ្ពស់*** | | | |
| ៣២ | អត្រាកំណើន *ផសស* ប្រចាំឆ្នាំ គិតតាមថ្លៃថេរ | ៦,៥០ | ៦,៥០ | |
| ៣៣ | *ផសស* សម្រាប់មនុស្សម្នាក់ គិតតាមថ្លៃថេរ (ពាន់រៀល) | ១.៤០០ | ២.២៤៣ | |
| ៣៤ | អត្រាអតិផរណា | ៥,៥០ | ៣,០០ | |
| | ***កែលម្អការប្រើប្រាស់ថវិកា*** | | | |
| ៣៥ | សមាមាត្រចំណូលថវិការដ្ឋសរុបនៃ*ផសស* | ១១,៣០ | ១៣,៧០ | |
| ៣៦ | សមាមាត្រចំណាយថវិការដ្ឋសរុបនៃ*ផសស* | ១៦,៨០ | ១៦,៨០ | |
| | ***បង្កើនល្បឿនកំណើនក្នុងវិស័យឧស្សាហកម្មនិងការងារ*** | | | |

| | | | | |
|---|---|---|---|---|
| ៣៧ | អត្រាកំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាល គិតតាមថ្លៃថេរ | ១០,២ | ៧,២ | |
| ៣៨* | សមាមាត្រពលកម្មកុមារអាយុ ពី៥ ដល់១៧ឆ្នាំ | ២២,៣ | ១០,៦ | ៨ |
| | ***ទេសចរណ៍*** | | | |
| ៣៩ | ចំនួនភ្ញៀវទេសចរណ៍ប្រចាំឆ្នាំ (ពាន់នាក់) | ១.៣០០ | ៣.១២០ | |
| | ***ការបោសសំអាតមីន ការជួយសង្គ្រោះជនរងគ្រោះ*** | | | |
| ៤០* | ចំនួនអ្នករងគ្រោះ (ស្លាប់ និងរបួស) | ៧៩៧ | ២០០ | ០ |
| ៤១* | *សមាមាត្រនៃតំបន់ដែលបានបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ* | ៥០,៣ | ៧៧ | ១០០ |
| | ***ហេដ្ឋារចនាសម្ព័ន្ធ*** | | | |
| ៤២ | ផ្លូវក្រាលកៅស៊ូ (ផ្លូវជាតិនិងផ្លូវខេត្ត) លើប្រវែងផ្លូវសរុប១១.៣១០ គម | ២.១០០ | ៤.១០០ | |
| | ***ថាមពល*** | | | |
| ៤៣ | ការប្រើប្រាស់ថាពលអគ្គិសនីក្នុងមនុស្សម្នាក់ (គីឡូវ៉ាត់ម៉ោង) | ៥៤ | ៨៩ | |

គោលដៅ និងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា

[១] **យេនឌ័រដែលពាក់ព័ន្ធ និងគោលដៅ បានបង្ហាញ ដាច់ដោយឡែកក្នុងវិស័យអប់រំ និងសុខាភិបាល**

១១២- បញ្ហាសមធម៌យេនឌ័រ ត្រូវបានបញ្ជ្រាបចូលគ្រប់សកម្មភាពទាំងអស់ ហើយត្រូវបានដោះស្រាយនៅគ្រប់វិស័យ ពិសេស ក្នុងវិស័យកសិកម្ម សុខាភិបាល និងអប់រំ ។ ក្រុមប្រឹក្សាជាតិសំរាប់ស្ត្រីនឹងបន្តដោះស្រាយបញ្ហាជាច្រើននៃការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃអភិបាលកិច្ច និងសង្គម ។

១១៣- រាជរដ្ឋាភិបាលយល់ថា អាចមានហានិភ័យខ្លះៗដែលមិនអាចទស្សទាយជាមុន ហើយដែលអាចប៉ះពាល់ដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចជា ធនធានមិនអាចទទួលបានគ្រប់ចំនួនតាមការរំពឹងទុក ពិសេសពីដៃគូអភិវឌ្ឍន៍ តំលៃប្រេងនិងឧស្ម័ននៅទីផ្សារអន្តរជាតិនៅតែបន្តកើនឡើងខ្ពស់ ដែលអាចជំរុញឱ្យមានអតិផរណា ការប្រែប្រួលស្ថានភាពនយោបាយ សន្តិសុខ និងសង្គមក្នុងតំបន់ និងពិភពលោកដោយសារភេរវកម្ម ឧបសគ្គពាណិជ្ជកម្មមិនអាចកាត់បន្ថយតាមជំហានគ្រោងទុក ការរីករាលដាលនៃជំងឺ ដូចជាផ្តាសាយបក្សីនិងជំងឺឆ្លងផ្សេងៗទៀត គ្រោះថ្នាក់ធម្មជាតិ ដូចជាទឹកជំនន់ និងភាពរាំងស្ងួតដែលអាចកើតឡើង ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏រាជរដ្ឋាភិបាលមានជំនឿថា រាជរដ្ឋាភិបាលអាចជំនះបញ្ហាប្រឈមទាំងនេះបាន ហើយនឹងធ្វើការកែតំរូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដើម្បីសំរបសំរួលតាមស្ថានភាពជាក់ស្តែង ។ រាជរដ្ឋាភិបាលមានសុទិដ្ឋិនិយមថា ជាមួយនឹងការប្តេជ្ញាចិត្តនិងកិច្ចសហប្រតិបត្តិការពីដៃគូទាំងអស់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រាកដជាអាចអនុវត្តប្រកបដោយជោគជ័យ ដើម្បីសំរេចបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់សុខុមាលភាពប្រជាជនកម្ពុជាគ្រប់រូប ។

# ជំពូកទី៤

# ការកសាងភាពជាដៃគូ សំរាប់បង្កើនប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ

> **ការកសាងភាពជាដៃគូ ដើម្បីបង្កើនប្រសិទ្ធភាពជំនួយអភិវឌ្ឍន៍ផ្លូវការ**
>
> ១- វឌ្ឍនភាពបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧
>
> ២- បញ្ហាប្រឈមនានា និងទិសដៅអនាគត

១១៤- ចាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧ ដែលបានប្រព្រឹត្តទៅនាខែធ្នូ ឆ្នាំ២០០៤ កន្លងមក យើងបានកត់សំគាល់អំពីវឌ្ឍនភាពជាច្រើន ទាំងនៅលើឆាកអន្តរជាតិ ទាំងក្នុងប្រទេសកម្ពុជា ក្នុងការខិតខំដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពជំនួយ ។ ផ្នែកនេះនឹងបង្ហាញអំពីវឌ្ឍនភាពសំខាន់ៗដែលសំរេចបាន បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបលលើកទី៧ និងបញ្ហាប្រឈមនានា ដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវប្រឈមដោះស្រាយដើម្បីបង្កើនប្រសិទ្ធភាពជំនួយ ព្រមទាំងលើកឡើង នូវអាទិភាពមួយចំនួនដែលត្រូវអនុវត្តសំរាប់បោះជំហានទៅមុខបន្តទៀត ។

## ១- សមិទ្ធិផលសំរេចបានបន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ចុងក្រោយ

១១៥- នៅលើឆាកអន្តរជាតិ វេទិកាកំរិតខ្ពស់លើកទី២បានប្រារព្ធឡើង ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី០២ ខែមិនា ឆ្នាំ២០០៥ នៅទីក្រុងប៉ារីស ដើម្បីពិនិត្យឡើងវិញអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍ការប្តេជ្ញានៃ «សេចក្តីប្រកាសទីក្រុងរ៉ូម» ។ នៅក្នុងវេទិកានោះ រាជរដ្ឋាភិបាលបានលើកបង្ហាញពី «របាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការពង្រឹងប្រសិទ្ធភាពជំនួយនៅកម្ពុជា» ។ នៅពេលបិទសម័យប្រជុំនេះ សេចក្តីប្រកាសរួមដែលបានឯកភាពដោយរដ្ឋមន្ត្រីនៃបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ទទួលបន្ទុកខាងកិច្ចអភិវឌ្ឍន៍ និងប្រធានស្ថាប័នទទួលបន្ទុកកិច្ចអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី បានកំណត់គោលការណ៍ថ្មីៗមួយចំនួន សំរាប់បណ្តាប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍ សំរាប់ដោះស្រាយបញ្ហាប្រសិទ្ធភាពនៃជំនួយ ។ បណ្តាការប្តេជ្ញាចិត្តនៃ «សេចក្តីប្រកាសទីក្រុងប៉ារីស» បានកំណត់បណ្តាវិធានការសកម្មភាពទូលំទូលាយមួយចំនួន ហើយដែលអាចត្រួតពិនិត្យបាន ដើម្បីកែទំរង់បែបបទនៃការផ្តល់ និងគ្រប់គ្រងជំនួយ ។

១១៦- បន្ទាប់ពី «សេចក្តីប្រកាសទីក្រុងប៉ារីស»មក ក្រុមការងារស្តីពីប្រសិទ្ធភាពជំនួយនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ បានរៀបចំបញ្ចប់នូវតារាងសូចនាករតាមដាន និងបានបង្កើតក្របខ័ណ្ឌសំរាប់ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍ «សេចក្តីប្រកាសទីក្រុងប៉ារីស» ។ នៅខែកញ្ញា ឆ្នាំ២០០៥ ក្រុមការងារនេះបានបង្កើតក្រុមការងារចំណុះមួយសំរាប់ត្រួតពិនិត្យការអនុវត្តន៍ «សេចក្តីប្រកាសទីក្រុងប៉ារីស» ។ ក្រុមការងារចំណុះនេះត្រូវបានដឹកនាំដោយសហប្រធាន ដែលវៀតណាមជាតំណាងឱ្យប្រទេសជាដៃគូ និងចក្រភពអង់គ្លេសជាតំណាងឱ្យដៃគូអភិវឌ្ឍន៍ ។ រីឯសមាជិកនៃក្រុមការងារចំណុះនេះរួមមាន តំណាងប្រទេសអូទ្រីស កម្ពុជា កាណាដា សហគមន៍ អឺរ៉ុប បារាំង អាល្លឺម៉ង់ ហ្កាណា ម៉ាលី នីការ៉ាហ្គា ណ័រវេ៊ សេនេហ្គាល់ អាហ្វ្រិកខាងត្បូង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សហរដ្ឋអាមេរិក និងធនាគារពិភពលោក ។ ការចូលរួមនៃបណ្តាប្រទេសជាដៃគូក្នុងកិច្ចការនេះ ក៏ត្រូវពង្រីកឱ្យកាន់តែទូលំទូលាយផងដែរ

ហើយបច្ចុប្បន្ននេះ ក្រុមការងារនេះរួមមានប្រទេសដៃគូចំនួន២៣ និងដៃគូអភិវឌ្ឍន៍ទ្វេភាគី ២៣ និងស្ថាប័នពហុភាគីជាច្រើនទៀត ។ ក្រុមការងារចំណុះនេះមានភារកិច្ចរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពចំនួនពីរ ស្តីពីការអនុវត្តន៍ការប្តេជ្ញាចិត្តនៃ «សេចក្តីប្រកាសទីក្រុងប៉ារីស» មុនពេលប្រារព្ធវេទិកាកំរិតខ្ពស់លើកទី៣ ដែលគ្រោងរៀបចំនៅប្រទេសហ្គាណា នាឆ្នាំ២០០៨ ។ ការរៀបចំរបាយការណ៍លើកទី១ ស្តីពីវឌ្ឍនភាពនឹងត្រូវអនុវត្តក្នុងឆ្នាំ២០០៦នេះ ។ ប្រទេសកម្ពុជាត្រូវបានជ្រើសរើសជាប្រទេសមួយក្នុងចំណោមប្រទេសដៃគូចំនួន៦ សំរាប់អនុវត្តសាកល្បងសំណួរអង្កេតស្តីពីការអនុវត្តន៍ការប្តេជ្ញាចិត្តដែលមានចែងក្នុង «សេចក្តីប្រកាសទីក្រុងប៉ារីស» នាដើមឆ្នាំ ២០០៦ ។

១១៧- រីឯនៅក្នុងប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ២០០៥នេះ រាជរដ្ឋាភិបាល ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយដៃគូអភិវឌ្ឍន៍ បានសម្រេចនូវវឌ្ឍនភាពជាដុំកំភួនក្នុងកិច្ចការមួយចំនួន ដូចជា ÷

- បង្កើតយន្តការថ្មីមួយសម្រាប់សម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលយន្តការនេះអាចឱ្យរាជរដ្ឋាភិបាលត្រួតពិនិត្យ ជារៀងរាល់ត្រីមាស អំពីវឌ្ឍនភាពនៃការអនុវត្តន៍សកម្មភាពនានានៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករត្រួតពិនិត្យតាមដានរួមគ្នាដែលបានឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី៧កន្លងមក ។
- ការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខុដុមនីយកម្ម និងការតំរឹម ។
- ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍ ។
- ការរៀបចំគោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់គ្រប់គ្រងជំនួយឥតសំណង និងនីតិវិធីបទដ្ឋានប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី ។
- ការគាំទ្រមន្ត្រីជាន់ខ្ពស់នៅតាមក្រសួងនិងស្ថាប័ននានា ដើម្បីពង្រឹងភាពជាម្ចាស់ក្នុងការគ្រប់គ្រង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។
- រៀបចំ និងអនុវត្តការប្រមូលព័ត៌មាន ស្តីពីការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមគេហទំព័ររបស់ ក.អ.ក/គ.ជ.នា ។

## ១.១- យន្តការថ្មីសំរាប់សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

១១៨- បន្ទាប់ពីការពិគ្រោះយោបល់ជាច្រើនជាមួយដៃគូអភិវឌ្ឍន៍នាចុងឆ្នាំ២០០៣ និងឆ្នាំ២០០៤មក យើងបានដាក់ឱ្យដំណើរការ នូវយន្តការសម្រាប់សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងឆ្នាំ២០០៥ ។ យន្តការនេះរួមមាន ÷ ១) ក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យ និង២) គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ សំរាប់សម្របសម្រួលកិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះទាំង១៨ និងផ្តល់ការណែនាំកំរិតគោលនយោបាយ កំណត់អាទិភាពនានា និងស្នើឡើងនូវវិធានការដើម្បីដោះស្រាយបញ្ហានានា ដែលលើកឡើងដោយក្រុមការងារបច្ចេកទេសចម្រុះ ។ នៅក្នុងកិច្ចប្រជុំត្រៀមពិគ្រោះយោបល់នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានចាត់តាំង

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យធ្វើជាប្រធាននៃគណៈកម្មាធិការនេះ ។ រីឯសមាជិកនៃគណៈកម្មាធិការនេះរួមមាន រដ្ឋមន្ត្រី ឬប្រធានស្ថាប័ននានារបស់រាជរដ្ឋាភិបាល ឯកអគ្គរដ្ឋទូត ឬប្រធានបេសកកម្មការទូត និងប្រធាននៃស្ថាប័នពហុភាគី ។ គណៈកម្មាធិការនេះមានលេខាធិការដ្ឋានមួយ នៅគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជាជាអគ្គលេខាធិការនៃលេខាធិការដ្ឋាននេះ ។ លេខាធិការដ្ឋាននេះមានភារកិច្ចទាក់ទងជាមួយក្រុមការងារ បច្ចេកទេស និងរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព ដែលក្រុមការងារបច្ចេកទេសចម្រុះសំរេចបានក្នុងការអនុវត្តន៍ភារកិច្ចជូនគណៈកម្មាធិការសម្របសម្រួល ។ គណៈកម្មាធិការនេះត្រូវជួបប្រជុំគ្នាជាទៀងទាត់រយៈពេល៣ខែម្តង ។ លេខាធិការដ្ឋានត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំត្រីមាស បញ្ហាប្រឈមនានាក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ និងអំពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករត្រួតពិនិត្យរួមគ្នា ដើម្បីឱ្យគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ពិនិត្យនិងសម្រេច ។ ការបង្កើតគណៈកម្មាធិការសម្របសម្រួលនេះ បានជួយឱ្យរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រួតពិនិត្យវឌ្ឍនភាពរួមគ្នា និងចាត់វិធានការតំរង់ទិស សំដៅសម្រេចឱ្យបាននូវសូចនាករត្រួតពិនិត្យតាមដានរួមគ្នាទាំងនេះ ។

១១៩- ការបង្កើតយន្តការក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺជាការផ្លាស់ប្តូរជាសារវ័ន្ត ខាងផ្នែកស្ថាប័ន ខាងការរៀបចំផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យវឌ្ឍនភាពស្តីពីការអនុវត្តន៍ជំនួយអភិវឌ្ឍន៍ ដើម្បីពង្រឹងប្រសិទ្ធភាពជំនួយ ។ ការពង្រឹងយន្តការនេះសំរាប់កែលំអដំណើរការនៃការកៀរគរ ការបែងចែក និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការសំរាប់បង្កើនប្រសិទ្ធភាពជំនួយ គឺជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។

១២០- គោលការណ៍មូលដ្ឋានដែលបានឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក្នុងការបង្កើតក្រុមការងារ បច្ចេកទេសចម្រុះតាមវិស័យ រួមមាន ÷

ក- ដើម្បីពង្រឹងភាពជាម្ចាស់និងភាពដឹកនាំរបស់រាជរដ្ឋាភិបាល ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ត្រូវដឹកនាំដោយក្រសួងឬស្ថាប័ន ហើយមានសមាជិកមកពីក្រសួងពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ ។ រីខាងភាគីដៃគូអភិវឌ្ឍន៍វិញ ក៏ត្រូវជ្រើសតាំងអ្នកសម្របសម្រួលនាំមុខ ដើម្បីសម្របសម្រួលការងាររវាងបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ផងដែរ ។

ខ- ស្នើរគ្រប់ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានរៀបចំលក្ខខ័ណ្ឌយោងរបស់ខ្លួន ។ ទោះយ៉ាងណាក៏ដោយ ដើម្បីធានាអោយមានសង្គតភាព ក្រុមការងារបច្ចេកទេសត្រូវមានលក្ខខ័ណ្ឌយោងរៀងៗខ្លួន ដែលរួមបញ្ចូលនូវគោលការណ៍សំខាន់ៗ ដូចខាងក្រោម ÷

- ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ត្រូវរៀបចំរួមគ្នានូវយុទ្ធសាស្ត្រ ឬគោលនយោបាយលំអិតសម្រាប់វិស័យរបស់ក្រុមការងារនីមួយៗ ដោយធានាច្បាស់ថា យុទ្ធសាស្ត្រ ឬគោលនយោបាយ

ទាំងនេះមានសង្គតភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណ ប្រសិនមិនទាន់បានរៀបចំ ។ ចំពោះវិស័យណាដែលយុទ្ធសាស្ត្រ ឬគោលនយោបាយត្រូវបានបង្កើតរួចរាល់ហើយ ក្រុមការងារនោះត្រូវកែសម្រួលឡើងវិញ ប្រសិនបើចាំបាច់ ។

- ក្រោយពីការរៀបចំយុទ្ធសាស្ត្រឬគោលនយោបាយរួចហើយ ក្រុមការងារនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងកំណត់អាទិភាព និងទំរង់ការនៃការគាំទ្រដល់ការអនុវត្តន៍ផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ផែនការសកម្មភាពនេះត្រូវចាត់ទុកជាឯកសាររួមរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ សម្រាប់ត្រួតពិនិត្យរួមគ្នានូវវឌ្ឍនភាពនៃការអនុវត្តន៍ ។
- ក្រុមការងារបច្ចេកទេសនិមួយៗ ត្រូវទទួលខុសត្រូវក្នុងការកៀរគរធនធានដែលត្រូវការ សម្រាប់អនុវត្តផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសដែលបានឯកភាព ។ ប្រសិនបើធនធានមានមិនគ្រប់គ្រាន់ ទាំងរាជរដ្ឋាភិបាល ទាំងអ្នកផ្តល់ជំនួយ ត្រូវពិភាក្សាជាមួយគ្នាឡើងវិញ ដើម្បីកំណត់អាទិភាពសកម្មភាពនៃក្រុមការងារអោយស្របតាមធនធានដែលទទួលបាន ។
- ក្រុមការងារបច្ចេកទេសនីមួយៗត្រូវត្រួតពិនិត្យរួមគ្នា អំពីវឌ្ឍនភាពធៀបនឹងលក្ខខ័ណ្ឌវិនិច្ឆ័យដែលបានកំណត់ ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ និងដើម្បីសម្រេចឱ្យបាននូវបណ្តាគោលដៅដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ។

១២១- ជារួម ក្រុមការងារបច្ចេកទេសចម្រុះសម្រេចបាននូវវឌ្ឍនភាពជាដុំកំភួនក្នុងឆ្នាំ២០០៥នេះ ។ ក្រុមការងារខ្លះបំពេញកិច្ចការរបស់ខ្លួនបានប្រសើរជាងក្រុមការងារដទៃទៀត ។ ឆ្នាំ២០០៥ គឺជា «ឆ្នាំរៀន ផង- ធ្វើផង» សម្រាប់ក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ដែលជាសមាជិកនៃក្រុមការងារចម្រុះ ។ ក្នុងពេលរៀបចំប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នាខែធ្នូ ឆ្នាំ ២០០៥ លេខាធិការដ្ឋានបានព្យាយាមប្រមូលពត៌មានពីក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីការប៉ាន់ស្មានធនធានហិរញ្ញវត្ថុ ដែលក្រុមការងារត្រូវការសម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងធនធានដែលក្រុមការងារអាចកៀរគរបាន ក្នុងឆ្នាំ២០០៥ នេះ ។ កំហើញដ៏សំខាន់មួយនៃការអង្កេតនេះ បានបង្ហាញថាមានក្រុមការងារបច្ចេកទេសតិចតួចប៉ុណ្ណោះ ដែលបានរៀបចំការប៉ាន់ស្មានពីតំរូវការធនធាន សម្រាប់អនុវត្តផែនការសកម្មភាពឆ្នាំ២០០៥ ។ ក្នុងរបាយការណ៍ដែលស្នើជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ លេខាធិការដ្ឋានបានបញ្ជាក់ថា ក្រុមការងារបច្ចេកទេសណាដែលបាន ផ្សារភ្ជាប់សកម្មភាពរបស់ខ្លួនជាមួយនឹងតំរូវការធនធានសម្រាប់អនុវត្ត ក្រុមការងារបច្ចេកទេសនោះ សម្រេចបានលទ្ធផលប្រសើរជាងក្រុមការងារណាដែលមិនបានអនុវត្តតាមរបៀបនេះ ។ លើសពីនេះលេខាធិការដ្ឋានក៏បានកត់សំគាល់ផងដែរថា ក្នុងវិស័យដែលមានទំនាក់ទំនងយ៉ាងច្បាស់លាស់ រវាងសកម្មភាពដែលបានគ្រោងទុក ជាមួយនឹងធនធានដែលត្រូវការសម្រាប់អនុវត្តសកម្មភាពទាំងនេះ វិស័យនោះមានវឌ្ឍនភាពល្អប្រសើរជាងវិស័យដែលមានទំនាក់ទំនងខ្សោយ ឬគ្មានទំនាក់ទំនង ឬខ្វះភាពជាម្ចាស់របស់ស្ថាប័នពាក់ព័ន្ធ ។ ដូចនេះ ក្រុមការងារបច្ចេកទេសចម្រុះចាំបាច់ត្រូវយកចិត្តទុកដាក់ ពិសេស ទៅលើបញ្ហានេះ ។ ដោយសារតែធនធានហិរញ្ញវត្ថុមានក៏រិតជំនួយអភិវឌ្ឍន៍ផ្លូវការគឺជាប្រភពដសំខាន់សម្រាប់

ផ្តល់ហិរញ្ញប្បទានដល់កម្មវិធីអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ ការបែងចែក និងការប្រើប្រាស់ធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព ក្នុងក្របខ័ណ្ឌគណនេយ្យភាពទ្វេទិស ដើម្បីឆ្លើយតបនឹងអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល គឺជាប្រការមានសារៈសំខាន់សម្រាប់រាជរដ្ឋាភិបាល ។

១២២- នៅក្នុងដំណាក់កាល «រៀនផង-ធ្វើផង» បទពិសោធន៍ដែលក្រុមការងារបានដកស្រង់បាន គឺភាពប្រាកដប្រជានៃការកំណត់កាលបរិច្ឆេទសំរាប់អនុវត្តឱ្យបានសំរេចនូវផែនការសកម្មភាពរបស់ខ្លួន ។ នេះជាបទពិសោធន៍ដ៏សំខាន់មួយ ហើយរាជរដ្ឋាភិបាលសូមស្នើសមាជិកនៃក្រុមការងារទាំងអស់ កំណត់អំពីកាលបរិច្ឆេទឱ្យប្រាកដប្រជា ដោយត្រូវយកចិត្តទុកដាក់ដល់សមត្ថភាពរបស់ស្ថាប័ននៃរាជរដ្ឋាភិបាល និងភាពស្មុគស្មាញនៃដំណើរការអនុវត្តផងដែរ ។

## ១.២- ការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម និងការតម្រឹម

១២៣- ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ដែលបានរៀបចំតាមរយៈការពិគ្រោះយោបល់ទូលំទូលាយរវាងបណ្តាក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រី នាថ្ងៃ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤កន្លងមក ។ ដៃគូអភិវឌ្ឍន៍ចំនួន១២ ដែលបានបង្ហាញអំពីឆន្ទៈរបស់ខ្លួន ក្នុងការគាំទ្រការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម បានចុះហត្ថលេខាជាមួយរាជរដ្ឋាភិបាល នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍ទាំងនោះរួមមាន ÷ អូស្ត្រាលី កាណាដា ដាណឺម៉ាក បារាំង អាល្លឺម៉ង់ ជប៉ុន ស៊ុយអ៊ែត ចក្រភពអង់គ្លេស ធនាគារអភិវឌ្ឍន៍អាស៊ី សហគមន៍អឺរ៉ុប អង្គការអភិវឌ្ឍន៍សហប្រជាជាតិ និងធនាគារពិភពលោក ។

១២៤- សមាសភាគសំខាន់មួយនៃផែនការសកម្មភាពនេះ គឺការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រាប់រយៈពេល៥ឆ្នាំ ២០០៦-២០១០ សំរាប់ជាក្របខ័ណ្ឌក្នុងការតម្រឹមគ្រប់សកម្មភាពនានានៃជំនួយអភិវឌ្ឍន៍ផ្លូវការ ។ ក្នុងឆ្នាំ២០០៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះត្រូវបានរៀបចំ តាមរយៈការពិភាក្សាទូលំទូលាយមួយ រវាងរាជរដ្ឋាភិបាល បណ្តាដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ ២០០៦-២០១០ គឺជាឯកសារតែមួយគត់ ដែលបង្ហាញអំពីគោលដៅ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សំដៅកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់ និងសម្រេចឱ្យបាន នូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងបណ្តាគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច សម្រាប់អត្ថប្រយោជន៍របស់ប្រជាជនកម្ពុជាគ្រប់រូប ។

១២៥- ក្នុងដំណើរការរៀបចំរចនាសម្ព័ន្ធនៃក្រុមការងារបច្ចេកទេសចម្រុះឡើងវិញ លក្ខខ័ណ្ឌយោងនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ត្រូវបានពិនិត្យនិងកែតម្រូវ ហើយក្នុងឆ្នាំ២០០៥ ក្រុមការងារបច្ចេកទេសចម្រុះនេះបានប្តូរឈ្មោះជាក្រុមការងារស្តីពីភាពជាដៃគូនិងសុខដុម-នីយកម្មវិញ ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម មានភារកិច្ចក្នុងការសម្របសម្រួលការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ។ ក្រុមការងារនេះ

ក៏បានពិភាក្សាជាមួយក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ក្នុងការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម និងការតម្រឹម ដើម្បីឱ្យស្របនឹងការប្តេជ្ញាចិត្តនៃសេចក្តីប្រកាសទីក្រុងប៉ារីស ។ សេចក្តីប្រកាសទីក្រុងប៉ារីស គឺជាការប្តេជ្ញាចិត្តរបស់រដ្ឋមន្ត្រីនៃប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ និងប្រធានស្ថាប័នទ្វេភាគី និងពហុភាគី ដែលបានចូលរួមក្នុងវេទិកាកំរិតខ្ពស់ លើកទី២ នៅទីក្រុងប៉ារីស នាថ្ងៃទី២ ខែមិនា ឆ្នាំ២០០៥ ដើម្បីរៀបចំសកម្មភាព សំរាប់កំណែទំរង់លើ របៀប និងការគ្រប់គ្រងជំនួយអភិវឌ្ឍន៍ផ្លូវការ ក្នុងទិសដៅបង្កើនប្រសិទ្ធភាពជំនួយ ។ សេចក្តីប្រកាស ទីក្រុងប៉ារីស រួមមានការប្តេជ្ញាសំរាប់ពង្រឹងភាពជាដៃគូ ចំនួន ៥ ដូចខាងក្រោម÷

ក- ភាពជាម្ចាស់ : ប្រទេសដៃគូដឹកនាំ និងសម្របសម្រួលគ្រប់សកម្មភាពអភិវឌ្ឍន៍ ។

ខ- ការតម្រែតម្រង់ : អ្នកផ្តល់ជំនួយត្រូវតម្រឹមជំនួយរបស់ខ្លួនអោយស្របនឹងយុទ្ធសាស្ត្រ ស្ថាប័ន និងនីតិវិធីរបស់ប្រទេសដៃគូ ។

គ- សុខដុមនីយកម្ម : សកម្មភាពរវាងបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវមានសុខដុមនីយកម្ម តម្លាភាព និងប្រសិទ្ធភាព ។

ឃ- ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល : ការគ្រប់គ្រងធនធាន និងការកែលំអការធ្វើសេចក្តីសម្រេចដោយផ្តោតលើលទ្ធផល ។

ង- គណនេយ្យភាពទ្វេទិស : ដៃគូអភិវឌ្ឍន៍និងប្រទេសដៃគូត្រូវមានគណនេយ្យភាពរួមគ្នា ចំពោះលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។

១២៦- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំសិក្ខាសាលាមួយ រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នៅថ្ងៃទី ៤-៥ខែកក្កដាឆ្នាំ២០០៥ ដើម្បីពិនិត្យឡើងវិញនូវសេចក្តីព្រាងលើកទីមួយនៃផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ដែលគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានធ្វើបច្ចុប្បន្នភាព ។ បន្ទាប់មក សេចក្តីព្រាងដែលបានកែសំរួលរួចហើយនេះ ក៏ត្រូវបានពិភាក្សាម្តងទៀត រវាងបណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល នៅក្នុងសិក្ខាសាលា ២ថ្ងៃ នៅក្រុងព្រះសីហនុ នាថ្ងៃទី១-២ ខែ កញ្ញា ឆ្នាំ២០០៥ ។ គោលដៅចំបងនៃសិក្ខាសាលានេះ គឺដើម្បីពិនិត្យខ្លឹមសារនៃផែនការសកម្មភាព ព្រមទាំងបង្កើនការយល់ដឹងផែនការសកម្មភាពនេះក្នុងមជ្ឈដ្ឋាននៃរាជរដ្ឋាភិបាល សំដៅពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំដល់មន្ត្រីរាជការរបស់ក្រសួងនិងស្ថាប័ន ក្នុងការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ ។

១២៧- បន្ទាប់ពីសិក្ខាសាលាទាំងនេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជាបានពិនិត្យអំពីការអនុវត្តន៍នានារបស់ប្រទេសដទៃ ។ ទន្ទឹមនេះដែរ ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នាថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០០៥ របាយការណ៍ស្តីពីវឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្មនេះ បានបង្ហាញថា វឌ្ឍនភាពជាវិជ្ជមានលើផ្នែកទាំងឡាយណាដែលទាមទារអោយមាន

សកម្មភាពពីរាជរដ្ឋាភិបាល ។ ប៉ុន្តែ ផ្នែកទាំងឡាយណាដែលតម្រូវអោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍វិញ គឺមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ។ ផ្អែកតាមភាពជាក់ស្តែងនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបាន ពិនិត្យឡើងវិញសារជាថ្មីម្តងទៀត នូវផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលនេះ ដោយផ្អែកលើគោលការណ៍ដូចខាងក្រោម ÷

ក- ផែនការសកម្មភាពត្រូវតែស្របនឹងបណ្តាគោលការណ៍ស្តីពីភាពជាដៃគូ នៃសេចក្តីប្រកាស ទីក្រុងប៉ារីស ។

ខ- សកម្មភាពនីមួយៗនៃផែនការនេះត្រូវកំណត់ច្បាស់លាស់អំពីអ្នកទទួលខុសត្រូវអនុវត្ត ។

គ- ត្រូវកំណត់អំពីតម្រូវការធនធានហិរញ្ញវត្ថុ និងស្វែងរកដៃគូអភិវឌ្ឍន៍សំរាប់ផ្តល់ធនធាន ។

ឃ- ត្រូវកំណត់កាលបរិច្ឆេទប្រាកដប្រជា ក្នុងការអនុវត្តន៍បញ្ចប់សកម្មភាពនីមួយៗ ដោយត្រូវផ្អែក លើភាពស្មុគស្មាញនៃកិច្ចដំណើរការផងដែរ ។

១២៨- ផ្អែកតាមភាពជាក់ស្តែងនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានពិនិត្យកែសំរួលសេចក្តីព្រាងផែនការ សកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលនេះឡើងវិញ ហើយបានដាក់ស្នើតំណាងក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពិភាក្សាម្តងទៀតក្នុងសិក្ខាសាលា កាលពីថ្ងៃទី០៧ ខែ មករា ឆ្នាំ២០០៦ ។ សេចក្តីព្រាងបញ្ចប់នៃផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល បានអនុមតិដោយសម្តេច នាយករដ្ឋមន្ត្រី នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦ (ឧបសម្ព័ន្ធទី១) ។

១២៩- ទន្ទឹមនេះ របកគំហើញនៃការសិក្សារបស់ចក្រភពអង់គ្លេសស្តីពីសុខដុមនីយកម្ម និងការសម្របសម្រួល ជំនួយនៅកម្ពុជា ដែលបានបញ្ចប់នាចុងឆ្នាំ២០០៥នេះ ក៏បានបង្ហាញដែរថា ទាំងខាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ មិនទាន់យល់បានច្បាស់លាស់អំពីការប្តេជ្ញាដែលបានឯកភាពជាអន្តរជាតិ ហើយដែលមាន ចែងក្នុងសេចក្តីប្រកាសទីក្រុងរ៉ូម និងទីក្រុងប៉ារីសនៅឡើយ ។ នៅក្នុងកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេស ចម្រុះស្តីពីភាពជាដៃគូនិងសុខដុមនីយកម្ម នាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៥ និងកិច្ចប្រជុំរបស់គណៈកម្មាធិការ សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៥ កន្លងមកនេះ រាជ រដ្ឋាភិបាលបានស្នើឱ្យភាគីទាំង២ចាត់វិធានការចាំបាច់នានា ដើម្បីកែលំអស្ថានភាពនេះ ព្រមទាំងលើកឡើង អំពីតម្រូវការនានា សម្រាប់ភាគីទាំងសងខាងធ្វើការរួមគ្នា ក្នុងស្មារតីគណនេយ្យភាពទ្វេទិស ដែលជា គ្រឹះនៃសេចក្តីប្រកាសទីក្រុងប៉ារីស ។ លើសពីនេះ រាជរដ្ឋាភិបាលបានកត់សំគាល់ឃើញថា បើគ្រាន់តែ រៀបចំផែនការសកម្មភាព ដោយមិនយល់ច្បាស់អំពីបញ្ហា និងដោយគ្មានការប្តេជ្ញាចិត្តក្នុងការអនុវត្តន៍ សកម្មភាព នោះយើងមិនអាចសំរេចផែនការនេះប្រកបដោយជោគជ័យឡើយ ។

១៣០- ក្នុងការត្រួតពិនិត្យ និងសម្របសម្រួលការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និង លទ្ធផល តាមរយៈការពិភាក្សានៅក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងបន្តផ្តល់នូវការណែនាំ និងជំនួយបច្ចេកទេសដល់ក្រុមការងារបច្ចេកទេស ចម្រុះទាំងអស់ ហើយក្រុមបច្ចេកទេសចម្រុះតាមវិស័យនិមួយៗ នឹងបន្តទទួលខុសត្រូវការគ្រប់គ្រងការ

អនុវត្តន៍សកម្មភាពនានា ដែលមានចែងក្នុងផែនការសកម្មភាព ព្រមទាំងត្រួតពិនិត្យវឌ្ឍនភាពក្នុងវិស័យនិមួយៗដែលខ្លួនទទួលខុសត្រូវ ។

## ១.៣- ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

១៣១- ក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍តាមរយៈការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍ ។ សេចក្តីព្រាងយុទ្ធសាស្ត្រនេះត្រូវបានអនុមតិដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ ដំណើរការពិគ្រោះយោបល់នេះ រួមមាន ÷

- ការពិនិត្យឡើងវិញនូវសេចក្តីព្រាងដំបូងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រ តាមរយៈកិច្ចប្រជុំអន្តរក្រសួងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នាថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ ។ សេចក្តីព្រាងដំបូងត្រូវបានកែសម្រួលដោយផ្អែកតាមធាតុចូលដែលទទួលបានពីកិច្ចប្រជុំនេះ ។
- សេចក្តីព្រាងដែលបានកែសម្រួលនេះ ត្រូវបានដាក់ជូនឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យនិងផ្តល់អនុសាសន៍ ។ អនុសាសន៍របស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិត្រូវបានច្របាច់បញ្ចូលទៅក្នុងសេចក្តីព្រាង ហើយដែលត្រូវបានអនុម័តជាផ្លូវការដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ នៅខែកញ្ញា ឆ្នាំ២០០៥ ។
- ប្រធានក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូនិងសុខដុមនីយកម្ម បានផ្ញើសេចក្តីព្រាងលើកទី២ នេះ ជូនអ្នកសម្របសម្រួលនាំមុខរបស់ក្រុមការងារនេះ ដើម្បីយកទៅពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ និងផ្តល់អនុសាសន៍ពីដៃគូអភិវឌ្ឍន៍មកប្រធានក្រុមការងារវិញ ។
- សេចក្តីព្រាងបញ្ចប់ត្រូវបានរៀបចំឡើងវិញ ដែលបញ្ចូលនូវមតិយោបល់របស់ដៃគូអភិវឌ្ឍន៍ ក្នុងប៉ារ៉ាម៉ែត្រនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងស្នើជូនគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងអនុមតិ ។ រីឯដៃគូអភិវឌ្ឍន៍ទាំងអស់ក៏បានទទួលសេចក្តីព្រាងបញ្ចប់នេះផងដែរ តាមរយៈអ្នកសម្របសម្រួលនាំមុខនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ។

១៣២- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ បានបញ្ជាក់អំពីក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបណ្តាកិច្ចប្រតិបត្តិការនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកិច្ចសហ-ប្រតិបត្តិការអភិវឌ្ឍន៍ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះបានរៀបរាប់អំពី ÷

ក- តួនាទីនិងភារកិច្ចនៃ «ចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល» ក្នុងការកៀរគរនិងសម្របសម្រួលជំនួយ ។

ខ- ស្ថានភាពបច្ចុប្បន្ន និងគំនិតផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាលនិងសហគមន៍អន្តរជាតិ ក្នុងការពង្រឹង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

គ- គោលដៅនិងគោលការណ៍សំខាន់ៗសំរាប់ណែនាំការគ្រប់គ្រងកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ ។

ឃ- កម្មវិធីជាតិសំរាប់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ។

១៣៣- ដូចបានបញ្ជាក់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្ររួចហើយ រាជរដ្ឋាភិបាលចង់អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ តាមរយៈកម្មវិធីដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើន ។ ទស្សនៈស្នូលនៃកម្មវិធីនេះ គឺការពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំលើដំណើរការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងការគ្រប់គ្រងជំនួយអភិវឌ្ឍន៍ផ្លូវការ ដើម្បីសម្រេចអោយបានលទ្ធផលខ្ពស់ ក្នុងកិច្ចអភិវឌ្ឍន៍ ។ កម្មវិធីនេះមានគោលដៅក្នុងការអភិវឌ្ឍន៍សមត្ថភាពរបស់ ក.អ.ក/គ.ជ.នា ដែលជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាលសម្រាប់កៀរគរនិងសម្របសម្រួលជំនួយ ។ កម្មវិធីនេះក៏មានគោលដៅអភិវឌ្ឍសមត្ថភាពរបស់ក្រសួងនិងស្ថាប័នជំនាញពាក់ព័ន្ធនានាផងដែរ ដើម្បីគ្រប់គ្រងជំនួយបរទេសឱ្យមានប្រសិទ្ធភាពដែរ ។ កម្មវិធីដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើន នឹងត្រូវគ្រប់គ្រងដោយ ក.អ.ក/គ.ជ.នា ។ ទំរង់ការនៃការផ្តល់ហិរញ្ញប្បទានដែលរាជរដ្ឋាភិបាលចង់បាន សំរាប់អនុវត្តកម្មវិធី នេះ គឺការដាក់ធនធានបញ្ចូលគ្នា ឬការធ្វើសហហិរញ្ញប្បទាន រួមគ្នាដោយដៃគូអភិវឌ្ឍន៍នានា ។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនឹងបង្កើតយន្តការធនធានបញ្ចូលគ្នា ដើម្បីគ្រប់គ្រងហិរញ្ញប្បទានដែលទទួលពីដៃគូអភិវឌ្ឍន៍ ។ ក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិសម្រាប់ឆ្នាំ២០០៦-២០១០ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបានផ្តល់ថវិកាចំនួន១,១៦លានដុល្លារអាមេរិក ទៅក្នុងយន្តការធនធានរួមគ្នា នេះ ។ ដោយប្រើប្រាស់ថវិកានេះជាធនធានស្នូល ក.អ.ក/គ.ជ.នា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនឹងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលមានបំណងផ្តល់ហិរញ្ញប្បទានដល់កម្មវិធីនេះ តាមរយៈទំរង់ការនៃធនធានបញ្ចូលគ្នា ។ មកដល់ពេលនេះ បន្ថែមលើធនធានសន្យារបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ចក្រភពអង់គ្លេសបានសំដែងអំពីការគាំទ្រ ក្នុងការចូលរួមក្នុងការផ្តល់ហិរញ្ញប្បទាន តាមរយៈយន្តការធនធានបញ្ចូលគ្នានេះដែរ ។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនឹងទទួលខុសត្រូវលើការបំពេញបែបបទផ្លូវការផ្សេងៗជាមួយដៃគូអភិវឌ្ឍន៍ ហើយក៏ទទួលខុសត្រូវក្នុងការទទួល និងការប្រើប្រាស់ធនធានដែលប្រមូលបានពីដៃគូអភិវឌ្ឍន៍នេះផងដែរ ។

១៣៤- ចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយណាដែលមិនអាចរួមចំណែកដល់កម្មវិធីនេះ តាមរយៈ «ទំរង់ការធនធានបញ្ចូលគ្នា» ដោយសារច្បាប់និងនីតិវិធីផ្ទៃក្នុងនៃដៃគូអភិវឌ្ឍន៍ ដៃគូអភិវឌ្ឍន៍នោះអាចគាំទ្រកម្មវិធីនេះដោយផ្តល់ហិរញ្ញប្បទានដោយផ្ទាល់មក ក.អ.ក/គ.ជ.នា ។ ទំរង់បែបបទផ្លូវការនានាសម្រាប់ចូលរួមតាមទំរង់ការនេះ នឹងត្រូវរៀបចំដោយឡែក តាមរយៈកិច្ចព្រមព្រៀងរវាង ក.អ.ក/គ.ជ.នា និងដៃគូអភិវឌ្ឍន៍នោះ ។ ដៃគូអភិវឌ្ឍន៍ដែលជ្រើសរើសយកទំរង់ការនេះ នឹងបានទទួលរបាយការណ៍តាមកាលកំណត់ ស្តីពីហិរញ្ញវត្ថុនិងវឌ្ឍនភាពដែលសម្រេចបាន តាមទំរង់របាយការណ៍ដូចគ្នានឹងទំរង់របាយការណ៍ដែលប្រើប្រាស់សម្រាប់ «ទំរង់ការធនធានបញ្ចូលគ្នា» ដែរ ។

## ១.៤- ការរៀបចំគោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់ជំនួយឥតសំណង និង នីតិវិធីបទដ្ឋានសហប្រតិបត្តិការសំរាប់ជំនួយជាកម្ចី

១៣៥- ក្រុមការងារបច្ចេកទេសចំរុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម បានរៀបចំ «គោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់ជំនួយឥតសំណង» ។ អនុក្រុមការងារ ដែលរួមមានតំណាងរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើងសំរាប់ដឹកនាំការរៀបចំនេះ ។ គោលដៅចំបងនៃ «គោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់ជំនួយឥតសំណង» នេះ គឺការកំណត់អំពីគោលនយោបាយ និងទំរង់ការប្រតិបត្តិការសំរាប់រៀបចំផែនការនិងការគ្រប់គ្រងបណ្តាសកម្មភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ «គោលការណ៍ណែនាំ» នេះ បានបញ្ជាក់លំអិតបន្ថែម អំពីគោលការណ៍ និងគោលនយោបាយដែលមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ «គោលការណ៍ណែនាំ» នេះត្រូវបានរៀបចំឡើង ដោយផ្អែកតាមគោលការណ៍សំខាន់ៗនៃការអនុវត្តន៍ល្អៗរបស់គណៈកម្មាធិការសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ ព្រមទាំងបញ្ចូលនូវការអនុវត្តន៍ល្អៗរបស់កម្ពុជា ក្នុងការរៀបចំផែនការការគ្រប់គ្រង និងការអនុវត្តន៍កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ ។ «គោលការណ៍ណែនាំ» នេះគឺជាឯកសារបង្អែក ដែលបានបញ្ជាក់អំពីគោលនយោបាយ ទំរង់ការប្រតិបត្តិការ និងភារកិច្ចទទួលខុសត្រូវខាងផ្នែកស្ថាប័ន ដែលបណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវប្រើប្រាស់ទាំងអស់គ្នា សំរាប់មិនត្រឹមតែបង្កើនប្រសិទ្ធភាពជំនួយប៉ុណ្ណោះទេ ប៉ុន្តែ ក៏អាចជួយកាត់បន្ថយបន្ទុករបស់ស្ថាប័នអនុវត្តរបស់រាជរដ្ឋាភិបាលផងដែរ ។ រាជរដ្ឋាភិបាលសូមស្នើអោយដៃគូអភិវឌ្ឍន៍ទាំងអស់ប្រើប្រាស់ «គោលការណ៍ណែនាំ» នេះ សំរាប់រៀបចំផែនការ និងគ្រប់គ្រងគំរោង និងកម្មវិធីអភិវឌ្ឍន៍របស់ខ្លួន ។ ការរៀបចំ «គោលការណ៍ណែនាំ» នេះត្រូវបានគាំទ្រដោយអង្គការអភិវឌ្ឍន៍សហប្រជាជាតិ ។

១៣៦- ការរៀបចំ«គោលការណ៍ណែនាំប្រតិបត្តិការជាតិសំរាប់ជំនួយឥតសំណង» នេះ ត្រូវបានសហការយ៉ាងជិតស្និទ្ធជាមួយនឹងការរៀបចំ «ទំរង់ការស្តង់ដារនៃកិច្ចប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី» ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបរៀបចំបញ្ចប់ ដោយមានកិច្ចសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ។

## ១.៥- ការគាំទ្រមន្ត្រីនៃក្រសួងនិងស្ថាប័ននានា ក្នុងការធ្វើជាម្ចាស់ពិតប្រាកដលើសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍

១៣៧- ក្នុងឆ្នាំ២០០៥ ក.អ.ក/គ.ជ.នា បានចាប់ផ្តើមពិភាក្សាមួយជាមួយក្រសួងពាក់ព័ន្ធនៃរាជរដ្ឋាភិបាល អំពីបញ្ហាបង្កើនប្រសិទ្ធភាពជំនួយ និងការកំណត់តំរូវការគាំទ្រជាក់លាក់ សំរាប់ឱ្យក្រសួងទាំងនោះមានលទ្ធភាពពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ក.អ.ក/គ.ជ.នា បានកំណត់អាទិភាពក្នុងការបន្តផ្តល់ការគាំទ្រ តាមរយៈការធ្វើសិក្ខាសាលា និងទំរង់ការគាំទ្រផ្សេងៗទៀត ដើម្បីឆ្លើយតបនឹងតម្រូវការទាំងនេះ ។ ក.អ.ក/គ.ជ.នា បានចាប់ផ្តើមរៀបចំសិក្ខាសាលា

ដើម្បីបង្កើនការយល់ដឹងកាន់តែស៊ីជំរៅអំពីបញ្ហា និងអភិក្រមនៅក្នុងវិស័យគន្លឹះមួយចំនួន ដូចជា ÷ សុខដុមនីយកម្មនិងការតម្រែតម្រង់ អភិក្រមគ្រប់គ្រងតាមកម្មវិធី ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងការគ្រប់គ្រងដោយផ្តោតទៅលើលទ្ធផល ។ បន្ថែមលើសិក្ខាសាលាស្តីពីការងារសុខដុមនីយកម្ម និងការតម្រឹម ក.អ.ក/គ.ជ.នា ក៏បានរៀបចំសិក្ខាសាលាមួយទៀត ស្តីពីទស្សនៈនៃការគ្រប់គ្រងទូទាំងវិស័យ រយៈពេល ២ថ្ងៃ នៅថ្ងៃទី៩-១០ ខែមិថុនា ឆ្នាំ២០០៥ ក្រោមការឧបត្ថម្ភពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ស៊ុយអ៊ែដ ។ លើសពីនេះ ក.អ.ក/គ.ជ.នា ក៏បានរៀបចំសិក្ខាសាលា រយៈពេល២ថ្ងៃ មួយទៀត នៅ ក្រុងព្រះសីហនុ នាថ្ងៃទី១-២ ខែកញ្ញា ឆ្នាំ២០០៥ ដោយអញ្ជើញតំណាងក្រសួងនិងស្ថាប័ននានានៃរាជ រដ្ឋាភិបាល ដើម្បីពិភាក្សាសេចក្តីប្រកាសទីក្រុងប៉ារីស និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពី សុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។ បទបង្ហាញនានា និងការពិភាក្សាក្នុងសិក្ខាសាលានាពេលនោះ បានផ្តោតលើសេចក្តីប្រកាសទីក្រុងប៉ារីស ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ព្រមទាំងការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។ សិក្ខាសាលានេះត្រូវបានឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ។ ក្នុងឆ្នាំ២០០៦ ក.អ.ក/គ.ជ.នា នឹងបន្តរៀបចំសិក្ខាសាលារបៀបនេះ សំរាប់ពិភាក្សាលើប្រធានបទពាក់ព័ន្ធដទៃទៀត ។

## ១.៦- ការរៀបចំ និងអនុវត្តន៍ការប្រមូលព័ត៌មានអំពីការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ តាមគេហទំព័ររបស់ ក.អ.ក/ គ.ជ.នា

១៣៨- ក្នុងឆ្នាំ២០០៥ ក.អ.ក/គ.ជ.នា បានបង្កើត និងដាក់ឱ្យដំណើរការគេហទំព័រមួយសម្រាប់ប្រមូលព័ត៌មានអំពីការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ។ គេហទំព័រនេះត្រូវបានរៀបចំបង្កើតឡើង ដើម្បីឱ្យ ÷ ១) ដៃគូអភិវឌ្ឍន៍អាចធ្វើរបាយការណ៍អំពីការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការដោយផ្ទាល់នៅក្នុងគេហទំព័រ និង ២) សាធារណជនទូទៅអាចទទួលពត៌មានស្តីពីការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ។ គេហទំព័រនេះមាន ប្រព័ន្ធ "Query" ដែលអ្នកប្រើប្រាស់អាចទទួលបានព័ត៌មានជាក់លាក់ស្តីពីលំហូរជំនួយអភិវឌ្ឍន៍ផ្លូវការតាមរយៈប្រព័ន្ធពត៌មាននេះ ។ ទន្ទឹមនេះ គេហទំព័រនេះក៏ត្រូវបានប្រើប្រាស់ ដើម្បីប្រមូលទិន្នន័យស្តីពីការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ពីដៃគូអភិវឌ្ឍន៍សំរាប់ឆ្នាំ២០០៥ផងដែរ ។ គេហទំព័រត្រូវបានរៀបចំ បង្កើត និងអនុវត្តដោយបុគ្គលិកកម្ពុជា ។ នៅឆ្នាំក្រោយនេះ ក.អ.ក/គ.ជ.នា នឹងបញ្ចេញនូវ Software ដែលបានបង្កើតឡើងដោយគ្មានចំណាយបន្ថែម សំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ដែលចង់បង្កើតប្រព័ន្ធគ្រប់គ្រងពត៌មានរបស់ខ្លួន សំរាប់គ្រប់គ្រងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមរយៈគេហទំព័រនេះ ។

## ១.៧- ភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជន

១៣៩- រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជន ជាក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលនឹងបន្តតួនាទីជាយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីបង្កើតបរិស្ថានធុរៈកិច្ចអោយកាន់តែប្រសើរសំរាបវិស័យឯកជន និងការ

គ្រប់គ្រងការអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលបានកំណត់ថា ការកែលំអបរិស្ថានសំរាប់ធុរៈកិច្ច និងការបង្កើតបរិស្ថានអំណោយផលសំរាប់អភិវឌ្ឍវិស័យឯកជន គឺជាបុរេលក្ខខ័ណ្ឌសំរាប់ជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ដើម្បីលុបបំបាត់កត្តារាំងស្ទះដល់ការអភិវឌ្ឍន៍វិស័យឯកជន និងក្នុងដំណើរការកំណែទំរង់រដ្ឋបាលនិងគតិយុត្តិ រាជរដ្ឋាភិបាលបានបន្តវេទិការវាងរាជរដ្ឋាភិបាលនិងឯកជន ជាទៀងទាត់រៀងរាល់៦ខែម្តង ។ លើសពីនេះ ដើម្បីពង្រឹងវេទិការវាងរាជរដ្ឋាភិបាលនិងឯកជននេះ រាជរដ្ឋាភិបាលក៏បានបង្កើតគណៈកម្មាធិការដឹកនាំការងារ សំរាប់ការអភិវឌ្ឍន៍ផ្នែកឯកជន នាពាក់កណ្តាលឆ្នាំ២០០៤ ។ គណៈកម្មាធិការដឹកនាំការងារសំរាប់កិច្ចអភិវឌ្ឍន៍ផ្នែកឯកជនបានបង្កើតអនុគណៈកម្មាធិការចំនួន ៣ គឺ ÷ ១)អនុគណៈកម្មាធិការសំរាប់បរិស្ថានវិនិយោគនិងការចូលរួមរបស់ផ្នែកឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ ដែលដឹកនាំដោយឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២) អនុគណៈកម្មាធិការ ទទួលខាងកិច្ចសំរួលពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង៣) អនុគណៈកម្មាធិការខាងសហគ្រាសតូចនិងមធ្យម ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ កន្លងមក យន្តការទាំងនេះមិនត្រឹមតែបានដំណើរការប្រកបប្រសិទ្ធភាព ក្នុងការពង្រឹងភាពជាដៃគូជាមួយវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់ធាតុចូលសំខាន់ៗសំរាប់ដំណើរការនៃការធ្វើអាទិភាពនីយកម្មសកម្មភាពក្នុងកម្មវិធីកំណែទំរង់ទៀតផង ។

## ១.៨- ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល

១៤០- រាជរដ្ឋាភិបាលមានជំនឿថា សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលអាចដើរតួយ៉ាងសំខាន់ ក្នុងការពិនិត្យ តាមដានការអនុវត្តន៍គំនិតផ្តួចផ្តើមស្តីពីការកាត់បន្ថយភាពក្រីក្រ ដែលមានចែងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ៥ឆ្នាំ ២០០៦-២០១០ ។ អង្គការក្រៅរដ្ឋាភិបាលកម្ពុជាគឺជាផ្នែកមួយនៃសង្គមស៊ីវិល ។ អង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមចំណែកយ៉ាងច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ ដោយផ្អែកលើបទពិសោធន៍ អំពីការងារអភិវឌ្ឍន៍របស់ខ្លួន ហើយក៏ដើរតួនាទីសំខាន់ក្នុងការពាំនាំតម្រូវការ និងការបារម្ភរបស់ក្រុមជនងាយរងគ្រោះ ជំរាបមកអ្នករៀបចំគោលនយោបាយផងដែរ ។ លើសពីនេះ អង្គការមិនមែនរដ្ឋាភិបាលបានចូលរួមយ៉ាងទៀងទាត់ ក្នុងកិច្ចប្រជុំប្រចាំត្រីមាសនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែទូលំទូលាយឡើងថែមទៀត ពីសំណាក់សហជីព សមាគមជនជាតិ និងសមាគមកសិករ នៅក្នុងការតាមដានការអនុវត្តន៍គំនិតផ្តួចផ្តើមនានាស្តីពីការកាត់បន្ថយភាពក្រីក្រនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។ ដើម្បីកំណត់គំនិតផ្តួចផ្តើមស្តីពីការកាត់បន្ថយភាពក្រីក្រឱ្យបានចំទិស ចាំបាច់ត្រូវពង្រឹងការចូលរួមរបស់ជន ក្រីក្រ និងក្រុមជនងាយរងគ្រោះ ក្នុងការតាមដានកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ។ ទន្ទឹមនេះ ក៏មានការចាំបាច់ផងដែរ ក្នុងការពង្រឹងសមត្ថភាពរបស់ស្ថាប័ននីតិបញ្ញត្តិ ដើម្បីឱ្យស្ថាប័នទាំងនេះអាចផ្តល់ធាតុចូលជាក់ស្តែង ។

## ២- បញ្ហាប្រឈម និងទិសដៅអនាគត

១៤១- សេចក្តីប្រកាសទីក្រុងរ៉ូមស្តីពីសុខដុមនីយកម្មឆ្នាំ ២០០៣ និងសេចក្តីប្រកាសទីក្រុងប៉ារីស ស្តីពីប្រសិទ្ធភាពជំនួយ នាដើមឆ្នាំ២០០៥ បានបញ្ជាក់ពីភាពជាម្ចាស់នៃកិច្ចដំណើរការអភិវឌ្ឍន៍របស់ប្រទេសទទួលជំនួយអភិវឌ្ឍន៍ផ្លូវការ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាធ្វើជាម្ចាស់យ៉ាងពេញលេញ មិនត្រឹមតែក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ ប៉ុន្តែ នឹងធានាថា ធនធានជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវបានប្រើប្រាស់ចំទិសដៅ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍អាទិភាព សម្រាប់ជាអត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

១៤២- ទោះជាមានការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិយ៉ាងណាក៏ដោយ ក៏ការអនុវត្តន៍ជាក់ស្តែងរបស់ដៃគូអភិវឌ្ឍន៍មួយចំនួន បាននិងកំពុងបន្តអនុវត្តតាមគន្លងនៃទសវត្សរ៍ឆ្នាំ១៩៩០ ដែលការសិក្សាជាច្រើនបានប្រសិទ្ធនាមថា ជាដំណាក់នៃ «ការផ្តល់ជំនួយតាមទស្សនៈរបស់ពួកអ្នកផ្តល់ជំនួយ» ។ បញ្ហាប្រឈមរបស់ដៃគូអភិវឌ្ឍន៍ទ្វេ- ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល គឺការប្រែក្លាយឱ្យបានឆាប់នូវការប្តេជ្ញាចិត្តដែលបានធ្វើឡើងក្នុងវេទិកាអន្តរជាតិ ឱ្យទៅជាសកម្មភាពប្រតិបត្តិការជាក់លាក់ ដើម្បីផ្លាស់ប្តូរទំលាប់នៃការអនុវត្តន៍របស់ដៃគូអភិវឌ្ឍន៍ សំដៅផ្តល់ឱកាសអោយរាជរដ្ឋាភិបាលពង្រឹងភាពជាម្ចាស់ក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ក្នុងបរិបថនៃកិច្ចសហប្រតិបត្តិការ ដោយមានការជឿទុកចិត្តគ្នាទៅវិញទៅមក មានគណនេយ្យទ្វេទិស សំដៅបង្កើនប្រសិទ្ធភាពជំនួយ ដើម្បីផ្តល់អត្ថប្រយោជន៍ឱ្យបានច្រើនបំផុត ដល់ប្រជាពលរដ្ឋកម្ពុជា ។ ចំពោះបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលវិញ គឺការបន្តពង្រឹងប្រព័ន្ធគ្រប់គ្រង និងការរៀបចំស្ថាប័នឱ្យមានតម្លាភាព និងគណនេយ្យភាព សំដៅពង្រឹងប្រសិទ្ធភាពជំនួយ ។

១៤៣- បញ្ហាបន្ទាន់នាពេលនេះ គឺការបោះបង់ចោលនូវទំលាប់ដែលធ្លាប់អនុវត្តកន្លងមកក្នុងកំឡុងទស្សវត្សរ៍ ឆ្នាំ៩០ ដែលសកម្មភាពនៃជំនួយអភិវឌ្ឍន៍បានត្រូវរៀបចំ គ្រប់គ្រង និងផ្តល់ដោយដៃគូអភិវឌ្ឍន៍ ហើយ ភាពជាម្ចាស់ក្នុងការជ្រើសរើសសំរាប់កិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងអភិវឌ្ឍន៍របស់ស្ថាប័នកម្ពុជានៅ មានកំរិត ។ ដូចបានរៀបរាប់ពីខាងដើម ក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នាខែធ្នូ ឆ្នាំ២០០៥ ស្តីពីវឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្មនិងការតម្រឹម លេខាធិការដ្ឋានបានបញ្ជាក់ថា មានវឌ្ឍនភាពជាវិជ្ជមាននៅតាមបណ្តាផ្នែកដែលទាមទារអោយមានសកម្មភាពពីរាជរដ្ឋាភិបាល ។ ប៉ុន្តែ ចំពោះផ្នែកទាំងឡាយណាដែលគាំទ្រពីដៃគូអភិវឌ្ឍន៍វិញ គឺមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ។ ទន្ទឹមនេះ របកគំហើញនៃការសិក្សារបស់ចក្រភពអង់គ្លេស ស្តីពីសុខដុមនីយកម្មនិងការសម្របសម្រួលជំនួយនៅកម្ពុជាដែលបានបញ្ចប់នៅចុងឆ្នាំ២០០៥នេះ ក៏បានបង្ហាញថា ទាំងខាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ មិនទាន់យល់បានច្បាស់លាស់អំពីការប្តេជ្ញាដែលបានឯកភាពជាអន្តរជាតិ ហើយដែលមានចែងក្នុងសេចក្តីប្រកាសទីក្រុងរ៉ូម និងសេចក្តីប្រកាសទីក្រុងប៉ារីសនៅឡើយ ។ រាជរដ្ឋាភិបាលទទួលស្គាល់អំពីភាពចាំបាច់ក្នុងការពង្រឹងការយល់ដឹងអំពីសេចក្តីប្រកាសទីក្រុងរ៉ូមនិងទីក្រុងប៉ារីស ដល់មន្ត្រីរបស់ក្រសួងនិងស្ថាប័ន

តាមរយៈការចាត់វិធានការជាក់លាក់ក្នុងឆ្នាំ២០០៥កន្លងមក ។ រាជរដ្ឋាភិបាលក៏ចង់អោយដៃគូអភិវឌ្ឍន៍បញ្ជាក់អំពីការប្តេជ្ញានិងឆន្ទៈខាងនយោបាយរៀងៗខ្លួន ដើម្បីអនុវត្តរួមគ្នានូវការប្តេជ្ញាចិត្តនៃសេចក្តីប្រកាសទីក្រុងរ៉ូម និងទីក្រុងប៉ារីស ។ តាមរយៈស្មារតីនៃសេចក្តីប្រកាសទទាំង២នេះ ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវផ្តល់អាទិភាពខ្ពស់ទៅលើកិច្ចការមួយចំនួនដូចខាងក្រោម ÷

- ធ្វើសុខដុមនីយកម្មការអនុវត្តន៍របស់ខ្លួន ដើម្បីកាត់បន្ថយបន្ទុកខាងស្ថាប័នប្រតិបត្តិឱ្យបានច្រើន និងកាត់បន្ថយភាពខ្ជះខ្ជាយ តាមរយៈការកាត់បន្ថយសកម្មភាពជាន់គ្នា សំដៅបង្កើនប្រសិទ្ធភាពជំនួយអភិវឌ្ឍន៍ផ្លូវការ ។
- តម្រឹមការគាំទ្ររបស់ខ្លួន ជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ ២០០៦-២០១០ ។
- ទម្រង់ការនៃការគ្រប់គ្រងកម្មវិធី និងគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវអនុវត្តតាមគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ ស្តីពីការអនុវត្តន៍ល្អៗសម្រាប់ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងគោលការណ៍នៃភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ។
- ផ្ទេរធនធានជំនួយអភិវឌ្ឍន៍ផ្លូវការច្រើនជាងមុន ដោយឆ្ពោះទៅលើជនក្រីក្រ និងជនងាយរងគ្រោះសំដៅកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

១៤៤- រាជរដ្ឋាភិបាលបានប្តេជ្ញាពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ (អ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល) ដោយផ្អែកលើគោលការណ៍នៃកិច្ចសហប្រតិបត្តិការការជឿទុកចិត្តគ្នាទៅវិញទៅមក និងគណនេយ្យភាពទ្វេទិស ។ ដូចបានរៀបរាប់ពីខាងដើម យន្តការថ្មីក្នុងការពង្រឹងការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ ។ យន្តការថ្មីនេះ ដែលមានក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យទាំង ១៨ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺជាវេទិកាសម្រាប់ឱ្យស្ថាប័នផ្តល់ជំនួយទ្វេ-ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមពិភាក្សាជាមួយរាជរដ្ឋាភិបាល ទាំងក្នុងកំរិតបច្ចេកទេស និងកំរិតនយោបាយ ។ រីឯយន្តការនៃវេទិការវាងវិស័យឯកជននិងរាជរដ្ឋាភិបាលវិញ ក៏បានដំណើការរលូនសម្រាប់កសាងភាពជាដៃគូឱ្យមានប្រសិទ្ធភាពជាមួយនឹងវិស័យឯកជនផងដែរ ។

១៤៥- ចំពោះអាទិភាពសំរាប់ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាស្នើដៃគូអភិវឌ្ឍន៍ទ្វេនិងពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល ឱ្យយកចិត្តទុកដាក់លើបណ្តាចំណុចដូចខាងក្រោម ÷

ក- បង្កើនភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើកម្មវិធីនិងគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ ក្នុងក្របខ័ណ្ឌនៃគណនេយ្យភាពទ្វេទិស ។ លើសពីនេះ បណ្តាអង្គការមិនមែនរដ្ឋាភិបាល ត្រូវសម្របសម្រួលសកម្មភាពរបស់ខ្លួន ជាមួយនឹងក្រសួងពាក់ព័ន្ធ ដើម្បីកំណត់ទិសដៅ និងកាត់បន្ថយសកម្មភាពជាន់គ្នាឱ្យបាន ច្រើនសំដៅទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនបំផុតពីធនធានអភិវឌ្ឍន៍ដែលមានកំរិតកំណត់ ។

ក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យត្រូវអាចដើរតួនាទីដ៏សំខាន់ ក្នុងការសម្របសម្រួលកិច្ចការងារទាំងនេះ ។

ខ- ពង្រឹងការសម្របសម្រួលកម្មវិធី និងគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល ជាមួយនឹងក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមថ្នាក់ជាតិ ។

គ- អនុវត្តបណ្តាគោលការណ៍ ដែលចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងមាត្រា១៣ ១៤ ១៥ និង១៦ នៃអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥ ក៏ដូចជាគោលការណ៍ណែនាំ និងនីតិវិធី ដែលមានចែងក្នុងគោលការណ៍ប្រតិបត្តិជាតិរបស់រាជរដ្ឋាភិបាលសម្រាប់ជំនួយឥតសំណង និងទំរង់ការស្តង់ដារនៃកិច្ចប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី ។

ឃ- បង្វែរពីរូបភាពទៅខ្លឹមសារ សំរាប់កិច្ចពិភាក្សារបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ការងារនេះទាមទារឱ្យមានការចូលរួមពីមន្ត្រីរបស់ដៃគូអភិវឌ្ឍន៍ដែលមានជំនាញកំរិតខ្ពស់ នៅតាមវិស័យនីមួយៗនៃក្រុមការងារបច្ចេកទេសចម្រុះ ។ រាជរដ្ឋាភិបាលស្នើអោយដៃគូអភិវឌ្ឍន៍បញ្ឈប់ការចំណាយ សំរាប់រក្សាអ្នកដែលគ្មានឯកទេសច្បាស់លាស់នៅតាមក្រុមការងារ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏ស្នើឱ្យដៃគូអភិវឌ្ឍន៍នីមួយៗធ្វើការជ្រើសរើសវិស័យសំខាន់ចម្បងៗរបស់ខ្លួន ហើយផ្តល់អ្នកឯកទេសកំរិតអន្តរជាតិតាមវិស័យទាំងនោះ ទៅតាមលទ្ធភាពថវិការបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។ រាជរដ្ឋាភិបាលមិនលើកទឹកចិត្តការប្រើប្រាស់មន្ត្រីរបស់ដៃគូអភិវឌ្ឍន៍ ដែលគ្មានជំនាញបច្ចេកទេសឯកទេសគ្រប់គ្រាន់និងច្បាស់លាស់ ឬគ្មានបទពិសោធន៍ មកជួយរៀបចំផែនការ និងយុទ្ធសាស្ត្រនៅតាមក្រុមការងារបច្ចេកទេសតាមវិស័យនីមួយៗទៀតឡើយ ។

ង- បង្កើនប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ។ ប្រធាននិងអ្នកសម្របសម្រួលនាំមុខ ត្រូវធានាថា កិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសចម្រុះនីមួយៗត្រូវមានគោលបំណងច្បាស់លាស់ និងត្រូវកំណត់អោយបានអំពីលទ្ធផលរំពឹងទុក ។ ដើម្បីកាត់បន្ថយចំនួននៃការចូលរួមប្រជុំរបស់មន្ត្រីតំណាងក្រសួងនិងស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាលយល់ថា ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវកំណត់អោយបានច្បាស់លាស់ អំពីការចូលរួមរបស់ខ្លួននៅតាមក្រុមការងារបច្ចេកទេសចម្រុះចំពោះតែវិស័យណាដែលដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទាន ឬសម្រេចការគាំទ្ររបស់ខ្លួននៅក្នុងវិស័យអាទិភាពមួយចំនួន ដែលមានចែងក្នុងយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។

ច- ពិនិត្យអំពីរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីឆ្លើយតបនឹងតំរូវការបច្ចុប្បន្ននិងបន្ទាន់របស់ក្រុមការងារ ក៏ដូចជារៀបចំគោលការណ៍ណែនាំរួមសម្រាប់កិច្ចដំណើរការរបស់ក្រុមការងារបច្ចេកទេស ដើម្បីកាត់បន្ថយបន្ទុករបស់ក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ក្នុងការចូលរួមការងារក្នុងក្រុមការងារបច្ចេកទេសចម្រុះ ។

ឆ- ជំរុញការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីកាត់បន្ថយចំនួនគម្រោងទោល ។ ការសម្រេចអនុវត្តអភិក្រមនេះ មិនត្រឹមតែកែលំអការតម្រឹមសកម្មភាពរបស់

ដៃគូអភិវឌ្ឍន៍ជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ អភិក្រមនេះនឹងជំរុញឱ្យមានសុខដុមនីយកម្មនៃការអនុវត្តន៍របស់បណ្តាដៃគូអភិវឌ្ឍន៍ និងកាត់បន្ថយបន្ទុកខាងផ្នែកសមត្ថភាពរបស់ក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាលដែលជាអ្នកអនុវត្តផងដែរ ។

ជ- កាត់បន្ថយចំនួននៃការសិក្សារបស់ដៃគូអភិវឌ្ឍន៍លើប្រធានបទប្រហាក់ប្រហែល ដោយបង្កើតនីតិវិធី មួយសម្រាប់ត្រួតពិនិត្យសំណើស្តីពីការសិក្សាដែលបានគ្រោងឡើងដោយដៃគូអភិវឌ្ឍន៍ និងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ។

ឈ- កាត់បន្ថយចំនួនជំនួយបច្ចេកទេសរយៈពេលវែង ដោយផ្តោតជាសំខាន់ទៅលើគុណភាព និងដោយយកចិត្តទុកដាក់លើចំណុចទី៣ខាងលើ ដោយធានាថា ជំនួយបច្ចេកទេសរយៈពេលខ្លីពិតជាតម្រូវការពិតប្រាកដ ដូចមានចែងក្នុងចំណុចទី៤ខាងលើដែរ ។ រាជរដ្ឋាភិបាលជឿជាក់ថា វត្តមានរបស់អ្នកជំនាញឯកទេសកំរិតខ្ពស់ ក្នុងការិយាល័យរបស់ដៃគូអភិវឌ្ឍន៍ ដែលមានភារកិច្ចចូលរួមយ៉ាងសកម្មក្នុងកិច្ចការនៃក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ នឹងជួយកាត់បន្ថយបានច្រើននូវតម្រូវការជំនួយ បច្ចេកទេសរយៈពេលខ្លី ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ក្នុងរយៈពេលពេលខ្លីនិងមធ្យម យើងនៅត្រូវការជំនួយបច្ចេកទេសកំរិតខ្ពស់ ដើម្បីជួយសម្របសម្រួលការអនុវត្តន៍គម្រោងធំៗ ការអនុវត្តន៍កម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល និងការងារនានាដែលពាក់ព័ន្ធនឹងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច និងសម្រាប់ពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសំរាប់រៀបចំ អនុវត្ត និងត្រួតពិនិត្យសកម្មភាពអភិវឌ្ឍន៍ ។ ទន្ទឹមនេះ តម្រូវការជំនួយបច្ចេកទេសក្នុងរយៈពេលខ្លី និងមធ្យម ត្រូវគិតគូរដល់ការងារខ្លះៗដែលត្រូវធ្វើជំនួសជាបណ្តោះអាសន្ន នៅតាមវិស័យយុទ្ធសាស្ត្រមួយចំនួន ទន្ទឹមនឹងការជួយពង្រឹងសមត្ថភាពផងដែរ ។ ទន្ទឹមនឹងនេះដែរ នៅពេលដែលសមត្ថភាពក្នុងស្រុកត្រូវបានពង្រឹង រាជរដ្ឋាភិបាលក៏ចង់អោយមានការកាត់បន្ថយដោយពិត ប្រាកដនូវការធ្វើជំនួសជាបណ្តោះអាសន្នដោយអ្នកជំនាញការបរទេសផងដែរ ។

ញ- បញ្ជាក់ពីឆន្ទៈ និងការប្តេជ្ញាចិត្ត ព្រមទាំងអនុវត្តនូវទស្សនៈនៃការគ្រប់គ្រងដោយផ្តោតលើលទ្ធផលដើម្បីឱ្យស្របតាមគោលការណ៍ដែលមានចែងក្នុងសេចក្តីប្រកាសទីក្រុងរ៉ូម និងសេចក្តីប្រកាសទីក្រុងប៉ារីស ។ ទន្ទឹមនេះ ក៏ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាអោយក្រុមការងារបច្ចេកទេសចម្រុះអាចពង្រឹងសមត្ថភាពរបស់ខ្លួន សំរាប់អនុវត្តផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ដែលបានឯកភាពរួមគ្នារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ក្នុងស្មារតីនេះ ដៃគូអភិវឌ្ឍន៍ចាំបាច់ត្រូវប្រញាប់អនុវត្តនូវសកម្មភាពដូចខាងក្រោម ÷

- ធ្វើប្រតិភូកម្មអំណាចក្នុងការអនុវត្តន៍កិច្ចសហប្រតិបត្តិការ ពីការិយាល័យកណ្តាលនៃប្រទេសផ្តល់ជំនួយ ឱ្យការិយាល័យនៃដៃគូអភិវឌ្ឍន៍នៅកម្ពុជាអោយបានច្រើន ដើម្បីអោយពួកគេអាចអនុវត្តការងារដែលពាក់ព័ន្ធនឹងសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ជាមួយនឹងដៃគូអភិវឌ្ឍន៍ដទៃទៀត និងជាមួយរាជរដ្ឋាភិបាល នៅក្នុងបរិបថនៃកម្ពុជា ។
- បង្កើនការរៀបចំកម្មវិធីរួមគ្នា តាមរយៈការធ្វើប្រតិភូកម្មក្នុងកិច្ចសហប្រតិបត្តិការ ។

- កាត់បន្ថយចំនួនបេសកកម្មទោលរបស់ដៃគូអភិវឌ្ឍន៍ និងបង្កើនចំនួនបេសកកម្មរួមគ្នា ដោយត្រូវសម្របបេសកកម្មដែលបានគ្រោង តាមរយៈយន្តការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីកាត់បន្ថយចំណាយ និងបន្ទុកលើក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល។

១៤៦- ទោះបីជាមានការលំបាកជាច្រើន រាជរដ្ឋាភិបាលសូមស្វាគមន៍ចំពោះជំនួយដែលដៃគូអភិវឌ្ឍន៍បានផ្តល់មកកម្ពុជា ។ ប៉ុន្តែ ដើម្បីពង្រឹងប្រសិទ្ធភាពជំនួយបន្ថែមទៀត រាជរដ្ឋាភិបាលក៏ចង់មានការផ្ទេរនូវធនធានទាំងនោះឱ្យបានច្រើនបំផុត សំរាប់ជាប្រយោជន៍ដល់ជនក្រីក្រ និងជនងាយរងគ្រោះ ។ រាជរដ្ឋាភិបាលទទួលស្គាល់ផងដែរថា ដៃគូអភិវឌ្ឍន៍ត្រូវចំណាយផ្នែករដ្ឋបាលជាច្រើន ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍មកកម្ពុជា ហើយដែលចំណាយទាំងនេះត្រូវបានកត់ត្រានិងរាប់បញ្ចូលទៅក្នុងបរិមាណសរុបនៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានប្រើប្រាស់នៅកម្ពុជា ។ ប៉ុន្តែ រហូតមកដល់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលមិនមានព័ត៌មានគ្រប់គ្រាន់ស្តីពីបរិមាណជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានចំណាយផ្នែករដ្ឋបាល ទាំងក្នុងប្រទេស និងក្រៅប្រទេសឡើយ ហើយក៏មិនទាន់ដឹងអំពីបរិមាណជំនួយពិតប្រាកដដែលត្រូវបានប្រើប្រាស់សំរាប់ជាផលប្រយោជន៍របស់ជនក្រីក្រ និងជនងាយរងគ្រោះនៅឡើយដែរ ។

## ជំពូកទី៥

## ហិរញ្ញប្បទាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈកម្មវិធីវិនិយោគសាធារណៈ

១៤៧- អាទិភាពចំបងនៃផែនការសកម្មភាពលើកទី១ស្តីពីសុខដុមនីយកម្មនិងការតម្រឹម ដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នាមុនកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៤ គឺការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំរាប់៥ឆ្នាំ ២០០៦-២០១០ ដើម្បីឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់តំរឹមកម្មវិធី និងគំរោងផ្តល់ជំនួយរបស់ខ្លួនឱ្យស្របនឹងបណ្តាអាទិភាពអភិវឌ្ឍន៍របស់កម្ពុជា ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះត្រូវបានរៀបចំ តាមរយៈកិច្ចពិគ្រោះយោបល់រវាងបណ្តាភាគីពាក់ព័ន្ធ ។ ផែនការយុទ្ធសាស្ត្រនេះ គឺជាឯកសាររស់រវើក ដែលត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងវាយតំលៃ ។

១៤៨- ការអនុវត្តន៍យុទ្ធសាស្ត្រ និងគោលនយោបាយដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងត្រូវអនុវត្តឱ្យបានសំរេច តាមរយៈការធ្វើអាទិភាពរូបនីយកម្មនៃកម្មវិធីវិនិយោគសាធារណៈ ដែលជាឧបករណ៍យ៉ាងសំខាន់ សំរាប់អនុវត្តបណ្តាយុទ្ធសាស្ត្រនិងគោលនយោបាយទាំងនេះ ។ កម្មវិធីវិនិយោគសាធារណៈនេះក៏ត្រូវបានអនុមតិពីរាជរដ្ឋាភិបាលក្នុងកិច្ចប្រជុំកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ។ កម្មវិធីវិនិយោគសាធារណៈនេះត្រូវបានរៀបចំក្នុងក្របខ័ណ្ឌរំកិលបីឆ្នាំ ដើម្បីឆ្លុះបញ្ចាំងអំពីតំរូវការអាទិភាព ដែលកំពុងអនុវត្ត ។ កម្មវិធី និងគំរោងដែលចែងក្នុងកម្មវិធីវិនិយោគសាធារណៈនឹងត្រូវធ្វើហិរញ្ញប្បទានដោយថវិការដ្ឋ និងពីដៃគូអភិវឌ្ឍន៍ ។ ចាប់ពីពេលនេះទៅ ថវិការដ្ឋនឹងត្រូវតម្រឹម ដើម្បីគាំទ្រដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈការធ្វើហិរញ្ញប្បទានកម្មវិធីវិនិយោគសាធារណៈ ។ កម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល រួមមានបណ្តាគំរោងអាទិភាពដែលកំពុងអនុវត្ត និងគំរោងដែលគ្រោងអនុវត្តនៅតាមវិស័យនានា ហើយក៏ជាប្រភពព័ត៌មានដ៏សំខាន់ សំរាប់វិភាជន៍ថវិការដ្ឋ និងសំរាប់កៀរគរធនធានពីដៃគូអភិវឌ្ឍន៍ដែរ ។

១៤៩- ការអនុវត្តន៍គោលនយោបាយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ប្រកបដោយជោគជ័យ និងទាន់ពេលវេលា និងការអនុវត្តន៍អោយបានសំរេច នូវបណ្តាគោលដៅនៃផែនការយុទ្ធសាស្ត្រ ទាមទារនូវធនធានវិនិយោគបន្ថែមជាច្រើន ដែលត្រូវប្រើប្រាស់អោយចំទិសដៅ និងមានប្រសិទ្ធភាព ។ យើងត្រូវការវិនិយោគនេះ ពីវិស័យសាធារណៈផង និងវិស័យឯកជនផង ។

១៥០- នៅក្នុងគំនិតផ្តួចផ្តើមស្តីពីលុបចោលបំណុលរបស់ដៃគូពហុភាគី គណៈកម្មាធិការប្រតិបត្តិនៃអង្គការរូបិយវត្ថុអន្តរជាតិ បានសម្រេចលុបចោលបំណុលកម្ពុជា ក្នុងកិច្ចប្រជុំរបស់ខ្លួននាខែធ្នូ ឆ្នាំ២០០៥ ។ តាមគំនិតផ្តួចផ្តើមនេះ អង្គការរូបិយវត្ថុអន្តរជាតិនឹងលុបចោលបំណុល១០០% ដែលកម្ពុជាបានខ្ចីរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ពីអង្គការនេះ ចំនួន ៨២លានដុល្លារអាមេរិក ។ ការគ្រប់គ្រងសេដ្ឋកិច្ចយ៉ាងប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាល គឺជាកត្តាសំខាន់នៃការសំរេចចិត្តរបស់អង្គការរូបិយវត្ថុអន្តរជាតិនេះដែរ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាប្រើប្រាស់ថវិកាទាំងនេះ សំរាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ រាជ

រដ្ឋាភិបាលកំពុងអនុវត្តវិធានការនានា សំដៅពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ។ លទ្ធផលជាក់ស្តែងដែលបានមកពីការចរចាកំណត់ពេលសងបំណុល ដែលកម្ពុជាបានខ្ចីពីសហរដ្ឋអាមេរិក និងសហភាពរុស្សី កាលពីទសវត្សរ៍ឆ្នាំទី៧០ និង៨០ នឹងបង្កើនបន្ទុកលើធនធានថវិកាដែលនៅមានកំរិតរបស់កម្ពុជា ។ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងកាត់បន្ថយបន្ទុកដល់មនុស្សជំនាន់ក្រោយ រាជរដ្ឋាភិបាលសូមស្នើឱ្យដៃគូអភិវឌ្ឍន៍ ពិចារណាអំពីលទ្ធភាពផ្តល់ជំនួយឥតសំណង សំរាប់អនុវត្តបណ្តាគោលនយោបាយ និងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ រាជរដ្ឋាភិបាលនឹងដាក់កំហិតក្នុងការប្រើប្រាស់ជំនួយជាកំចី សំរាប់តែគំរោង ឬកម្មវិធីណាដែលមិនអាចស្វែងរកហិរញ្ញប្បទានជាជំនួយឥតសំណង ហើយដែលជាគំរោង ឬកម្មវិធីផ្តល់លទ្ធផលសេដ្ឋកិច្ចមកវិញភ្លាមៗ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងពិនិត្យដោយប្រយ័ត្នប្រយែង អំពីការជះឥទ្ធិពលនៃកម្ចីទៅលើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច មុននឹងយល់ព្រមទទួលកម្ចីទាំងនេះ ។ កម្ចីអាចប្រើប្រាស់សម្រាប់អនុវត្តកម្មវិធី និងគំរោងដូចខាងក្រោម ÷

- គំរោង និងកម្មវិធីផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដែលអាចផ្តល់ផលប្រយោជន៍ខ្លាំងក្លាដល់សេដ្ឋកិច្ចជាតិ ហើយគំរោងវិនិយោគនេះត្រូវមានអត្រាចំណូលផ្ទៃក្នុងខ្ពស់ ។
- គំរោង និងកម្មវិធីទាំងឡាយ ដែលជំរុញឱ្យមានការអភិវឌ្ឍន៍អន្តរកម្មនៃពាណិជ្ជកម្មក្រៅប្រទេស ដែលអាចលើកកំពស់សមត្ថភាពរបស់រដ្ឋ ក្នុងការប្រមូលចំណូលជារូបិយប័ណ្ណអន្តរជាតិ ។

ចំពោះគំរោង និងកម្មវិធីអភិវឌ្ឍន៍ធំៗដែលនឹងត្រូវធ្វើហិរញ្ញប្បទានដោយកម្ចី ហើយដែលទាមទារឱ្យមានសមិទ្ធិសិក្សា ឬការវិភាគនានាមុនធ្វើវិនិយោគ ការសិក្សាទាំងនេះត្រូវតែប្រើប្រាស់ជំនួយឥតសំណង ។ រាជរដ្ឋាភិបាលនឹង ÷

- បញ្ឈប់ការប្រើប្រាស់កម្ចី សម្រាប់ការសិក្សាទាំងឡាយណា ដែលមិនពាក់ព័ន្ធផ្ទាល់នឹងកម្មវិធីនិងគំរោងវិនិយោគ ។
- កាត់បន្ថយឱ្យបានច្រើនបំផុតនូវការប្រើប្រាស់កម្ចី សម្រាប់ចំណាយលើសេវាទីប្រឹក្សាបរទេស ។

១៥១- ផ្អែកតាមការប៉ាន់ស្មានកំណើនម៉ាក្រូសេដ្ឋកិច្ច និងតំរូវការវិនិយោគក្នុងវិស័យសាធារណៈ តំរូវការនៃវិស័យសាធារណៈសំរាប់៥ឆ្នាំ ២០០៦-២០១០ មានប្រមាណ ៣.៥០០លានដុល្លារអាមេរិក សំរាប់រយៈពេល៥ឆ្នាំ ដើម្បីសំរេចឱ្យបាន នូវបណ្តាគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្នុងកញ្ចប់ថវិកានេះ យើងក៏ត្រូវផ្តោតការយកចិត្តទុកដាក់ដល់ការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ ហើយការវិភាជន៍ធនធានក៏ត្រូវផ្តោតទៅលើសកម្មភាពទាំងឡាយដែលផ្តល់ផលប្រយោជន៍ផ្ទាល់ដល់តំបន់ជនបទទាំងនោះ ។

១៥២- ធនធានសំរាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ អាចមានប្រភពមកពី ÷

- អតិរេកនៃគណនីចរន្តរបស់ថវិការដ្ឋ ។
- ជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ជាប្រពៃណី ។
- កម្ចីសម្បទាននៃស្ថាប័នហិរញ្ញវត្ថុពហុភាគី ។
- ធនធានពីដៃគូអភិវឌ្ឍន៍មិនប្រពៃណី រួមទាំងធនធានមូលធនធម្មតា (Ordinary capital

resources-OCR) ពីស្ថាប័នហិរញ្ញវត្ថុពហុភាគី សំរាប់អនុវត្តគំរោងនិងកម្មវិធីយុទ្ធសាស្រ្ត ដែលមានផលចំណូលខ្ពស់ ។

- ធនធានដែលបានមកពីការលុបបំណុល ។

អាទិភាពរបស់រាជរដ្ឋាភិបាល គឺការផ្ទេរធនធានដែលមានសំរាប់ការវិនិយោគពិតប្រាកដ និងការកាត់បន្ថយចំណាយលើជំនួយបច្ចេកទេស ព្រមទាំងស្នើដៃគូអភិវឌ្ឍន៍តម្រឹមជំនួយរបស់ខ្លួន ឱ្យស្របនឹងអាទិភាពនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។

១៥៣- រាជរដ្ឋាភិបាលបានធ្វើការងារយ៉ាងសកម្ម ដើម្បីដាក់ឱ្យដំណើរការនូវយន្តការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ និងដើម្បីធានាថាជំនួយត្រូវបានប្រើប្រាស់សំរាប់ជាគុណប្រយោជន៍របស់ប្រជាជន ប្រកបដោយតំលាភាព និងគណនេយ្យភាព ក្នុងគោលដៅឈានទៅសំរេចនូវគោលដៅនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ ។ ក្រុមការងារតាមវិស័យ និងគណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលបានដំណើរការក្នុងរយៈពេលជាងមួយឆ្នាំកន្លងមក នេះគឺជាវេទិកាសំរាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ពិនិត្យរួមគ្នាប្រចាំត្រីមាស អំពីវឌ្ឍនភាពការងារ និងចាត់វិធានការកែតំរូវនានា ដើម្បីប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ សំរាប់អនុវត្តកម្មវិធី និងគំរោងនានាដែលមានចែងក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ ២០០៦-២០០៨ ក្នុងគោលដៅឈានទៅសំរេចឱ្យបាននូវបណ្តាអាទិភាពដែលមានចែងក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ ។

១៥៤- កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ២០០៦-២០០៨ បានបញ្ចូលនូវបណ្តាគំរោងកំពុងអនុវត្ត និងគំរោងមានការសន្យាផ្តល់ហិរញ្ញប្បទានដែលមានពតិមានគ្រប់គ្រាន់ ។ បណ្តាគំរោងអាទិភាពខ្ពស់ដែលបានស្នើដោយក្រសួង និងស្ថាប័នជំនាញត្រូវបានដាក់បញ្ចូលមួយចំនួនប៉ុណ្ណោះ ដើម្បីឱ្យស្របនឹងកំរិតវិភាជន៍តំរូវការជាអតិប្បរមានៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។ នៅក្នុងករណីខ្លះ ធនធានខ្លះក៏បានវិភាជន៍ សំរាប់ គំរោងនិងកម្មវិធីអាទិភាពខ្ពស់មួយចំនួនដែលត្រូវរៀបចំ សំរាប់អនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ដែរ ។ ទន្ទឹមនេះ ក៏មានគំរោងនិងកម្មវិធីអាទិភាពខ្ពស់មួយចំនួន ដែលត្រូវការហិរញ្ញប្បទានពីដៃគូ អភិវឌ្ឍន៍ ។ ក្នុងន័យនេះ រាជរដ្ឋភិបាលមិនលើកទឹកចិត្តអោយដៃគូអភិវឌ្ឍន៍ទាំងអស់ផ្តល់ជំនួយរបស់ខ្លួនសំរាប់គាំទ្រគំរោង ឬកម្មវិធីក្រៅពីកម្មវិធីវិនិយោគសាធារណៈនេះឡើយ ។ កម្មវិធីវិនិយោគសាធារណៈសំរាប់ឆ្នាំ២០០៧-២០០៩ នឹងត្រូវរៀបចំនាចុងឆ្នាំនេះ ។

១៥៥- សរុបតំរូវការហិរញ្ញប្បទានសំរាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ២០០៦-២០០៨ គឺ ១.៩៧៥លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ៥៦,៥០% នៃតំរូវការហិរញ្ញប្បទានសរុបនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ៥ ឆ្នាំ ២០០៦-២០១០ ដែលមានចំនួន ៣.៥០០លានដុល្លារអាមេរិក ។ ផែនការវិភាជន៍ថវិកាសំរាប់អនុវត្តគំរោង និងកម្មវិធីនៃកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ ២០០៦-២០០៨ មានលក្ខណៈស្របជាមួយនឹងការវិភាជន៍ធនធានតាមវិស័យអាទិភាពនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (តារាងទី៥) ។ ថវិការដ្ឋប្រមាណជាង ៨០% ត្រូវបានវិភាជន៍សំរាបវិស័យសង្គមកិច្ច ។ ទន្ទឹមនេះ បន្ថែមលើធនធានដែលរាជ

រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានសន្យារួចហើយ ធនធានដែលត្រូវកៀរគរបន្ថែមទៀត សំរាប់រយៈពេល ៣ឆ្នាំ ២០០៦-២០០៨ មានចំនួន ៥៦៣,៤លានដុល្លារអាមេរិក សំរាប់វិស័យដូចខាងក្រោមនេះ ÷

- ចំនួន១៨៩,៨លានដុល្លារអាមេរិក ស្មើនឹង៣៣,៧% សំរាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ ។
- ចំនួន១៧១,៧លានដុល្លារអាមេរិក ស្មើនឹង៣០,៥% សំរាប់វិស័យសេដ្ឋកិច្ច ។
- ចំនួន១២៩,៧លានដុល្លារអាមេរិក ស្មើនឹង២៣% សំរាប់ផ្នែកសេវា និងកម្មវិធីអន្តរវិស័យ ។
- ចំនួន៧២,២លានដុល្លារអាមេរិក ស្មើនឹង១២,៨% សំរាប់វិស័យសង្គមកិច្ច ។

១៥៦- នៅក្នុងកម្មវិធីវិនិយោគសាធារណៈ ធនធានប្រមាណ៨២% នឹងត្រូវប្រើប្រាស់សំរាប់អនុវត្តកម្មវិធី និងគំរោងដែលកំពុងអនុវត្ត និងដែលមានការសន្យាហិរញ្ញប្បទានរួចហើយ ។ រីឯធនធានប្រមាណ ១៨% សំរាប់គាំទ្រគំរោង និងកម្មវិធីដែលមានអាទិភាពខ្ពស់ (តារាងទី៦) ។ លើសពីនេះ ធនធានដែលដៃគូអភិវឌ្ឍន៍បានសន្យាសំរាប់៣ឆ្នាំខាងមុខ ប្រមាណ ២៥% នឹងត្រូវប្រើប្រាស់សំរាប់ជំនួយបច្ចេកទេស ។ ដូចនេះ ធនធានដែលត្រូវកៀរគរសំរាប់រយៈពេល៣ឆ្នាំខាងមុខ នឹងត្រូវផ្តោតទៅលើការកាត់បន្ថយផ្នែកជំនួយបច្ចេកទេស ឱ្យនៅក្រោម ១៥% នៃធនធានថ្មីដែលត្រូវកៀរគរ ។

១៥៧- បណ្តាគំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ ត្រូវបានបែងចែកតាមវិស័យ (តារាងទី៧) ដូចខាងក្រោម ÷

- ក្នុងវិស័យសង្គមកិច្ច គំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ មានប្រមាណ៩៨% នៃធនធានដែលបានវិភាជន៍សំរាប់វិស័យនេះ ។
- ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ គំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ មានប្រមាណ៨១% នៃធនធានដែលបានវិភាជន៍សំរាប់វិស័យនេះ ។
- ក្នុងវិស័យសេដ្ឋកិច្ច និងសេវានិងកម្មវិធីអន្តរវិស័យ គំរោង និងកម្មវិធីដែលកំពុងអនុវត្ត និងដែលមានការសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ មានប្រមាណជាង ២/៣ នៃធនធានដែលបានវិភាជន៍សំរាប់វិស័យទាំងនេះ ។

១៥៨- ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ ២០០៣-២០០៥ ការប្រើប្រាស់ជំនួយបរទេសប្រចាំឆ្នាំមាន ៥៣៩,៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៣ និង ៥៥៥,៤ លានដុល្លារអាមេរិកនាឆ្នាំ២០០៤ ។ តាមតួរលេខបឋមរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការប្រើប្រាស់ជំនួយ ក្នុងឆ្នាំ២០០៥ មានចំនួន ៥២៥លានដុល្លារអាមេរិក ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ ហើយសង្ឃឹមថា ដៃគូអភិវឌ្ឍន៍នឹងបន្តផ្តល់ជំនួយដល់កម្ពុជាបន្ថែមទៀត ដើម្បីកម្ពុជាអាចសំរេចបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

១៥៩- តំរូវការហិរញ្ញប្បទានសរុបសំរាប់អនុវត្តកម្មវិធីកំពុងដំណើរការនិងកម្មវិធីថ្មី ក្នុងរយៈពេល៣ឆ្នាំខាងមុខ ២០០៦-២០០៨ មានប្រមាណ១.៩៧៥លានដុល្លារអាមេរិក ។ រាជរដ្ឋាភិបាលបានប្តេជ្ញាផ្តល់ធនធានផ្ទាល់ចំនួន៣៥០លានដុល្លារអាមេរិកសំរាប់កម្មវិធីអភិវឌ្ឍន៍ទាំងនេះ ។ ដូចនេះ តម្រូវការធនធានបន្ថែមសំរាប់

រយៈពេល៣ឆ្នាំខាងមុខ គឺ ១.៦២៥លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ៥៤១,៧លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។ ដៃគូអភិវឌ្ឍន៍ទ្វេ-ពហុភាគីមួយចំនួនបានសន្យាផ្តល់ហិរញ្ញប្បទានចំនួន ១.១១៧,៣លានដុល្លារអាមេរិករួចហើយ ។ ដូចនេះ រាជរដ្ឋាភិបាលត្រូវស្វះស្វែងរកការគាំទ្របន្ថែមទៀតចំនួន ៥៦៣,៤ លានដុល្លារអាមេរិក ពីដៃគូអភិវឌ្ឍន៍ជាប្រពៃណី និងមិនជាប្រពៃណីរបស់ខ្លួន ។

### តារាង ៥ : កម្មវិធី និងគម្រោងអភិវឌ្ឍន៍តាមវិស័យនៃកម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨

(ពាន់ដុល្លារអាមេរិក)

| វិស័យ | វិភាជន៍ថវិកាតាម NSDP ២០០៦-២០១០ | តម្លៃសរុបនៃកម្មវិធី/គម្រោង PIP: ២០០៦-២០០៨ | | ការសន្យាផ្តល់ធនធាន | | | | ទិសដៅនៃការកៀរគរធនធានសរុប | |
|---|---|---|---|---|---|---|---|---|---|
| | | | | រាជរដ្ឋាភិបាល | | ដៃគូអភិវឌ្ឍន៍ | | | |
| | | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % |
| វិស័យសង្គមកិច្ច | ៣២,៨៦% | ៦៦៨.៨៦៧ | ៣៣.៨៥ | ២៣៧.៩១៥ | ៨០,៨៤ | ៣៥៨.៣៤១ | ៣២,០៧ | ៧២.២១១ | ១២,៨២ |
| វិស័យសេដ្ឋកិច្ច | ២២,២៩% | ៤៦៩.៧៤៥ | ២៣.៧៨ | ២៤.៤៥៦ | ៨,៣១ | ២៧៣.៥៤៣ | ២៤,៤៨ | ១៧១.៧៤៦ | ៣០,៤៨ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត | ២៥,១៤% | ៥៥០.៨៧៥ | ២៧.៨៩ | ២៥.០៧៣ | ៨,៥២ | ៣៣៦.០០៣ | ៣០,០៧ | ១៨៩.៨០០ | ៣៣,៦៩ |
| សេវាកម្ម និងពហុវិស័យ | ១៤,០០% | ២៨៥.៩១២ | ១៤.៤៨ | ៦.៨៧៧ | ២,៣៤ | ១៤៩.៣៧៨ | ១៣,៣៧ | ១២៩.៦៥៧ | ២៣,០១ |
| មិនវិភាជន៍ថវិកា | ៥,៧១% | .... | .... | .... | .... | .... | .... | .... | .... |
| សរុបៈ គ្រប់វិស័យ | **១០០**% | ១.៩៧៥.០០០ | ១០០ | ២៩៤.៣២១ | ១០០ | ១.១១៧.២៦៥ | ១០០ | ៥៦៣.៤១៤ | ១០០ |

### តារាង ៦ : ស្ថានភាពកម្មវិធី និងគម្រោងអភិវឌ្ឍន៍តាមប្រភេទជំនួយនៃកម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨

(ពាន់ដុល្លារអាមេរិក)

| ស្ថានភាពកម្មវិធី/គម្រោង | ចំនួនកម្មវិធី/គម្រោង | តម្លៃសរុបនៃកម្មវិធី/ គម្រោង២០០៦-២០០៨ | | | ការសន្យាផ្តល់ធនធាន | | | | ទិសដៅនៃការកៀរគរធនធានសរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | រាជរដ្ឋាភិបាល | | ដៃគូអភិវឌ្ឍន៍ | | | |
| | | ដុល្លារអាមេរិក | % | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % |
| **គម្រោងកំពុងដំណើរការ និងបានសន្យា** | **៣៣៤** | ១.៦១៦.៣៦៩ | ១០០ | ៨១,៨៤ | ២៩២.៩៧៦ | ១០០ | ១.១១៥.៦៥៥ | ១០០ | ២០៧.៧៣៧ | ១០០ |
| - ជំនួយហិរញ្ញវត្ថុ | ២០៣ | ១.២៦៩.៧១១ | ៧៨,៥៥ | ៨០,៨៥ | ២៥០.០៤១ | ៨៥,៣៥ | ៨៣៧.០៥៤ | ៧៥,០៣ | ១៨២.៦១៤ | ៨៧,៩១ |
| - ជំនួយបច្ចេកទេស | ១៣១ | ៣៤៦.៦៥៨ | ២១,៤៥ | ៨៥,៦៧ | ៤២.៩៣៤ | ១៤,៦៥ | ២៧៨.៦០០ | ២៤,៩៧ | ២៥.១២៣ | ១២,០៩ |
| **គម្រោងអាទិភាពខ្ពស់** | **២៨៣** | ៣៥៨.៦៣១ | ១០០,០០ | ១៨,១៦ | ១.៣៤៥ | ១០០ | ១.៦១០ | ១០០ | ៣៥៥.៦៧៧ | ១០០ |
| - ជំនួយហិរញ្ញវត្ថុ | ១៩១ | ៣០០.៦៤៦ | ៨៣,៨៣ | ១៩,១៥ | ១៩៧ | ១៤,៦៥ | ១.៤១០ | ៨៧,៥៨ | ២៩៩.០៤០ | ៨៤,០៨ |
| - ជំនួយបច្ចេកទេស | ៩២ | ៥៧.៩៨៥ | ១៦,១៧ | ១៤,៣៣ | ១.១៤៨ | ៨៥,៣៥ | ២០០ | ១២,៤២ | ៥៦.៦៣៧ | ១៥,៩២ |
| **សរុប** | **៦១៧** | **១.៩៧៥.០០០** | **១០០** | ១០០ | **២៩៤.៣២១** | **១០០** | **១.១១៧.២៦៥** | **១០០** | **៥៦៣.៤១៤** | **១០០** |
| - ជំនួយហិរញ្ញវត្ថុ | ៣៩៤ | ១.៥៧០.៣៥៧ | ៧៩,៥១ | ១០០ | ២៥០.២៣៨ | ៨៥,០២ | ៨៣៨.៤៦៤ | ៧៥,០៥ | ៤៨១.៦៥៤ | ៨៥,៤៩ |
| - ជំនួយបច្ចេកទេស | ២២៣ | ៤០៤.៦៤៣ | ២០,៤៩ | ១០០ | ៤៤.០៨២ | ១៤,៩៨ | ២៧៨.៨០០ | ២៤,៩៥ | ៨១.៧៦០ | ១៤,៥១ |

**តារាង ៧ : កម្មវិធី និងគម្រោងអភិវឌ្ឍន៍កំពុងដំណើរការ និងមានការសន្យាផ្តល់ជំនួយ ព្រមទាំងអាទិភាពខ្ពស់តាមវិស័យនៃកម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨**

(ពាន់ដុល្លារអាមេរិក)

| វិស័យ | តម្លៃនៃកម្មវិធីអភិវឌ្ឍន៍ដែលបានគ្រោងក្នុង | | | | | ការសន្យាផ្តល់ធនធាន | | ទិសដៅនៃការកៀរគរធនធានជំនួយអភិវឌ្ឍន៍ផ្លូវការសរុប |
|---|---|---|---|---|---|---|---|---|
| | ២០០៦ | ២០០៧ | ២០០៨ | ២០០៦-២០០៨ | | រាជរដ្ឋាភិបាល | ដៃគូអភិវឌ្ឍន៍ | |
| **វិស័យសង្គមកិច្ច** | | | | | | | | |
| - គម្រោងកំពុងដំណើរការ និងបានសន្យា | ១៥៧.០៧០ | ២០៤.៨៨២ | ២៩១.៩០៤ | ៦៥៣.៨៥៦ | ៩៧,៨១% | ២៣៧.៦៨១ | ៣៥៨.១៤១ | ៥៨.០៣៤ |
| - គម្រោងអាទិភាពខ្ពស់ | ៤.៧៧៧ | ៥.៥០៦ | ៤.៣២៨ | ១៤.៦១១ | ២,១៩% | ២៣៤ | ២០០ | ១៤.១៧៧ |
| **សរុបៈវិស័យសង្គមកិច្ច** | **១៦១.៨៤៧** | **២១០.៣៨៨** | **២៩៦.២៣២** | **៦៦៨.៤៦៧** | **១០០%** | **២៣៧.៩១៥** | **៣៨៥.៣៤១** | **៧២.២១១** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | |
| - គម្រោងកំពុងដំណើរការ និងបានសន្យា | ១២៦.៥០៥ | ១០៨.២២៧ | ៨៥.០៨១ | ៣១៩.៨១២ | ៦៨,០៨ % | ២៣.៣៤៥ | ២៧៣.៥៤៣ | ២២.៩២៤ |
| - គម្រោងអាទិភាពខ្ពស់ | ៣៥.៨០៥ | ៤៧.២៥៤ | ៦៦.៨៧៤ | ១៤៩.៩៣៣ | ៣១,៩២ % | ១.១១១ | - | ១៤៨.៨២២ |
| **សរុបៈវិស័យសេដ្ឋកិច្ច** | **១៦២.៣១០** | **១៥៥.៤៨១** | **១៥១.៩៥៥** | **៤៦៩.៧៤៥** | **១០០%** | **២៤.៤៥៦** | **២៧៣.៥៤៣** | **១៧១.៧៤៦** |
| **ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** | | | | | | | | |
| - គម្រោងកំពុងដំណើរការ និងបានសន្យា | ១៦៥.១៣២ | ១៥៣.៨០៩ | ១២៨.២១០ | ៤៤៧.១៥១ | ៨១,១៧% | ២៥.០៧៣ | ៣៣៦.០០៣ | ៨៦.០៧៦ |
| - គម្រោងអាទិភាពខ្ពស់ | ២២.៨៨០ | ៣៦.១៤១ | ៤៤.៧០៣ | ១០.៧២៤ | ១៨,៨៣% | - | - | ១០៣.៧២៤ |
| **សរុបៈហេដ្ឋារចនាសម្ព័ន្ធ** | ១៨៨.០១២ | ១៨៩.៩៥០ | ១៧២.៩១៣ | **៥៥០.៨៧៥** | **១០០ %** | **២៥.០៧៣** | **៣៣៦.០០៣** | **១៨៩.៨០០** |
| **សេវាកម្ម និងពហុវិស័យ** | | | | | | | | |
| - គម្រោងកំពុងដំណើរការ និងបានសន្យា | ៧១.៤២៥ | ៦៣.៥៤៥ | ៦០.៥៧៩ | ១៩៥.៥៤៩ | ៦៨,៣៩% | ៦.៨៧៧ | ១៤៧.៩៦៨ | ៤០.៧០៣ |
| - គម្រោងអាទិភាពខ្ពស់ | ១៦.៤០៦ | ៣០.៦៣៦ | ៤៣.៣២២ | ៩០.៣៦៣ | ៣១,៦១% | - | ១.៤១០ | ៨៨.៩៥៤ |
| **សរុបៈសេវាកម្ម និងពហុវិស័យ** | **៨៧.៨៣១** | **៩៤.១៨១** | **១០៣.៩០១** | **២៨៥.៩១២** | **១០០ %** | **៦.៨៧៧** | **១៤៩.៣៧៨** | **១២៩.៦៥៧** |
| **សរុបៈ គ្រប់វិស័យ** | | | | | | | | |
| - គម្រោងកំពុងដំណើរការ និងបានសន្យា | ៥០២.១៣២ | ៥៣០.៤៦៣ | ៥៦៥.៧៧៣ | ១.៦១៦.៣៦៩ | ៨១,៨៤% | ២៩២.៩៧៦ | ១.១១៥.៦៥៥ | ២០៧.៧៣៧ |
| - គម្រោងអាទិភាពខ្ពស់ | ៩៧.៨៦៨ | ១១៩.៥៣៧ | ១៥៩.២២៧ | ៣៥៨.៦៣១ | ១៨,១៦% | ១.៣៤៥ | ១.៦១០ | ៣៥៥.៦៧៧ |
| **សរុប** | **៦០០.០០០** | **៦៥០.០០០** | **៧២៥.០០០** | **១.៩៧៥.០០០** | **១០០ %** | **២៩៤.៣២១** | **១.១១៧.២៦៥** | **៥៦៣.៤១៤** |

# ជំពូកទី៦

## សេចក្តីសន្និដ្ឋាន

១៦០- ឯកសារនេះបានបង្ហាញអំពីសមិទ្ធផលដែលរាជរដ្ឋាភិបាលសំរេចបាន បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់នៅរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០០៤ ។ ឯកសារបានធ្វើបច្ចុប្បន្នភាពលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរូបិយវត្ថុ សារពើពន្ធ និងការអនុវត្តន៍គោលនយោបាយនានារបស់រាជរដ្ឋាភិបាល ។ ឯកសារនេះបានលើកឡើងដោយសង្ខេប អំពីបណ្តាបញ្ហានានាដែលត្រូវប្រឈមដោះស្រាយ សំរាប់អនុវត្ត «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ២០០៦-២០១០» ដោយជោគជ័យ និងដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ ។ ឯកសារបានធ្វើបច្ចុប្បន្នភាពអំពីស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អំពីស្ថានភាពរូបិយវត្ថុនិងសារពើពន្ធ ព្រមទាំងវឌ្ឍនភាពនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ។ វឌ្ឍនភាពរយៈពេលមួយឆ្នាំកន្លងមក ក្នុងការពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ (ដៃគូសហប្រតិបត្តិការទ្វេ-ពហុភាគី និងអន្តរជាតិ ផ្នែកឯកជន និងសង្គមស៊ីវិល) ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ ។ លើសពីនេះ ក៏បានលើកឡើងអំពីបញ្ហាប្រឈម នានា និងសកម្មភាពអាទិភាពមួយចំនួន ដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវដោះស្រាយរួមគ្នា ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ ព្រមទាំងបានលើកឡើងអំពីបណ្តាផ្នែកអាទិភាព ដែលដៃគូអភិវឌ្ឍន៍ត្រូវផ្តល់ការយកចិត្តទុកដាក់ ។ ចុងបញ្ចប់ ក៏បានផ្តល់ព័ត៌មានអំពីតំរូវការក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សំរាប់បន្ថែមលើធនធានក្នុងស្រុកដែលមាន ក្នុងការអនុវត្តន៍កម្មវិធី និងគំរោង ដែលមានចែងក្នុង «កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ២០០៦-២០០៨» ។

១៦១- ដើម្បីសំរេចទិសដៅក្នុងកិច្ចអភិវឌ្ឍន៍ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ និងបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសណ្តាប់ធ្នាប់ខាងសារពើពន្ធ ។ រាជរដ្ឋាភិបាលនឹងខិតខំដោយពេញទំហឹង ក្នុងការបង្កើនសញ្ច័យក្នុងស្រុកនិងធនធានមូលធន ដើម្បីផ្តល់ហិរញ្ញប្បទានអោយបានច្រើនដល់កម្មវិធីអភិវឌ្ឍន៍ ។ សំរាប់រយៈពេលខ្លីខាងមុខនេះ រាជរដ្ឋាភិបាលទទួលស្គាល់ថាកម្ពុជានៅតែត្រូវការធនធានពីដៃគូអភិវឌ្ឍន៍របស់ខ្លួន ។ សំរាប់រយៈពេល៣ឆ្នាំ២០០៦-២០០៨ ខាងមុខនេះ ធនធានក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍន៍ សំរាប់អនុវត្តគំរោងនិងកម្មវិធីអាទិភាព មានចំនួនសុរបប្រមាណ១.៦២៥លានដុល្លារអាមេរិក ហើយរាជរដ្ឋាភិបាលបានប្តេជ្ញាផ្តល់ថវិកាចំនួន៣៥០លានដុល្លារអាមេរិក ។ រាជរដ្ឋាភិបាលស្វាគមន៍ការសន្យាផ្តល់ជំនួយសំរាប់រយៈពេល៣ឆ្នាំ ដើម្បីឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការរៀបចំផែនការសំរាប់អនុវត្តបណ្តាគំរោងជាអាទិភាពរបស់ខ្លួន ។ នៅក្នុងក៏រិតអភិវឌ្ឍន៍បច្ចុប្បន្ន រាជរដ្ឋាភិបាលយល់យ៉ាងច្បាស់ពីការលំបាក ក្នុងការផ្តល់ហិរញ្ញប្បទានសំរាប់កម្មវិធីអភិវឌ្ឍន៍តាមរយៈកម្ចី ដែលអាចជះឥទ្ធិពលដល់ការបំពេញកាតព្វកិច្ចបំណុល ហើយដែលជាឧបសគ្គធ្វើឱ្យរាំងស្ទះដល់ការវិភាជន៍ថវិកាឱ្យបានច្រើនសំរាប់វិស័យសង្គមកិច្ចនាពេលអនាគត ។ អាស្រ័យហេតុនេះ អាទិភាពរបស់រាជរដ្ឋាភិបាល គឺការស្វែងរកជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍របស់ខ្លួន ។

១៦២- ក្នុងបណ្តាឆ្នាំកន្លងមក ដៃគូអភិវឌ្ឍន៍បានផ្តល់ជំនួយសំរាប់គាំទ្រដល់ការអនុវត្តន៍កម្មវិធីវិនិយោគរបស់កម្ពុជា ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណចំពោះជំនួយទាំងនេះ ហើយសង្ឃឹមថា ដៃគូអភិវឌ្ឍន៍នឹងបន្តផ្តល់ការគាំទ្របន្ថែមទៀត សំរាប់ឱ្យកម្ពុជាអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍនជាតិ សំរាប់សំរេចគោលដៅជាយុទ្ធសាស្រ្តក្នុងការកាត់បន្ថយភាពក្រីក្រ ដើម្បីឈានទៅសំរេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ។

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០២....សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ផែនការសកម្មភាពស្ដីពីសុខដុមនីយកម្ម ឆ្នាំ២០០៦-២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ១៤៧អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ស្ដីពីសុខដុមនីយកម្មដើម្បីបង្កើនប្រសិទ្ធិភាពនៃជំនួយ សម្រាប់ឆ្នាំ២០០៦-២០១០ មានខ្លឹមសារដូចមានភ្ជាប់ជាមួយនឹងសេក្ដីសម្រេចនេះ ។

**ប្រការ ២:** គណៈកម្មាធិការនីតិសម្បទាននិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចតាមដានការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្មនេះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង និង ស្ថាប័នពាក់ព័ន្ធ និងជាមួយបណ្តាដៃគូអភិវឌ្ឍន៍ ដោយត្រូវវាយតម្លៃអំពីវឌ្ឍភាពនៃការអនុវត្តន៍ផែនការនេះ ក្នុងមួយឆ្នាំម្តងជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣:** គណៈកម្មាធិការនីតិសម្បទាននិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចធ្វើការពិនិត្យ និងកែសម្រួលសកម្មភាពជាក់ស្តែងនៃផែនការសកម្មភាពនេះ ដើម្បីអោយស្របនឹងស្ថានភាពវិវត្តន៍ ទាំងក្នុងប្រទេស និងទាំងលើឆាកអន្តរជាតិ ដោយត្រូវពិភាក្សា និងឯកភាពជាមួយបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងជាមួយបណ្តាដៃគូអភិវឌ្ឍន៍ ដោយត្រូវរាយការណ៍ ជូនគណៈរដ្ឋមន្ត្រីជ្រាបជាព័ត៌មាន ។

**ប្រការ ៤:** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងនិងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ព្រមទាំងក្រុមការងារបច្ចេកទេសចម្រុះ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៥:** សេចក្តីសម្រេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីសុខដុមនីយកម្ម ឆ្នាំ២០០៦-២០១០

| ផ្នែក A : ភាពជាម្ចាស់: រាជរដ្ឋាភិបាលពង្រឹងភាពដឹកនាំ ប្រកបដោយប្រសិទ្ធភាពក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងសម្របសម្រួលសកម្មភាពអភិវឌ្ឍន៍ | | | | | |
|---|---|---|---|---|---|
| **លទ្ធផល** | **សកម្មភាព** | **ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល** | **អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍** | **សកម្មភាពកំណត់ជាក់ស្តែង** | **ពេលវេលា** |
| ក- ការអនុវត្តន៍ឱ្យបានសម្រេច នូវបណ្តាទិសដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ (សូចនករទី ១) | - ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រសួង និង ស្ថាប័នតាមវិស័យ រៀបចំផែនការតាមវិស័យ និងកម្មវិធីអាទិភាព ផ្អែកតាមលទ្ធផល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមតាមវិស័យ | ប្រធាននៃក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យ | អ្នកសម្របសម្រួលនៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះ | រៀបចំផែនការលំអិតតាមវិស័យ កម្មវិធីអាទិភាពតាមវិស័យ និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម | ខែកញ្ញា ឆ្នាំ២០០៦ |
| | - យោងតាមកម្មវិធីអាទិភាពរបស់ក្រសួង និងស្ថាប័នតាមវិស័យ កម្មវិធីវិនិយោគសាធារណៈរំកិលរយៈពេល៣ឆ្នាំ ត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ដើម្បីស្របឱ្យតាមខួបនៃដំណើរការរៀបចំថវិការជ្ជប្រចាំឆ្នាំ | ក្រសួងផែនការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ គ.ជ.នា/ក.អ.ក និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីរៀបចំផែនការនិងកាត់បន្ថយភាពក្រីក្រ | រៀបចំកម្មវិធីវិនិយោគសាធារណៈរំកិលរយៈពេល៣ឆ្នាំ សម្រាប់ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំបញ្ចូលក្នុងថវិការជ្ជឆ្នាំ ២០០៧ | ខែកញ្ញា ឆ្នាំ២០០៦ និងឆ្នាំបន្តបន្ទាប់ |
| ខ- ក.អ.ក/គ.ជ.នា ដែលជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរធនធាន និងសម្របសម្រួលជំនួយបរទេស ដឹកនាំដំណើរការកៀរគរជំនួយ និងសម្របសម្រួលជំនួយជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ | - អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលបានអនុមតិដោយគណៈរដ្ឋមន្ត្រី ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងសមត្ថភាព ក.អ.ក/គ.ជ.នា និងក្រសួង និងស្ថាប័នតាមវិស័យ | ក.អ.ក/គ.ជ.នា | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម | អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ តាមរយៈកម្មវិធីដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើន ដោយមានការប្តេជ្ញាខាងការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ | ២០០៦-២០១០ |
| គ- ក្រសួង និងស្ថាបន័តាមវិស័យ ដឹកនាំការគ្រប់គ្រងសកម្មភាពជំនួយអភិវឌ្ឍន៍ផ្លូវការ | - ក.អ.ក/គ.ជ.នា ផ្តល់ជំនួយបច្ចេកទេសដល់បណ្តាក្រសួង និង ស្ថាប័នតាមវិស័យស្តីពីការងារសម្របសម្រួល និងគ្រប់គ្រងជំនួយ ដោយផ្អែកលើតម្រូវការ ដែលស្នើឡើងដោយប្រធានក្រុមការងារបច្ចេកទេសចម្រុះ | ក.អ.ក/គ.ជ.នា | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម | តាមរយៈកម្មវិធីដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាច្រើន ក.អ.ក/គ.ជ.នា នឹងផ្តល់ការគាំទ្រនានា ដែលស្នើឡើងដោយប្រធាននៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះ | កំពុងអនុវត្ត |

| ផ្នែក B :  ការតវីមៈ ដៃគូអភិវឌ្ឍន៍ផ្តល់ជំនួយ សំរាប់គាំទ្រយុទ្ធសាស្រ្តអភិវឌ្ឍន៍ ស្ថាប័ន និងនីតិវិធីរបស់កម្ពុជា | | | | | |
|---|---|---|---|---|---|
| **លទ្ធផល** | **សកម្មភាព** | **ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល** | **អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍** | **សកម្មភាពកំណត់ជាក់ស្តែង** | **ពេលវេលា** |
| **១- ការផ្តល់ជំនួយនៃដៃគូអភិវឌ្ឍន៍ត្រូវតម្រឹមជាមួយនឹងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ដូចជា ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ ជាដើម** | | | | | |
| ក- ដៃគូអភិវឌ្ឍន៍ទាំងអស់ផ្តល់ជំនួយសំរាប់គាំទ្របណ្តាអាទិភាពនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈ (សូចនាករទី ៣) | - ដៃគូអភិវឌ្ឍន៍ត្រួតពិនិត្យឡើងវិញ នូវគោលនយោបាយ និងយុទ្ធសាស្រ្តផ្តល់ជំនួយរបស់ខ្លួនដើម្បីតម្រឹមជាមួយនឹងអាទិភាពនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ | ក.អ.ក/គ.ជ.នា និងប្រធានក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | ដៃគូអភិវឌ្ឍន៍ទាំងអស់ | ការត្រួតពិនិត្យឡើងវិញអំពីគោលនយោបាយ និងយុទ្ធសាស្រ្តផ្តល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍ ត្រូវបានបញ្ចប់ | ខែមិថុនា ឆ្នាំ២០០៦ |
| | - ដៃគូអភិវឌ្ឍន៍តម្រឹមគម្រោង និងកម្មវិធីអភិវឌ្ឍន៍របស់ខ្លួនដើម្បីផ្តល់ហិរញ្ញប្បទាន សំរាប់អនុវត្តផែនការតាមវិស័យដែលបានឯកភាពគ្នា និងកម្មវិធីអាទិភាពតាមវិស័យ ដែលមានក្នុងកម្មវិធីវិនិយោគសាធារណៈរំកិលរយៈពេលបីឆ្នាំ | ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក.អ.ក/គ.ជ.នា និងប្រធានក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | អ្នកសម្របសម្រួល នៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះ | គ្រប់គម្រោង និងកម្មវិធីថ្មី ក្នុងក្របខ័ណ្ឌនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវបានតម្រឹមយ៉ាងពេញលេញជាមួយនឹងកម្មវិធីវិនិយោគសាធារណៈ | ខែធ្នូ ឆ្នាំ២០០៦ |
| **២- ដៃគូអភិវឌ្ឍន៍បង្កើនការប្រើប្រាស់ស្ថាប័ន ប្រព័ន្ធ និងនីតិវិធីរបស់កម្ពុជា នៅពេលដែលបានបំពេញក៏រិតស្តង់ដាររួចហើយ** | | | | | |
| ក- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្ម ត្រូវបញ្ចូល នូវការអនុវត្តន៍ល្អៗរបស់អន្តរជាតិ (សូចនាករទី ២) | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តអនុវត្តកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើការពង្រឹងសមត្ថភាព ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្ម ដោយផ្អែកតាមការអនុវត្តន៍ល្អៗរបស់អន្តរជាតិ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អ្នកសម្របសម្រួលនៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ត្រូវបានផ្ញើជូនមកគណៈកម្មាធិការសម្របស្រម្ចួលរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ | កំពុងអនុវត្ត |
| ខ- បង្កើនសមាមាត្រនៃជំនួយអភិវឌ្ឍន៍ ដែលប្រើប្រាស់ស្ថាប័នរដ្ឋ ប្រព័ន្ធ និងនីតិវិធីរបស់រដ្ឋ (សូចនាករទី ៥) | - ដៃគូអភិវឌ្ឍន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្កើតក្របខ័ណ្ឌឯកភាពរួមគ្នា ដើម្បីវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្ម ហើយប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះ ដើម្បីបង្កើនការប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាល នៅពេលដែលបានបំពេពាក៏រិតស្តង់ដាររួចហើយ | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១- ដៃគូអភិវឌ្ឍន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឯកភាពលើវិធីសាស្រ្តក្នុងការអនុវត្តន៍ការវាយតម្លៃដែលអាចជឿទុកចិត្តបាន នូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្ម | ខែមិថុនា ឆ្នាំ២០០៦ |

| ផ្នែក B : ការតវ៉ៃមៈ ដៃគូអភិវឌ្ឍន៍ផ្ដល់ជំនួយ សំរាប់គាំទ្រយុទ្ធសាស្រ្តអភិវឌ្ឍន៍ ស្ថាប័ន និងនីតិវិធីរបស់កម្ពុជា | | | | | |
|---|---|---|---|---|---|
| លទ្ធផល | សកម្មភាព | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍ | សកម្មភាពកំណត់ជាក់ស្ដែង | ពេលវេលា |
| | | | | ២- ចាប់ផ្ដើមដំណើរការវាយតម្លៃលើកទី១<br>៣- ដៃគូអភិវឌ្ឍន៍ផ្ដល់របាយការណ៍តាមកាលបរិច្ឆេទ មកគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយស្ដីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្ម | ខែធ្នូ ឆ្នាំ ២០០៦<br>ខែមិថុនា ឆ្នាំ២០០៧ តទៅ |
| គ- ដៃគូអភិវឌ្ឍន៍ផ្ដល់របាយការណ៍ស្ដីពីការប្រើប្រាស់ជំនួយ សំរាប់រយៈពេល ១ឆ្នាំ ឬច្រើនឆ្នាំ តាមកាលបរិច្ឆេទដែលបានព្រមព្រៀង (សូចនករទី ៧) | - ដៃគូអភិវឌ្ឍន៍នីមួយៗផ្ដល់អំពីតួលេខនៃការសន្យាផ្ដល់ជំនួយប្រចាំឆ្នាំ ឬច្រើនឆ្នាំ មក ក.អ.ក/គ.ជ.នា ហើយផ្ដល់ជំនួយ អោយបានទាន់ពេលវេលា តាមកាលបរិច្ឆេទដែលបានឯកភាពគ្នា | ក.អ.ក/គ.ជ.នា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ដៃគូអភិវឌ្ឍន៍ទាំងអស់ | ដៃគូអភិវឌ្ឍន៍ទាំងអស់ ផ្ដល់តួលេខស្ដីពីការសន្យាផ្ដល់ជំនួយរបស់ខ្លួន | កំពុងបន្ត |
| ឃ- កាត់បន្ថយចំនួនអង្គភាពគ្រប់គ្រងគម្រោងឬ អង្គភាពអនុវត្តគម្រោង ដែលគ្រប់គ្រង និងអនុវត្តប្រចាំថ្ងៃ នូវគម្រោង និងកម្មវិធីដែលទទួលហិរញ្ញប្បទានពីបរទេស (សូចនករទី ៦) | - ដោយមានការគាំទ្រដៃគូអភិវឌ្ឍន៍ ក.អ.ក/គ.ជ.នា នឹងធ្វើអង្កេតស្ដីពីចំនួនអង្គភាពគ្រប់គ្រងគម្រោង ឬអង្គភាពអនុវត្តគម្រោងដែលមានបច្ចុប្បន្ន ហើយរៀបចំយុទ្ធសាស្រ្ត ដើម្បីធ្វើសមាហរណកម្មអង្គភាពគ្រប់គ្រងគម្រោង ឬអង្គភាពអនុវត្តគម្រោងទាំងនេះ ទៅក្នុងរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល | ក.អ.ក/គ.ជ.នា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះ ស្ដីពីភាពជាដៃគូ និងសុខដុមនីយកម្ម | ការធ្វើអង្កេតត្រូវបានបញ្ចប់ និងយុទ្ធសាស្រ្តត្រូវបានរៀបចំ និងបានឯកភាពជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ | ខែកញ្ញា ឆ្នាំ២០០៦ |
| | - អនុវត្តយុទ្ធសាស្រ្តដែលបានឯកភាពគ្នា | ប្រធានក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | អ្នកសម្របសម្រួល នៃបណ្ដាក្រុមការងារបច្ចេកទេសចម្រុះ | យុទ្ធសាស្រ្តត្រូវបានអនុវត្ត | ខែតុលា ឆ្នាំ២០០៦ តទៅ |
| | | ក.អ.ក/គ.ជ.នា | អ្នកសម្របសម្រួលនៃបណ្ដាក្រុមការងារបច្ចេកទេសចម្រុះ | កិច្ចព្រមព្រៀងត្រូវបានអនុមតិ | ខែធ្នូ ឆ្នាំ២០០៦ |

| ផ្នែក B : ការតាំរឹមៈ ដៃគូអភិវឌ្ឍន៍ផ្តល់ជំនួយ សំរាប់គាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍន៍ ស្ថាប័ន និងនីតិវិធីរបស់កម្ពុជា | | | | | |
|---|---|---|---|---|---|
| **លទ្ធផល** | **សកម្មភាព** | **ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល** | **អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍** | **សកម្មភាពកំណត់ជាក់ស្តែង** | **ពេលវេលា** |
| **៣- ការពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំផែនការ គ្រប់គ្រង អនុវត្ត និងក្នុងគណនេយ្យភាពចំពោះលទ្ធផលនៃការអនុវត្តន៍គោលនយោបាយ និងកម្មវិធី ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍** | | | | | |
| ក- ការពង្រឹងសមត្ថភាពត្រូវបានបញ្ចូលក្នុងផែនការតាមវិស័យ និងកម្មវិធី/គម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ ហើយត្រូវទទួលការគាំទ្រហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍន៍សមត្ថភាព (សូចនាករទី ៤) | - វាយតម្លៃអំពីកង្វះខាតផ្នែកសមត្ថភាព ដើម្បីរៀបចំផែនការពង្រឹងសមត្ថភាព ហើយត្រូវបញ្ចូលទៅក្នុងផែនការតាមវិស័យ និងកម្មវិធី/គម្រោងអភិវឌ្ឍន៍ទាំងអស់ ក្នុងទិសដៅដើម្បីសម្រេចអោយបានគោលដៅនៃការអភិវឌ្ឍន៍សមត្ថភាព | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះទាំងអស់ | អ្នកសម្របសម្រួលនៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះ | ការវាយតម្លៃពីកង្វះខាតផ្នែកសមត្ថភាព ហើយផែនការសម្រាប់ពង្រឹងសមត្ថភាព ត្រូវបានបញ្ចូលក្នុងផែនការតាមវិស័យ និងឯកសារគម្រោង/កម្មវិធី | កំពុងអនុវត្ត |
| | - ក្រុមការងារបច្ចេកទេសចម្រុះតាមវិស័យនីមួយៗ រៀបចំ និងអនុវត្តកម្មវិធីពង្រឹងសមត្ថភាពសម្រាប់ក្រសួង/ស្ថាប័នតាមវិស័យ | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះទាំងអស់ | អ្នកសម្របសម្រួលនៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះ | វិធានការសំរាប់ពង្រឹងសមត្ថភាពរបស់ក្រសួង/ស្ថាប័នតាមវិស័យ ត្រូវបានបញ្ចូលក្នុងផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | វិធានការត្រូវបញ្ចូលក្នុងផែនការសកម្មភាពនៃក្រុមការងារបច្ចេកទេសចម្រុះ សំរាប់ឆ្នាំ ២០០៦ |
| | - ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រផ្នែកហិរញ្ញប្បទាន សម្រាប់អនុវត្តប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមសមិទ្ធផល ឬកន្សោមអាទិភាព (MBPI/PMG) ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រពង្រឹងសមត្ថភាព | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក.អ.ក/គ.ជ.នា និង ក្រសួង/ស្ថាប័នតាមវិស័យដែលពាក់ព័ន្ធ | អ្នកសម្របសម្រួលនៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះ | ១- រៀបចំបញ្ចប់ នូវទម្រង់ការសំរាប់អនុវត្តប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមសមិទ្ធផល ឬកន្សោមអាទិភាព (MBPI/PMG) ក្នុងវិស័យអប់រំ សុខាភិបាល វិស័យដីធ្លី ក.អ.ក និងក្រសួងផែនការ<br>២- ពង្រីកការអនុវត្តន៍ប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមសមិទ្ធផល ឬកន្សោមអាទិភាព (MBPI/PMG) នៅតាមវិស័យដទៃទៀត | ខែធ្នូ ឆ្នាំ២០០៦<br>កំពុងរៀបចំ |

| ផ្នែក B : ការតវ៉ាមៈ ដៃគូអភិវឌ្ឍន៍ផ្តល់ជំនួយ សំរាប់គាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍន៍ ស្ថាប័ន និងនីតិវិធីរបស់កម្ពុជា | | | | | |
|---|---|---|---|---|---|
| លទ្ធផល | សកម្មភាព | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍ | សកម្មភាពកំណត់ជាក់ស្តែង | ពេលវេលា |
| **៤- ដៃគូអភិវឌ្ឍន៍ផ្តល់ជំនួយដោយគ្មានលក្ខខ័ណ្ឌ** | | | | | |
| ក- បង្កើនសមាមាត្រនៃជំនួយគ្មានលក្ខខ័ណ្ឌ (សូចនាករទី ៨) | - ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក.អ.ក/គ.ជ.នា រៀបចំធ្វើអង្កេតមួយ ដើម្បីប្រមូលពតិមានស្តីពីសមាមាត្រនៃជំនួយដែលបានផ្តល់តាមរយៈទម្រង់ជំនួយគ្មានលក្ខខ័ណ្ឌ ។ ផ្អែកលើការរបកគំឃើញនេះ ក.អ.ក/គ.ជ.នា រួមជាមួយដៃគូអភិវឌ្ឍន៍ នឹងរៀបចំ ហើយអនុវត្តយុទ្ធសាស្ត្រ ដើម្បីបង្កើនសមាមាត្រនៃជំនួយគ្មានលក្ខខ័ណ្ឌ | ក.អ.ក/គ.ជ.នា | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុដុមនីយកម្ម | ១- បញ្ចប់ការធ្វើអង្កេត ហើយកំណត់យុទ្ធសាស្ត្រ សំរាប់អនុវត្ត<br>២- អនុវត្តយុទ្ធសាស្ត្រដែលបានឯកភាពគ្នា | ខែធ្នូ ឆ្នាំ២០០៦<br><br>ខែធ្នូ ឆ្នាំ២០០៧ |

| ផ្នែក C : សុខដុមនីយកម្មៈ  ការបង្កើនសុខដុមនីយកម្ម តម្លាភាព និងប្រសិទ្ធភាពនៃសកម្មភាពផ្តល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍ | | | | | |
|---|---|---|---|---|---|
| **លទ្ធផល** | **សកម្មភាព** | **ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល** | **អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍** | **សកម្មភាពកំណត់ជាក់ស្តែង** | **ពេលវេលា** |
| **១- ដៃគូអភិវឌ្ឍន៍អនុវត្តទម្រង់ការរៀបចំរួម និងធ្វើអោយសាមញ្ញ នូវនីតិវិធីផ្តល់ជំនួយ** | | | | | |
| ក- បង្កើនសមាមាត្រនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ តាមអភិក្រមគ្រប់គ្រងទូទាំងវិស័យ (សូចនាករទី ៩) | - ក.អ.ក/គ.ជ.នា និងដៃគូអភិវឌ្ឍន៍កំណត់រួមគ្នា នូវគោលដៅស្តីពីសមាមាត្រនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ តាមអភិក្រមគ្រប់គ្រងទូទាំងវិស័យ  ដែលត្រូវសំរេចអោយបាន នាឆ្នាំ ២០១០ នៅក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ ដើម្បីសម្រេចអោយបាន នូវគោលដៅដែលបានព្រមព្រៀងគ្នា | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះស្តីពីភាពជាដៃគូ និងសុដុមនីយកម្ម | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម | ១- ឯកភាពលើទិសដៅ ហើយរៀបចំយុទ្ធសាស្ត្រ<br><br>២- អនុវត្តយុទ្ធសាស្ត្រដែលបានឯកភាពគ្នា | ខែធ្នូ ឆ្នាំ២០០៦<br><br>ចាប់ផ្តើមនាឆ្នាំ ២០០៧ |
| | - ក្រុមការងារបច្ចេកទេសនីមួយៗ រៀបចំផែនការមួយ ដើម្បីបង្កើនការធ្វើប្រតិភូកម្មខាងផ្នែកកិច្ចសហប្រតិបត្តិការ ក្នុងវិស័យនីមួយៗ | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះទាំងអស់ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | ក្រុមការងារបច្ចេកទេសចម្រុះត្រូវរៀបចំរបាយការណ៍តាមកាលបរិច្ឆេទកំណត់ ស្តីពីការបង្កើនប្រតិភូកម្មខាងផ្នែកកិច្ចសហប្រតិបត្តិការក្នុងវិស័យនីមួយៗ មកគណៈកម្មា-ធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ | កំពុងអនុវត្ត |
| ខ- កាត់បន្ថយចំនួនបេសកកម្មទោល និងបេសកកម្មជាន់គ្នា សំរាប់ការសិក្សា ឬសំរាប់ការត្រួតពិនិត្យរបស់របស់ដៃគូអភិវឌ្ឍន៍ (សូចនាករទី ១០) | - ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗរៀបចំតារាងពេលវេលានៃបេសកកម្មមកកម្ពុជា រួមទាំងបេសកកម្មត្រួតពិនិត្យ និងការសិក្សារបស់ដៃគូអភិវឌ្ឍន៍  នៅតាមវិស័យដែលឋិតក្នុងសមត្ថភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះទាំងអស់ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | ក្រុមការងារបច្ចេកទេសចម្រុះត្រូវរៀបចំរបាយការណ៍តាមកាលបរិច្ឆេទកំណត់ ហើយផ្ញើមកគណៈកម្មាធិការសម្របសម្រួល រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ | កំពុងអនុវត្ត |
| គ- ដៃគូអភិវឌ្ឍន៍អនុវត្តដោយជោគជ័យនូវផែនការសកម្មភាពរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្ត ដូចមានចែងក្នុងសេចក្តីប្រកាសទីក្រុងប៉ារីស | - ដៃគូអភិវឌ្ឍន៍ទាំងអស់ ផ្តល់របាយការណ៍ប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មរបស់ខ្លួន ដែលជាផ្នែកមួយនៃការតាមដានសេចក្តីប្រកាសទីក្រុងប៉ារីស មក ក.អ.ក/គ.ជ.នា | ក.អ.ក/គ.ជ.នា | ដៃគូអភិវឌ្ឍន៍ | ផ្អែកតាមពត៌មានរបស់ដៃគូអភិវឌ្ឍន៍ ក.អ.ក/គ.ជ.នា រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សេចក្តីប្រកាសទីក្រុងប៉ារីស | កំពុងអនុវត្ត |

| | | | | | |
|---|---|---|---|---|---|
| | | | | ជូនអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍/គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (OECD/DAC) | |
| **២- ពង្រឹងប្រព័ន្ធវាយតម្លៃបរិស្ថាន និងបញ្ហាពហុវិស័យ ដូច ជាសមភាពយេនឌ័រ និងបញ្ហាផ្សេងៗទៀត តាមទស្សនៈសុខដុមនីយកម្ម** | | | | | |
| ក- ពង្រឹងការអនុវត្តន៍ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន និងទស្សនទាននៃការវាយតម្លៃយុទ្ធសាស្ត្របរិស្ថាននៅកំរិតវិស័យ និងកំរិតជាតិ | - តាមរយៈការពិភាក្សាជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្រសួងនិងដៃគូអភិវឌ្ឍន៍រៀបចំនីតិវិធីរួមមួយ ដើម្បីពង្រឹងការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាននៅកំរិតវិស័យ និងកំរិតជាតិ | ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខប្រម៉ាញ់ និងនេសាទ ដឹកនាំកិច្ចការនេះដោយសហការជាមួយក្រសួងពាក់ព័ន្ធ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | រៀបចំសេចក្ដីព្រាងស្ដីពីនីតិវិធី ដើម្បីពង្រឹងការវាយតម្លៃផលប៉ះពាល់ខាងផ្នែកបរិស្ថាន | កំណត់ដោយក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ |
| | - ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធរៀបចំ និងអនុវត្តផែនការសកម្មភាព សំរាប់ពង្រឹងសមត្ថភាពផ្នែកបច្ចេកទេស និងគោលនយោបាយរបស់ស្ថាប័ន ក្នុងការអនុវត្តន៍ការវិភាគផលប៉ះពាល់ផ្នែកបរិស្ថាន និងក្នុងការពង្រឹងការអនុវត្តន៍ច្បាប់ | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះពាក់ព័ន្ធ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | របាយការណ៍ស្ដីពីវឌ្ឍនភាពត្រូវផ្ដល់មកគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ | កំពុងអនុវត្ត |
| ខ- ក្រសួងតាមវិស័យ និងដៃគូអភិវឌ្ឍន៍អនុមតិរួមគ្នា នូវទស្សនទាននេះសំរាប់ដោះស្រាយបញ្ហាដែលមានចរិតជាពហុវិស័យ ដូចជាសមភាពយេនឌ័រ | - ក្រសួង និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធរៀបចំគោលការណ៍ណែនាំរួម ដើម្បីដោះស្រាយបញ្ហាដែលមានចរិតជាពហុវិស័យ ដូចជាបញ្ហាសមភាពយេនឌ័រ និងអេដស៍ជាដើម | ក្រសួងតាមវិស័យ | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | រៀបចំ និងអនុមតិរួមគ្នា រវាងរាជ-រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ លើនីតិវិធីរួម ដើម្បីដោះស្រាយបញ្ហាដែលមានចរិតជាពហុវិស័យ | ខែធ្នូ ឆ្នាំ២០០៦ |

| ផ្នែក D : ការគ្រប់គ្រងដោយផ្តោតទៅលើលទ្ធផលៈ គ្រប់គ្រងធនធាន និងកែលំអការធ្វើសេចក្តីសំរេចចិត្តដោយផ្តោតទៅលើលទ្ធផល | | | | | |
|---|---|---|---|---|---|
| **លទ្ធផល** | **សកម្មភាព** | **ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល** | **អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍** | **សកម្មភាពកំណត់ជាក់ស្តែង** | **ពេលវេលា** |
| ក- រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ប្រើប្រាស់ក្របខ័ណ្ឌវាយតម្លៃ និងប្រព័ន្ធរបាយការណ៍ ដែលមានសូចនាករតាមដាន និងគ្រប់គ្រង សំរាប់ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍គោលដៅសំខាន់ៗនៃយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្រ្តតាមវិស័យ | - ក្រសួងផែនការរៀបចំ និងអនុវត្តក្របខ័ណ្ឌ ដើម្បីត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ព្រមទាំងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ | ក្រសួងផែនការ | អ្នកសម្របសម្រួលនាំមុខនៃក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីការរៀបចំផែនការ និងកាត់បន្ថយភាពក្រីក្រ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីការរៀបចំផែនការ និងកាត់បន្ថយភាពក្រីក្រ រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំឆ្នាំលើកទីមួយ សម្រាប់ឆ្នាំ ២០០៦ ហើយផ្ញើជូនរាជរដ្ឋាភិបាល | ខែមិនា ឆ្នាំ២០០៧ និងរាល់ឆ្នាំ |
| | - ដៃគូអភិវឌ្ឍន៍អនុវត្តទំរង់ការស្តង់ដារនៃកិច្ចសហប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី (SOP) និងគោលការណ៍ណែនាំប្រតិបត្តិការជាតិ សំរាប់គ្រប់គ្រងជំនួយឥតសំណង (NOG) ដើម្បីត្រួតពិនិត្យ និងធ្វើរបាការណ៍អំពីការអនុវត្តន៍ កម្មវិធី និងគំរោងរបស់ខ្លួន ដើម្បីកាត់បន្ថយបន្ទុកមកលើស្ថាប័ន ប្រតិបត្តិរបស់រាជរដ្ឋាភិបាល | ប្រធានក្រុមការងារបច្ចេក-ទេសចម្រុះ | ដៃគូអភិវឌ្ឍន៍ទាំងអស់ | ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ផ្តល់របាយការណ៍តាមកាលបរិច្ឆេទ ស្តីពីការអនុវត្តន៍ទំរង់ការស្តង់ដារនៃកិច្ចសហ-ប្រតិបត្តិការសំរាប់គ្រប់គ្រងជំនួយជាកម្ចី (SOP) និងគោលការណ៍ណែនាំប្រតិបត្តិការជាតិ សំរាប់គ្រប់គ្រងជំនួយឥតសំណង (NOG) មកគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ | កំពុងអនុវត្ត |

| ផ្នែក E : គណនេយ្យភាពរួមគ្នា: រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានគណនេយ្យភាពចំពោះលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ | | | | | |
|---|---|---|---|---|---|
| **លទ្ធផល** | **សកម្មភាព** | **ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល** | **អ្នកនាំមុខខាងដៃគូអភិវឌ្ឍន៍** | **សកម្មភាពកំណត់ជាក់ស្តែង** | **ពេលវេលា** |
| ក- រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវមានគណនេយ្យភាពរួមគ្នាទៅលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ | - ក.អ.ក/គ.ជ.នា និងដៃគូអភិវឌ្ឍន៍ វាយតម្លៃរួមគ្នា និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពជាទៀងទាត់ ក្នុងការអនុវត្តន៍ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសុខដុមនីយកម្ម | ក.អ.ក/គ.ជ.នា និងបណ្តាក្រសួង/ស្ថាប័នពាក់ព័ន្ធ | ដៃគូអភិវឌ្ឍន៍ទាំងអស់ | រៀបចំរបាយការណ៍ ហើយផ្ញើជូនគណៈកម្មាធិការសម្របស្រម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ | កំពុងអនុវត្ត |
| | - ក.អ.ក/គ.ជ.នា និងដៃគូអភិវឌ្ឍន៍ ត្រួតពិនិត្យរួមគ្នាលើប្រសិទ្ធភាពនៃយន្តការក្រុមការងារបច្ចេកទេសចម្រុះ | ក.អ.ក/គ.ជ.នា | អ្នកសម្របសម្រួលនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុដុមនីយកម្ម | ការធ្វើអង្កេតត្រូវបានបញ្ចប់ ហើយរាល់អនុសាសន៍ ត្រូវបានផ្ញើមកគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ | ខែមិថុនា ឆ្នាំ២០០៦ |
| ខ- ដៃគូអភិវឌ្ឍន៍ផ្តល់ពតិមានស្តីពីលំហូរនៃជំនួយ ប្រកបដោយតម្លាភាព និងទាន់ពេលវេលា មករាជរដ្ឋាភិបាល (សូចនាករទី ១២) | - អ្នកផ្តល់ជំនួយផ្តល់ពតិមានស្តីពីលំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវការ (រួមទាំង ជំនួយដែលបានផ្តល់ឱ្យអង្គការមិនមែនរដ្ឋាភិបាល) ប្រកបដោយតម្លាភាព មក ក.អ.ក/គ.ជ.នា អោយបានទាន់ពេលវេលា ដើម្បីបញ្ចូលក្នុងថវិការដ្ឋ | ក.អ.ក/គ.ជ.នា | ដៃគូអភិវឌ្ឍន៍ | តាមការស្នើសុំរបស់ ក.អ.ក/គ.ជ.នា ដៃគូអភិវឌ្ឍន៍ផ្តល់ពតិមានស្តីពីលំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវការតាមកាលបរិច្ឆេទកំណត់ | កំពុងអនុវត្ត |